CAO COMPLIANCE ADVISOR OMBUDSMAN

*The Independent Accountability Mechanism for IFC & MIGA*

# ការវាយតម្លៃភាពអនុលោមនៃពាក្យបណ្ដឹងពាក់ព័ន្ធនឹងការផ្ដល់កម្ចីរបស់ IFC ដល់ស្ថាប័នមីក្រូហិរញ្ញវត្ថុចំនួនប្រាំមួយ នៅប្រទេសកម្ពុជា (អេស៊ីលីដា អម្រឹត ធនាគារហត្ថា ប្រាសាក់ អិលអូអិលស៊ី និង ស្ថាបនា)

**គម្រោង IFC លេខ ២១៨៥៦ ២៧៨២៧ ៣១៤៦៧ ៣៤៧៤៨ ៣៨៦០៩ ៣៩១៦៧ ៤១២៩៤ ៤២៤៨០ ៤៤២១១ ៤៤២៣១ ៤៤៧៤២ ៤៤៨៨២ ៤៥៥៣៥**

ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣

## អំពីស៊ីអេអូ

ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ស៊ីអេអូ) គឺជាយន្តការគណនេយ្យភាពឯករាជ្យរបស់សាជីវ-កម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និង ទីភ្នាក់ងារធានាការវិនិយោគពហុភាគី (MIGA) ដែលជាសមាជិកក្រុមធនាគារពិភពលោក។ យើងធ្វើការសម្របសម្រួលដោះស្រាយបណ្តឹងពីប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ពីគម្រោងរបស់ IFC និង MIGA ដោយយុត្តិធម៌ ឥតលម្អៀង និងប្រកបដោយភាពស្ថាបនា លើកកម្ពស់លទ្ធផលផ្នែកបរិស្ថាន និងសង្គមនៃគម្រោងទាំងនោះ និងបង្កើនគណនេយ្យភាពសាធារណៈ និង ការរៀនសូត្រនៅ IFC និង MIGA។

ស៊ីអេអូ គឺជាការិយាល័យឯករាជ្យ ដែលរាយការណ៍ទៅកាន់ក្រុមប្រឹក្សានាយកប្រតិបត្តិការរបស់ IFC និង MIGA ដោយផ្ទាល់។ សម្រាប់ព័ត៌មានបន្ថែម សូមមើល៖ www.cao-ombudsman.org។

## អំពីមុខងារភាពអនុលោម

មុខងារភាពអនុលោមរបស់ស៊ីអេអូ ត្រួតពិនិត្យឡើងវិញលើភាពអនុលោមរបស់ IFC និង MIGA ចំពោះគោលនយោបាយបរិស្ថាន និងសង្គម វាយតម្លៃលើគ្រោះថ្នាក់ដែលពាក់ព័ន្ធ និងផ្តល់អនុសាសន៍អំពីវិធានការដោះស្រាយដែលសមស្រប។

មុខងារអនុលោមភាពរបស់ស៊ីអេអូអនុវត្តតាមអភិក្រមបីជំហាន៖

**ការវាយតម្លៃ**

ត្រួតពិនិត្យជាបឋម ដើម្បីកំណត់ថាតើពាក្យបណ្តឹង ឬសំណើផ្ទៃក្នុង ចាំបាច់ត្រូវធ្វើការស៊ើបអង្កេតភាពអនុលោមដែរឬទេ។

**ការស៊ើបអង្កេត**

ការកំណត់ជាប្រព័ន្ធ និងប្រកបដោយភាពអព្យាក្រឹត្យ ថាតើ IFC/MIGA បានអនុលោមតាមគោលនយោបាយបរិស្ថាន និងសង្គមរបស់ខ្លួនដែរឬទេ និងថាតើមានគ្រោះថ្នាក់ ពាក់ព័ន្ធនឹងបដិលោមភាពណាមួយដែរឬទេ។

**ការពិនិត្យតាមដាន**

ការផ្ទៀងផ្ទាត់អំពីការអនុវត្តវិធានការគ្រប់គ្រង ដែលត្រូវបានបង្កើតឡើង ឆ្លើយតបនឹងរបកគំហើញ និងអនុសាសន៍ពីការស៊ើបអង្កេតអំពីភាពអនុលោមប្រកបដោយប្រសិទ្ធភាព។

# តារាងមាតិកា


អក្សរកាត់ .......... 4

សេចក្តីសង្ខេប .......... 6

១. សេចក្តីផ្តើម .......... 12

ក) បរិបទនៃការវិនិយោគមីក្រូហិរញ្ញវត្ថុរបស់ IFC នៅកម្ពុជា .......... 12

ខ) ការផ្តល់កម្ចីរបស់ IFC ដល់គ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជាទាំងប្រាំមួយ .......... 12

គ) វិសាលភាព និងវិធីសាស្ត្រវាយតម្លៃភាពអនុលោម .......... 14

២. កង្វល់ដែលត្រូវបានលើកឡើងដោយដើមបណ្តឹង .......... 15

៣. សេចក្តីសង្ខេបអំពីការឆ្លើយតបរបស់ IFC .......... 18

៤. ការវិភាគអំពីការវាយតម្លៃរបស់ស៊ីអេអូ .......... 20

ក) ក្របខណ្ឌគោលនយោបាយ និងស្តង់ដារសមិទ្ធកម្មរបស់ IFC ដែលពាក់ព័ន្ធ .......... 21

ខ) ការចង្អុលបង្ហាញជាបឋមអំពីគ្រោះថ្នាក់ .......... 23

គ) ការចង្អុលបង្ហាញជាបឋមអំពីភាពបដិលោមតាមគោលនយោបាយរបស់ IFC .......... 29

ឃ) ទំនាក់ទំនងដែលអាចជឿជាក់បាន រវាងការចោទប្រកាន់អំពីគ្រោះថ្នាក់ និងភាពបដិលោមជាសក្តានុពលរបស់ IFC .......... 40

ង) លក្ខខណ្ឌតម្រូវនៃគោលនយោបាយដែលពាក់ព័ន្ធបន្ថែមទៀត .......... 41

៥. សេចក្តីសម្រេចរបស់ស៊ីអេអូ .......... 44

ឧបសម្ព័ន្ធទី១៖ អតិថិជន និងអតិថិជនបន្ត ដែលទាក់ទងនឹងសំណុំរឿងរបស់ IFC .......... 46

ឧបសម្ព័ន្ធទី២៖ ទិដ្ឋភាពទូទៅអំពីគម្រោងវិនិយោគរបស់ IFC ដែលទាក់ទងនឹងសំណុំរឿង .......... 52

ឧបសម្ព័ន្ធទី៣៖ ការអនុវត្តឧស្សាហកម្មល្អជាអន្តរជាតិសម្រាប់ការវិនិយោគប្រកបដោយទំនួលខុសត្រូវនៅក្នុងវិស័យហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្ន .......... 54

ឧបសម្ព័ន្ធទី៤៖ ពាក្យបណ្តឹងដែលត្រូវបានលុបចោល .......... 56

ឧបសម្ព័ន្ធទី៥៖ ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC .......... 116

ឧបសម្ព័ន្ធទី៦៖ ការពិចារណាអំពីគោលនយោបាយស៊ីអេអូចំពោះការវាយតម្លៃភាពអនុលោម .......... 146

ឧបសម្ព័ន្ធទី៧៖ លក្ខខណ្ឌយោងនៃការស៊ើបអង្កេត .......... 148

## អក្សរកាត់

| អក្សរកាត់ | និយមន័យ |
|---|---|
| អេស៊ីលីដា | ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| Advans | Advans S.A. SICAR |
| AIP | គោលនយោបាយស្តីពីលទ្ធភាពទទួលបានព័ត៌មាន |
| អម្រឹត | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត |
| ស៊ីអេអូ | ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (IFC និង MIGA) |
| CBC | ក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ ខេមបូឌា |
| CMA | សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា |
| E&S | បរិស្ថាន និងសង្គម |
| ESAP | ផែនការសកម្មភាពបរិស្ថាន និងសង្គម |
| ESMS | ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម |
| ESRS | សេចក្តីសង្ខេបអំពីការត្រួតពិនិត្យផ្នែកបរិស្ថាន និងសង្គម |
| ESRP | នីតិវិធីត្រួតពិនិត្យផ្នែកបរិស្ថាន និងសង្គម |
| FCP | កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ |
| FI | អន្តរការីហិរញ្ញវត្ថុ |
| GIIP | ការអនុវត្តឧស្សាហកម្មល្អជាអន្តរជាតិ |
| Hattha Bank | ធនាគារ ហត្ថា |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| អិលអូអិលស៊ី | អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី |
| MEF | ឥណទានពង្រឹងមីក្រូហិរញ្ញវត្ថុ S.A., SICAV-SIF |
| MIFA | មូលនិធិគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុលអាស៊ី SA, SICAV-SIF |
| MIGA | ទីភ្នាក់ងារធានាការវិនិយោគពហុភាគី |
| MSME | សហគ្រាសធុនមីក្រូ តូច និងមធ្យម |
| NBC | ធនាគារជាតិកម្ពុជា |

| **អក្សរកាត់** | **និយមន័យ** |
|---|---|
| North Haven Thai | ក្រុមហ៊ុន North Haven Thai Private Equity L.P |
| PS | ស្តង់ដារសមិទ្ធកម្ម IFC |
| Prasac | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក |
| Sathapana | ធនាគារ ស្ថាបនា ភីអិលស៊ី |
| SME | សហគ្រាសធុនតូច និងមធ្យម |
| SPI | សេចក្តីសង្ខេបអំពីការវិនិយោគដែលបានស្នើឡើង |
| TOR | លក្ខខណ្ឌយោង |

# សេចក្តីសង្ខេប

ការវាយតម្លៃភាពអនុលោម ចងក្រងឯកសារនៃការត្រួតពិនិត្យបឋមរបស់ស៊ីអេអូលើពាក្យបណ្តឹង ដែលបានដាក់ជូន ដោយអង្គការមិនមែនរដ្ឋាភិបាលចំនួនពីរ – អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) និងអង្គការសមធម៌កម្ពុជា (EC) – តាងនាមឲ្យអ្នកខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុមួយក្រុមនៅកម្ពុជា ("ដើមបណ្តឹង")។ ពាក្យបណ្តឹងនេះចោទប្រកាន់ថា គ្រឹះស្ថានហិរញ្ញវត្ថុចំនួនប្រាំមួយនៅកម្ពុជា ដែលជាអតិថិជន ឬអតិថិជនបន្តរបស់ IFC មានការអនុវត្តនៃការផ្តល់កម្ចី និងការប្រមូលប្រាក់ ដែលបណ្តាលឲ្យមានផលប៉ះពាល់សង្គមអវិជ្ជមានយ៉ាងខ្លាំង រួមទាំងការបាត់បង់ដីធ្លី និងមុខរបរចិញ្ចឹមជីវិតផងដែរ។ ស៊ីអេអូ សន្និដ្ឋានថា ពាក្យបណ្តឹងនេះសមស្របនឹងទទួលបានការស៊ើបអង្កេតអំពីភាពអនុលោម ទាក់ទងនឹងការវិនិយោគដោយផ្ទាល់ និងដោយប្រយោលរបស់ IFC នៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុចំនួនប្រាំមួយ–អេស៊ីលីដា អម្រឹត ធនាគារហត្ថា ប្រាសាក់ អិលអូអិលស៊ី និងស្ថាបនា។ ពាក្យបណ្តឹងបំពេញតាមលក្ខណវិនិច្ឆ័យសម្រាប់ការស៊ើបអង្កេតភាពអនុលោមរបស់ស៊ីអេអូ ពីព្រោះវាមានការចង្អុលបង្ហាញជាបឋមដែលថា IFC អាចនឹងខកខានក្នុងការអនុវត្តតាមគោលនយោបាយបរិស្ថាន និងសង្គម (E&S) របស់ខ្លួន ក្នុងការវាយតម្លៃ និងត្រួតពិនិត្យផលប៉ះពាល់សង្គមនៃការវិនិយោគទាំងនេះ និងថា គ្រោះថ្នាក់ចំពោះដើមបណ្តឹង ដែលត្រូវបានចោទប្រកាន់ មានទំនាក់ទំនងនឹងបដិអនុលោមតាមដែលអាចកើតឡើងនេះ។

## បរិបទ និងការវិនិយោគ

ការជំពាក់បំណុលច្រើនពេក នៅក្នុងចំណោមប្រជាជនក្រីក្រ និងងាយរងគ្រោះនៅកម្ពុជា គឺជាកង្វល់អន្តរជាតិដែលកំពុងកើនឡើង ដែលលើកឡើងដោយធនាគារពិភពលោក IFC និងទីភ្នាក់ងារអង្គការសហប្រជាជាតិជាច្រើនទៀត[1] រួមជាមួយក្របខណ្ឌការពារអ្នកប្រើប្រាស់ដែលមានភាពទន់ខ្សោយ ស្ថានភាពនេះមានផលអវិជ្ជមានដល់សង្គម ដែលប៉ះពាល់ដល់កម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាជាច្រើននាក់។

ក្រុមធនាគារពិភពលោក (WBG) បានផ្តល់ការគាំទ្រយ៉ាងទូលំទូលាយដល់វិស័យហិរញ្ញវត្ថុកម្ពុជា តាមរយៈជំនួយបច្ចេកទេស និងការវិនិយោគផ្ទាល់ ដោយផ្តោតលើមីក្រូហិរញ្ញវត្ថុ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ។ ជាពិសេស IFC បានធ្វើការវិនិយោគជាច្រើននៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើនកន្លែង។ ទាក់ទងនឹងករណីនេះ IFC មានការវិនិយោគផ្ទាល់នៅក្នុងធនាគារអេស៊ីលីដា អម្រឹត និងធនាគារ ហត្ថា និងការផ្តល់កម្ចីហិរញ្ញវត្ថុដោយប្រយោលដល់ប្រាសាក់ អិលអូអិលស៊ី និងស្ថាបនា តាមរយៈការវិនិយោគនៅក្នុងតណទានពង្រឹងមីក្រូហិរញ្ញវត្ថុ (MEF) មូលនិធិគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុលអាស៊ី (MIFA) ក្រុមហ៊ុន North Haven Thai (ក្រុមហ៊ុនមូលធនឯកជន) និង Advans S.A. (ក្រុមហ៊ុនមេរបស់អម្រឹត)។ ជារួម សំណុំរឿងនេះជាប់ពាក់ព័ន្ធនឹងគម្រោងរបស់ IFC ចំនួន ១៣ គម្រោង ដែលគាំទ្រដល់ការផ្តល់កម្ចីរបស់អតិថិជនដល់សហគ្រាសធុនមីក្រូ ធុនតូច និងមធ្យម (MSMEs) និងមានភាពសកម្ម នៅពេលដែលពាក្យបណ្តឹងនេះត្រូវបានដាក់ជូនស៊ីអេអូ។

[1] ប្រភពព័ត៌មាននៅក្នុងតួសេចក្តីនៃរបាយការណ៍។ សូមមើលជើងទំព័រទី ២៧ ដល់ ៣៤។

## ពាក្យបណ្ដឹង

ស៊ីអេអូ បានទទួលពាក្យបណ្ដឹងនៅខែកុម្ភៈ ឆ្នាំ២០២២ ដែលចោទប្រកាន់ថា ការអនុវត្តផ្ដល់កម្ចីដ៏ឃោឃៅ និងការប្រមូលប្រាក់ដោយបោកបញ្ឆោត ដោយធនាគារអេស៊ីលីដា អម្រឹត ធនាគារ ហត្ថា អិលអូអិលស៊ី ប្រាសាក់ និងស្ថាបនា បានបណ្ដាលឱ្យមានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងដល់សង្គម រួមទាំងការបាត់បង់ដីធ្លី និងមុខរបរចិញ្ចឹមជីវិតផងដែរ។ ដើមបណ្ដឹងផ្ដល់ទឡ្ហីករណ៍ថា IFC បរាជ័យម្ដងហើយម្ដងទៀតក្នុងការអនុវត្តការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នលើផ្នែក E&S និងការត្រួតពិនិត្យសកម្មភាពផ្ដល់កម្ចីរបស់មីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ខ្លួនឱ្យបានគ្រប់គ្រាន់ ហើយប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) "មានភាពមិនគ្រប់គ្រាន់យ៉ាងច្បាស់"។ ដើមបណ្ដឹង ដែលជាអ្នកខ្ចីពីគ្រឹះស្ថានហិរញ្ញវត្ថុមួយ ឬច្រើនក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុទាំងនេះ ចោទប្រកាន់ថា អ្នកផ្ដល់កម្ចីទាំងនេះស្នើសុំឱ្យពួកគេប្រើប្រាស់ដីធ្លីរបស់ពួកគេជាវត្ថុបញ្ចាំ ហើយបន្ទាប់មក បង្ខំឱ្យអ្នកខ្ចីលក់ដីធ្លីរបស់ពួកគេមុនពេលកំណត់ ដើម្បីប្រមូលប្រាក់កម្ចីមកវិញ។ បន្ថែមពីលើការលក់ដីធ្លីរបស់ពួកគេ រួមទាំងទឹកដីសហគមន៍ជនជាតិដើមភាគតិច និងទ្រព្យសកម្មសម្រាប់បង្កើតប្រាក់ចំណូលដទៃទៀត ដូចជា ឧបករណ៍ធ្វើសិប្បកម្ម ជាដើមនោះ ដើមបណ្ដឹងអះអាងថា បានកំណត់បរិមាណអាហាររបស់ពួកគេ បញ្ឈប់កូនៗមិនឲ្យទៅសាលារៀន និងធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើ ដើម្បីសងបំណុលប្រាក់កម្ចីដែលមានការកើនឡើងនោះ។

ពាក្យបណ្ដឹងបញ្ជាក់ថា IFC បានដឹងអំពីព័ត៌មានដែលមានជាសាធារណៈ ទាក់ទងនឹងគ្រោះថ្នាក់ផ្នែកសង្គមដែលបណ្ដាលមកពីកិច្ចការពារអ្នកប្រើប្រាស់មិនគ្រប់គ្រាន់ នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា ប៉ុន្តែនៅតែបន្តអនុម័តហិរញ្ញប្បទានដោយពុំមានលក្ខខណ្ឌតម្រូវបន្ថែម។ ពួកគេបានផ្ដល់ទឡ្ហីករណ៍ថា IFC គួរតែតម្រូវឱ្យអ្នកផ្ដល់កម្ចីទាំងនេះត្រួតពិនិត្យសកម្មភាពរបស់ពួកគេចំពោះហានិភ័យ E&S និងលទ្ធផល ដែលបង្កគ្រោះថ្នាក់ដល់អ្នកខ្ចី។ ដើមបណ្ដឹងចង្អុលបង្ហាញថា អ្នកខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុទំនងជាប្រជាជនដែលងាយរងគ្រោះ ដូច្នេះពួកគេត្រូវការការការពារ និងពិនិត្យតាមដានបន្ថែមទៀត ដើម្បីធានាថា គម្រោង IFC មិនបង្កផលប៉ះបាល់អវិជ្ជមានដល់សង្គម។ ពួកគេក៏បង្ហាញពីភាពភ័យខ្លាចសងសឹក ចំពោះការនិយាយប្រឆាំងនឹងឧស្សាហកម្មមីក្រូហិរញ្ញវត្ថុផងដែរ និងបានស្នើសុំឱ្យស៊ីអេអូ រក្សាអត្តសញ្ញាណរបស់ពួកគេជាការសម្ងាត់។

## ការឆ្លើយតបរបស់ IFC

ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC ចំពោះពាក្យបណ្ដឹង ទទួលស្គាល់ថាគ្រោះថ្នាក់ដែលត្រូវបានចោទប្រកាន់គឺធ្ងន់ធ្ងរ។ ទោះបីជាយ៉ាងណាក៏ដោយ គេអះអាងថា ផលប៉ះពាល់លើអ្នកខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុ ស្ថិតនៅក្រៅវិសាលភាពនៃគោលនយោបាយ E&S របស់ IFC ដោយហេតុផលថា៖

- អ្នកប្រើប្រាស់ផលិតផលរបស់អតិថិជនមិនត្រូវបានយោងដល់ នៅក្នុងគោលនយោបាយនិរន្តរភាព ឬស្តង់ដារសមិទ្ធកម្មរបស់ IFC ថាជាភាគីពាក់ព័ន្ធមួយប្រភេទ ដែលត្រូវអនុវត្តវិធានការកាត់បន្ថយហានិភ័យ E&S នោះទេ។

- ក្របខណ្ឌនិរន្តរភាពអនុវត្តចំពោះហានិភ័យ E&S ជាសក្តានុពល និងផលប៉ះពាល់នៃ "សកម្មភាពអាជីវកម្ម" ដែលត្រូវបានគាំទ្រ លើ "សហគមន៍ជុំវិញ និងពលករ" ប៉ុន្តែមិនអនុវត្តចំពោះផលប៉ះពាល់ E&S លើអតិថិជនបន្តដោយផ្ទាល់នោះទេ (ក្នុងករណីនេះ ជាអ្នកខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុ)។
- សកម្មភាពអាជីវកម្ម ដែល IFC គាំទ្រ តាមរយៈអតិថិជន FI មិនមែនជាការផ្តល់កម្ចីដោយមីក្រូហិរញ្ញវត្ថុដោយផ្ទាល់នោះទេ ប៉ុន្តែជាសកម្មភាពដែលកើតចេញពីការប្រើប្រាស់កម្ចីទាំងនោះដោយអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ (ឧទាហរណ៍ កសិកម្មខ្នាតតូច ឬសកម្មភាពពាណិជ្ជកម្ម ដូចជា ហាងទំនិញ ជាដើម)។
- IFC ដោះស្រាយបញ្ហា ទាក់ទងនឹងការអនុវត្តក្នុងការផ្តល់កម្ចី និងការប្រមូលប្រាក់របស់អតិថិជន តាមរយៈក្របខណ្ឌហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់ខ្លួន និងដំណើរការក្នុងការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នផ្នែកហិរញ្ញវត្ថុកាន់តែទូលំទូលាយ ដោយមិនស្ថិតនៅក្នុងក្របខណ្ឌនិរន្តរភាពនោះទេ។

IFC ក៏បានកត់សម្គាល់ផងដែរថា ក្រៅពីលក្ខខណ្ឌតម្រូវនៃក្របខណ្ឌនិរន្តរភាពរបស់ IFC ខ្លួនក៏បានធ្វើការនៅកម្រិតស្ថាប័ន និងកម្រិតវិស័យ ដើម្បីពង្រឹងការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវនៅកម្ពុជាផងដែរ។

## ការវិភាគរបស់ស៊ីអេអូ

យោងតាមគោលនយោបាយស៊ីអេអូ គោលបំណងនៃការវាយតម្លៃភាពអនុលោមរបស់ស៊ីអេអូគឺ ដើម្បីកំណត់ថាតើពាក្យបណ្តឹងស័ក្តិសមនឹងទទួលបានការស៊ើបអង្កេតដែរឬទេ ដោយប្រើលក្ខណវិនិច្ឆ័យដូចតទៅ៖ (ក) ថាតើមានការចង្អុលបង្ហាញជាបឋមអំពីគ្រោះថ្នាក់ ឬគ្រោះថ្នាក់ដែលអាចកើតឡើងដែរឬទេ (ខ) ថាតើមានការចង្អុលបង្ហាញជាបឋម ដែល IFC ប្រហែលជាមិនបានអនុលោមតាមគោលនយោបាយ E&S របស់ខ្លួនដែរឬទេ និង (គ) ថាតើគ្រោះថ្នាក់ ដែលត្រូវបានចោទប្រកាន់ មានទំនាក់ទំនងយ៉ាងសមហេតុផល នឹងភាពបដិលោម ដែលអាចកើតឡើងដែរឬទេ។

ចំពោះការវាយតម្លៃនេះ ស៊ីអេអូបានធ្វើការត្រួតពិនិត្យលើកដំបូងលើព័ត៌មានដែលមាន រួមទាំងគណនីផ្ទាល់ខ្លួនរបស់ដើមបណ្តឹងអំពីផលប៉ះពាល់អវិជ្ជមានពីការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុ និងប្រភពបន្ទាប់បន្សំដែលពាក់ព័ន្ធផងដែរ។ ស៊ីអេអូសន្និដ្ឋានថា ពាក្យបណ្តឹងបំពេញតាមលក្ខណវិនិច្ឆ័យទាំងបីខាងលើ ទាក់ទងនឹងការវិនិយោគផ្ទាល់របស់ IFC នៅអេស៊ីលីដា, អម្រឹត, ធនាគារ ហត្ថា, ក្រុមហ៊ុន Advans, ក្រុមហ៊ុន North Haven Thai, MEF និង MIFA និងការវិនិយោគដោយប្រយោលនៅប្រាសាក់, អិលអូលអិលស៊ី និងស្ថាបនា តាមរយៈ MEF និង MIFA។

ក) **មានការចង្អុលបង្ហាញជាបឋមអំពីគ្រោះថ្នាក់** ទាក់ទងនឹងការចោទប្រកាន់ពីផលប៉ះពាល់អវិជ្ជមាននៃការ ផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុ ដែលបានលើកឡើងដោយដើមបណ្តឹង។ ស៊ីអេអូបានធ្វើការសន្និដ្ឋាននេះ ដោយផ្អែកលើព័ត៌មាននៅកម្រិតគ្រួសារស្តីពីផលប៉ះពាល់សង្គមអវិជ្ជមាននៃកម្ចីមីក្រូហិរញ្ញវត្ថុ ដែលផ្តល់ដោយដើមបណ្តឹងដែលមានសង្គតិភាពនឹងព័ត៌មានដ៏ទូលំទូលាយអំពីហានិភ័យ និងផលប៉ះពាល់នៃការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុ

និងការជំពាក់ប្រាក់ច្រើនពេកនៅប្រទេសកម្ពុជា និងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត[2] ដូចខាងក្រោម៖

- **ការបាត់បង់ដីធ្លី** ដើមបណ្ដឹងបញ្ជាក់ថា គ្រឹះស្ថានហិរញ្ញវត្ថុបានបង្ខំពួកគេឱ្យប្រើប្រាស់បណ្ណកម្មសិទ្ធិដីធ្លីជាវត្ថុបញ្ចាំ ហើយបន្ទាប់មកបង្ខំឱ្យលក់ដីធ្លីមុនពេលកំណត់ ដើម្បីប្រមូលប្រាក់កម្ចី។ ការចោទប្រកាន់ទាំងនេះមានសង្គតិភាពនឹងការរាយការណ៍ជាសាធារណៈអំពីការអនុវត្តបែបនេះ និងហានិភ័យដែលពួកគេបង្កឡើង ដល់ការបាត់បង់ដីធ្លីរបស់អ្នកខ្ចីក្រីក្រ និងងាយរងគ្រោះ។
- **ផលប៉ះពាល់លើជីវភាពរស់នៅ** ដើមបណ្ដឹងបញ្ជាក់ថា ពួកគេត្រូវលក់ទ្រព្យសម្បត្តិដទៃទៀត ហើយងាកទៅទទួលទានអាហារតិច និងមានគុណភាពមិនល្អ ដោយសារការខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុ។ ការត្រួតពិនិត្យជាបឋមលើការសិក្សាដែលពាក់ព័ន្ធ ផ្ដល់ភស្តុតាងថា ផលប៉ះពាល់អវិជ្ជមាននៃមីក្រូហិរញ្ញវត្ថុលើជីវភាពរស់នៅរបស់អ្នកខ្ចីកម្ពុជា ជាញឹកញាប់ រួមមាន ការទទួលទានអាហារតិច ឬមានគុណភាពមិនល្អ ដើម្បីសងកម្ចី។
- **ផលប៉ះពាល់ដល់គ្រួសារ** ដើមបណ្ដឹងមួយចំនួននិយាយថា ពួកគេត្រូវបញ្ឈប់កូនៗពីសាលារៀនដើម្បីទៅធ្វើការ ឬត្រូវធ្វើចំណាកស្រុកដើម្បីសងកម្ចីរបស់ពួកគេ។ ដើមបណ្ដឹងក៏បានគូសបញ្ជាក់អំពីរបាយការណ៍ស្ដីពីការធ្វើអត្តឃាតដោយសារបំណុល ដែលកំពុងកើនឡើងនៅក្នុងប្រទេសផងដែរ។ ទិន្នន័យពីអង្គការអន្តរជាតិខាងការងារ (ILO) និង អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) គាំទ្រដល់ភាពអាចជឿជាក់បាននៃការចោទប្រកាន់របស់ដើមបណ្ដឹង ដែលថា បំណុលមានទំនាក់ទំនងនឹងពលកម្មកុមារ និងការធ្វើចំណាកស្រុកនៅកម្ពុជា។ ដើមបណ្ដឹងក៏បានគូសបញ្ជាក់អំពីរបាយការណ៍ជាសាធារណៈស្ដីពីការធ្វើអត្តឃាតដោយសារបំណុល ដែលកំពុងកើនឡើងនៅក្នុងប្រទេស ថាជាផលប៉ះពាល់លើគ្រួសារមួយទៀត មកពីស្ថានភាពដែលបានពណ៌នានៅក្នុងពាក្យបណ្ដឹងរបស់ពួកគេ។
- **ផលប៉ះពាល់លើជនជាតិដើមភាគតិច** ដើមបណ្ដឹង ដែលពួកគេមួយចំនួនត្រូវបានកំណត់អត្តសញ្ញាណថាជាជនជាតិដើមភាគតិច បញ្ជាក់ថា អ្នកផ្ដល់កម្ចីបានទទួលយកដីជនជាតិដើមភាគតិចជាវត្ថុបញ្ចាំ ហើយក្រោយមក បានបង្ខំឱ្យពួកគេលក់ដីនោះ នៅពេលខ្លះ ទៅឱ្យជនដែលនៅខាងក្រៅសហគមន៍ជនជាតិដើមភាគតិចរបស់ពួកគេ។ អតិក្រមនេះរំលោភបំពានលើសិទ្ធិ វប្បធម៌ប្រពៃណី និងជីវភាពរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិច។ ការរាយការណ៍ជាសាធារណៈគាំទ្រដល់ភាពអាចជឿជាក់បាននៃការចោទប្រកាន់ទាំងនេះ ដោយបង្ហាញថា នៅខណៈពេលដែលមានការរឹតបន្តឹងតាមផ្លូវច្បាប់លើការលក់ដីជនជាតិដើមភាគតិចនោះ ការពន្យារពេលក្នុងការផ្ដល់បណ្ណកម្មសិទ្ធិដីសមូហភាព បានអនុញ្ញាតឱ្យមានការរីករាលដាលនៃការប្រើប្រាស់ប្លង់ដីទន់ជាវត្ថុបញ្ចាំនៅក្នុងតំបន់ជនជាតិដើមភាគតិច សម្រាប់ជនជាតិដើមភាគតិច ដើម្បីទទួលបានកម្ចី។

[2] ប្រភពនៃការសិក្សា និងការរាយការណ៍ជាសាធារណៈ ដែលត្រូវបានចង្អុលបង្ហាញ ពាក់ព័ន្ធនឹងផលប៉ះពាល់នីមួយៗ មាននៅក្នុងផ្នែកការចង្អុលបង្ហាញជាបឋមអំពីគ្រោះថ្នាក់ នៅក្នុងតួសេចក្ដីនៃរបាយការណ៍។ សូមមើលជើងទំព័រទី៣៥ ដល់ ៥២។

- **ការគំរាមកំហែង និងការសងសឹក** ដើមបណ្តឹង និងអង្គការមិនមែនរដ្ឋាភិបាល ដែលតំណាងឱ្យពួកគេ បានលើកឡើងអំពីកង្វល់នៃការសងសឹកពីអ្នកផ្តល់កម្ចីខ្នាតមីក្រូ និងអាជ្ញាធរមូលដ្ឋាន។ អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយ រាយការណ៍ថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាបានចោទប្រកាន់អ្នករិះគន់អំពីឧស្សាហកម្មនេះពីបទបរិហារកេរ្តិ៍និង "ការសម្របសម្រួល" ធ្វើឱ្យប៉ះពាល់ដល់មុខមាត់របស់ឧស្សាហកម្ម និងបានស្នើឱ្យអាជ្ញាធររដ្ឋាភិបាលចាត់វិធានការប្រឆាំងនឹងពួកគេ។

**ខ) មានការចង្អុលបង្ហាញជាបឋម ដែល IFC ប្រហែលជាមិនបានអនុលោមតាមគោលនយោបាយបរិស្ថាន និងសង្គមរបស់ខ្លួន** ជាពិសេស ទំនួលខុសត្រូវក្នុងការអនុវត្តការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន E&S និងការត្រួតពិនិត្យជាបន្តបន្ទាប់លើផលប៉ះពាល់ផ្នែកសង្គមនៃការវិនិយោគទាំងនេះលើអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ។

CAO សន្និដ្ឋានថា ផលប៉ះពាល់នៃគម្រោងលើអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ ត្រូវបានគ្របដណ្តប់ដោយ គោលនយោបាយ E&S របស់ IFC ដោយសារមូលហេតុដូចខាងក្រោម៖

- ក្របខណ្ឌនិរន្តរភាព***អនុវត្តចំពោះគម្រោង IFC ទាំងអស់*** និងផលប៉ះពាល់ E&S របស់គម្រោងទាំងនោះ ***លើកលែងតែត្រូវបានផាត់ចេញជាពិសេស*** (សូមមើល ឧទាហរណ៍ គោលនយោបាយនិរន្តរភាព កថាខណ្ឌទី ១ ៣ ២០ និង ២២)។
- ពុំមានការផាត់ចេញ ឬការដាក់កម្រិតបែបនោះ ទាក់ទងនឹងផលប៉ះពាល់លើអ្នកប្រើប្រាស់ហិរញ្ញវត្ថុ ឬអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ នៅក្នុងគោលនយោបាយនិរន្តរភាព ឬស្តង់ដារសមិទ្ធកម្ម (PS) របស់ IFC នោះទេ។ លើសពីនេះទៀត ការណែនាំរបស់ IFC បញ្ជាក់ថា ដំណើរការវាយតម្លៃផលប៉ះពាល់របស់គម្រោង ស្របតាម PS១ គួរតែគ្របដណ្តប់លើ "វិសាលភាពពេញលេញនៃហានិភ័យ និងផលប៉ះពាល់" ដែលពាក់ព័ន្ធនឹងគម្រោង រួមទាំង "ផលប៉ះពាល់ពិសេស" ដែលមិនត្រូវបានគ្របដណ្តប់ជាពិសេសដោយ PS ២ ដល់ ៨ (កំណត់សម្គាល់អំពីការណែនាំរបស់ IFC ចំពោះ PS១ កថាខណ្ឌទី ១៦ និង ១៧)។
- ដូច្នេះ ផលប៉ះពាល់សង្គម ដែលត្រូវបានចោទប្រកាន់ដោយដើមបណ្តឹង ដូចជា ការបាត់បង់ដីធ្លី និងជីវភាពរស់នៅ ភាពក្រីក្រ ការបាត់បង់អត្តសញ្ញាណ វប្បធម៌ និងជីវភាពរស់នៅដែលផ្អែកលើធនធានធម្មជាតិដោយជនជាតិដើមភាគតិច និងផលប៉ះពាល់សង្គមអវិជ្ជមានលើគ្រួសារ មកពីការធ្វើចំណាកស្រុកផ្នែកសេដ្ឋកិច្ច និងកុមារដែលត្រូវឈប់រៀន ត្រូវបានគ្របដណ្តប់ដោយគោលនយោបាយ E&S របស់ IFC ។
- លើសពីនេះទៀត មានលក្ខខណ្ឌតម្រូវជាក់លាក់ ពាក់ព័ន្ធនឹងការវិនិយោគមីក្រូហិរញ្ញវត្ថុទាំងនេះនៅក្នុង PS១ (ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម) ទាក់ទងនឹងប្រជាជនងាយរងគ្រោះ និងច្បាប់ជាតិ PS៧ (ជនជាតិដើមភាគតិច) និងបញ្ជីផាត់ចេញរបស់ IFC ទាក់ទងនឹងជនជាតិដើមភាគតិច។

ផ្អែកលើការវិភាគខាងលើ ក្របខណ្ឌនិរន្តរភាពអនុវត្តចំពោះផលប៉ះពាល់ដែលបានលើកឡើងដោយ

ដើមបណ្តឹង។ ទោះបីជាយ៉ាងណាក៏ដោយ ការត្រួតពិនិត្យជាបឋមរបស់ស៊ីអេអូ បានរកឃើញការចង្អុលបង្ហាញថា IFC មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនយ៉ាងសកម្ម និងជាប្រព័ន្ធ ទាក់ទងនឹងការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន និងការត្រួតពិនិត្យ E&S នៃគម្រោង ទាក់ទងនឹងហានិភ័យ និងផលប៉ះពាល់លើអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៃការវិនិយោគទាំងនេះទេ។

**គ)** គ្រោះថ្នាក់ចំពោះដើមបណ្តឹង ដែលត្រូវបានចោទប្រកាន់ មានទំនាក់ទំនងយ៉ាងសមហេតុផលនឹងភាពបដិលោម ដែលអាចកើតឡើង ពីព្រោះពួកគេអាចកាត់បន្ថយបានយ៉ាងសមហេតុផល ឬអាចដោះស្រាយប្រសិនបើហានិភ័យ និងផលប៉ះពាល់សង្គម ដែលទាក់ទងនឹងការអនុវត្តក្នុងការផ្តល់កម្ចី និងការប្រមូលប្រាក់របស់អតិថិជន ត្រូវបានកំណត់ដោយ IFC នៅក្នុងការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន និងការត្រួតពិនិត្យ E&S របស់ខ្លួន ដូចមានចែងនៅក្នុងក្របខណ្ឌនិរន្តរភាពរបស់ IFC។

## ជំហានបន្ទាប់

ស៊ីអេអូនឹងបន្តធ្វើការស៊ើបអង្កេតភាពអនុលោមនៃការវិនិយោគរបស់ IFC នៅអេស៊ីលីដា, អម្រឹត, ធនាគារ ហត្ថា, ក្រុមហ៊ុន Advans, ក្រុមហ៊ុន North Haven Thai, MEF និង MIFA និងការវិនិយោគដោយប្រយោលនៅប្រាសាក់ អិលអូអិលស៊ី និង ស្ថាបនា តាមរយៈ MEF និង MIFA ពីព្រោះការវិនិយោគទាំងនេះទាក់ទងនឹងបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង។ លក្ខខណ្ឌយោងសម្រាប់ការស៊ើបអង្កេត ស្របតាមគោលនយោបាយស៊ីអេអូ អាចស្វែងរកបាននៅក្នុងឧបសម្ព័ន្ធទី៧ នៃរបាយការណ៍នេះ និងការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC នៅក្នុងឧបសម្ព័ន្ធទី៥។ សេចក្តីព្រាងរបាយការណ៍ស៊ើបអង្កេតភាពអនុលោម នឹងត្រូវបញ្ចប់ក្នុងរយៈពេល ១៨ ខែ ក្រោយពេលបង្ហាញរបាយការណ៍វាយតម្លៃនេះ។[3]

របាយការណ៍វាយតម្លៃនេះនឹងត្រូវផ្សព្វផ្សាយនៅលើវេបសាយត៍របស់ស៊ីអេអូ និងចែករំលែកជាមួយក្រុមប្រឹក្សាគណៈគ្រប់គ្រង IFC អតិថិជន និងដើមបណ្តឹង។

[3] ជាវិធានការបណ្តោះអាសន្នចំពោះការអនុវត្តតាមខ្សែបន្ទាប់ពេលវេលានៃគោលនយោបាយស៊ីអេអូ នៅក្នុង FY២៤ ស៊ីអេអូនឹងបញ្ចប់សេចក្តីព្រាងការស៊ើបអង្កេតអំពីភាពអនុលោមក្នុងរយៈពេល ១៨ ខែ ក្រោយពេលបង្ហាញរបាយការណ៍វាយតម្លៃ។

## ១. សេចក្ដីផ្ដើម

ផ្នែកនេះផ្ដល់ជូននូវទិដ្ឋភាពទូទៅ និងបរិបទស្ដីពីការវិនិយោគដោយផ្ទាល់ និងដោយប្រយោលរបស់ IFC នៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជាចំនួនប្រាំមួយ ដែលជាកម្មវត្ថុនៃពាក្យបណ្ដឹងរបស់ស៊ីអេអូ ទាក់ទងនឹងការអនុវត្តផ្ដល់កម្ចី និងការប្រមូលប្រាក់។ បន្ទាប់មក វាពណ៌នាអំពីវិសាលភាព និងវិធីសាស្ត្រ ដែលស៊ីអេអូប្រើសម្រាប់ការវាយតម្លៃភាពអនុលោម ដែលបានអនុវត្តតាម នៅក្នុងរបាយការណ៍នេះ។

### ក) បរិបទនៃការវិនិយោគមីក្រូហិរញ្ញវត្ថុរបស់ IFC នៅកម្ពុជា

ក្រុមធនាគារពិភពលោកបានផ្ដល់ការគាំទ្រយ៉ាងទូលំទូលាយដល់វិស័យហិរញ្ញវត្ថុកម្ពុជា តាមរយៈជំនួយបច្ចេកទេស និងការវិនិយោគផ្ទាល់ ដោយផ្ដោតលើមីក្រូហិរញ្ញវត្ថុ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ។[4] IFC បានគាំទ្រដល់វិស័យមីក្រូហិរញ្ញវត្ថុរបស់ប្រទេសនេះ យ៉ាងហោចណាស់ ចាប់តាំងពីឆ្នាំ១៩៩៨ មក។

វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាបានផ្ដល់លទ្ធភាពទទួលបានឥណទានផ្លូវការដល់អ្នកខ្ចីមួយផ្នែកធំ ដែលពីមុនមក ត្រូវបានដាត់ចេញពីប្រព័ន្ធធនាគារផ្លូវការ ធ្វើឲ្យសុខុមាលភាពរបស់គ្រួសារជាច្រើននៅក្នុងប្រទេសកម្ពុជាមានភាពប្រសើរឡើង។ ស្របគ្នានេះដែរ IFC បានធ្វើការជាមួយរដ្ឋាភិបាលកម្ពុជា ធនាគារជាតិនៃកម្ពុជា (NBC) និងសមាគមនៃវិស័យហិរញ្ញវត្ថុ ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់ប្រទេស និងលើកកម្ពស់ការផ្ដល់កម្ចីប្រកបដោយទំនួលខុសត្រូវ ការរាយការណ៍អំពីឥណទានប្រកបដោយតម្លាភាព និងការអនុវត្តល្អៗក្នុងការប្រមូលបំណុល។[5] ទោះបីជាយ៉ាងណាក៏ដោយ ភាពរីកចម្រើនយ៉ាងឆាប់រហ័សរបស់ឧស្សាហកម្មនេះ និងអវត្តមានក្របខណ្ឌនិយ័តកម្មរឹងមាំបានធ្វើឱ្យមានកង្វល់អំពីនិរន្តរភាពរបស់វិស័យនេះ និងផលប៉ះពាល់អវិជ្ជមានដែលអាចកើតឡើង នៃការជំពាក់បំណុលច្រើនពេក។

### ខ) ការផ្ដល់កម្ចីរបស់ IFC ដល់គ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជាទាំងប្រាំមួយ

នៅខែកុម្ភៈ ឆ្នាំ២០២២ ស៊ីអេអូបានទទួលពាក្យបណ្ដឹងមួយ ទាក់ទងនឹងការអនុវត្តក្នុងការផ្ដល់កម្ចី និងការប្រមូលប្រាក់របស់គ្រឹះស្ថានហិរញ្ញវត្ថុចំនួនប្រាំមួយ ដែលដំណើរការនៅកម្ពុជា៖ ធនាគារ អេស៊ីលីដា ភីអិលស៊ី (អេស៊ីលីដា), គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត (អម្រឹត), ធនាគារ ហត្ថា (ធនាគារ ហត្ថា), អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី (អិលអូអិលស៊ី), គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក (ប្រាសាក់) និង ធនាគារ ស្ថាបនា ភីអិលស៊ី (ស្ថាបនា)។ IFC មានការវិនិយោគផ្ទាល់នៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុបីដំបូង និងការផ្ដល់ហិរញ្ញវត្ថុដោយប្រយោលនៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុបីក្រោយ តាមរយៈការវិនិយោគនៅក្នុងមូលនិធិចំនួនបី–ឥណទានពង្រឹងមីក្រូហិរញ្ញវត្ថុ S.A., SICAV-SIF (MEF), មូលនិធិគំនិតផ្ដួចផ្ដើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុលអាស៊ី SA, SICAV-SIF (MIFA) និង ក្រុមហ៊ុន North Haven Thai Private Equity L.P (North Haven Thai) ព្រមទាំង ក្រុមហ៊ុនហូលឌិញ Advans

---

[4] ក្របខណ្ឌភាពជាដៃគូប្រចាំប្រទេសរបស់ក្រុមធនាគារពិភពលោកសម្រាប់ប្រទេសកម្ពុជា (FY២០១៩-FY២០២៣) ទំព័រ ២៥ https://pressroom.ifc.org/all/pages/PressDetail.aspx?ID=24563

[5] ក្របខណ្ឌភាពជាដៃគូប្រចាំប្រទេសរបស់ក្រុមធនាគារពិភពលោកសម្រាប់ប្រទេសកម្ពុជា (FY២០១៩-FY២០២៣) ទំព័រ ២៥

S.A. (Advans)។ ជារួម សំណុំរឿងនេះពាក់ព័ន្ធនឹងគម្រោង IFC ចំនួន ១៣ ដែលគាំទ្រកម្មវិធីផ្តល់កម្ចីដល់សហគ្រាសធុនមីក្រូ ធុនតូច និងមធ្យម (MSME)[6] និងមានភាពសកម្មនៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់ជូនស៊ីអេអូ។[7] ព័ត៌មានលម្អិតបន្ថែមទៀត អំពីអតិថិជននីមួយៗរបស់ IFC ត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធទី១។

[6] កម្ចីមួយចំនួនបង្កើតការវិនិយោគជាអប្បបរមានៅក្នុងប្រភេទអ្នកខ្ចីចុងក្រោយ (ឧ. ៥០ ភាគរយ ដើម្បីផ្តល់មូលនិធិដល់ MSEs ដែលគ្រប់គ្រងដោយស្ត្រី ឬកសិអាជីវកម្ម) ប៉ុន្តែមិនដាក់កម្រិតលើរាល់ប្រាក់ចំណូលទាំងអស់ចំពោះអ្នកខ្ចីចុងក្រោយនៅក្នុងប្រភេទណាមួយនោះទេ។

[7] **អេស៊ីលីដា៖** គម្រោងលេខ 44882 និង 42480 ដែលនៅមានភាពសកម្ម, **អម្រឹត៖** គម្រោងលេខ 34748 44231 (ទាំងពីរមានភាពសកម្ម) លេខ 41294 (បានចាកចេញនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២), ធនាគារ ហត្ថា៖ គម្រោងលេខ 39167 44211 (បានចាកចេញនៅថ្ងៃទី១៥ និង ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២២ រៀងៗគ្នា) និងលេខ 45535 និង 44742 ដែលនៅមានភាពសកម្ម, MEF គម្រោងលេខ 27827 MIFA គម្រោងលេខ 31467 North Haven Thai គម្រោងលេខ 38609 និង Advans S.A. គម្រោងលេខ 21856។ ក្នុងចំណោមគម្រោងទាំង ១៣ ដែលជាប់ពាក់ព័ន្ធ គម្រោងចំនួន ៧ ត្រូវបានចាត់ថ្នាក់ជា FI-៣ គម្រោងចំនួន ៣ ជា FI-៣ និងគម្រោងចំនួន ៣ ជា FI (ស្របតាមគោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦)។ គម្រោងចំនួនប្រាំផ្សេងទៀតនៅអេស៊ីលីដា កាលពីដំបូង ត្រូវបានរួមបញ្ចូលនៅក្នុងសំណុំរឿងនេះ (លេខ 32642 30607 34386 35963 និង 37594) ពីព្រោះវាត្រូវបានកត់ត្រាថាមានភាពសកម្ម នៅពេលដែលស៊ីអេអូធ្វើការសម្រេចចិត្តលើភាពសមស្រប នៅខែមេសា ឆ្នាំ២០២២។ ចាប់តាំងពីពេលនោះមក IFC បានបញ្ជាក់ប្រាប់ស៊ីអេអូថា គម្រោងចំនួនបួនដំបូងត្រូវបានចាកចេញមុនរយៈពេល ១៥ ខែ ដែលត្រូវបានអនុញ្ញាតដោយគោលនយោបាយស៊ីអេអូ ក្នុងការពិចារណាអំពីគម្រោងដែលត្រូវបានចាកចេញ (កថាខណ្ឌទី ៤៩ នៃគោលនយោបាយស៊ីអេអូ)។ គម្រោងលេខ 30607 ត្រូវបានចាកចេញនៅខែសីហា ឆ្នាំ២០១៨ លេខ 32642 ត្រូវបានចាកចេញនៅខែតុលា ឆ្នាំ២០១៩ លេខ 34386 ត្រូវបានចាកចេញនៅខែមិថុនា ឆ្នាំ២០១៨ និង លេខ 35963 បានចាកចេញនៅខែមិថុនា ឆ្នាំ ២០២០។ ដូច្នេះ គម្រោងរបស់អេស៊ីលីដាទាំងបួននេះ នឹងត្រូវដកចេញពីការពិចារណានៅក្នុងសំណុំរឿងនេះ។ គម្រោងលេខ 37594 បានចាកចេញនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ដែលស្ថិតនៅក្នុងរយៈពេល ១៥ ខែ ដែលមានចែងនៅក្នុងគោលនយោបាយស៊ីអេអូ សម្រាប់ការទទួលយកគម្រោងដែលបានចាកចេញជាសក្តានុពល។ ទោះបីជាយ៉ាងណាក៏ដោយ ការសម្រេចចិត្តលើភាពសមស្របរបស់ស៊ីអេអូបានកំណត់ការដកចេញនូវគម្រោងដែលបានចាកចេញ មុនពេលដែលពាក្យបណ្តឹងត្រូវបានដាក់ជូនស៊ីអេអូ។ ដូច្នេះ គម្រោងនេះ ដែល IFC បានបញ្ជាក់ថា បានចាកចេញនៅខែកុម្ភៈ ឆ្នាំ២០២១ នឹងមិនត្រូវបានពិចារណាថាជាផ្នែកមួយនៃការត្រួតពិនិត្យភាពអនុលោមនៅក្នុងសំណុំរឿងនេះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ដូចបានជូនដំណឹងអំពីការសម្រេចចិត្តលើភាពសមស្រប ក្នុងខែមេសា ឆ្នាំ២០២២ នៅខណៈពេលដែលស៊ីអេអូនឹងមិនត្រួតពិនិត្យភាពអនុលោមរបស់ IFC ទាក់ទងនឹងការវិនិយោគដែលបានចាកចេញទាំងនេះទេនោះ ស៊ីអេអូនឹងពិចារណាលើការវិនិយោគដែលបានចាកចេញទាំងអស់ ដែលទាក់ទងនឹងសំណុំរឿងនេះ ជាផ្នែកមួយនៃបរិបទរបស់ពាក្យបណ្តឹង ដើម្បីធានាបាននូវការយល់ដឹងយ៉ាងពេញលេញអំពីទំនាក់ទំនងហិរញ្ញវត្ថុ និងទំនាក់ទំនងរបស់ IFC ជាមួយអតិថិជន និងអតិថិជនបន្តខុសៗគ្នា។

**រូបភាពទី១៖ ការផ្តល់ហិរញ្ញវត្ថុរបស់ IFC ដល់អេស៊ីលីដា អម្រឹត ធនាគារហត្ថា អិលអូអិលស៊ី ប្រាសាក់ និងស្ថាបនា**




## គ) វិសាលភាព និងវិធីសាស្ត្រវាយតម្លៃភាពអនុលោម

វិសាលភាពនៃការវាយតម្លៃភាពអនុលោមរបស់ស៊ីអេអូត្រូវបានដាក់កម្រិតចំពោះបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្ដឹង និងរបាយការណ៍វាយតម្លៃរបស់ស៊ីអេអូ។[8] ស៊ីអេអូធ្វើការសម្រេចចិត្តលើការវាយតម្លៃ ដោយផ្អែកលើលក្ខណវិនិច្ឆ័យនៃការវាយតម្លៃ និងការពិចារណាដែលពាក់ព័ន្ធដទៃទៀត ដែលមាននៅក្នុងគោលនយោបាយស៊ីអេអូ។ ការវាយតម្លៃរួមបញ្ចូលការត្រួតពិនិត្យជាបឋមលើព័ត៌មានខាងក្រោម៖

- ឯកសារទាក់ទងនឹងពាក្យបណ្ដឹង របាយការណ៍វាយតម្លៃរបស់ស៊ីអេអូ និងការឆ្លើយតបពីគណៈគ្រប់គ្រងរបស់ IFC ចំពោះពាក្យបណ្ដឹង
- IFC និងឯកសារអតិថិជនស្តីពីការអនុវត្តលក្ខខណ្ឌតម្រូវផ្នែកបរិស្ថាន និងសង្គម (E&S) របស់គម្រោង និងការពិចារណាផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ
- ព័ត៌មានដែលប្រមូលបានតាមរយៈបទសម្ភាសន៍ជាមួយតំណាងដើមបណ្ដឹង និងក្រុមការងារនៃគម្រោង IFC និង

[8] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ៨៨.

- របាយការណ៍សាធារណៈដែលពាក់ព័ន្ធ ឯកសារយោងនៃការសិក្សា និងរបាយការណ៍ពីប្រព័ន្ធផ្សព្វផ្សាយ។

ស៊ីអេអូសូមថ្លែងអំណរគុណដល់ភាគីទាំងអស់ ដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ ដែលបានចែករំលែកទស្សនៈ ចំណេះដឹង និងពេលវេលា។

## ២. កង្វល់ដែលត្រូវបានលើកឡើងដោយដើមបណ្តឹង

នៅខែកុម្ភៈ ឆ្នាំ២០២២ ស៊ីអេអូបានទទួលពាក្យបណ្តឹងពីអង្គការមិនមែនរដ្ឋាភិបាលចំនួនពីរ–អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) និង អង្គការសមធម៌កម្ពុជា (EC)–តាមនាមឲ្យក្រុមអ្នកខ្ចីប្រាក់មួយក្រុមពីប្រទេសកម្ពុជា។ ពាក្យបណ្តឹងនេះបានលើកឡើងអំពីកង្វល់ទាក់ទងនឹងការអនុវត្តក្នុងការផ្តល់កម្ចី និងការប្រមូលប្រាក់របស់គ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារចំនួនប្រាំមួយ ដែលដំណើរការនៅក្នុងប្រទេស។

ដើមបណ្តឹងគឺសុទ្ធតែជាអ្នកទទួលកម្ចីពីគ្រឹះស្ថានហិរញ្ញវត្ថុមួយ ឬច្រើនក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុទាំងប្រាំមួយ ដែលពាក់ព័ន្ធ។ ដោយខ្លាចការសងសឹក ពួកគេបានស្នើសុំឱ្យស៊ីអេអូ រក្សាអត្តសញ្ញាណរបស់ពួកគេជាការសម្ងាត់ និងមិនបញ្ជាក់អំពីចំនួនដើមបណ្តឹង ឬព័ត៌មានលម្អិតអំពីកម្ចីរបស់ពួកគេនោះទេ។ កំណែដែលបានកែសម្រួល នៃពាក្យបណ្តឹង ត្រូវបានភ្ជាប់មកជាមួយរបាយការណ៍វាយតម្លៃនេះ នៅក្នុងឧបសម្ព័ន្ធទី៤។[9]

ជារួម អ្នកខ្ចីចោទប្រកាន់ថា ពួកគេបានទទួលរងគ្រោះថ្នាក់ដោយសារការអនុវត្តក្នុងការផ្តល់កម្ចី និងការប្រមូលប្រាក់របស់ធនាគារ ហើយថា ពួកគេបានទទួលរងការដាក់សម្ពាធឱ្យលក់ទ្រព្យសម្បត្តិរបស់ពួកគេដើម្បីសងកម្ចី។ ពួកគេអះអាងថា អ្នកផ្តល់កម្ចីមិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ ដើម្បីឱ្យអ្នកខ្ចីអាចធ្វើការវាយតម្លៃអំពីផលវិបាកនៃការចុះកិច្ចព្រមព្រៀងកម្ចីបានទេ រួមទាំងកង្វះខាតព័ត៌មានជាភាសាជនជាតិដើមភាគតិច។

ដើមបណ្តឹងផ្តល់ទឡ្ហីករណ៍ថា ការរួមបញ្ចូលគ្នានៃការជ្រៀតចូលទីផ្សារកម្រិតខ្ពស់ តិត្ថិភាពខ្ពស់ កង្វះខាតកិច្ចការពារអ្នកប្រើប្រាស់ និងការអនុវត្តច្បាប់ដែលមានស្រាប់របស់រដ្ឋាភិបាលមិនគ្រប់គ្រាន់ បានជំរុញឱ្យមានកលយុទ្ធដែលមានការឈ្លានពាន ការបោកប្រាស់ និងឃោឃៅដោយមន្ត្រីឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ។ ពួកគេចោទប្រកាន់ថា វាគឺជាការអនុវត្តទូទៅសម្រាប់អ្នកផ្តល់កម្ចីនៅកម្ពុជា–រួមទាំងអ្វីដែលបានដកស្រង់នៅក្នុងពាក្យបណ្តឹងផងដែរ–ដើម្បីពង្រីកអាជីវកម្មរបស់ពួកគេ តាមរយៈការផ្តល់កម្ចីលើសចំនួនកំណត់ ដល់សហគ្រាសធុនមីក្រូ ធុនតូច និងមធ្យម នៅពេលខ្លះ ម្តងហើយម្តងទៀត និងក្នុងចំនួនទឹកប្រាក់កាន់តែច្រើនដោយមិនបានវាយតម្លៃយ៉ាងពេញលេញអំពីសមត្ថភាពរបស់អ្នកខ្ចីក្នុងការសងកម្ចីនោះទេ។ នៅពេលដែលអ្នកខ្ចីខកខានមិនបានបង់ប្រាក់ សូម្បីតែពីរបីថ្ងៃ ដើមបណ្តឹងបញ្ជាក់ថា អ្នកផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុ ជាញឹកញាប់ បានប្រើកលយុទ្ធក្នុងការប្រមូលប្រាក់ក្រៅប្រព័ន្ធតុលាការដោយបង្ខំ។ ទាំងនេះ រួមមាន ការបៀតបៀនអ្នកខ្ចីនៅផ្ទះ ការ

---

[9] ដើមបណ្តឹងបានស្នើសុំឲ្យរក្សាពាក្យបណ្តឹងពេលលេញ ជាលាយលក្ខណ៍អក្សរ និងអត្តសញ្ញាណរបស់ពួកគេជាការសម្ងាត់។ កំណែពាក្យបណ្តឹងដែលត្រូវបានកែសម្រួល ត្រូវបានភ្ជាប់មកជាមួយរបាយការណ៍វាយតម្លៃនេះ និងបានផ្សព្វផ្សាយនៅលើវែបសាយត៍សំណុំរឿងរបស់ស៊ីអេអូ នៅទីនេះ៖ https://bit.ly/3B16eHG។

គំរាមនាំពួកគេទៅជួបអាជ្ញាធរមូលដ្ឋាន និងការដាក់សម្ពាធឲ្យអ្នកខ្ចីលក់ដីធ្លីរបស់ពួកគេដើម្បីសងកម្ចី ជាជាងការបន្តប្រមូលប្រាក់តាមនីតិវិធីច្បាប់។

ដើមបណ្តឹងផ្តល់ទឡ្ហីករណ៍ថា IFC បានបរាជ័យម្តងហើយម្តងទៀត ទាំងក្នុងការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នឲ្យបានគ្រប់គ្រាន់លើការវិនិយោគរបស់ខ្លួននៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុទាំងនេះ និងការត្រួតពិនិត្យការងាររបស់ពួកគេ នៅពេលមានភាពសកម្ម។ ជាពិសេស ពួកគេចោទប្រកាន់ថា IFC មិនបានត្រួតពិនិត្យឱ្យបានគ្រប់គ្រាន់លើប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) របស់អតិថិជនដែលជាអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុ ដែលពួកគេពណ៌នាថា "មិនគ្រប់គ្រាន់យ៉ាងច្បាស់លាស់ ក្នុងការដោះស្រាយការអនុវត្តប្រាក់កម្ចីដ៏ឃោឃៅ និងបោកបញ្ឆោត ការផ្តល់កម្ចីគ្មានទំនួលខុសត្រូវ [...] និងការបង្ខិតបង្ខំ និងការគំរាមកំហែងពីមន្ត្រីឥណទាន"។ ពួកគេបានចោទប្រកាន់ថា កង្វះខាតការត្រួតពិនិត្យគម្រោងយ៉ាងប្រុងប្រយ័ត្ន និងការត្រួតពិនិត្យឲ្យបានត្រឹមត្រូវនេះអនុញ្ញាតឱ្យមានគ្រោះថ្នាក់ផ្នែកសង្គមដែលពាក់ព័ន្ធ ចំពោះដើមបណ្តឹង និងសហគមន៍របស់ពួកគេ "ដើម្បីបន្តប្រព្រឹត្តិផ្ទុយពីស្តង់ដារសមិទ្ធកម្មរបស់ IFC ឥតឈប់ឈរ"។

អ្នកខ្ចីក៏ចោទប្រកាន់ផងដែរថា តម្លាភាពរបស់ IFC ទាក់ទងនឹងការវិនិយោគនៅក្នុងអន្តរការីហិរញ្ញវត្ថុ (FIs) នៅមានកម្រិត មិនគ្រប់គ្រាន់ និងផ្ទុយពីគោលនយោបាយសិទ្ធិទទួលបានព័ត៌មានរបស់ IFC។ ពួកគេផ្តល់ទឡ្ហីករណ៍ថា ការលាតត្រដាងរបស់ IFC អំពីគម្រោងអន្តរការីហិរញ្ញវត្ថុ (FI) ផ្តល់ព័ត៌មានតិចតួច និងអសង្គតិភាពនឹង ESMS ការវាយតម្លៃ E&S ដែលពាក់ព័ន្ធ និងផែនការសកម្មភាពបរិស្ថាន និងសង្គម (ESAP) ដែលបានព្រមព្រៀងគ្នារវាង IFC និងអតិថិជន ព្រមទាំងការត្រួតពិនិត្យរបស់ IFC ជាបន្តបន្ទាប់ផងដែរ។

ដោយសារការអនុវត្ត និងការខកខានមិនបានអនុវត្តទាំងនោះ ដើមបណ្តឹងអះអាងថា ពួកគេបានរងគ្រោះដោយសារផលប៉ះពាល់អវិជ្ជមានដូចខាងក្រោម ដោយសារការរំលោភបំពេញលើគោលនយោបាយ E&S របស់ IFC៖

- **ការបាត់បង់ដីធ្លី៖** ដើមបណ្តឹងអះអាងថា អ្នកផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុតែងតែស្នើសុំឲ្យពួកគេដាក់ដីធ្លីរបស់ពួកគេ—រួមទាំងដីសហគមន៍ជនជាតិដើមភាគតិច—ជាវត្ថុបញ្ចាំ ដើម្បីទទួលបានការអនុម័តលើកម្ចី និងបន្ទាប់មក បង្ខំពួកគេឲ្យលក់ដីធ្លីមុនពេលកំណត់ ដើម្បីប្រមូលប្រាក់។ ពួកគេអះអាងថា អ្នកផ្តល់កម្ចីចាប់អារម្មណ៍លើការធានាកម្មសិទ្ធិដីធ្លីច្រើនជាងលទ្ធភាពរបស់អ្នកខ្ចីក្នុងការសងកម្ចី។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនត្រឹមតែរក្សាទុកបណ្ណកម្មសិទ្ធដីធ្លីប៉ុណ្ណោះទេ ប៉ុន្តែ ជាញឹកញាប់ ពួកគេថែមទាំងតម្រូវឱ្យអ្នកខ្ចីដាក់បណ្ណកម្មសិទ្ធិជាច្រើន លើសពីតម្លៃកម្ចីថែមទៀត ដើម្បីទប់ស្កាត់ពួកគេមិនឲ្យប្រើប្រាស់បណ្ណកម្មសិទ្ធិដីធ្លីដើម្បីធានាកម្ចីពីគ្រឹះស្ថានដទៃទៀត។ យោងតាមអ្នកដាក់ពាក្យបណ្តឹង អ្នកផ្តល់កម្ចីបានបង្ខំពួកគេឱ្យលក់ដីធ្លីក្រៅនីតិវិធីច្បាប់ ដើម្បីប្រមូលវត្ថុបញ្ចាំដោយពុំមានព័ត៌មានគ្រប់គ្រាន់ជាមុននោះទេ។ អ្នកខ្ចីនៅកម្ពុជា ជាញឹកញាប់ មានការយល់ដឹងតិចតួចអំពីសិទ្ធិតាមផ្លូវច្បាប់របស់ពួកគេ។ ការយល់ខុសជាទូទៅ រួមមាន ការភ័យខ្លាចថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាចលក់ដីរបស់ពួកគេ ប្រសិនបើពួកគេយឺតយ៉ាវក្នុងការសងប្រាក់មួយថ្ងៃ និងថា ប្រសិនបើពួកគេមិនលក់ដីដោយខ្លួនឯងទេ អ្នកផ្តល់កម្ចីអាចលក់ដីនោះ

ក្នុងតម្លៃទាបជាងទីផ្សារ ដើម្បីយកកម្ចីមកវិញ។ យោងតាមដើមបណ្ដឹង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាញយកផលប្រយោជន៍ពីភាពគ្មានចំណេះដឹងរបស់អ្នកខ្ចីអំពីដំណើរការតាមផ្លូវច្បាប់ និងសិទ្ធិរបស់ពួកគេក្នុងការបញ្ជាក់ថា ការសងយឺតនឹងនាំមកនូវផលវិបាកបន្ថែមទៀត និងគំរាមកំហែងថានឹងត្រូវដោះស្រាយជាមួយអាជ្ញាធរមូលដ្ឋាន។

- **ផលប៉ះពាល់លើជីវភាពរស់នៅ៖** ដើមបណ្ដឹងបញ្ជាក់ថា ពួកគេមិនត្រឹមតែត្រូវលក់ដីធ្លីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រភពចំណូលផ្សេងទៀត ដូចជា ឧបករណ៍នានា ដើម្បីសងបំណុលដល់អ្នកផ្ដល់កម្ចី។ ជាលទ្ធផល ប្រភពចំណូលរបស់ពួកគេបានថយចុះ ច្រើនជាងរីកចម្រើន ដោយសារការខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុ ដែលធ្វើឱ្យពួកគេបរិភោគអាហារតិច និងមានគុណភាពទាប ដើម្បីឆ្លើយតបនឹងការទូទាត់កម្ចី។
- **ផលប៉ះពាល់លើគ្រួសារ៖** ដើមបណ្ដឹង រួមទាំងគ្រួសារដែលត្រូវបញ្ឈប់កូនពីសាលារៀន ដោយសារពួកគេពុំមានលទ្ធភាពបង់ថ្លៃសិក្សា និងត្រូវការឲ្យកូនរបស់ពួកគេទៅធ្វើការ និងរួមចំណែកដល់ការសងបំណុល។ គ្រួសារខ្លះក៏រាយការណ៍ថាបានធ្វើចំណាកស្រុក ឬត្រូវការឲ្យកូនរបស់ពួកគេធ្វើចំណាកស្រុកដើម្បីបង្កើតប្រាក់ចំណូលបន្ថែមដើម្បីសងកម្ចី។ លើសពីនេះទៀត ដើមបណ្ដឹងបានរាយការណ៍អំពីការកើនឡើងនៃការធ្វើអត្តឃាតដែលទាក់ទងនឹងបំណុល ដោយសារវិបត្តិបំណុលច្រើនពេក។
- **ផលប៉ះពាល់លើជនជាតិដើមភាគតិច៖** ដើមបណ្ដឹងមួយចំនួនជាសមាជិកសហគមន៍ជនជាតិដើមភាគតិច។ ពួកគេអះអាងថា អ្នកផ្ដល់កម្ចី ជាញឹកញាប់ បានទទួលយកដីជនជាតិដើមភាគតិចជាវត្ថុបញ្ចាំ ដែលក្រោយមក ត្រូវបានលក់ទៅឱ្យជនដែលមិនមែនជាសមាជិកសហគមន៍ ដែលរំលោភបំពានលើសិទ្ធិ វប្បធម៌ ប្រពៃណី និងជីវភាពរស់នៅរបស់ជនជាតិដើមភាគតិច។ យោងតាមដើមបណ្ដឹង អ្នកផ្ដល់កម្ចី ជាញឹកញាប់ លើកទឹកចិត្តឲ្យសមាជិកសហគមន៍ជនជាតិដើមភាគតិចស្នើសុំប្លង់ទន់ដីធ្លីផ្ទាល់ខ្លួន[10] និងបោះបង់ចោលបណ្ណកម្មសិទ្ធិសហគមន៍ ដើម្បីធានាកម្ចី។
- **ការគំរាមកំហែង និងការសងសឹក៖** ដើមបណ្ដឹងបានសម្ដែងភាពភ័យខ្លាចចំពោះការសងសឹកពីអ្នកផ្ដល់កម្ចីខ្នាតមីក្រូរបស់ពួកគេ និងអាជ្ញាធរមូលដ្ឋាន ដោយបញ្ជាក់ថា មន្ត្រីឥណទាន ជាញឹកញាប់ ងាកទៅធ្វើការគំរាមកំហែង បំភិតបំភ័យ និងបៀតបៀន។ អង្គការមិនមែនរដ្ឋាភិបាល ដែលតំណាងឱ្យដើមបណ្ដឹងក៏រាយការណ៍ថា កំពុងទទួលរងការគំរាមកំហែងពីចំណាត់ការផ្លូវច្បាប់ និងការចោទប្រកាន់ពីបទញុះញង់ ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន ដែលមានឈ្មោះនៅក្នុងពាក្យបណ្ដឹងនេះផងដែរ។

ដើមបណ្ដឹងបញ្ជាក់ថា IFC បានដឹងពីព័ត៌មានដែលមានជាសាធារណៈ ទាក់ទងនឹងគ្រោះថ្នាក់ផ្នែកសង្គមយ៉ាងទូលំទូលាយ និងការការពារអ្នកប្រើប្រាស់មិនបានគ្រប់គ្រាន់ នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា ចាប់តាំងពីឆ្នាំ ២០១៦ មកម្ល៉េះ ប៉ុន្តែ IFC បានអនុម័តហិរញ្ញប្បទានបន្ថែម និងចាត់ថ្នាក់គម្រោងថ្មីៗថា មានហានិភ័យទាប។ ពួកគេអះអាងថា ទោះបីជាមានការកើនឡើងនូវគ្រោះថ្នាក់ផ្នែកសង្គមក៏ដោយ ក៏ពុំមានការចង្អុលបង្ហាញថា IFC

[10] ពាក្យ ប្លង់ទន់ដីធ្លី សំដៅលើ ការអនុវត្តរបស់អាជ្ញាធរមូលដ្ឋាននៅកម្ពុជា ដែលចេញលិខិតបញ្ជាក់ភាពជាកម្មសិទ្ធិដីធ្លី ដែលបន្ទាប់មក ត្រូវបានជួញដូរនៅក្រៅប្រព័ន្ធសុរិយោដីផ្លូវការ។

បានវាយតម្លៃឡើងវិញលើការប្តេជ្ញាចិត្ត ឬសមត្ថភាពរបស់អតិថិជន FI របស់ខ្លួន ក្នុងការគ្រប់គ្រងគម្រោងប្រចាំថ្ងៃ ដែលមានហានិភ័យ និងមានផលប៉ះពាល់សង្គមខ្ពស់ មុនពេលអនុម័តការវិនិយោគបន្ថែមទៀតនោះទេ។

ពួកគេអះអាងបន្ថែមទៀតថា ការអនុវត្ត និងនីតិវិធី ស្របតាមគោលនយោបាយ E&S របស់ IFC នាពេលបច្ចុប្បន្ន បានបង្ហាញចន្លោះប្រហោងនៅក្នុងការពិនិត្យតាមដាន និងត្រួតពិនិត្យរបស់ IFC លើអតិថិជន FI របស់ខ្លួន។ ជាពិសេស ដើមបណ្តឹងអះអាងថា IFC មិនបានត្រួតពិនិត្យឱ្យបានត្រឹមត្រូវលើសកម្មភាពអាជីវកម្មរបស់អតិថិជនមីក្រូហិរញ្ញវត្ថុរបស់ខ្លួននោះទេ ដោយសារអតិថិជនទាំងនេះមិនត្រូវបានតម្រូវឱ្យត្រួតពិនិត្យសកម្មភាពផ្តល់កម្ចីរបស់ពួកគេ ដើម្បីពិនិត្យមើលហានិភ័យ E&S និងបណ្តាលឱ្យមានគ្រោះថ្នាក់ដល់អ្នកខ្ចី។ ពាក្យបណ្តឹងពណ៌នាអំពីចន្លោះប្រហោងនៅក្នុងការត្រួតពិនិត្យ E&S ថា មានសារៈសំខាន់ ពីព្រោះអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ ជាញឹកញាប់ ជាប្រជាជនដែលងាយរងគ្រោះ ដូច្នេះហើយទាមទារឲ្យមានការការពារ និងការត្រួតពិនិត្យបន្ថែមទៀត ដើម្បីធានាថាគម្រោង IFC ពុំមានផលប៉ះពាល់ដែលបង្កគ្រោះថ្នាក់ដល់សង្គម។

នៅខែមេសា ឆ្នាំ២០២២ ស៊ីអេអូបានរកឃើញថា ពាក្យបណ្តឹងមានភាពសមស្រប និងចាប់ផ្តើមធ្វើការវាយតម្លៃ។ ដោយសារពុំមានការឯកភាពជាឯកច្ឆន្ទលើដំណើរការដោះស្រាយវិវាទក្រោមការគាំទ្ររបស់ស៊ីអេអូ និងដោយមានការយល់ព្រមពីដើមបណ្តឹង សំណុំរឿងនេះត្រូវបានផ្ទេរទៅកាន់មុខងារភាពអនុលោមរបស់ស៊ីអេអូ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២ ដើម្បីធ្វើការវាយតម្លៃភាពអនុលោម។[11]

### ៣. សេចក្តីសង្ខេបអំពីការឆ្លើយតបរបស់ IFC

ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC ចំពោះពាក្យបណ្តឹង អះអាងថា នៅខណៈពេលដែលគ្រោះថ្នាក់ដែលត្រូវបានអះអាងនៅក្នុងពាក្យបណ្តឹងគឺ ធ្ងន់ធ្ងរ នោះ វាមិនមែនជាលទ្ធផលនៃភាពបដិលោមតាមគោលនយោបាយ E&S របស់ IFC នោះទេ។[12]

យោងតាមគណៈគ្រប់គ្រង IFC ផលប៉ះពាល់នៃការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុលើអ្នកខ្ចីស្ថិតនៅក្រៅវិសាលភាពនៃគោលនយោបាយ E&S របស់ IFC សម្រាប់ហេតុផលដូចខាងក្រោម៖

ក. អ្នកប្រើប្រាស់ផលិតផលរបស់អតិថិជនមិនត្រូវបានយោងដល់ នៅក្នុងគោលនយោបាយនិរន្តរភាព ឬស្តង់ដារសមិទ្ធកម្មថាជាភាគីពាក់ព័ន្ធមួយប្រភេទ ដែលវិធានការកាត់បន្ថយហានិភ័យ E&S គួរតែអនុវត្តចំពោះពួកគេនោះទេ។

[11] ស៊ីអេអូ របាយការណ៍វាយតម្លៃអំពីកង្វល់នានា ទាក់ទងនឹងគម្រោង និងអនុគម្រោងរបស់ IFC នៅកម្ពុជា ពាក់ព័ន្ធនឹងគ្រឹះស្ថានហិរញ្ញវត្ថុចំនួន ៧ និងមូលនិធិចំនួន ៣ (គម្រោង IFC លេខ ២១៨៥៦ ២៧៨២៧ ៣០៦០៧ ៣១៤៦៧ ៣២៦៤២ ៣៤៣៨៦ ៣៤៧៤៨ ៣៥៩៦៣ ៣៧៥៩៤ ៣៨៦០៩ ៣៩១៦៧ ៤១២៩៤ ៤២៤៨០ ៤៤២១១ ៤៤២៣១ ៤៤៧៤២ ៤៤៨៨២ ៤៥៥៣៥) ខែវិច្ឆិកា ឆ្នាំ២០២២ មាននៅ https://bit.ly/3HFXQ49

[12] សូមមើល ឧបសម្ព័ន្ធទី២៖ ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC (ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២).

ខ. ក្របខណ្ឌនិរន្តរភាពអនុវត្តចំពោះហានិភ័យ E&S ដែលអាចកើតឡើង និងផលប៉ះពាល់នៃ "សកម្មភាពអាជីវកម្ម" ដែលបានទទួលការគាំទ្រលើ "សហគមន៍ជុំវិញ និងពលករ" ប៉ុន្តែវាមិនអនុវត្តចំពោះផលប៉ះពាល់ E&S លើអតិថិជនបន្តដោយផ្ទាល់ទេ (ក្នុងករណីនេះ ជាអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ)។

គ. សកម្មភាពអាជីវកម្ម ដែល IFC គាំទ្រតាមរយៈអតិថិជន FI មិនមែនជាការផ្តល់កម្ចីដោយមីក្រូហិរញ្ញវត្ថុដោយផ្ទាល់នោះទេ ប៉ុន្តែជាសកម្មភាពដែលកើតចេញពីការប្រើប្រាស់កម្ចីទាំងនោះដោយអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ (ឧទាហរណ៍ កសិកម្មខ្នាតតូច ឬសកម្មភាពពាណិជ្ជកម្ម ដូចជា ហាងទំនិញ)។

ឃ. IFC ដោះស្រាយបញ្ហាទាក់ទងនឹងការអនុវត្តក្នុងការផ្តល់កម្ចី និងការប្រមូលប្រាក់របស់អតិថិជន តាមរយៈក្របខណ្ឌហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់ខ្លួន និងជាផ្នែកមួយនៃដំណើរការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នផ្នែកហិរញ្ញវត្ថុដ៏ទូលំទូលាយរបស់ខ្លួន មិនមែននៅក្នុងក្របខណ្ឌនិរន្តរភាពនោះទេ។

លើសពីនេះទៀត IFC កត់សម្គាល់ថា ក្រៅពីលក្ខខណ្ឌតម្រូវនៃក្របខណ្ឌនិរន្តរភាពរបស់ IFC ខ្លួនបានធ្វើការនៅកម្រិតស្ថាប័ន និងកម្រិតវិស័យ ដើម្បីពង្រឹងការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវនៅកម្ពុជា។

នៅកម្រិតស្ថាប័ន សកម្មភាពទាំងនេះរួមមានការធ្វើការជាមួយ FIs ដែលមានការអនុវត្តក្នុងការផ្តល់កម្ចីប្រកបដោយទំនួលខុសត្រូវ វាយតម្លៃការធានា និងការប្រមូលប្រាក់របស់ FIs ក្នុងអំឡុងពេលដំណើរការការត្រួតពិនិត្យដោយប្រុងប្រយ័ត្ន និងតាមដានការវិវត្តនៃការអនុវត្តទាំងនេះតាមរយៈការត្រួតពិនិត្យផលបត្រ។[13] លើសពីនេះទៀត IFC បានផ្តល់សេវាទីប្រឹក្សាដល់ FIs មួយចំនួន ដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹងនេះ ដោយជួយពួកគេកែលម្អអភិបាលកិច្ចសាជីវកម្ម សមត្ថភាពគ្រប់គ្រងហានិភ័យ និងការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។ នៅខែមេសា ឆ្នាំ២០២១ IFC បានផ្សព្វផ្សាយអំពីគំនិតផ្តួចផ្តើមផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវដែលវាយតម្លៃលើការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់អតិថិជន FI កម្ពុជា និងជួយពួកគេក្នុងការធ្វើឱ្យប្រសើរឡើងតាមពេលវេលា។[14]

នៅកម្រិតវិស័យ IFC បញ្ជាក់ថា ខ្លួនបានធ្វើការជាមួយធនាគារជាតិនៃកម្ពុជា (NBC) តាំងពីឆ្នាំ២០០៦ ដើម្បីបង្កើតក្រុមហ៊ុនក្រេឌីតប៊្យូរ៉ូកម្ពុជា (CBC) ដែលជាប្រភពនៃតម្លាភាព និងព័ត៌មានសម្រាប់ការរាយការណ៍អំពីឥណទាន ក៏ដូចជាឧបករណ៍មួយដើម្បីកាត់បន្ថយហានិភ័យនៃការជំពាក់បំណុលច្រើនពេករបស់អ្នកខ្ចី។ លើសពីនេះទៀត IFC បានសហការជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) CBC និងយុទ្ធនាការ SMART ដើម្បីលើកកម្ពស់គោលការណ៍ណែនាំស្តីពីការផ្តល់កម្ចីដល់មីក្រូហិរញ្ញវត្ថុ និងបានអនុវត្តគម្រោងអសាធនភាព

---

[13] ក្នុងន័យនេះ IFC បានចង្អុលបង្ហាញថា ខ្លួនបានរួមបញ្ចូលការព្រមព្រៀងដែលមានការបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងកម្ចីរបស់អតិថិជន ដែលពាក់ព័ន្ធនឹងពាក្យបណ្តឹងនេះ ដើម្បីទាមទារឱ្យមានការអនុលោមតាមគោលការណ៍កិច្ចការពារអតិថិជន និងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ដែលគ្របដណ្តប់លើការជៀសវាងការជំពាក់ច្រើនពេក ការកំណត់តម្លៃប្រកបដោយតម្លាភាព ការអនុវត្តការប្រមូលប្រាក់យ៉ាងសមស្រប អាកប្បកិរិយារបស់បុគ្គលិកប្រកបដោយសីលធម៌ យន្តការដោះស្រាយបណ្តឹងសារទុក្ខ និង/ឬការការពារឯកជនភាពរបស់ទិន្នន័យ។

[14] សេវាទីប្រឹក្សានៅកម្ពុជា RF លេខ ៦០៦១១៩.

និងការដោះស្រាយបំណុល ដើម្បីពង្រឹងការអនុវត្តក្នុងការប្រមូលបំណុលដោយយុត្តិធម៌ និងមានតម្លាភាពនៅក្នុងប្រទេសកម្ពុជា ឲ្យកាន់តែទូលំទូលាយ។

ការឆ្លើយតបរបស់ IFC បញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការត្រួតពិនិត្យ និងដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង រួមជាមួយភាគីពាក់ព័ន្ធដទៃទៀត ដូចជាធនាគារពិភពលោក NBC CMA សមាគមធនាគារនៅកម្ពុជា និងគ្រឹះស្ថានហិរញ្ញវត្ថុពហុភាគីដទៃទៀត។ នៅខណៈពេលទទួចថា បញ្ហាទាំងនេះស្ថិតនៅក្រៅក្របខណ្ឌនិរន្តរភាពនោះ IFC ស្នើឱ្យធ្វើសកម្មភាពនៅកម្រិតគម្រោង វិស័យ និងបទប្បញ្ញត្តិ។ យោងតាម IFC ទាំងនេះនឹងដោះស្រាយ "ភាពមិនប្រក្រតីតាមគម្រោងជាក់លាក់" ដែលត្រូវបានអះអាងដោយដើមបណ្តឹងហានិភ័យនៃការសងសឹក អភិក្រមរបស់ IFC ចំពោះហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងបទប្បញ្ញត្តិស្តីពីកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ (FCP) នៅក្នុងប្រទេសកម្ពុជា។ សម្រាប់ការឆ្លើយតបយ៉ាងពេញលេញ សូមមើលឧបសម្ព័ន្ធទី៥។

ពុំមានអតិថិជន IFC ណាម្នាក់បានផ្តល់ជូនស៊ីអេអូនូវការឆ្លើយតបទៅនឹងពាក្យបណ្តឹងនេះទេ។

## ៤. ការវិភាគអំពីការវាយតម្លៃរបស់ស៊ីអេអូ

ផ្អែកនេះសង្ខេបអំពីការវិភាគរបស់ស៊ីអេអូលើពាក្យបណ្តឹង ដោយផ្អែកលើការស្រាវជ្រាវ ការត្រួតពិនិត្យឯកសារ និងការសម្ភាសន៍ ដែលបានធ្វើឡើងនៅចន្លោះខែវិច្ឆិកា ឆ្នាំ២០២២ ដល់ ខែឧសភា ឆ្នាំ២០២៣។ វាពណ៌នាអំពីក្របខណ្ឌគោលនយោបាយ និងស្តង់ដារសមិទ្ធកម្មរបស់ IFC ដែលពាក់ព័ន្ធ ដែលអាចអនុវត្តចំពោះពាក្យបណ្តឹង និងបន្ទាប់មក បង្ហាញការសន្និដ្ឋានរបស់ស៊ីអេអូ ទាក់ទងនឹងលក្ខណវិនិច្ឆ័យនៃការវាយតម្លៃទាំងបី ដែលត្រូវបានតម្រូវ ដើម្បីចាប់ផ្តើមការស៊ើបអង្កេតភាពអនុលោម ពោលគឺ៖

ក. ថាតើមានការចង្អុលបង្ហាញជាបឋមអំពីគ្រោះថ្នាក់ ឬគ្រោះថ្នាក់ដែលអាចកើតឡើងដែរឬទេ

ខ. ថាតើមានការចង្អុលបង្ហាញជាបឋម ដែល IFC ប្រហែលជាមិនបានអនុលោមតាមគោលនយោបាយ E&S របស់ខ្លួនដែរឬទេ និង

គ. ថាតើគ្រោះថ្នាក់ ដែលត្រូវបានចោទប្រកាន់ មានទំនាក់ទំនងយ៉ាងសមហេតុផល នឹងភាពបដិលោម ដែលអាចកើតឡើងដែរឬទេ។[15]

ផ្អែកតាមការវិភាគខាងក្រោម ស៊ីអេអូរកឃើញថា ពាក្យបណ្តឹងបំពេញតាមលក្ខណវិនិច្ឆ័យសម្រាប់ការស៊ើបអង្កេតអំពីភាពអនុលោម ទាក់ទងនឹងការវិនិយោគផ្ទាល់របស់ IFC នៅអេស៊ីលីដា, អម្រឹត, ធនាគារ ហត្ថា, ក្រុមហ៊ុន Advans, ក្រុមហ៊ុន North Haven Thai, MEF និង MIFA និងការវិនិយោគដោយប្រយោលនៅប្រាសាក់ អិលអូអិលស៊ី និង ស្ថាបនា តាមរយៈ MEF និង MIFA។

[15] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ៩១.

## ក) ក្របខណ្ឌគោលនយោបាយ និងស្តង់ដារសមិទ្ធកម្មរបស់ IFC ដែលពាក់ព័ន្ធ

គោលនយោបាយស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម (គោលនយោបាយនិរន្តរភាព) របស់ IFC[16] ស្តង់ដារសមិទ្ធកម្ម (PS)[17] និងគោលនយោបាយលទ្ធភាពទទួលបានព័ត៌មាន (AIP)[18] ត្រូវបានហៅកាត់រួមគ្នាថា ក្របខណ្ឌនិរន្តរភាព។

គោលនយោបាយនិរន្តរភាពចែងថា "ការប្រឹងប្រែងអនុវត្តសកម្មភាពវិនិយោគ និងការផ្តល់ប្រឹក្សាដោយមានចេតនា 'មិនបង្កគ្រោះថ្នាក់' ដល់មនុស្ស និងបរិស្ថាន" និង "ពង្រឹងនិរន្តរភាពនៃប្រតិបត្តិការរបស់វិស័យឯកជន និងទីផ្សារ ដែលពួកគេធ្វើការ" គឺជា "ចំណុចសំខាន់នៃបេសកកម្មអភិវឌ្ឍន៍របស់ IFC។[19] គោលនយោបាយនិរន្តរភាពធ្វើឲ្យ IFC ប្តេជ្ញាចិត្ត "ធានាថា តម្លៃនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចមិនដាក់បន្ទុកមិនស្មើគ្នាលើជនក្រីក្រ ឬងាយរងគ្រោះនោះទេ"។[20] ដើម្បីជួយបំពេញអាណត្តិនេះ IFC ប្តេជ្ញាចិត្តធានាថា គម្រោងដែលខ្លួនផ្តល់ហិរញ្ញប្បទាន "ត្រូវបានអនុវត្តស្របតាមលក្ខខណ្ឌតម្រូវរបស់ស្តង់ដារសមិទ្ធកម្ម"។[21]

ការប្តេជ្ញាចិត្តរបស់ IFC ស្របតាមគោលនយោបាយនិរន្តរភាព ត្រូវបានអនុវត្តតាមបីដំណាក់កាលនៃវដ្តគម្រោង៖[22]

- ការត្រួតពិនិត្យ E&S យ៉ាងប្រុងប្រយ័ត្ន មុនពេលអនុវត្តការវិនិយោគ (ហៅថា ការវាយតម្លៃ) ដែលត្រូវតែសមស្របតាមហានិភ័យ និងផលប៉ះពាល់នៃសកម្មភាពអាជីវកម្មរបស់អតិថិជនជាសក្តានុពល
- ការរួមបញ្ចូលលក្ខខណ្ឌតម្រូវ E&S ដែលអាចអនុវត្តបាន នៅក្នុងកិច្ចព្រមព្រៀងវិនិយោគ (លក្ខខណ្ឌនៃការវិនិយោគ) ដែលអតិថិជនយល់ព្រមអនុវត្តតាម
- ការត្រួតពិនិត្យ E&S នៃភាពអនុលោមតាមរបស់អតិថិជនចំពោះការប្តេជ្ញាចិត្តផ្នែក E&S នៅក្នុងកិច្ចព្រមព្រៀងវិនិយោគ។

លើសពីនេះទៀត IFC មានកាតព្វកិច្ច ស្របតាមគោលនយោបាយសិទ្ធិទទួលបានព័ត៌មាន (AIP) ដើម្បីបង្ហាញព័ត៌មានជាក់លាក់ ទាក់ទងនឹងហានិភ័យ និងផលប៉ះពាល់ E&S សំខាន់ៗរបស់ FI។[23]

នៅក្នុងក្របខណ្ឌនិរន្តរភាព លក្ខខណ្ឌតម្រូវ E&S ខាងក្រោម ពាក់ព័ន្ធនឹងគ្រោះថ្នាក់ ដែលអះអាងដោយដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ៖

[16] IFC. ២០១២. គោលនយោបាយស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម. មាននៅ https://bit.ly/3BsISeg

[17] IFC. ២០១២. ស្តង់ដារសមិទ្ធកម្ម. មាននៅ https://bit.ly/42UMsdc

[18] IFC. ២០១២. គោលនយោបាយលទ្ធភាពទទួលបានព័ត៌មាន. មាននៅ https://bit.ly/42zRGep

[19] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី ៩

[20] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី ៩

[21] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី ៣

[22] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី ២០ ២១ ២២ ២៤ ៣២ ៣៣ ៣៤ ៣៥ និង ៤៥

[23] "AIP តម្រូវឲ្យ IFC លាតត្រដាង (i) ហេតុផលសម្រាប់ការចាត់ថ្នាក់ការវិនិយោគរបស់ IFC (ii) ការពណ៌នាអំពីហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គមសំខាន់ៗ ទាក់ទងនឹងការវិនិយោគរបស់ IFC និងសេចក្តីសង្ខេបអំពីប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) និង (iii) វិធានការសំខាន់ៗ ដែលត្រូវបានកំណត់ ដើម្បីពង្រឹង ESMS ដូចបានបញ្ជាក់នៅក្នុង ESAP"។ AIP កថាខណ្ឌទី ៣១(ខ)

- ស្តង់ដារសមិទ្ធកម្មទី១ (PS១)៖ ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម និងផលប៉ះពាល់នៃសកម្មភាពអាជីវកម្ម ដែល IFC គាំទ្រ រួមទាំងការកាត់បន្ថយផលប៉ះពាល់លើក្រុមងាយរងគ្រោះ និងគោលការណ៍ប្រឆាំងការសងសឹក
- ស្តង់ដារសមិទ្ធកម្មទី៧ (PS៧)៖ ជនជាតិដើមភាគតិច (IPs) រួមទាំងលក្ខខណ្ឌតម្រូវដើម្បីជៀសវាងផលប៉ះពាល់លើដីធ្លី និងវប្បធម៌ជនជាតិដើមភាគតិច និងចូលរួមជាមួយ IPs តាមវប្បធម៌សមស្រប
- បញ្ជីផាត់ចេញរបស់ IFC[24] ជាពិសេសទាក់ទងនឹងកាតព្វកិច្ច ដែលមិនប៉ះពាល់ដល់ដីធ្លី ដែលត្រូវបានកាន់កាប់ ឬទាមទារ ស្របតាមការវិនិច្ឆ័យក្តី ដោយជនជាតិដើមភាគតិច ដោយពុំមានការយល់ព្រមជាឯកសារពេញលេញពីប្រជាជនទាំងនោះ។

ដើមបណ្តឹងអះអាងថា ផលប៉ះពាល់ដែលត្រូវបានចោទប្រកាន់ ក៏ជាប់ពាក់ព័ន្ធនឹងការបំពានលើស្តង់ដារសមិទ្ធកម្មទី២ ទី៤ និង ទី៥ របស់ IFC ផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ស្តង់ដារទាំងនេះមិនអាចអនុវត្តជាទូទៅនៅក្នុងសំណុំរឿងនេះទេ ដោយសារមូលហេតុខាងក្រោម៖

- PS២ អនុវត្តចំពោះទំនាក់ទំនងការងាររវាងអតិថិជន IFC និងបុគ្គលិករបស់ខ្លួន ថាតើពួកគេជាបុគ្គលិកផ្ទាល់ បុគ្គលិកជាប់កិច្ចសន្យា ឬបុគ្គលិកផ្នែកខ្សែសង្វាក់ផ្គត់ផ្គង់ (PS២ កថាខណ្ឌទី៤)។ ជាលទ្ធផល PS២ មិនអាចអនុវត្តបានទេ។ ហានិភ័យនៃពលកម្មកុមារ ដែលជាប់ពាក់ព័ន្ធនឹងគម្រោង ទាក់ទងនឹងការជំពាក់បំណុលច្រើនពេក ដែលត្រូវបានចោទប្រកាន់ដោយដើមបណ្តឹង ត្រូវបានដោះស្រាយយ៉ាងសមស្រប ស្របតាមលក្ខខណ្ឌតម្រូវទូទៅនៃ PS១។
- PS៤ ដោះស្រាយ "ហានិភ័យ និងផលប៉ះពាល់ដល់សុខភាព សុវត្ថិភាព និងសន្តិសុខសហគមន៍ ដែលអាចកើតចេញពីសកម្មភាពទាក់ទងនឹងគម្រោង" ដោយយកចិត្តទុកដាក់ជាពិសេសចំពោះផលប៉ះពាល់ដែលកើតចេញពីគម្រោង "បរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធ" (PS៤ កថាខណ្ឌទី១ និង ទី៤)។ ផលប៉ះពាល់សុខភាព ដែលត្រូវបានចោទប្រកាន់ដោយដើមបណ្តឹង (កាត់បន្ថយអាហារូបត្ថម្ភ និងចំណីអាហារ និងការសម្លាប់ខ្លួនដោយសារបំណុល ទាក់ទងនឹងការជំពាក់បំណុលច្រើនពេក) ជាទូទៅ នឹងត្រូវដោះស្រាយស្របតាម PS១ ច្រើនជាង PS៤ នៅក្នុងបរិបទនៃការវិនិយោគដែលទាក់ទងនឹងមីក្រូហិរញ្ញវត្ថុទាំងនេះ។

[24] បញ្ជីផាត់ចេញរបស់ IFC រួមបញ្ចូលបញ្ញត្តិដូចតទៅ ដែលស៊ីអេអូយល់ថាអាចអនុវត្តចំពោះការចោទប្រកាន់នៅក្នុងសំណុំរឿងនេះ "នៅពេលវិនិយោគលើសកម្មភាពមីក្រូហិរញ្ញវត្ថុ FIs នឹងអនុវត្តចំណុចដូចតទៅ បន្ថែមពីលើបញ្ជីផាត់ចេញរបស់ IFC៖ [...] ផលិតកម្ម ឬសកម្មភាព ដែលប៉ះពាល់ដល់ដីធ្លី ដែលត្រូវបានកាន់កាប់ ឬទាមទារ ស្របតាមការវិនិច្ឆ័យក្តី ដោយជនជាតិដើមភាគតិច ដោយពុំមានការយល់ព្រមជាឯកសារពេញលេញពីប្រជាជនទាំងនោះ"។ ទោះបីជាយ៉ាងណាក៏ដោយ ស៊ីអេអូមិនបានរកឃើញការហាមឃាត់ពលកម្មកុមារនៅក្នុងបញ្ជីផាត់ចេញ ដែលអាចអនុវត្តបានចំពោះការចោទប្រកាន់នៅក្នុងសំណុំរឿងនេះទេ ដោយសារការហាមឃាត់នៅក្នុងបញ្ជីផាត់ចេញសំដៅលើសកម្មភាពដែលផ្តល់ហិរញ្ញប្បទានដោយអន្តរការីហិរញ្ញវត្ថុ ឬគម្រោងពោលគឺ ហាមឃាត់ FIs មិនឲ្យផ្តល់សេវាហិរញ្ញវត្ថុដល់សកម្មភាពដែលមានទម្រង់បង្កគ្រោះថ្នាក់ ឬកេងប្រវ័ញ្ចពលកម្មកុមារ ដែលមានគ្រោះថ្នាក់។ គេមិនបានអះអាងថា FIs ដោយផ្ទាល់ កំពុងចូលរួមក្នុងសកម្មភាពពលកម្មកុមារ ឬផ្តល់ហិរញ្ញប្បទាន ដែលពាក់ព័ន្ធនឹងពលកម្មកុមារនោះទេ។ ការចោទប្រកាន់របស់ដើមបណ្តឹង ត្រូវបានគ្របដណ្តប់ ស្របតាមការពិចារណាទូទៅអំពីផលប៉ះពាល់សង្គមនៅក្នុង PS១។

- PS៥ អនុវត្តចំពោះ "ការទិញដី ដែលទាក់ទងនឹងគម្រោង" (PS៥ កថាខណ្ឌទី១ ទី៥ និង ទី៦) និងមិនអនុវត្តចំពោះការតាំងទីលំនៅថ្មី ដែលកើតចេញពី "ប្រតិបត្តិការទីផ្សារ" (កថាខណ្ឌទី៥ និង ទី៦) ដែលអ្នកលក់ត្រូវបានផ្តល់ជូននូវ "សំណងយ៉ាងសមរម្យ" ដោយផ្អែកលើ "ការយល់ព្រមដោយមានព័ត៌មានគ្រប់គ្រាន់" របស់ពួកគេនោះទេ (PS៥ GN១៧)។ PS៥ ចែងថា "ផលប៉ះពាល់ទូទៅបន្ថែមទៀត លើសហគមន៍ [... ] ត្រូវបានគ្របដណ្តប់នៅក្នុងស្តង់ដារសមិទ្ធកម្មទី១"។ (PS៥ ជើងទំព័រទី១០)។ ជាលទ្ធផល ការបាត់បង់ដីធ្លីដោយសារការជំពាក់បំណុលច្រើនពេក ដែលត្រូវបានចោទប្រកាន់ ជាទូទៅនឹងត្រូវដោះស្រាយស្របតាម PS១ ច្រើនជាង PS៥។

## ខ) ការចង្អុលបង្ហាញជាបឋមអំពីគ្រោះថ្នាក់

ការវាយតម្លៃភាពអនុលោមរបស់ស៊ីអេអូ ត្រូវបានតម្រូវ ដើម្បីពិចារណាថាតើពាក្យបណ្តឹងលើកឡើងអំពី "ការចង្អុលបង្ហាញជាបឋមអំពីគ្រោះថ្នាក់ ឬគ្រោះថ្នាក់ដែលអាចកើតឡើង" ដែរឬទេ។[25] គោលនយោបាយស៊ីអេអូកំណត់និយមន័យគ្រោះថ្នាក់ថាជា "ផលប៉ះពាល់វិជ្ជមានផ្នែកបរិស្ថាន និងសង្គមលើមនុស្ស ឬបរិស្ថាន ដែលជាលទ្ធផលដោយផ្ទាល់ ឬដោយប្រយោលពីគម្រោង ឬអនុគម្រោង។ គ្រោះថ្នាក់អាចនឹងកើតឡើងជាក់ស្តែង ឬទំនងជាអាចកើតឡើងនៅពេលអនាគត"។[26] ការចង្អុលបង្ហាញជាបឋមអំពីគ្រោះថ្នាក់ ដែលត្រូវបានកំណត់នៅដំណាក់កាលវាយតម្លៃ មានវត្តមាន នៅពេលដែលការត្រួតពិនិត្យលើកដំបូងរបស់ស៊ីអេអូ លើព័ត៌មានដែលមានបង្កើតបានជាកង្វល់គួរឱ្យជឿជាក់ ឬគួរឲ្យទុកចិត្តថា គ្រោះថ្នាក់បានកើតឡើង ឬទំនងជានឹងកើតឡើងយ៉ាងសមហេតុផល។ វាមិនស្មើនឹង*ការរកឃើញ*គ្រោះថ្នាក់ ដែលអាចកើតចេញពីការស៊ើបអង្កេតភាពអនុលោមតែមួយមុខនោះទេ។[27]

មានឯកសារយោងជាច្រើន ដែលចងក្រងឯកសារអំពីទំហំ និងភាពធ្ងន់ធ្ងរនៃផលប៉ះពាល់សង្គម ដែលទាក់ទងនឹងការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។ ការជំពាក់បំណុលច្រើនពេក នៅក្នុងចំណោមប្រជាជនក្រីក្រ និងងាយរងគ្រោះរបស់ប្រទេសគឺជាកង្វល់កាន់តែខ្លាំង។ ចាប់តាំងពីឆ្នាំ២០១៥ មក IFC បានកំណត់ហានិភ័យ ដែលការជំពាក់បំណុលច្រើនពេក រួមជាមួយក្របខណ្ឌការពារអ្នកប្រើប្រាស់ទន់ខ្សោយ សម្រាប់ទីផ្សារហិរញ្ញវត្ថុ អាចកើតឡើងចំពោះទាំងសេដ្ឋកិច្ចកម្ពុជា និងបុគ្គលអ្នកប្រើប្រាស់។[28] នៅឆ្នាំ២០១៩ ធនាគារពិភពលោកបានចេញកំណត់សម្គាល់គោលនយោបាយស្តីពីមីក្រូហិរញ្ញវត្ថុ និងសុខុមាលភាពគ្រួសារកម្ពុជា ដែលជូនដំណឹងអំពី "ការកើនឡើងយ៉ាងឆាប់រហ័សនៃផលធៀបបំណុលនឹងការប្រើប្រាស់ [ដែល] បានលើកឡើងនូវកង្វល់អំពីសមត្ថភាពសង

---

[25] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ៩១

[26] គោលនយោបាយស៊ីអេអូ សទ្ទានុក្រម

[27] ក្នុងន័យនេះ កថាខណ្ឌទី ៩៤ នៃគោលនយោបាយស៊ីអេអូ ចែងថា "ដំណើរការវាយតម្លៃមិននាំឲ្យមានការវាយតម្លៃយ៉ាងជាច់ខាតចំពោះភាពអនុលោមរបស់ IFC/MIGA ចំពោះគោលនយោបាយ E&S របស់ខ្លួន ឬគ្រោះថ្នាក់ដែលពាក់ព័ន្ធនោះទេ។ ស៊ីអេអូអាចធ្វើការវាយតម្លៃទាំងនេះតែនៅក្នុងបរិបទនៃការស៊ើបអង្កេតតែប៉ុណ្ណោះ"។

[28] IFC ការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា ឆ្នាំ២០១៥ ទំព័រទី ២៩-៣៣. មាននៅ https://bit.ly/3VCU817

បំណុលរបស់អ្នកខ្ចីជាច្រើននាក់"។[29] នៅឆ្នាំ២០២០ IFC បានចេញរបាយការណ៍សន្ទស្សន៍មីក្រូហិរញ្ញវត្ថុនៃការផ្សព្វផ្សាយទីផ្សារ និងតិត្ថិភាព (MIMOSA)។ របាយការណ៍នេះបានសន្និដ្ឋានថា ប្រទេសកម្ពុជាបានឈានដល់កម្រិតខ្ពស់បំផុតនៃតិត្ថិភាពទីផ្សារ និងបានកត់សម្គាល់អំពីការកើនឡើងនៃទំហំកម្ចី ការកើនឡើងនៃរយៈពេលសងកម្ចី ការជ្រៀតចូលទីផ្សារកម្រិតខ្ពស់ និងកង្វះខាតការការពារអ្នកប្រើប្រាស់ និងបទប្បញ្ញត្តិ។[30]

អង្គការសហប្រជាជាតិក៏បានលើកឡើងអំពីកង្វល់ទាំងនោះផងដែរ។ នៅក្នុងរបាយការណ៍ឆ្នាំ២០២២ ស្តីពីប្រទេសកម្ពុជា អគ្គលេខាធិការអង្គការសហប្រជាជាតិ បានបញ្ជាក់ថា ការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុបានបង្កើនភាពងាយរងគ្រោះរបស់ប្រជាជនដែលងាយរងគ្រោះរួចហើយ[31] និងបានកត់សម្គាល់ថា បំណុលសរុបដែលនៅជំពាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគិតជាភាគរយនៃ GDP នៅកម្ពុជាគឺ ស្ថិតក្នុងចំណោមតួលេខខ្ពស់បំផុតនៅលើពិភពលោក។[32] អ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិស្តីពីផលប៉ះពាល់នៃបំណុលបរទេស និងកាតព្វកិច្ចហិរញ្ញវត្ថុអន្តរជាតិពាក់ព័ន្ធដទៃទៀតរបស់រដ្ឋ លើការទទួលបានសិទ្ធិមនុស្សយ៉ាងពេញលេញ (ឆ្នាំ២០២០)[33] អគ្គលេខាធិការអង្គការសហប្រជាជាតិ និងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (ឆ្នាំ២០២១ និង ២០២២)[34] និង គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ឆ្នាំ២០២៣)[35] ទាំងអស់បានសម្តែងការព្រួយបារម្ភអំពីផលប៉ះពាល់សង្គមអវិជ្ជមាននៃការជំពាក់បំណុលច្រើនពេក និង "អន្ទាក់

---

[29] ក្រុមធនាគារពិភពលោក កំណត់សម្គាល់អំពីគោលនយោបាយស្តីពីមីក្រូហិរញ្ញវត្ថុ និងសុខុមាលភាពគ្រួសារកម្ពុជាWorld Bank Group, Cambodia Policy Note on Microfinance and Household Welfare, 2019, p.11. Available at https://bit.ly/3NITywL

[30] របាយការណ៍របស់ MIMOSA ស្តីពីប្រទេសកម្ពុជា ខែមីនា ឆ្នាំ២០២០ ទំព័រទី ៧-៨. បន្ទាប់ពីមានរបាយការណ៍របស់ Mimosa អង្គការឃ្លាំមើលសិទ្ធិមនុស្សបានជំរុញឱ្យក្រុមធនាគារពិភពលោកស៊ើបអង្កេតអំពីកម្ចីខ្នាតមីក្រូរបស់ប្រទេសកម្ពុជា និងបានផ្ញើ លិខិត ពីរច្បាប់ ទៅកាន់ IFC ដែលបង្ហាញអំពីការរំលោភបំពាននៅក្នុងការផ្តល់កម្ចីខ្នាតមីក្រូ (ដូចជាការលក់ដីដោយបង្ខំ ដែលត្រូវបានចោទប្រកាន់) និងជូនដំណឹងដល់ IFC អំពីការកើនឡើងនៃបញ្ហានេះក្នុងអំឡុងពេលមានជំងឺកូវីដ១៩។ ព័ត៌មានមាននៅទីនេះ៖ https://tinyurl.com/3bwakzbv។ អង្គការលើកលែងទោសអន្តរជាតិក៏បានគូសបញ្ជាក់អំពីរបៀបដែលកម្ពុជាគឺជាប្រទេសដែលជំពាក់បំណុលមីក្រូហិរញ្ញវត្ថុច្រើនបំផុតនៅលើពិភពលោក ហើយអសន្តិសុខសេដ្ឋកិច្ចសង្គមមានសភាពកាន់តែធ្ងន់ធ្ងរដោយសារបំណុលមីក្រូហិរញ្ញវត្ថុកម្រិតខ្ពស់ និងការខកខានក្នុងការការពារប្រជាជនងាយរងគ្រោះពីការបង្ខំឲ្យលក់ដីធ្លីដោយសារការប្រើប្រាស់បណ្ណកម្មសិទ្ធិដីធ្លីជាវត្ថុបញ្ចាំ។ អង្គការលើកលែងទោសអន្តរជាតិ របាយការណ៍ឆ្នាំ២០២០/២១ ទំព័រទី ១០៦ និង ១០៨ មាននៅ៖ https://bit.ly/3p9M8bE។

[31] របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស របាយការណ៍ប្រចាំឆ្នាំរបស់ OHCHR ស្តីពីតួនាទី និងសមិទ្ធិផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សក្នុងការជួយរដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស (តទៅនេះហៅថា "របាយការណ៍ OHCHR ស្តីពីកម្ពុជា ឆ្នាំ២០២១-២០២២") ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ A/HRC/៥១/៦៣ កថាខណ្ឌទី ៤២

[32] របាយការណ៍ OHCHR ស្តីពីកម្ពុជា ឆ្នាំ២០២១-២០២២") ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ A/HRC/51/63 កថាខណ្ឌទី ៤២

[33] របាយការណ៍របស់អ្នកជំនាញឯករាជ្យនៃអង្គការសហប្រជាជាតិ ស្តីពីបំណុលឯកជន និងសិទ្ធិមនុស្ស របាយការណ៍ប្រចាំឆ្នាំរបស់ OHCHR របាយការណ៍របស់អ្នកជំនាញឯករាជ្យស្តីពីផលប៉ះពាល់នៃបំណុលបរទេស និងកាតព្វកិច្ចហិរញ្ញវត្ថុអន្តរជាតិដែលពាក់ព័ន្ធដទៃទៀតរបស់រដ្ឋលើការទទួលបានសិទ្ធិមនុស្សពេញលេញ ជាពិសេសសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ឆ្នាំ២០២០) A/HRC/43/45 នៅទំព័រទី១ និងកថាខណ្ឌទី ៣២–៣៤

[34] របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ស្តីពីតួនាទី និងសមិទ្ធិផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សក្នុងការជួយរដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ A/HRC/48/49 កថាខណ្ឌទី ៤២ (តទៅនេះហៅថា "របាយការណ៍ OHCHR ស្តីពីកម្ពុជា ឆ្នាំ២០២០-២០២១") និងរបាយការណ៍ OHCHR ស្តីពីកម្ពុជា ឆ្នាំ២០២១-២០២២ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ A/HRC/51/63 កថាខណ្ឌទី ៤២

[35] គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ការសង្កេតបញ្ចប់អំពីរបាយការណ៍តាមកាលកំណត់ទីពីររបស់ប្រទេសកម្ពុជា ថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០២៣ E/C.12/KHM/CO/2 កថាខណ្ឌទី ៣៨ និង ៣៩(ខ)

ភាពក្រីក្រ" ដែលវាបង្កើតឡើង ដោយមានបំណុលឯកជនជាឧបសគ្គដល់កម្រិតជីវភាពសមរម្យរបស់គ្រួសារ ដែលមានចំណូលទាបជាច្រើនគ្រួសារនៅក្នុងប្រទេសកម្ពុជា។

ដោយពិចារណាអំពីបរិបទទូទៅនេះ សក្ខីកម្មផ្ទាល់ខ្លួនរបស់ដើមបណ្តឹង មានសង្គតិភាពនឹងព័ត៌មានដែលបានបោះពុម្ពផ្សាយអំពីហានិភ័យ និងផលប៉ះពាល់សង្គមនៃការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុ និងការជំពាក់បំណុលច្រើនពេកនៅក្នុងប្រទេសកម្ពុជា និងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត។ ផ្អែកលើមូលដ្ឋាននេះ ស៊ីអេអូយល់ថា មានការចង្អុលបង្ហាញជាបឋមអំពីគ្រោះថ្នាក់ ឬគ្រោះថ្នាក់ដែលអាចកើតឡើង ទាក់ទងនឹងបញ្ហាខាងក្រោម ដែលបានលើកឡើងដោយដើមបណ្តឹង៖

១ **ការបាត់បង់ដីធ្លី** ដើមបណ្តឹងចោទប្រកាន់ថា គ្រឹះស្ថានហិរញ្ញវត្ថុដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹង បានបង្ខំពួកគេឱ្យប្រើប្រាស់បណ្ណកម្មសិទ្ធិជាវត្ថុបញ្ចាំ ហើយបន្ទាប់មកបង្ខំពួកគេឱ្យលក់ដីធ្លីមុនពេលកំណត់ដើម្បីប្រមូលប្រាក់។ ក្នុងករណីជាច្រើន ដីធ្លីនេះគឺជាប្រភពចំណូលចម្បងរបស់ពួកគេ។ ការចោទប្រកាន់ទាំងនេះហាក់បីមានសង្គតិភាពនឹងការរាយការណ៍ជាសាធារណៈ ដែលមានតាំងពីឆ្នាំ២០១៥ មកម្ល៉េះ ដែលបានកត់សម្គាល់អំពីហានិភ័យនៃការបាត់បង់ដីធ្លី ទាក់ទងនឹងការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដោយសារការប្រើប្រាស់ដីធ្លីយ៉ាងទូលំទូលាយជាវត្ថុបញ្ចាំសម្រាប់អ្នកខ្ចីក្រីក្រ។ ចាប់តាំងពីពេលនោះមក ការសិក្សា និងរបាយការណ៍ជាច្រើនគាំទ្រការចោទប្រកាន់របស់ដើមបណ្តឹង ទាក់ទងនឹងទំនាក់ទំនងរវាងការខ្ចីមីក្រូហិរញ្ញវត្ថុ និងការបាត់បង់ដីធ្លីសម្រាប់គ្រួសារក្រីក្រ និងងាយរងគ្រោះ។[36]

IFC បានបោះពុម្ពរបាយការណ៍ផ្ទាល់ខ្លួនរបស់ខ្លួនលើប្រធានបទ "ការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា" ក្នុងឆ្នាំ២០១៥។ របាយការណ៍នេះបានកំណត់ការអនុវត្តនៃការតម្រូវឲ្យដាក់ដីធ្លីជាវត្ថុបញ្ចាំ ពីគ្រួសារក្រីក្រដែលមានកម្រិតអក្ខរកម្មទាប ថាជាហានិភ័យគន្លឹះរបស់អ្នកប្រើប្រាស់។[37] ការសិក្សាបន្ថែម ក្នុងឆ្នាំ២០១៧ និង ឆ្នាំ២០២០ បានកំណត់ដីធ្លីជាវត្ថុបញ្ចាំទូទៅបំផុត ដែលត្រូវបានប្រើប្រាស់សម្រាប់កម្ចីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដែលតំណាងឱ្យហានិភ័យជាក់លាក់មួយសម្រាប់គ្រួសារ

[36] បន្ថែមពីលើការសិក្សា និងឯកសារ ដែលបានដកស្រង់មួយៗនៅខាងក្រោម សូមមើល ក្នុងចំណោមឯកសារដទៃទៀត៖ Bateman (២០១៧) ផ្តល់ទឡ្ហីករណ៍ថា វិស័យមីក្រូហិរញ្ញវត្ថុកំពុងនាំអ្នកក្រីក្រទៅរកភាពគ្មានដីធ្លីកាន់តែខ្លាំងឡើង ដោយ "ការបាត់បង់ដីធ្លីបន្តិចម្តងៗ ដែលបណ្តាលមកពីកម្ចីខ្នាតមីក្រូ ដែលមិនអាចសងបាន" គឺជាផ្នែកមួយក្នុងចំណោម "លទ្ធផលអាក្រក់បំផុត ទាក់ទងនឹងការកើនឡើងនៃគំរូមីក្រូហិរញ្ញវត្ថុនៅកម្ពុជា"។ Bateman, Milford "ការកើនឡើងនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា៖ ការលោតត្រដាងភយន្តរាយ" Globalization at the Crossroads ការជាន់ពន្លិចវិសមភាព និងព្រំដែនសារជាថ្មី EADI NORDIC ឆ្នាំ២០១៧ ទំព័រទី១៤ ១៦. សូមមើលផងដែរ ក្នុងចំណោមឯកសារដទៃទៀត៖ Green, Nathan W., Bylander, Maryann "អំណាចដែលមិនត្រូវបានរួមបញ្ចូលរបស់មីក្រូហិរញ្ញវត្ថុ៖ ការជំពាក់បំណុលច្រើនពេក និងការរឹបអូសដីធ្លីនៅកម្ពុជា" Sociology of Development ច្បាប់ទី ៧.២ ឆ្នាំ២០២១; Rido, Thath, "មីក្រូហិរញ្ញវត្ថុនៅកម្ពុជា៖ ការអភិវឌ្ឍន៍ បញ្ហាប្រឈម និងទស្សនវិស័យ" *MPRA Papers* ឆ្នាំ២០១៨ ទំព័រទី ១០-១១; Marks, Simon, Reaksmey, Hul, "ផ្លូវចេញសម្រាប់មនុស្សមួយចំនួន ប៉ុន្តែជាអន្ទាក់បំណុលសម្រាប់មនុស្សមួយចំនួនទៀត" *Cambodia Daily* ខែឧសភា ឆ្នាំ២០១១ មាននៅ https://bit.ly/3IN7Glj; Surrusco, Matt, Kimsay, Buth, "ការងារកម្ចីខ្នាតមីក្រូសម្រាប់មនុស្សមួយចំនួន បន្សល់ទុកមនុស្សជាច្រើនទៀតនៅក្នុងបំណុល" *Cambodia Daily* ខែមីនា ឆ្នាំ២០១៧ មាននៅ https://bit.ly/42gN8J9

[37] IFC ការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា ឆ្នាំ២០១៥ ទំព័រទី ២៩-៣២. មាននៅ https://bit.ly/3VCU817

ដែលមានចំណូលទាប។[38] នៅឆ្នាំ២០២២ ការសិក្សារបស់ INEF-BMZ បានប៉ាន់ស្មានថា បំណុលមីក្រូហិរញ្ញវត្ថុបានបង្កឱ្យមានការលក់ដីធ្លីរហូតដល់ ១៦៧.០០០ ចាប់ពីឆ្នាំ២០១៧ មក។[39] ផលប៉ះពាល់លើកសិកម្មគ្រួសារ ត្រូវបានចងក្រងឯកសារនៅក្នុងការស្ទង់មតិអំពីសេដ្ឋកិច្ចសង្គមដោយវិទ្យាស្ថានជាតិស្ថិតិរបស់ក្រសួងផែនការ ដែលបានរកឃើញថា ១ លានគ្រួសារបានឈប់ធ្វើកសិកម្ម ឬបានកាត់បន្ថយដីកសិកម្ម នៅចន្លោះឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៩/២០២០ រួមជាមួយផលប៉ះពាល់អវិជ្ជមានកាន់តែខ្ពស់ចំពោះស្ត្រីដែលជាម្ចាស់ដី។[40] សម្ព័ន្ធសហគមន៍កសិករកម្ពុជា បានចង្អុលបង្ហាញថា នេះបណ្តាលមកពីកសិករលក់ដីធ្លីយកប្រាក់បន្ទាន់ ដោយសារវិបត្តិបំណុលកាន់តែខ្លាំង។[41]

**២ ផលប៉ះពាល់ការចិញ្ចឹមជីវិត** ដើមបណ្តឹងចោទប្រកាន់ថា ដើម្បីសងបំណុលប្រាក់កម្ចី បន្ថែមពីលើការលក់ដីធ្លី ពួកគេបានលក់ទ្រព្យសម្បត្តិដែលបង្កើតប្រាក់ចំណូលដទៃទៀត ដូចជា ឧបករណ៍ និងមធ្យោបាយដឹកជញ្ជូន ជាដើម។ នៅពេលដែលប្រាក់ចំណូលរបស់ពួកគេធ្លាក់ចុះ ពួកគេពណ៌នាអំពីការងាកទៅទទួលទានអាហារតិច ឬមានគុណភាពទាប ដើម្បីកាត់បន្ថយចំណាយ។ វិធានការបែបនេះត្រូវបានបញ្ជាក់នៅក្នុងការសិក្សា ដែលគាំទ្រដោយក្រសួងសហព័ន្ធអាល្លឺម៉ង់ដើម្បីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច (BMZ) ក្នុងឆ្នាំ២០១៧ និង ឆ្នាំ២០២២។[42]

ដោយមើលឃើញពីវិបត្តិបំណុលរបស់កម្ពុជា ស៊ីអេអូ សន្និដ្ឋានថា ទិន្នន័យខាងលើ ដែលទាក់ទងនឹងការបាត់បង់ និងផលប៉ះពាល់លើដីធ្លី និងការចិញ្ចឹមជីវិត រួមជាមួយព័ត៌មានផ្ទាល់ខ្លួនរបស់ដើមបណ្តឹង នាំឱ្យមានការចង្អុលបង្ហាញជាបឋមថា ការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុអាចមានផលប៉ះពាល់អវិជ្ជមានដល់ការ

[38] មជ្ឈមណ្ឌលមីក្រូហិរញ្ញវត្ថុ (MFC), Good Return, CBC ការសិក្សាអំពីការជំពាក់បំណុលច្រើនពេកនៅកម្ពុជា លើកទី២៖ របាយការណ៍ចុងក្រោយ ខែតុលា ឆ្នាំ២០១៧ ទំព័រទី ៦២-៦៣ និងរបាយការណ៍របស់ MIMOSA ស្តីពីកម្ពុជា ខែមីនា ឆ្នាំ២០២០ ទំព័រទី៧

[39] ដោយមើលឃើញកាលៈទេសៈពិសេសនៃបរិបទកម្ពុជា ទាក់ទងនឹងការផ្តល់បណ្ណកម្មសិទ្ធិ និងកម្មសិទ្ធិដីធ្លី ការគណនាវិសាលភាពនៃផលប៉ះពាល់អាចមានការលំបាក. Bliss, Frank "មីក្រូ" ហិរញ្ញវត្ថុនៅកម្ពុជា. ការអភិវឌ្ឍន៍ បញ្ហាប្រឈម និងអនុសាសន៍" *ការសិក្សារបស់ AVE លេខ ៣០/២០២២ វិធីចាកចេញពីភាពក្រីក្រ ភាពងាយរងគ្រោះ និងអសន្តិសុខស្បៀង* វិទ្យាស្ថានអភិវឌ្ឍន៍ និងសន្តិភាព (INEF) សាកលវិទ្យាល័យ Duisburg-Essen ឆ្នាំ២០២២ ទំព័រទី ៧៦ គម្រោងដែលផ្តល់មូលធិនិដោយក្រសួងសហព័ន្ធអាល្លឺម៉ង់ដើម្បីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច (BMZ)

[40] វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ របាយការណ៍ស្ទង់មតិអំពីសេដ្ឋកិច្ចសង្គម ឆ្នាំ២០១៧ មាននៅ https://bit.ly/3LXJIod; វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ របាយការណ៍ស្ទង់មតិអំពីសេដ្ឋកិច្ចសង្គម ឆ្នាំ២០១៩/២០ មាននៅ https://bit.ly/3NMoYIS;

[41] Techseng, Tran, Dickison, Michael "កំណត់ត្រាអំពីការកើនឡើងនៃការបាត់បង់ដីធ្លី បំណុលនៅក្នុងការស្ទង់មតិអំពីសេដ្ឋកិច្ចសង្គមលើកចុងក្រោយ" *VOD* ខែកុម្ភៈ ឆ្នាំ២០២១ មាននៅ https://bit.ly/41alrAZ

[42] យោងតាមការសិក្សារបស់មជ្ឈមណ្ឌលមីក្រូហិរញ្ញវត្ថុ (MFC) ឆ្នាំ២០១៧ អ្នកខ្ចី ៤៨ ភាគរយ បានកាត់បន្ថយគុណភាពម្ហូបអាហារ ក្នុងឆ្នាំ២០១២ ៣៥ ភាគរយ ក្នុងឆ្នាំ២០១៧ នៅខណៈពេលដែល ៤៤ ភាគរយកាត់បន្ថយបរិមាណអាហារក្នុងឆ្នាំ២០១២ និង ២៩ ភាគរយក្នុងឆ្នាំ២០១៧។ ការសិក្សាឆ្នាំ២០២២ (Bliss ២០២២) បានរកឃើញថា ៣៦,៦ ភាគរយបានរឹតត្បិតការប្រើប្រាស់របស់ពួកគេ (ជាពិសេស ការទិញម្ហូបអាហារ) ដើម្បីទូទាត់សង។ មជ្ឈមណ្ឌលមីក្រូហិរញ្ញវត្ថុ (MFC), Good Return, CBC ការសិក្សាអំពីការជំពាក់បំណុលច្រើនពេកនៅកម្ពុជា លើកទី២៖ របាយការណ៍ចុងក្រោយ ខែតុលា ឆ្នាំ២០១៧ ទំព័រទី ៤៩-៥០. Bliss, Frank "មីក្រូ" ហិរញ្ញវត្ថុនៅកម្ពុជា. ការអភិវឌ្ឍន៍ បញ្ហាប្រឈម និងអនុសាសន៍" *ការសិក្សារបស់ AVE លេខ ៣០/២០២២ វិធីចាកចេញពីភាពក្រីក្រ ភាពងាយរងគ្រោះ និងអសន្តិសុខស្បៀង* វិទ្យាស្ថានអភិវឌ្ឍន៍ និងសន្តិភាព (INEF) សាកលវិទ្យាល័យ Duisburg-Essen ឆ្នាំ២០២២ ទំព័រទី ៤៥ និង ៧៦. គម្រោងដែលផ្តល់មូលធិនិដោយក្រសួងសហព័ន្ធអាល្លឺម៉ង់ដើម្បីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច (BMZ). សូមមើលផងដែរ Green, Nathan W., Bylander, Maryann "អំណាចដែលមិនត្រូវបានរួមបញ្ចូលរបស់មីក្រូហិរញ្ញវត្ថុ៖ ការជំពាក់បំណុលច្រើនពេក និងការរឹបអូសដីធ្លីនៅកម្ពុជា" *Sociology of Development* ច្បាប់ទី ៧.២ ឆ្នាំ២០២១ ទំព័រទី ២០២ និង ២១១

ចិញ្ចឹមជីវិតរបស់សហគមន៍ជនបទនៅកម្ពុជា។[43] នេះគឺជាករណីពិសេសសម្រាប់គ្រួសារក្រីក្រ និងអ្នកបាត់បង់ដីធ្លី ដែលត្រូវបានដាក់ជាវត្ថុបញ្ចាំ។

៣ **ផលប៉ះពាល់ដល់គ្រួសារ** ដើមបណ្ដឹងចោទប្រកាន់ថា គ្រួសារមួយចំនួនត្រូវបញ្ឈប់កូនពីសាលារៀន ពីព្រោះពួកគេមិនអាចផ្គត់ផ្គង់ចំណាយបាន ឬពីព្រោះពួកគេត្រូវការឲ្យកូនរបស់ពួកគេទៅធ្វើការដើម្បីជួយសងកម្ចី។ នេះបណ្ដាលឱ្យកុមារបោះបង់ការសិក្សាកាន់តែច្រើន និងហេតុការណ៍ពលកម្មកុមារដែលអាចកើតឡើង ដែលជាកង្វល់ដ៏ធំមួយនៅកម្ពុជា។[44] អង្គការអន្តរជាតិខាងការងារ (ILO) និងប្រភពដទៃទៀតបានផ្ដល់ព័ត៌មានអំពីទំនាក់ទំនងរវាងពលកម្មកុមារ និងតម្រូវការរបស់គ្រួសារក្រីក្រក្នុងការសងបំណុល។[45]

ដើមបណ្ដឹងក៏បានចោទប្រកាន់អំពីផលប៉ះពាល់ដទៃទៀត ដែលប៉ះពាល់ដល់គ្រួសាររបស់ពួកគេ ដូចជាការធ្វើចំណាកស្រុកដោយសារតម្រូវការផ្នែកសេដ្ឋកិច្ច និងការកើនឡើងនៃការធ្វើអត្តឃាតដោយសារបំណុល។ ទាក់ទងនឹងការធ្វើចំណាកស្រុក អង្គការអន្តរជាតិទេសន្តរប្រវេសន៍បានរាយការណ៍ថា គិតត្រឹមដើមឆ្នាំ២០១៦ ជនចំណាកស្រុកកម្ពុជាចំនួន ៤០,៦ ភាគរយ បានចាកចេញពីប្រទេសដោយសារបំណុលហិរញ្ញវត្ថុ។[46] ទាក់ទងនឹងការធ្វើអត្តឃាតដោយសារបំណុល មានបទពិសោធន៍ដែលបានដឹងពីប្រទេសផ្សេងទៀត ដែលបំណុលមីក្រូហិរញ្ញវត្ថុបានបណ្ដាលឱ្យមានផលប៉ះពាល់សង្គមប្រភេទនេះ។[47] ប្រព័ន្ធផ្សព្វផ្សាយកម្ពុជាក៏បានរាយការណ៍អំពីហេតុការណ៍នៃការធ្វើអត្តឃាតនៅក្នុងបរិបទនៃការជំពាក់បំណុលមីក្រូហិរញ្ញវត្ថុច្រើនពេកផងដែរ។[48]

---

[43] ចំពោះហានិភ័យដែលអាចកើតឡើងចំពោះសុខុមាលភាពគ្រួសារ សូមមើល ក្រុមធនាគារពិភពលោក កំណត់សម្គាល់គោលនយលបាយកម្ពុជាស្ដីពីមីក្រូហិរញ្ញវត្ថុ និងសុខុមាលភាពគ្រួសារ ឆ្នាំ២០១៩ ទំព័រទី ៨ មាននៅ https://bit.ly/3NITywL.

[44] នៅឆ្នាំ២០២២ កម្ពុជាគឺជារដ្ឋដែលមានចំណាត់ថ្នាក់អាក្រក់បំផុតនៅអាស៊ីអាគ្នេយ៍ ពាក់ព័ន្ធនឹងពលកម្មកុមារ. សូមមើល https://tinyurl.com/yc2nn635.

[45] ILO កម្មវិធីអន្តរជាតិស្ដីពីការលុបបំបាត់ពលកម្មកុមារ (IPEC) ការអនុវត្តល្អៗដើម្បីដោះស្រាយពលកម្មកុមារនៅកម្ពុជា ឆ្នាំ២០១៤ ទំព័រទី២២ មាននៅ https://bit.ly/429drl4. ក្រសួងការបរទេសសហរដ្ឋអាមេរិក ការប្រឹក្សាធុរកិច្ចកម្ពុជាស្ដីពីការវិនិយោគ និងអន្តរកម្មដែលមានហានិភ័យខ្ពស់ សេចក្ដីប្រកាសព័ត៌មាន ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ មាននៅ https://bit.ly/41cQmfV. បំណុលមីក្រូហិរញ្ញវត្ថុក៏បានជំរុញកុមារឱ្យបំពេញការងារដែលមានគ្រោះថ្នាក់នៅក្នុងវិស័យកសិកម្មផងដែរ ដូចជា ការបាញ់ថ្នាំសម្លាប់សត្វល្អិតនៅចម្ការចេក ឬការប៉ះពាល់សារធាតុគីមីគ្រោះថ្នាក់។ Muyhong, Chan, Narin, Sun, Sarath, Sorn, Nachemson, Andrew "ពលករ រួមទាំងកុមារមិនគ្រប់អាយុ ហ៊ានប្រើសារធាតុគីមីគ្រោះថ្នាក់មកចិញ្ចឹមជីវិតនៅចំការចេកនៅកម្ពុជា" *CamboJA* News ខែវិច្ឆិកា ឆ្នាំ២០២១ មាននៅ https://bit.ly/41ds4m4.

[46] Dickson, Brett, Koenig, Andrea, "របាយការណ៍វាយតម្លៃ៖ ប្រវត្តិរូបរបស់ពលករចំណាកស្រុកកម្ពុជាដែលបានវិលត្រឡប់មកវិញ" អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) កម្ពុជា ឆ្នាំ២០១៦ ទំព័រទី ១៤ មាននៅ https://bit.ly/3nGFLwk

[47] សូមមើល៖ Biswas, Soutik "ការរាតត្បាតនៃការធ្វើអត្តឃាតដោយសារមីក្រូហិរញ្ញវត្ថុនៅប្រទេសឥណ្ឌា" *BBC News* ខែធ្នូ ឆ្នាំ២០១០ មាននៅ៖ https://tinyurl.com/yfkpjtns និងរបាយការណ៍របស់អ្នកជំនាញឯករាជ្យនៃអង្គការសហប្រជាជាតិ ស្ដីពីបំណុលឯកជន និងសិទ្ធិមនុស្ស របាយការណ៍របស់អ្នកជំនាញឯករាជ្យស្ដីពីផលប៉ះពាល់នៃបំណុលបរទេស និងកាតព្វកិច្ចហិរញ្ញវត្ថុអន្តរជាតិដែលពាក់ព័ន្ធដទៃទៀតរបស់រដ្ឋលើការទទួលបានសិទ្ធិមនុស្សពេញលេញ ជាពិសេសសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ឆ្នាំ២០២០) A/HRC/43/45 នៅទំព័រទី១ និងកថាខណ្ឌទី ៣៣.

[48] Chakrya, Khouth Sophak, "ការធ្វើអត្តឃាតបានយកជីវិត ៨៧៣ ឆ្នាំ មកទល់បច្ចុប្បន្ន៖ នគរបាលជាតិ" *The Phnom Penh Post* ខែធ្នូ ឆ្នាំ២០២២ មាននៅ https://tinyurl.com/yc7sm3je

**ផលប៉ះពាល់លើជនជាតិដើមភាគតិច** ដើមបណ្ដឹង ដែលពួកគេមួយចំនួនត្រូវបានកំណត់អត្តសញ្ញាណថាជាជនជាតិដើមភាគតិច ចោទប្រកាន់ថា គ្រឹះស្ថានហិរញ្ញវត្ថុដែលជាប់ពាក់ព័ន្ធនឹងពាក្យបណ្ដឹងនេះ បានទទួលយកដីធ្លីរបស់ជនជាតិដើមភាគតិចជាវត្ថុបញ្ចាំ ហើយក្រោយមក បានបង្ខំឱ្យពួកគេលក់ដីធ្លីនោះ។ នៅពេលខ្លះ ដីធ្លីនោះត្រូវបានលក់ទៅឱ្យជនដែលមិនមែនជាសមាជិកសហគមន៍ ដែលរំលោភបំពានលើសិទ្ធិ វប្បធម៌ ប្រពៃណី និងជីវភាពរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិច។ ការសិក្សារបស់ OHCHR ឆ្នាំ២០១៨ បានរាយការណ៍ថា ជាមធ្យម ៧០-៨០ ភាគរយនៃគ្រួសារជនជាតិដើមភាគតិចដែលត្រូវបានស្ទង់មតិនៅក្នុងខេត្តចំនួនបីក្នុងប្រទេសកម្ពុជា បានជំពាក់បំណុលតាមរយៈកម្ចីមីក្រូហិរញ្ញវត្ថុ ឬអ្នកផ្ដល់ឥណទានប្រភេទដទៃទៀត។[49] នៅខណៈពេលដែលមានការរឹតបន្តឹងផ្លូវច្បាប់លើការលក់ដីសហគមន៍ជនជាតិដើមភាគតិចនោះ របាយការណ៍ឆ្នាំ២០២១ របស់អគ្គលេខាធិការអង្គការសហប្រជាជាតិបានកត់សម្គាល់ថា ជនជាតិដើមភាគតិចនៅកម្ពុជាមានហានិភ័យខ្ពស់ក្នុងការបាត់បង់ដីធ្លីដោយសារភាពយឺតយ៉ាវ និងឧបសគ្គក្នុងការទទួលបានបណ្ណកម្មសិទ្ធិសមូហភាពសម្រាប់ដីប្រពៃណីរបស់ពួកគេ។[50] នៅឆ្នាំ២០២២ រដ្ឋាភិបាលបានថ្កោលទោសចំពោះការប្រើប្រាស់ប្លង់ដីទន់នៅក្នុងតំបន់ការពារជនជាតិដើមភាគតិច ដោយកត់សម្គាល់ថា វាបានក្លាយជាការអនុវត្តខុសច្បាប់យ៉ាងទូលំទូលាយ។[51] OHCHR និងអ្នកដទៃទៀតរាយការណ៍ថា ជនជាតិដើមភាគតិចតែងតែប្រើប្លង់ទន់ទាំងនេះជាវត្ថុបញ្ចាំដើម្បីទទួលបានកម្ចី ដែលមួយផ្នែកដោយសារសម្ពាធ និងការអនុវត្តដែលមានការបង្ខិតបង្ខំរបស់គ្រឹះស្ថានហិរញ្ញវត្ថុ។[52]

៤ **ការគំរាមកំហែង និងការសងសឹក** ដើមបណ្ដឹង និងតំណាងអង្គការមិនមែនរដ្ឋាភិបាលរបស់ពួកគេ បានលើកឡើងអំពីកង្វល់ចំពោះការសងសឹកពីអ្នកផ្ដល់កម្ចីខ្នាតមីក្រូ ដែលមានឈ្មោះនៅក្នុងសំណុំរឿងនេះ និងអាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធ។ របាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយផ្ដល់ភាពជឿជាក់ចំពោះកង្វល់នេះ ដោយពណ៌នាអំពីរបៀបដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងស្ថាប័នរដ្ឋាភិបាល បានចោទប្រកាន់អ្នករិះគន់ការផ្ដល់កម្ចីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ពីបទបរិហារកេរ្តិ៍ និង "ការសម្របសម្រួល" ធ្វើឱ្យប៉ះពាល់ដល់មុខមាត់ឧស្សាហកម្ម។ របាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយកត់សម្គាល់ថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានជំរុញឱ្យអាជ្ញាធររដ្ឋាភិបាលចាត់វិធានការ "ប្រឆាំងនឹងបុគ្គល

---

[49] ការសិក្សានេះបានស្ទង់មតិសហគមន៍ជនជាតិដើមភាគតិចចំនួន ១០ នៅក្នុងខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ។ សហគមន៍ទាំងដប់នេះស្ថិតក្នុងចំណោមសហគមន៍ទាំង ១៨ ក្នុងប្រទេសកម្ពុជា ដែលមានបណ្ណកម្មសិទ្ធិដីសមូហភាព នៅពេលដែលការសិក្សានេះត្រូវបានធ្វើឡើង ក្នុងឆ្នាំ២០១៧។ OHCHR កម្ពុជា ការវាយតម្លៃអំពីឱកាសឥណទានសម្រាប់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ដែលកាន់កាប់បណ្ណកម្មសិទ្ធិដីសមូហភាព សហគមន៍ជនជាតិដើមភាគតិចនៅក្នុងខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ ខែតុលា ឆ្នាំ២០១៨ ទំព័រទី ៧ និង ២៥

[50] របាយការណ៍ OHCHR កម្ពុជា ឆ្នាំ២០២០-២០២១ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ A/HRC/48/49 កថាខណ្ឌទី ៥២

[51] Brook, Jack "ការបាត់បង់ដីធ្លី និងបំណុល៖ "ខ្សែបន្ទាត់ខាងក្រោមសម្រាប់ការបំភ័ន្តអំពីកម្ចីខ្នាតមីក្រូ" *South East Asia Globe* ខែឧសភា ឆ្នាំ២០២២ មាននៅ https://bit.ly/44C6L0s

[52] OHCHR កម្ពុជា ការវាយតម្លៃអំពីឱកាសឥណទានសម្រាប់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ដែលកាន់កាប់បណ្ណកម្មសិទ្ធិដីសមូហភាព សហគមន៍ជនជាតិដើមភាគតិចនៅក្នុងខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ ខែតុលា ឆ្នាំ២០១៨ ទំព័រទី ២៧ និង Brook, Jack "ការបាត់បង់ដីធ្លី និងបំណុល៖ "ខ្សែបន្ទាត់ខាងក្រោមសម្រាប់ការបំភ័ន្តអំពីកម្ចីខ្នាតមីក្រូ" *South East Asia Globe* ខែឧសភា ឆ្នាំ២០២២ មាននៅ https://bit.ly/44C6L0s

ឬក្រុមណាមួយ ដែលញុះញង់ [ប្រជាជន] នាំឱ្យមានអស្ថិរភាពសេដ្ឋកិច្ច និងបាត់បង់ទំនុកចិត្តលើប្រព័ន្ធធនាគារ"។ របាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតពណ៌នាអំពីជនដែលត្រូវបានប្តឹងពីបទបរិហារកេរ្តិ៍ បន្ទាប់ពីបានរិះគន់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការចាប់ខ្លួនសកម្មជន បន្ទាប់ពីមានបាតុកម្មទាមទារឱ្យផ្អាកការសងកម្ចី"។[53]

ការពិចារណាខាងលើ និងព័ត៌មានគាំទ្រ ផ្តល់ការចង្អុលបង្ហាញជាបឋមយ៉ាងគ្រប់គ្រាន់អំពីគ្រោះថ្នាក់ចំពោះដើមបណ្តឹង ដោយសារការអនុវត្តដែលទាក់ទងនឹងបំណុលមីក្រូហិរញ្ញវត្ថុរបស់ពួកគេ។

### គ) ការចង្អុលបង្ហាញជាបឋមអំពីភាពបដិលោមតាមគោលនយោបាយរបស់ IFC

ការវាយតម្លៃភាពអនុលោមក៏ត្រូវតែពិចារណាផងដែរ ថាតើពាក្យបណ្តឹងលើកឡើងអំពី*ការចង្អុលបង្ហាញជាបឋម*ដែល IFC ប្រហែលជាមិនបានអនុលោមតាមគោលនយោបាយ E&S របស់ខ្លួនដែរឬទេ។[54] ការចង្អុលបង្ហាញជាបឋមអំពីភាពបដិអនុលោម ដែលបានកំណត់នៅដំណាក់កាលវាយតម្លៃគឺ មានវត្តមាននៅពេលដែលការត្រួតពិនិត្យលើកដំបូងរបស់ស៊ីអេអូ លើព័ត៌មានដែលមាន បង្កើតបានជាកង្វល់គួរឱ្យជឿជាក់ ឬគួរឲ្យទុកចិត្ត ពាក់ព័ន្ធនឹងភាពអនុលោមរបស់ IFC ចំពោះគោលនយោបាយ E&S របស់ខ្លួន ដូច្នេះ ការវិភាគបន្ថែមក្នុងអំឡុងពេលស៊ើបអង្កេតភាពអនុលោម គឺសមហេតុផល។ ការកំណត់បែបនេះមិនស្មើនឹង*ការរកឃើញ*ថាមានភាពបដិលោមនោះទេ។ ការរកឃើញបែបនេះអាចកើតចេញពីការស៊ើបអង្កេតភាពអនុលោមតែមួយមុខគត់[55] និងទាមទារ "ភស្តុតាងដែលពាក់ព័ន្ធយ៉ាងគ្រប់គ្រាន់" ដោយផ្អែកលើការពិចារណាប្រកបដោយភាពអព្យាក្រឹត្យលើ "អង្គហេតុ កាលៈទេសៈ ព័ត៌មាន និងភស្តុតាង ដែល (ស៊ីអេអូ) អាចស្វែងរកបាន ពីឯកសារ ការសម្ភាសន៍ សេចក្តីថ្លែងការណ៍ របាយការណ៍ ការឆ្លើយឆ្លង និងប្រភពផ្សេងទៀត ដែលស៊ីអេអូកំណត់ថាពាក់ព័ន្ធ"។[56]

ផ្អែកលើព័ត៌មានដែលមាន ក្នុងអំឡុងពេលវាយតម្លៃនេះ ស៊ីអេអូរកឃើញការចង្អុលបង្ហាញជាបឋមថា IFC មិនបានអនុលោមតាមកាតព្វកិច្ច E&S របស់ខ្លួននោះទេ ពាក់ព័ន្ធនឹងការត្រួតពិនិត្យឡើងវិញមុនពេលអនុវត្តគម្រោង និងការត្រួតពិនិត្យផលប៉ះពាល់សង្គម ទាក់ទងនឹងស្តង់ដារហិរញ្ញវត្ថុ និងអ្នកប្រើប្រាស់ហិរញ្ញវត្ថុប្រកបដោយ

---

[53] វិទ្យុអាស៊ីសេរី ធនាគារកាណាឌីយ៉ាងទាមទារឲ្យមាន "វិធានការ" ប្រឆាំងនឹង NGOs ដែលនិយាយថា ពលករត្រូវការការបន្ធូរបន្ថយបំណុល ខែកក្កដា ឆ្នាំ២០២០ មាននៅ https://bit.ly/3NNJZwS; Surrusco, Matt, "អ្នករិះគន់របាយការណ៍របស់ MFI សូមមើល 'ការសម្របសម្រួល' សង្គមនិយម និងភាពទូទៅរបស់ប្រព័ន្ធផ្សព្វផ្សាយ" *VOD* ខែសីហា ឆ្នាំ២០១៩ មាននៅ https://bit.ly/42x46Dp; Narin, Sun, "គ្រឹះស្ថានហិរញ្ញវត្ថុ សង្គមស៊ីវិលនិយាយអំពីរបាយការណ៍បំណុល" *VOA* ខែកក្កដា ឆ្នាំ២០២០ មាននៅ https://bit.ly/418HurS; Dara, Dara "ក្រុមហ៊ុនមីក្រូហិរញ្ញវត្ថុប្តឹងពីបទបរិហារកេរ្តិ៍ បន្ទាប់ពីអ្នកគ្រប់គ្រង Brach អស់សង្ឃឹម" *VOD* ខែវិច្ឆិកា ឆ្នាំ២០២១ មាននៅ https://bit.ly/3nLVmui; Sovuthy, Khy "មនុស្សប្រាំមួយនាក់បានជាប់ឃុំដោយសារប្រឆាំងតវ៉ានឹងការសងកម្ចីមីក្រូហិរញ្ញវត្ថុ" *Camboja* ខែឧសភា ឆ្នាំ២០២០ មាននៅ https://bit.ly/3HJhNY8

[54] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី៩១

[55] ក្នុងន័យនេះ កថាខណ្ឌទី ៩៤ នៃគោលនយោបាយស៊ីអេអូ ចែងថា "ដំណើរការវាយតម្លៃមិននាំឲ្យមានការវាយតម្លៃដាច់ខាតលើភាពអនុលោមរបស់ IFC/MIGA ចំពោះគោលនយោបាយ E&S របស់ខ្លួន ឬគ្រោះថ្នាក់ដែលពាក់ព័ន្ធនោះទេ។ ស៊ីអេអូអាចធ្វើការវាយតម្លៃទាំងនេះបានតែនៅក្នុងបរិបទនៃការស៊ើបអង្កេតប៉ុណ្ណោះ"។

[56] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ១១៧

ទំនួលខុសត្រូវ ពាក់ព័ន្ធនឹងការវិនិយោគរបស់ខ្លួននៅអេស៊ីលីដា, អម្រឹត, ធនាគារ ហត្ថា, MEF, MIFA, North Haven Thai និង Advans។

## ការអនុវត្តក្របខណ្ឌនិរន្តរភាពរបស់ IFC

IFC ផ្តល់ទឡ្ហីករណ៍ថា បញ្ហាដែលទាក់ទងនឹងផលប៉ះពាល់លើអ្នកខ្ចីនៃការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុ ស្ថិតនៅក្រៅវិសាលភាពនៃគោលនយោបាយ E&S របស់ខ្លួន ដោយសារក្របខណ្ឌនិរន្តរភាពឆ្នាំ២០១២ ពុំមានលក្ខខណ្ឌតម្រូវជាក់លាក់លើការអនុវត្ត និងហានិភ័យនៃកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ (FCP) នោះទេ។ IFC បញ្ជាក់បន្ថែមថា ក្របខណ្ឌនិរន្តរភាពមិនអនុវត្តចំពោះផលប៉ះពាល់ E&S លើអតិថិជនបន្តដោយផ្ទាល់នោះទេ (អ្នកខ្ចីមីក្រូហិរញ្ញវត្ថុ នៅក្នុងសំណុំរឿងនេះ)។ ផ្ទុយទៅវិញ IFC ផ្តល់ទឡ្ហីករណ៍ថា វាអនុវត្តចំពោះតែ "សកម្មភាពអាជីវកម្ម ដែល IFC គាំទ្រ តាមរយៈអតិថិជន FI និងអតិថិជនបន្តរបស់ខ្លួន [...] ដែលជាលទ្ធផលនៃការប្រើប្រាស់ប្រាក់ចំណូលពីកម្ចីដោយអ្នកខ្ចីរង (ឧទាហរណ៍ កម្ចីសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬកម្ចីដើម្បីទិញជាតុចូលសម្រាប់កសិកម្មខ្នាតតូច ឬផ្តល់ហិរញ្ញប្បទានដល់សកម្មភាពពាណិជ្ជកម្មខ្នាតតូច)"។[57]

នៅក្នុងកិច្ចពិភាក្សាជាមួយស៊ីអេអូ គណៈគ្រប់គ្រង IFC បានបញ្ជាក់ថា អភិក្រមនេះ (មិនរួមបញ្ចូលហានិភ័យ និងផលប៉ះពាល់ចំពោះអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ ដែលបណ្តាលមកពីការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន និងការត្រួតពិនិត្យ E&S) ត្រូវបានអនុវត្តដូចៗគ្នាចំពោះគម្រោងមីក្រូហិរញ្ញវត្ថុ ស្របតាមគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២។ ដូច្នេះ នៅខណៈពេលដែល IFC បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍគោលការណ៍ និងស្តង់ដារសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា ដូចជា គោលការណ៍កិច្ចការពារអតិថិជននៃយុទ្ធនាការ Smart ជាដើមនោះ វាដោះស្រាយហានិភ័យលើកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ និងផលប៉ះពាល់ដែលនៅខាងក្រៅគោលនយោបាយ E&S របស់ខ្លួន។[58]

ទោះបីជាយ៉ាងណាក៏ដោយ ស៊ីអេអូរកឃើញថា អត្ថបទស្តីពីក្របខណ្ឌនិរន្តរភាពមិនគាំទ្រទឡ្ហីករណ៍របស់គណៈគ្រប់គ្រង IFC ដែលថាផលប៉ះពាល់សង្គមលើអ្នកខ្ចីមីក្រូហិរញ្ញវត្ថុស្ថិតនៅក្រៅវិសាលភាពនៃគោលនយោបាយ E&S របស់ខ្លួននោះទេ។ ចំពោះហេតុផលដែលបានរៀបរាប់ខាងក្រោម ហានិភ័យ និងផលប៉ះពាល់ ទាក់ទងនឹងការផ្តល់កម្ចី ដែលបានលើកឡើងដោយដើមបណ្តឹង ដូចជា ការបាត់បង់ដីធ្លី ការបាត់បង់មុខរបរចិញ្ចឹមជីវិត ភាពក្រីក្រ និងការបាត់បង់អត្តសញ្ញាណ វប្បធម៌ និងការចិញ្ចឹមជីវិតដោយផ្អែកលើធនធានធម្មជាតិ របស់ជនជាតិដើមភាគតិច ត្រូវបានគ្របដណ្តប់ដោយក្របខណ្ឌនិរន្តរភាពរបស់ IFC។ ការកំណត់ និងការគ្រប់គ្រងហានិភ័យ

---

[57] ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC កថាខណ្ឌទី៣៣ ៣៤ និង ៣៥។

[58] គណៈគ្រប់គ្រង IFC បានផ្តល់កំណត់ហេតុផ្ទៃក្នុងចាប់ពីឆ្នាំ២០១១ និងការប្រាស្រ័យទាក់ទងចាប់ពីឆ្នាំ២០១២ ដែលគាំទ្រដល់ចំណុចនេះ ដែលជាការអនុវត្តរបស់ខ្លួន យ៉ាងហោចណាស់ ចាប់តាំងពីឆ្នាំ២០១១ មក។ គណៈគ្រប់គ្រង IFC ក៏បានផ្តល់ខ្សែបន្ទាប់ពេលវេលានៃកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការកោះប្រជុំ និងដឹកនាំគំនិតផ្តួចផ្តើមទូទាំងវិស័យ ដែលទាក់ទងនឹងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ចាប់តាំងពីឆ្នាំ២០០៨ មក នៅពេលដែលពួកគេសហស្ថាបនាយុទ្ធនាការ Smart ដែលបានបង្កើតគោលការណ៍ការពារអតិថិជន រហូតដល់ឆ្នាំ២០២២ នៅពេលដែលពួកគេបានចូលរួមក្នុងការចាប់ផ្តើមឡើងវិញនូវវេទិកាហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ (RFF) ដែលមានគោលបំណងនាំវិនិយោគិន ម្ចាស់ជំនួយ និងគ្រឹះស្ថានហិរញ្ញវត្ថុមកជួបជុំគ្នាដើម្បីចែករំលែកបទពិសោធន៍ កំណត់ការអនុវត្តល្អបំផុត និងពិភាក្សាអំពីបញ្ហានានាជុំវិញហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។

និងផលប៉ះពាល់ទាំងនេះ ត្រូវបានតម្រូវដោយគោលនយោបាយនិរន្តរភាពរបស់ IFC និងស្តង់ដារសមិទ្ធកម្មរបស់ IFC ដែលពាក់ព័ន្ធ និងមានសង្គតិភាពនឹងបេសកកម្មអភិវឌ្ឍន៍របស់ IFC ក្នុងការអនុវត្ត "សកម្មភាពវិនិយោគក្នុងគោលបំណង 'មិនបង្កគ្រោះថ្នាក់' ដល់មនុស្ស និងបរិស្ថាន ដើម្បីពង្រឹងនិរន្តរភាពនៃប្រតិបត្តិការរបស់វិស័យឯកជន និងទីផ្សារ ដែលពួកគេធ្វើការ និងសម្រេចបាននូវលទ្ធផលនៃការអភិវឌ្ឍន៍ជាវិជ្ជមាន"។[59] វាក៏មានសង្គតិភាពនឹងការប្តេជ្ញាចិត្តរបស់ IFC ក្នុងការធានា "ថា តម្លៃនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចមិនដាក់បន្ទុកមិនស្មើគ្នាលើជនក្រីក្រ ឬជនងាយរងគ្រោះនោះទេ"។[60]

ក្នុងន័យនេះ ស៊ីអេអូរកឃើញថា៖

១ **ក្របខណ្ឌនិរន្តរភាពមានភាពច្បាស់លាស់ថា វាអនុវត្តចំពោះគ្រប់គម្រោង<u>ទាំងអស់</u> និងផលប៉ះពាល់ E&S របស់គម្រោងទាំងនោះ លើកលែងតែត្រូវបានផាត់ចេញជាពិសេស។** គោលនយោបាយនិរន្តរភាពផ្តល់អាណត្តិឱ្យ IFC អនុវត្តក្របខណ្ឌនិរន្តរភាពរបស់ខ្លួនចំពោះរាល់ការវិនិយោគទាំងអស់។[61] ស្តង់ដារសមិទ្ធកម្មមានភាពច្បាស់លាស់ស្រដៀងគ្នាថា ពួកគេអនុវត្តចំពោះ "ហានិភ័យបរិស្ថាន និងសង្គម*ដែលពាក់ព័ន្ធទាំងអស់* និងផលប៉ះពាល់ដែលអាចកើតឡើង"។[62] ស្តង់ដារសមិទ្ធកម្មទី១ (PS១) កំណត់ថា វាអនុវត្តចំពោះ "គ្រប់គម្រោង *ទាំងអស់* ដែលមានហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម [និងថា] ផ្នែកលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធកម្មនីមួយៗ [អនុវត្ត] ចំពោះរាល់*សកម្មភាពទាំងអស់* ដែលបានទទួលហិរញ្ញប្បទាននៅក្រោមគម្រោងនោះ *លើកលែងតែបានកត់សម្គាល់ផ្សេងពីនេះ* នៅក្នុងដែនកំណត់ពិសេស ដែលបានពណ៌នានៅក្នុងកថាខណ្ឌនីមួយៗ"។[63] PS១ ក៏បញ្ជាក់ផងដែរថា ការវាយតម្លៃហានិភ័យ E&S របស់អតិថិជនគួរតែពិចារណាលើ "ហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម *ទាំងអស់*" របស់គម្រោងនោះ និង "អ្នកដែលទំនងជារងផលប៉ះពាល់ដោយសារហានិភ័យ និងផលប៉ះពាល់ទាំងនេះ"។[64]

២ **ពុំមានការផាត់ចេញ ឬដែនកំណត់ពិសេសនៅក្នុងក្របខណ្ឌនិរន្តរភាព ទាក់ទងនឹងផលប៉ះពាល់លើអ្នកប្រើប្រាស់ ឬអ្នកខ្ចីមីក្រូហិរញ្ញវត្ថុនោះទេ។** ដូចបានកត់សម្គាល់នៅក្នុងការឆ្លើយតបរបស់ IFC គោលនយោបាយនិរន្តរភាពលាតសន្ធឹងលក្ខខណ្ឌតម្រូវ E&S របស់ IFC ជាពិសេស ទៅកាន់អ្នកប្រើប្រាស់ចុងក្រោយនៃមូលនិធិដែលទទួលបានពីការវិនិយោគរបស់ខ្លួននៅក្នុងអន្តរការីហិរញ្ញវត្ថុ (ពោលគឺ ផល

[59] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី៩

[60] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី៩

[61] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី១ ៣ ២០ និង ២២

[62] ទិដ្ឋភាពទូទៅនៃ PS កថាខណ្ឌទី៣

[63] ទិដ្ឋភាពទូទៅនៃ PS កថាខណ្ឌទី៤ និង GN១ កថាខណ្ឌទី៥. ស្រដៀងគ្នានេះដែរ PS១ (កថាខណ្ឌទី៤) ចែងថា "លក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធកម្មនេះ *អនុវត្តចំពោះរាល់សកម្មភាពអាជីវកម្មទាំងអស់* លើកលែងតែត្រូវបានកត់សម្គាល់ផ្សេងពីនេះនៅក្នុងដែនកំណត់ពិសេស ដែលបានពណ៌នានៅក្នុងកថាខណ្ឌនីមួយៗខាងក្រោម"។

[64] PS១ កថាខណ្ឌទី៧

ប៉ះពាល់នៃសកម្មភាពអាជីវកម្មរបស់អ្នកដែលខ្ចីប្រាក់ពីអតិថិជន FI របស់ IFC)។[65] ទោះបីជាយ៉ាងណាក៏ដោយ គោលនយោបាយទាំងនេះមិនផាត់ចេញនូវផលប៉ះពាល់ E&S ដែលកើតចេញពីសកម្មភាពអាជីវកម្មរបស់អតិថិជន FI របស់ខ្លួននោះទេ (នៅក្នុងសំណុំរឿងនេះគឺ ផលប៉ះពាល់នៃការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុ លើអ្នកខ្ចី)។ ដោយសារតែពួកគេមិនត្រូវបានផាត់ចេញជាពិសេសទេនោះ គេយល់ថា គោលនយោបាយ E&S របស់ IFC គ្របដណ្តប់លើផលប៉ះពាល់សង្គម ដែលបណ្តាលមកពីសកម្មភាពអាជីវកម្មចម្បង ដែល IFC កំពុងគាំទ្រ នៅក្នុងសំណុំរឿងនេះគឺ ការផ្តល់សេវាហិរញ្ញវត្ថុដល់ជនក្រីក្រ។

៣ **គោលនយោបាយ E&S របស់ IFC អនុវត្តចំពោះផលប៉ះពាល់ E&S របស់គ្រប់គម្រោងទាំងអស់ សូម្បីតែគម្រោងដែលមិនបានលើកឡើងជាពិសេសនៅក្នុងគោលនយោបាយនេះ។** ការណែនាំរបស់ IFC មានភាពច្បាស់លាស់ថា ដំណើរការវាយតម្លៃផលប៉ះពាល់របស់គម្រោង ស្របតាម PS១ គួរតែគ្របដណ្តប់លើ "វិសាលភាពពេញលេញនៃហានិភ័យ និងផលប៉ះពាល់" ដែលពាក់ព័ន្ធនឹងគម្រោង រួមទាំង "ផលប៉ះពាល់ពិសេស" ដែលមិនបានគ្របដណ្តប់ជាពិសេស ដោយស្តង់ដារសមិទ្ធកម្មទី២ ដល់ ទី៨ ផងដែរ។[66] នៅក្នុងបរិបទដទៃទៀត ដូចជា អំពើហិង្សាលើយេនឌ័រ និងការរំលោភបំពានលើកុមារ IFC ទទួលស្គាល់ថា គោលនយោបាយ E&S របស់ខ្លួនគ្របដណ្តប់លើផលប៉ះពាល់សង្គម ដែលមិនបានបញ្ជាក់ឈ្មោះច្បាស់លាស់នៅក្នុងស្តង់ដារសមិទ្ធកម្ម។ ក្នុងករណីណាមួយក៏ដោយ PS១ ចែងថា ដំណើរការកំណត់ហានិភ័យ និងផលប៉ះពាល់របស់អតិថិជន IFC គួរតែ "មានសង្គតិភាពនឹងការអនុវត្តឧស្សាហកម្មល្អជាអន្តរជាតិ" (GIIP)។[67]

៤ **ការផាត់អ្នកខ្ចីមីក្រូហិរញ្ញវត្ថុចេញពីវិសាលភាពនៃគោលនយោបាយ E&S របស់ IFC ពុំមានមូលដ្ឋានរឹងមាំនៅក្នុងគោលនយោបាយនេះទេ។** ទឡ្ហីករណ៍របស់ IFC ដែលថា គោលនយោបាយ E&S របស់ខ្លួនមិនអនុវត្តចំពោះផលប៉ះពាល់សង្គមលើអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ ស្ថិតនៅក្នុងកំណត់សម្គាល់នៅជើងទំព័រមួយនៃគោលនយោបាយនិរន្តរភាព និង PS១ ដែលកំណត់ផលប៉ះពាល់ E&S ជា "ការប្រែប្រួល ជាសក្តានុពល ឬយ៉ាងជាក់ស្តែង ចំពោះ (i) បរិស្ថានរូបវន្ត ធម្មជាតិ ឬវប្បធម៌ និង (ii) ផលប៉ះពាល់លើសហគមន៍ជុំវិញ និងពលករ ដែលបណ្តាលមកពីសកម្មភាពអាជីវកម្មដែលនឹងត្រូវគាំទ្រ។ ជាពិសេស IFC ផ្តល់ទឡ្ហីករណ៍ថា អ្នកខ្ចីមីក្រូហិរញ្ញវត្ថុមិនមែនជាផ្នែកមួយនៃ "សហគមន៍ជុំវិញ" នោះទេ។[68] ចំណុចនេះផ្តល់មូលដ្ឋានមិនគ្រប់គ្រាន់ក្នុងការផាត់អ្នកខ្ចីមីក្រូហិរញ្ញវត្ថុចេញពីវិសាលភាពនៃគោល

---

[65] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី១

[66] សូមមើល កំណត់សម្គាល់ការណែនាំរបស់ IFC ចំពោះ PS១ កថាខណ្ឌទី ១៦ និង ១៧

[67] សូមមើល PS១ កថាខណ្ឌទី៧. GIIP "ត្រូវបានកំណត់និយមន័យថាជា ការអនុវត្តជំនាញវិជ្ជាជីវៈ ការត្រួតពិនិត្យ ការប្រុងប្រយ័ត្ន និងការគិតទុកជាមុនដែលអាចរំពឹងទុកយ៉ាងសមហេតុផលពីអ្នកជំនាញដែលមានជំនាញ និងបទពិសោធន៍ ដែលចូលរួមធ្វើការងារប្រភេទដូចគ្នា ក្រោមកាលៈទេសៈដូចគ្នា ឬស្រដៀងគ្នានៅទូទាំងពិភពលោក ឬក្នុងតំបន់" សូមមើល PS១ FN១០

[68] គោលនយោបាយនិរន្តរភាព FN២. PS១ FN៣. PS១ នៅកន្លែងផ្សេងទៀត សំដៅលើគោលនយោបាយ ដែលអនុវត្តចំពោះ "សហគមន៍ដែលរងផលប៉ះពាល់" ត្រូវបានកំណត់និយមន័យយ៉ាងទូលំទូលាយថាជា "សហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់ដោយផ្ទាល់ពីគម្រោង" (PS១ កថាខណ្ឌទី១)

នយោបាយ E&S របស់ IFC ជាពិសេសការពិចារណាថា អ្នកផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា តាមធម្មតាធ្វើប្រតិបត្តិការតាមរយៈសាខានៅក្នុងមូលដ្ឋាន។[69] ជាលទ្ធផល អ្នកខ្ចីអាចត្រូវបានចាត់ទុកថាជាផ្នែកមួយនៃ "សហគមន៍ជុំវិញ" ឬនៅក្នុងភាសារបស់ PS១ ជា "សហគមន៍មូលដ្ឋាន"[70] ដែលអាចរងផលប៉ះពាល់ដោយសារប្រតិបត្តិការរបស់អ្នកផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុ។ លើសពីនេះទៀត ការចោទប្រកាន់របស់ដើមបណ្តឹងអំពីផលប៉ះពាល់ ជាពិសេសដោយជនជាតិដើមភាគតិច ដែលចោទប្រកាន់អំពីការរំលោភបំពានលើសិទ្ធិ វប្បធម៌ ប្រពៃណី និងការចិញ្ចឹមជីវិតរបស់ពួកគេ ដោយសារការបាត់បង់ដីសហគមន៍ ដែលពាក់ព័ន្ធនឹងការជំពាក់បំណុលច្រើនពេក អាចបណ្តាលឱ្យមានការប្រែប្រួលចំពោះ "បរិស្ថានរូបវន្ត ធម្មជាតិ ឬវប្បធម៌" ដូច្នេះហើយ វាបំពេញតាមធាតុផ្សំដទៃទៀតនៃនិយមន័យផលប៉ះពាល់ E&S ដែលបានដកស្រង់ដោយ IFC។

៥ **ផលប៉ះពាល់ដែលត្រូវបានចោទប្រកាន់ដោយដើមបណ្តឹងមានលក្ខណៈសង្គម និងស្ថិតនៅក្នុងវិសាលភាពនៃគោលនយោបាយ E&S របស់ IFC។** IFC មិនជំទាស់នឹងការអះអាងរបស់ដើមបណ្តឹង ដែលថាគ្រោះថ្នាក់ ដែលត្រូវបានចោទប្រកាន់គឺជាផលប៉ះពាល់សង្គមអវិជ្ជមាននៃការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុ។[71] ផលប៉ះពាល់ដែលបានលើកឡើងដោយដើមបណ្តឹង ដូចជា ការបាត់បង់ដីធ្លី និងមុខរបរចិញ្ចឹមជីវិត ភាពក្រីក្រ និងការបាត់បង់អត្តសញ្ញាណ វប្បធម៌ និងការចិញ្ចឹមជីវិតដោយផ្អែកលើធនធានធម្មជាតិរបស់ជនជាតិដើមភាគតិច ត្រូវបានលើកឡើងនៅក្នុងគោលនយោបាយ E&S របស់ IFC។ ចំណុចនេះមានសង្គតិភាពនឹងបទដ្ឋានរបស់ឧស្សាហកម្ម ដែលកំណត់ផលប៉ះពាល់សង្គមយ៉ាងទូលំទូលាយ ឧទាហរណ៍ "បញ្ហាដែលទាក់ទងនឹងអន្តរាគមន៍ដែលបានគ្រោងទុក (ពោលគឺ គម្រោង) ដែលប៉ះពាល់ ឬធ្វើឲ្យមានកង្វល់ចំពោះមនុស្ស ទោះបីជាដោយផ្ទាល់ ឬដោយប្រយោលក្តី" និងគួរតែត្រូវបានកំណត់ថា "តាមអ្វីដែលបានដឹងអំពីគម្រោង និងការយល់ដឹងអំពីរបៀបដែលគម្រោងនឹងបង្កផលប៉ះពាល់ដល់អ្វីដែលមានសារសំខាន់ចំពោះភាគីពាក់ព័ន្ធរបស់គម្រោង"។[72] វាក៏មានសង្គតិភាពនឹងការណែនាំអំពី E&S របស់ IFC ដែលថា ដំណើរការកំណត់ប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោង ចាំបាច់ត្រូវតែពិចារណា ដោយផ្អែកលើ "កាលៈទេសៈជាក់លាក់របស់គម្រោង"។[73]

---

[69] ឧទាហរណ៍៖ អេស៊ីលីដា មាន ២៦៤ សាខា នៅក្នុងប្រទេសកម្ពុជា និងមានវត្តមាននៅគ្រប់ខេត្ត និងស្រុកនៅក្នុងប្រទេស ព្រមទាំងនៅតាមទីប្រជុំជននៃឃុំ-សង្កាត់ជាច្រើនផងដែរ។ អម្រឹត មាន ១៥៦ សាខា នៅគ្រប់ស្រុក-ខណ្ឌ នៅទូទាំង ២៥ ខេត្ត និងក្រុង នៅក្នុងប្រទេសកម្ពុជា។ ធនាគារ ហត្ថា មាន ១៧៧ សាខា នៅទូទាំង ២៥ ខេត្ត និងរាជធានី។ ប្រាសាក់ មាន ១៨២ សាខានៅទូទាំងប្រទេសកម្ពុជា។ អិលអូអិលស៊ី មាន ៨១ សាខានៅគ្រប់ខេត្ត នៅក្នុងប្រទេសកម្ពុជា និង ស្ថាបនា មានជាង ១៧០ សាខា។

[70] PS១ កថាខណ្ឌទី១

[71] ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC ទទួលស្គាល់ថា គ្រោះថ្នាក់ដែលត្រូវបានចោទប្រកាន់ដោយដើមបណ្តឹងអាចត្រូវបានមើលឃើញថាជា ផលប៉ះពាល់សង្គមនៃការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុ ដោយផ្តល់ទឡ្ហីករណ៍ថា ខ្លួនដោះស្រាយផលប៉ះពាល់សង្គមប្រភេទជាក់លាក់ទាំងនេះនៅខាងក្រៅក្របខណ្ឌនិរន្តរភាព។ "IFC ប្តេជ្ញាចិត្តដោះស្រាយ***ផលប៉ះពាល់សង្គម ដូចជា អ្វីដែលបានបញ្ជាក់នៅក្នុងពាក្យបណ្តឹង*** តាមរយៈការអនុវត្តនៃកិច្ចការពារអតិថិជន និងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ"។ ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC កថាខណ្ឌទី ៤០ បានបន្ថែមការសង្កត់ធ្ងន់។

[72] IAIA (២០១៥), SIA៖ ការណែនាំអំពីការវាយតម្លៃ និងការគ្រប់គ្រងផលប៉ះពាល់នៃគម្រោងចំពោះសង្គម ទំព័រទី ២. https://bit.ly/3p7g3RO

[73] IFC កំណត់សម្គាល់អំពីការអនុវត្តល្អ ការដោះស្រាយបណ្តឹងសារទុក្ខពីសហគមន៍ដែលរងផលប៉ះពាល់ដោយគម្រោង (ឆ្នាំ២០០៩) ទំព័រទី៩។

៦ **គម្រោងទាំងនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់ឥណទានដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ ជាក្រុមដែលអាចរងផលប៉ះពាល់ខុសៗគ្នា ឬអសមាមាត្រ ដោយសារស្ថានភាពលំបាក ឬងាយរងគ្រោះរបស់ពួកគេ។** វាបានថែងយ៉ាងច្បាស់ថា អ្នកខ្ចីមីក្រូហិរញ្ញវត្ថុតែងតែជួបការលំបាកដោយសារអក្ខរកម្ម និងអក្ខរកម្មផ្នែកហិរញ្ញវត្ថុ និងអាចប្រឈមមុខនឹងហានិភ័យកាន់តែខ្លាំងនៃការជំពាក់បំណុលច្រើនពេក និងការផ្តល់កម្ចីដ៏ឃោឃៅ ដែលមានផលប៉ះពាល់សង្គមអវិជ្ជមាន លុះត្រាតែមានវិធានការទប់ស្កាត់ និងកាត់បន្ថយឱ្យបានគ្រប់គ្រាន់។ ស្របតាម PS១ អតិថិជនរបស់ IFC គួរតែកំណត់ "ក្រុមដែលអាចរងផលប៉ះពាល់ដោយផ្ទាល់ និងខុសៗគ្នា ឬអសមាមាត្រ ពីគម្រោង ដោយសារស្ថានភាពលំបាក ឬងាយរងគ្រោះរបស់ពួកគេ" អនុវត្ត "វិធានការខុសៗគ្នា ដូច្នេះផលប៉ះពាល់អវិជ្ជមានមិនធ្លាក់លើពួកគេមិនស្មើគ្នា" និងធានាថាពួកគេពុំមាន "ការលំបាកក្នុងការចែករំលែកអត្ថប្រយោជន៍ និងឱកាសក្នុងការអភិវឌ្ឍន៍"។[74] PS១ ក៏តម្រូវឱ្យបុគ្គលិករបស់អតិថិជន ដែលធ្វើអន្តរកម្មជាមួយបុគ្គល ឬក្រុមដែលងាយរងគ្រោះ ឬជួបការលំបាក មានសមត្ថភាពក្នុងការស្វែងយល់អំពីបញ្ហាជាក់លាក់ ទាក់ទងនឹងបុគ្គល ឬក្រុមទាំងនោះដែលអាចធានាដល់ការបណ្តុះបណ្តាលជាក់លាក់ផងដែរ។[75] បទប្បញ្ញត្តិខាងលើហាក់បីដូចជាពាក់ព័ន្ធ និងអាចអនុវត្តចំពោះការវិនិយោគមីក្រូហិរញ្ញវត្ថុរបស់ IFC នៅកម្ពុជា។

៧ **គម្រោងទាំងនេះត្រូវបានចោទប្រកាន់ថា មានផលប៉ះពាល់ដល់សហគមន៍ជនជាតិដើមភាគតិច រួមជាមួយលទ្ធផល ដែលលក្ខខណ្ឌតម្រូវជាក់លាក់ ស្របតាម PS៧ និងបញ្ជីផាត់ចេញរបស់ IFC អាចត្រូវយកមកអនុវត្ត។** អតិថិជនមីក្រូហិរញ្ញវត្ថុរបស់ IFC នៅកម្ពុជា ធ្វើប្រតិបត្តិការនៅតំបន់ដែលជនជាតិដើមភាគតិចរស់នៅ។ ជនជាតិដើមភាគតិច (រួមទាំងដើមបណ្តឹងមួយចំនួន) កំពុងខ្ចីប្រាក់ពីអ្នកផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុ។ PS៧ អនុវត្តចំពោះ "គ្រប់សហគមន៍ទាំងអស់របស់ជនជាតិដើមភាគតិចនៅក្នុងតំបន់ដែលមានឥទ្ធិពលរបស់គម្រោង ដែលអាចរងផលប៉ះពាល់ដោយសារគម្រោង"។[76] នៅកន្លែងដែលជនជាតិដើមភាគតិចអាចរងផលប៉ះពាល់ដោយសារគម្រោង អតិថិជនរបស់ IFC ត្រូវបានតម្រូវឱ្យវាយតម្លៃ និងកាត់បន្ថយហានិភ័យ និងផលប៉ះពាល់ទាំងនោះ ដោយផ្អែកលើការពិគ្រោះយោបល់ដោយមានព័ត៌មានគ្រប់គ្រាន់ និងការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់។[77] លើសពីនេះទៀត បញ្ជីផាត់ចេញរបស់ IFC តម្រូវឱ្យសកម្មភាពមីក្រូហិរញ្ញវត្ថុ "មិនរំលោភលើដីធ្លី ដែលជាកម្មសិទ្ធិ ឬត្រូវបានទាមទារ ស្របតាមការវិនិច្ឆ័យក្តី ដោយជនជាតិដើមភាគតិច ដោយពុំមានការយល់ព្រមជាឯកសារពេញលេញពីប្រជាជនទាំងនោះ"។[78]

---

[74] PS១ កថាខណ្ឌទី១២

[75] PS១ កថាខណ្ឌទី១៨ និង GN79

[76] PS៧ កថាខណ្ឌទី៨

[77] PS៧ កថាខណ្ឌទី៩

[78] បញ្ជីផាត់ចេញរបស់ IFC មាននៅទីនេះ៖ http://www.ifc.org/exclusionlist

៨ **ក្របខណ្ឌនិរន្តរភាពតម្រូវឱ្យ IFC ធានាឱ្យមានភាពអនុលោមតាមច្បាប់ជាតិ ដែលរួមបញ្ចូលបទប្បញ្ញត្តិសម្រាប់ការការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ ដែលអាចអនុវត្តចំពោះគម្រោងទាំងនេះ។** គោលនយោបាយនិរន្តរភាព និង PS តម្រូវឱ្យអតិថិជន FI គ្រប់រូបអនុវត្តតាមច្បាប់ជាតិដែលពាក់ព័ន្ធ។[79] ផ្អែកតាមការត្រួតពិនិត្យជាបឋម មានការចង្អុលបង្ហាញថា លក្ខខណ្ឌតម្រូវនៃការការពារអ្នកប្រើប្រាស់ទូទៅមួយចំនួនអនុវត្តចំពោះការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។ ទាំងនេះរួមបញ្ចូលទាំងបទប្បញ្ញត្តិស្តីពីតម្លាភាព ឯកជនភាពនៃទិន្នន័យ ការរាយការណ៍អំពីឥណទាន និងការគ្រប់គ្រងពាក្យបណ្តឹងរបស់អ្នកប្រើប្រាស់ផងដែរ។[80] បទប្បញ្ញត្តិទាំងនេះពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវនៃក្របខណ្ឌនិរន្តរភាព ដែលអតិថិជនត្រូវតែអនុលោមតាមច្បាប់ជាតិ។

៩ **សំណុំឯកសារនៃគម្រោងរបស់ IFC ពុំមានសង្គតិភាពទាំងស្រុងនឹងសេចក្តីសន្និដ្ឋានរបស់ IFC ដែលថាគោលនយោបាយ E&S របស់ខ្លួនមិនអនុវត្តចំពោះអ្នកខ្ចីមីក្រូហិរញ្ញវត្ថុនោះទេ។** ការត្រួតពិនិត្យជាបឋមលើសំណុំឯកសាររបស់គម្រោងទាំង ១៣ ដែលពាក់ព័ន្ធនឹងករណីនេះបានរកឃើញថា ហានិភ័យ និងផលប៉ះពាល់លើអ្នកខ្ចីនៅក្នុងករណីមួយចំនួន ត្រូវបានចាត់ទុកថា ជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រង E&S របស់អតិថិជន។ ឧទាហរណ៍៖

- គោលនយោបាយគ្រប់គ្រងបរិស្ថាន និងសង្គមរបស់ Advans រួមបញ្ចូលបញ្ញត្តិស្តីពីកិច្ចការពារអតិថិជន និងការទប់ស្កាត់ការជំពាក់បំណុលច្រើនពេក។
- MEF មានផលប៉ះពាល់ និងក្របខណ្ឌ ESG ដែលរួមបញ្ចូលធាតុផ្សំស្តីពីកិច្ចការពារអតិថិជន ហើយរបាយការណ៍អំពីផលប៉ះពាល់របស់វាចាត់ទុកការអនុវត្តកិច្ចការពារជាវិមាត្រមួយនៃ "សមិទ្ធកម្មសង្គម"។ យោងតាម SPTF+Cerise (វេទិកាឈានមុខគេសម្រាប់សមិទ្ធកម្មសង្គមនៃការវិនិយោគមីក្រូហិរញ្ញវត្ថុ) MEF ប្រើប្រាស់ឧបករណ៍សវនកម្មសង្គមរបស់ខ្លួន ដែលរួមបញ្ចូលស្តង់ដារការពារអតិថិជន ដើម្បីវាយតម្លៃសមិទ្ធកម្មសង្គមរបស់អតិថិជន។[81]

---

[79] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី ៣៥ និងទិដ្ឋភាពទូទៅនៃ PS កថាខណ្ឌទី ៥. វាក៏មានសង្គតិភាពនឹងនីតិវិធីរបស់ IFC ក្នុងការវាយតម្លៃលើការវិនិយោគរបស់ FI ដែលតម្រូវឲ្យបុគ្គលិក "ត្រួតពិនិត្យការអនុវត្តក្នុងការគ្រប់គ្រងហានិភ័យ E&S របស់អតិថិជន ធៀបនឹងលក្ខខណ្ឌតម្រូវនៃ PS១ និងលក្ខខណ្ឌតម្រូវនៅក្នុងប្រទេសដែលពាក់ព័ន្ធណាមួយ" នៅក្នុងលក្ខខណ្ឌទូទៅ។ ESRP (ឆ្នាំ២០១៤) ផ្នែកទី៧ កថាខណ្ឌទី ២.៧ ៣.៣.៣ និង ៣.៣.៥។

[80] មានរបាយការណ៍ចម្រុះ ទាក់ទងនឹងវិសាលភាព និងគុណភាពនៃក្របខណ្ឌនិយ័តកម្ម សម្រាប់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា។ របាយការណ៍ Mimosa ឆ្នាំ២០២០ បានសន្និដ្ឋានថា បទប្បញ្ញត្តិកិច្ចការពារអតិថិជនកម្ពុជា មានលក្ខណៈតិចតួច ល្អបំផុត និងមិនស្មើគ្នា។ របាយការណ៍ MIMOSA ស្តីពីកម្ពុជា ខែមីនា ឆ្នាំ២០២០ ទំព័រទី ៧-៨. របាយការណ៍ និងឯកសារគម្រោងនាពេលថ្មីៗនេះ បង្ហាញថា ក្របខណ្ឌនិយ័តកម្មបានវិវត្ត ដើម្បីរួមបញ្ចូលលក្ខខណ្ឌតម្រូវច្បាស់លាស់មួយចំនួន ទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ ដែលអាចអនុវត្តចំពោះការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុ។ លើសពីនេះទៀត ក្រមសីលធម៌ទូទាំងវិស័យថ្មីមួយ ត្រូវបានបង្កើតឡើងដោយ CMA, ABC និងសមាគមហិរញ្ញវត្ថុ និងបច្ចេកវិទ្យាកម្ពុជា និងបានដាក់ឱ្យដំណើរការជាផ្លូវការនៅខែមីនា ឆ្នាំ២០២២។

[81] Cerise+SPTF គឺជាវិនិយោគទុនរួមគ្នារវាងអ្នកដឹកនាំពិភពលោកពីររូប ក្នុងការគ្រប់គ្រងសមិទ្ធភាពសង្គម និងបរិស្ថាន។ ដោយត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៥ ក្រុមការងារផ្នែកសមិទ្ធកម្មសង្គម ឬ SPTF បានបង្កើត និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវស្តង់ដារសកលសម្រាប់ការគ្រប់គ្រងសមិទ្ធកម្មសង្គម និងបរិស្ថាន (ស្តង់ដារសកល)។ Cerise ដែលជាអង្គការមិនស្វែងរកប្រាក់ចំណេញរបស់បារាំង ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៨ បានត្រួសត្រាយផ្លូវនៃ

## ការចង្អុលបង្ហាញជាបឋមអំពីភាពបដិលោមនៅក្នុងវដ្តនៃគម្រោងទាំងមូល

ដូចគ្នានឹងរាល់គម្រោងទាំងអស់ដែរ IFC មានកាតព្វកិច្ច ទាក់ទងនឹងការវាយតម្លៃគម្រោងអនាគត ការកំណត់ចន្លោះប្រហោងនៃ PS ការរួមបញ្ចូលលក្ខខណ្ឌតម្រូវផ្នែកច្បាប់ និងការត្រួតពិនិត្យស្តង់ដារទាំងនោះ។ ស្របតាមក្របខណ្ឌនិរន្តរភាព IFC តម្រូវឱ្យត្រួតពិនិត្យឡើងវិញ និងត្រួតពិនិត្យហានិភ័យ E&S និងផលប៉ះពាល់ជាសក្តានុពលនៃការវិនិយោគរបស់ខ្លួនលើអតិថិជនមីក្រូហិរញ្ញវត្ថុ។

ផ្អែកលើការត្រួតពិនិត្យជាបឋមលើសំណុំឯកសារនៃគម្រោងរបស់ IFC និងពិចារណាលើបញ្ហា ដែលបានលើកឡើងដោយដើមបណ្តឹង ស៊ីអេអូរកឃើញការចង្អុលបង្ហាញជាបឋមអំពីភាពបដិលោមនៅក្នុងវដ្តនៃការវិនិយោគមីក្រូហិរញ្ញវត្ថុរបស់ IFC ទាំងមូល នៅកម្ពុជា។ ផ្នែកនៃភាពបដិលោមជាសក្តានុពល រួមមាន ការវាយតម្លៃគម្រោង លក្ខខណ្ឌនៃការវិនិយោគ និងការត្រួតពិនិត្យការងារ ព្រមទាំងកាតព្វកិច្ចរបស់ IFC ស្របតាមគោលនយោបាយសិទ្ធិទទួលបានព័ត៌មានរបស់ខ្លួនផងដែរ។ ជាពិសេស ការរកឃើញរបស់ស៊ីអេអូ រួមមាន៖

- **ការវាយតម្លៃ៖** IFC ត្រូវបានតម្រូវឱ្យធ្វើការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នមុនពេលវិនិយោគ ទាក់ទងនឹងគ្រឹះស្ថានហិរញ្ញវត្ថុដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹង។ នេះរួមបញ្ចូលទាំងការត្រួតពិនិត្យឡើងវិញលើសកម្មភាពអាជីវកម្មរបស់អតិថិជននីមួយៗ ដើម្បីកំណត់សកម្មភាពដែល FIs និង IFC អាចប្រឈមនឹងហានិភ័យ ដែលបណ្តាលមកពីការវិនិយោគរបស់ពួកគេ និងកំណត់លក្ខខណ្ឌតម្រូវសម្រាប់ការគ្រប់គ្រងហានិភ័យទាំងនេះ។[82] IFC ក៏ត្រូវបានតម្រូវឲ្យធានាថា អតិថិជននីមួយៗបានកំណត់ និងវាយតម្លៃហានិភ័យ និងផលប៉ះពាល់ E&S លើអ្នកខ្ចី ដោយអនុវត្តតាមការអនុវត្តល្អនៃឧស្សាហកម្មជាអន្តរជាតិ (GIIP) ផងដែរ។[83] គោលនយោបាយនិរន្តរភាពចែងថា ក្នុងអំឡុងពេលវាយតម្លៃ "IFC ត្រួតពិនិត្យឡើងវិញលើសមត្ថភាពក្នុងការអនុវត្តរបស់ FIs ព្រមទាំង ESMS របស់ពួកគេ ដូចបានតម្រូវដោយស្តង់ដារសមិទ្ធកម្មទី១"។[84] លើសពីនេះទៀត IFC "ទទួលស្គាល់អំពីទំនួលខុសត្រូវរបស់អាជីវកម្មក្នុងការគោរពសិទ្ធមនុស្ស"។[85] ដោយមានសង្គតិភាពនឹងទំនួលខុសត្រូវនេះ គោលនយោបាយនិរន្តរភាពចែងថា IFC គួរតែអនុវត្តការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន "ដែលត្រូវបានជូនដំណឹងដោយប្រទេស វិស័យ និងចំណេះដឹងរបស់អ្នកឧបត្ថម្ភ"។[86]

  ដោយពិចារណាលើលក្ខខណ្ឌតម្រូវនៃគោលនយោបាយទាំងនេះ ស៊ីអេអូសន្និដ្ឋានថា៖

---

ការអនុវត្តការគ្រប់គ្រងសមិទ្ធកម្មសង្គម ដោយធ្វើការជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានការប្តេជ្ញាចិត្ត ដើម្បីចាប់ផ្តើមអនុវត្តគំនិតផ្តួចផ្តើមនៃសូចនាករសមិទ្ធកម្មសង្គម ក្នុងឆ្នាំ២០០១។ SPTF+Cerise បានកាន់កាប់ការគ្រប់គ្រងស្តង់ដារការពារអតិថិជន ដែលបង្កើតឡើងដោយយុទ្ធនាការ Smart នៅឆ្នាំ២០២០។ សូមមើល https://cerise-sptf.org/timeline/

[82] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី ៣៤

[83] PS១ កថាខណ្ឌទី៧

[84] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី ៣៤

[85] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី ១២

[86] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី ១២

ក. ក្របខណ្ឌនិរន្តរភាព ដែលត្រូវបានជូនដំណឹងដោយ GIIP[87] នៅក្នុងផ្នែកនេះ តម្រូវឱ្យ IFC ពិនិត្យមើល ត្រួតពិនិត្យឡើងវិញ តម្រូវឱ្យមានការកាត់បន្ថយ និងតាមដានហានិភ័យបរិស្ថាន និងសង្គមលើអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ ទាក់ទងនឹងការវិនិយោគមីក្រូហិរញ្ញវត្ថុរបស់ពួកគេ (សូមមើលព័ត៌មានលម្អិតបន្ថែមទៀត នៅក្នុងឧបសម្ព័ន្ធទី៣)។ ដោយផ្អែកលើការត្រួតពិនិត្យឡើងវិញរបស់ស៊ីអេអូ លើសំណុំឯកសារដែលមាន IFCហាក់បីដូចជាមិនបានត្រួតពិនិត្យឡើងវិញ ឬដោះស្រាយហានិភ័យទាំងនេះជាប្រព័ន្ធ ទាក់ទងនឹងគម្រោងទាំង ១៣ ដែលត្រូវបានរួមបញ្ចូលនៅក្នុងសំណុំរឿងនេះទេ។

ខ. IFC បានផ្តល់ភស្តុតាងអំពីការវាយតម្លៃផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ដែលបានបញ្ចប់ សម្រាប់អតិថិជនមួយរូបគឺ ធនាគារ ហត្ថា ដែលនាំឱ្យមានអនុសាសន៍ និងផែនការសកម្មភាព ដែលធនាគារបានអនុវត្ត។ ទោះបីជាយ៉ាងណាក៏ដោយ ស៊ីអេអូមិនបានរកឃើញការចង្អុលបង្ហាញថា IFC បានប្រើអភិក្រមជាប្រព័ន្ធ ក្នុងការពិនិត្យមើល និងត្រួតពិនិត្យឡើងវិញលើស្តង់ដារហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ឬគោលការណ៍ណែនាំអំពីកិច្ចការពារអ្នកប្រើប្រាស់នៅកម្រិតគម្រោងនីមួយៗនោះទេ។

គ. ស្តង់ដារសមិទ្ធកម្មតម្រូវឲ្យមានការយកចិត្តទុកដាក់ជាពិសេសចំពោះបុគ្គល និងក្រុមដែលងាយរងគ្រោះ។[88] ដូចបានគូសបញ្ជាក់ខាងលើ របាយការណ៍នៃការសិក្សារបស់អង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាល បានគូសបញ្ជាក់អំពីរបៀបដែលវិបត្តិបំណុលមីក្រូហិរញ្ញវត្ថុនៅកម្ពុជា បានបង្កើនភាពងាយរងគ្រោះរបស់ក្រុមដែលងាយរងគ្រោះរួចហើយ រួមទាំងជនជាតិដើមភាគតិចផងដែរ។ ដើមបណ្តឹងចោទប្រកាន់ថា អ្នកខ្ចី ជាញឹកញាប់ ត្រូវចុះហត្ថលេខា និងសន្យាទទួលយកកម្ចីដោយពុំមានការយល់ដឹងយ៉ាងត្រឹមត្រូវ ឬមិនអាចអានលក្ខខណ្ឌកម្ចីបាន ដោយសារឧបសគ្គផ្នែកភាសា ឬបញ្ហាអក្ខរកម្ម។ ពួកគេក៏បានចោទប្រកាន់ផងដែរថា សមាជិកសហគមន៍ជនជាតិដើមភាគតិច ត្រូវបានបង្ខំឱ្យសម្របសម្រួលប្លង់ដីសហគមន៍របស់ពួកគេ ដោយសារតម្រូវការវត្ថុបញ្ចាំរបស់អ្នកផ្តល់មីក្រូហិរញ្ញវត្ថុ។ ស៊ីអេអូមិនបានរកឃើញការចង្អុលបង្ហាញដែលថា IFC តម្រូវ ឬធានាថា ភាពងាយរងគ្រោះជាក់លាក់របស់អ្នកខ្ចីមីក្រូហិរញ្ញវត្ថុត្រូវបានដោះស្រាយ គ្រប់គ្រង ឬពិនិត្យតាមដានឱ្យបានគ្រប់គ្រាន់ ដោយអតិថិជន FI របស់ខ្លួននៅក្នុងបរិបទនៃគម្រោងវិនិយោគនីមួយៗនោះទេ។ ការវាយតម្លៃភាពអនុលោមនេះបានរកឃើញថា ពុំមានការចង្អុលបង្ហាញថា IFC បានធានាចំពោះការរួមបញ្ចូលការពិចារណាពិសេសៗនៅក្នុងកិច្ចព្រមព្រៀងអតិថិជនរបស់គម្រោងទាំងនេះ ដើម្បីដោះស្រាយភាពងាយរងគ្រោះនោះទេ។

---

[87] ការអនុវត្តល្អនៃឧស្សាហកម្មជាអន្តរជាតិសម្រាប់ការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុណែនាំឲ្យមានការពិនិត្យមើល ការត្រួតពិនិត្យឡើងវិញ ការកាត់បន្ថយ និងការពិនិត្យតាមដានហានិភ័យនៃកិច្ចការពារអ្នកប្រើប្រាស់នៅក្នុងការវិនិយោគ FI របស់ពួកគេ។ សូមមើលព័ត៌មានលម្អិតបន្ថែមទៀតនៅក្នុងឧបសម្ព័ន្ធទី៣ ខាងក្រោម។

[88] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី ១២។

ឃ. ទាក់ទងនឹងច្បាប់ជាតិស្តីពីកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ[89] នៅខណៈពេលដែល ស៊ីអេអូបាន រកឃើញការចង្អុលបង្ហាញមួយចំនួនអំពីការត្រួតពិនិត្យឡើងវិញរបស់ IFC លើភាពអនុលោមរបស់អតិថិជនចំពោះលក្ខខណ្ឌតម្រូវទាំងនោះ ការវាយតម្លៃបែបនេះហាក់បីដូចជាមិនអនុវត្តជាប្រព័ន្ធចំពោះរាល់ការវិនិយោគទាំងអស់នោះទេ។

ង. PS៧ និងបញ្ជីផាត់ចេញ តម្រូវឱ្យមានការពិចារណាអំពីផលប៉ះពាល់លើជនជាតិដើមភាគតិច។ ពុំមានការចង្អុលបង្ហាញថា អតិថិជនរបស់ IFC បានពិចារណាអំពីផលប៉ះពាល់អវិជ្ជមានជាសក្តានុពលនៃសកម្មភាពរបស់ពួកគេលើសហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ ឬសិទ្ធិដីធ្លីរបស់ពួកគេ [90] ឬព្យាយាមអនុលោមតាមលក្ខខណ្ឌតម្រូវនៃច្បាប់ជាតិដែលពាក់ព័ន្ធទាំងអស់នោះទេ។

- **លក្ខខណ្ឌនៃការវិនិយោគ៖** គោលនយោបាយនិរន្តរភាពតម្រូវឱ្យ IFC រួមបញ្ចូលលក្ខខណ្ឌតម្រូវ PS ដែលអាចអនុវត្តបាន នៅក្នុងកិច្ចព្រមព្រៀងវិនិយោគរបស់ខ្លួន។ ជាពិសេស វាតម្រូវឱ្យ IFC ដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នមុនពេលអនុវត្តការវិនិយោគ បង្កើតលក្ខខណ្ឌតម្រូវរបស់អតិថិជន វិសាលភាព ដែលនឹង "អាស្រ័យលើប្រភេទការវិនិយោគរបស់ IFC ការប្រើប្រាស់ប្រាក់ចំណូលពីការវិនិយោគរបស់ IFC[91] និងកម្រិតហានិភ័យដែលពាក់ព័ន្ធនឹងផលបត្ររបស់ FI"។[92] នៅគ្រប់ករណីទាំងអស់ អតិថិជន FI ត្រូវបានតម្រូវឲ្យបង្កើត និងអនុវត្តប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) "ដែលសមស្របនឹងកម្រិតហានិភ័យបរិស្ថាន និងសង្គមនៅក្នុងផលបត្ររបស់ខ្លួន និងសកម្មភាពអាជីវកម្មនាពេលអនាគត... [ដែលរួមបញ្ចូល] គោលការណ៍ពាក់ព័ន្ធនៃស្តង់ដារសមិទ្ធកម្មទី១" បញ្ជីផាត់ចេញរបស់ IFC និងច្បាប់ជាតិ។[93]

ការត្រួតពិនិត្យជាបឋមនេះបង្ហាញថា មិនមែនគ្រប់កិច្ចព្រមព្រៀងវិនិយោគសម្រាប់អតិថិជន FI របស់ IFC នៅកម្ពុជាទាំងអស់ ដែលទាក់ទងនឹងសំណុំរឿងនេះ សុទ្ធតែមានវិធានការទាក់ទងនឹងការកាត់

[89] មានរបាយការណ៍ចម្រុះ ទាក់ទងនឹងវិសាលភាព និងគុណភាពនៃក្របខណ្ឌនិយ័តកម្ម សម្រាប់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា។ របាយការណ៍ Mimosa ឆ្នាំ២០២០ បានសន្និដ្ឋានថា បទប្បញ្ញត្តិកិច្ចការពារអតិថិជនកម្ពុជា មានលក្ខណៈតិចតួច ល្អបំផុត និងមិនស្មើគ្នា។ របាយការណ៍ MIMOSA ស្តីពីកម្ពុជា ខែមីនា ឆ្នាំ២០២០ ទំព័រទី ៧-៨. របាយការណ៍ និងឯកសារគម្រោងនាពេលថ្មីៗនេះ បង្ហាញថា ក្របខណ្ឌនិយ័តកម្មបានវិវត្ត ដើម្បីរួមបញ្ចូលលក្ខខណ្ឌតម្រូវច្បាស់លាស់មួយចំនួន ទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ ដែលអាចអនុវត្តចំពោះការផ្តល់កម្ចីក្រូហិរញ្ញវត្ថុ។ លើសពីនេះទៀត ក្រមសីលធម៌ទូទាំងវិស័យថ្មីមួយ ត្រូវបានបង្កើតឡើងដោយ CMA, ABC និងសមាគមហិរញ្ញវត្ថុ និងបច្ចេកវិទ្យាកម្ពុជា និងបានដាក់ឱ្យដំណើរការជាផ្លូវការនៅខែមីនា ឆ្នាំ២០២២។

[90] PS៧ កថាខណ្ឌទី ៩

[91] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី ២៤

[92] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី ៣៥. លើសពីនេះទៀត កថាខណ្ឌទី ២៤ នៃគោលនយោបាយដដែលនេះ ចែងថា "កិច្ចព្រមព្រៀងរបស់ IFC ទាក់ទងនឹងការផ្តល់ហិរញ្ញប្បទានដល់សកម្មភាពរបស់អតិថិជន រួមបញ្ចូលបញ្ញត្តិជាក់លាក់ ដែលអតិថិជនត្រូវអនុលោមតាម។ ទាំងនេះរួមមាន ការអនុលោមតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធកម្ម ដែលអាចអនុវត្តបាន និងលក្ខខណ្ឌជាក់លាក់ ដែលត្រូវបានរួមបញ្ចូលនៅក្នុងផែនការសកម្មភាព ព្រមទាំងបញ្ញត្តិពាក់ព័ន្ធសម្រាប់ការរាយការណ៍អំពីបរិស្ថាន និងសង្គម និងចុះត្រួតពិនិត្យដល់បុគ្គលិក ឬតំណាងរបស់ IFC តាមភាពសមស្រប"។

[93] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី ៣៥។

បន្ថយផលប៉ះពាល់ E&S នៅលើ MSME របស់អ្នកខ្ចីនោះទេ។ កិច្ចព្រមព្រៀងតាមផ្លូវច្បាប់មួយចំនួនជាមួយអ្នកផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុ (ដែលគ្របដណ្តប់លើគម្រោងចំនួនប្រាំមួយក្នុងចំណោមគម្រោងទាំង ១៣) យោងលើស្តង់ដារ និងលក្ខខណ្ឌតម្រូវនៃកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុទូទៅ (FCP)។ [94] ទោះបីជាយ៉ាងណាក៏ដោយ ដោយផ្អែកលើព័ត៌មានដែលផ្តល់ជូនដោយ IFC វាមិនច្បាស់ទេថា ទាំងនេះអាចអនុវត្តបាន ឬត្រូវបានពិនិត្យតាមដានក្នុងអំឡុងពេលត្រួតពិនិត្យ។[95]

- **ការត្រួតពិនិត្យ៖** បន្ទាប់ពីគម្រោងមួយត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ IFC បានប្តេជ្ញាចិត្ត និងបានបញ្ចេញថវិកា IFC តាមដានការអនុវត្តរបស់ FI និងធ្វើការជាមួយអតិថិជនដើម្បី "ដោះស្រាយចំណុចខ្វះខាតណាមួយនៅក្នុង ESMS របស់ពួកគេ"។ ការពិនិត្យតាមដាននេះគួរតែរួមបញ្ចូលការត្រួតពិនិត្យតាមកាលកំណត់ដោយ IFC លើដំណើរការ និងលទ្ធផលនៃការត្រួតពិនិត្យ E&S យ៉ាងប្រុងប្រយ័ត្នរបស់អតិថិជនរបស់ខ្លួន ហើយក៏អាចរួមបញ្ចូលការចុះជួបអតិថិជន និងអ្នកទទួលកម្ចី/ការវិនិយោគរបស់អតិថិជន ដែលសមស្របនឹងហានិភ័យ ដែលបានកំណត់ក្នុងអំឡុងពេលពិនិត្យឡើងវិញមុនពេលធ្វើការវិនិយោគ។[96] ក្នុងករណីដែលអតិថិជនមិនបានអនុលោមតាមការប្តេជ្ញាចិត្តផ្នែក E&S របស់ខ្លួនទេនោះ IFC ត្រូវតែ "ធ្វើការជាមួយអតិថិជន ដើម្បីធ្វើឱ្យអតិថិជនមានភាពអនុលោមឡើងវិញ ហើយប្រសិនបើអតិថិជនខកខានក្នុងការបង្កើតភាពអនុលោមឡើងវិញនោះ IFC នឹងអនុវត្តសិទ្ធិ និងដំណោះស្រាយរបស់ខ្លួនតាមភាពសមស្រប"។[97]

  ដោយគិតគូរអំពីលក្ខខណ្ឌតម្រូវនៃគោលនយោបាយទាំងនេះ IFC ហាក់បីដូចជាមិនបានធ្វើការពិនិត្យតាមដានហានិភ័យ និងផលប៉ះពាល់សង្គមនៃការវិនិយោគ FI របស់ខ្លួនលើអ្នកខ្ចីមីក្រូហិរញ្ញវត្ថុនៅកម្ពុជានោះទេ។ ការវិនិយោគរបស់ IFC ទាំងប្រាំមួយ ដែលរួមបញ្ចូលការប្តេជ្ញាចិត្តរបស់អតិថិជនជាវិជ្ជមានក្នុងការអនុវត្តតាមស្តង់ដារហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ពុំមានលក្ខខណ្ឌតម្រូវក្នុងការរាយការណ៍ដែលពាក់ព័ន្ធ ឬនីតិវិធីតាមដានកិច្ចព្រមព្រៀងនោះទេ។ ស៊ីអេអូមិនបានរកឃើញការចង្អុលបង្ហាញអំពីការត្រួតពិនិត្យយ៉ាងសកម្មរបស់ IFC លើបញ្ហានេះនៅកម្រិតគម្រោងនីមួយៗនោះទេ។

- **គោលនយោបាយសិទ្ធិទទួលបានព័ត៌មាន៖** គោលនយោបាយ E&S របស់ IFC រួមបញ្ចូលកាតព្វកិច្ចរបស់ខ្លួនស្របតាម AIP។ នៅក្នុងសំណុំរឿងនេះ IFC ត្រូវបានតម្រូវឱ្យបង្ហាញភាពសមហេតុផលសម្រាប់ការចាត់ថ្នាក់គម្រោងនីមួយៗ ការពណ៌នាអំពីហានិភ័យ និងផលប៉ះពាល់ចម្បងៗរបស់ FI

---

[94] ទាំងនេះគឺជាកិច្ចព្រមព្រៀងកម្ចីសម្រាប់គម្រោងដូចតទៅ ដែលបានរួមបញ្ចូលនៅក្នុងសំណុំរឿងនេះ៖ អម្រឹត (លេខ ៤៤២៣១ និង ៣៤៧៤៨) និង ធនាគារ ហត្ថា (លេខ ៣៩១៦៧ ៤៤២១១ ៤៤៧៤២ ៤៥៥៣៥)។

[95] សូមមើលឧបសម្ព័ន្ធទី៣ នៃការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC នៅក្នុងឧបសម្ព័ន្ធទី៥ ខាងក្រោម។

[96] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី ៤៥. លើសពីនេះទៀត កថាខណ្ឌទី៤៥ ចែងថា ដើម្បីត្រួតពិនិត្យការវិនិយោគរបស់ FI IFC ក៏ត្រូវតែ "អនុវត្តកម្មវិធីត្រួតពិនិត្យជាទៀងទាត់មួយលើការវិនិយោគរបស់ FI រួមជាមួយហានិភ័យ និង/ឬផលប៉ះពាល់បរិស្ថាន និងសង្គម ស្របតាមលក្ខខណ្ឌតម្រូវនៃនីតិវិធីត្រួតពិនិត្យឡើងវិញផ្នែកបរិស្ថាន និងសង្គម របស់ IFC"។

[97] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី ២៤. ESRP (ឆ្នាំ២០១៤) ផ្នែកទី ៩ កថាខណ្ឌទី ២.១។

នីមួយៗ សេចក្តីសង្ខេបអំពីប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) ដែលបានព្រមព្រៀងគ្នា និងវិធានការសំខាន់ៗដែលបានដាក់ចេញ ដើម្បីពង្រឹង ESMS។[98] ដើមបណ្តឹងចោទប្រកាន់ថា ការបង្ហាញរបស់ IFC មិនគ្រប់គ្រាន់នោះទេ ហើយការត្រួតពិនិត្យជាបឋមលើការបង្ហាញរបស់ IFC ទាក់ទងនឹងគម្រោងទាំង ១៣ គាំទ្រដល់កង្វល់របស់ពួកគេ។ ផ្អែកលើការត្រួតពិនិត្យជាបឋម ការបង្ហាញព័ត៌មាន E&S របស់ IFC ទាក់ទងនឹងអតិថិជនទាំងនេះមានលក្ខណៈទូទៅ ហើយប្រហែលជាខ្វះខាតព័ត៌មានអំពីហានិភ័យ E&S និងវិធានការ ដែលចាំបាច់ និងត្រូវអនុវត្តដើម្បីដោះស្រាយហានិភ័យទាំងនោះ។

### ឃ) ទំនាក់ទំនងដែលអាចជឿជាក់បាន រវាងការចោទប្រកាន់អំពីគ្រោះថ្នាក់ និងភាពបដិលោមជាសក្តានុពលរបស់ IFC

ជាចុងក្រោយ ការវាយតម្លៃភាពអនុលោមរបស់ស៊ីអេអូ ត្រូវតែពិចារណាថាតើ "គ្រោះថ្នាក់ដែលត្រូវបានចោទប្រកាន់ មានទំនាក់ទំនងដែលអាចជឿជាក់បាន ជាមួយភាពបដិលោមជាសក្តានុពល" ដែរឬទេ។[99] ក្នុងការកំណត់ថាតើមាន "ទំនាក់ទំនងដែលអាចជឿជាក់បាន" រវាងភាពបដិលោម និងគ្រោះថ្នាក់ដែរឬទេនោះ ស៊ីអេអូពិចារណាអំពីទំនាក់ទំនងរវាងភាពបដិលោមជាសក្តានុពល និងគ្រោះថ្នាក់ ដែលត្រូវបានចោទប្រកាន់ ដោយមិនតម្រូវឱ្យមានមូលហេតុ ឬការរួមចំណែកណាមួយនោះទេ។

នៅក្នុងសំណុំរឿងនេះ ស៊ីអេអូសន្និដ្ឋានថា មានទំនាក់ទំនងដែលអាចជឿជាក់បានរវាងគ្រោះថ្នាក់ដែលត្រូវបានចោទប្រកាន់ដោយដើមបណ្តឹង និងភាពបដិលោមជាសក្តានុពលរបស់ IFC ទាំងនៅក្នុងការត្រួតពិនិត្យឡើងវិញមុនពេលវិនិយោគ និងការពិនិត្យតាមដានផ្នែក E&S លើការវិនិយោគរបស់ខ្លួន នៅអេស៊ីលីដា, អម្រឹត, ធនាគារហត្ថា, Advans, North Haven Thai, MEF និង MIFA។

គេបានទទួលស្គាល់យ៉ាងទូលំទូលាយ ដូចបានពណ៌នាខាងលើថា ការផ្តល់កម្ចីមីក្រូឥណទានអាចមានផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គម រួមទាំងអ្នកទទួលសេវាកម្ចីផងដែរ។[100] មានការយល់ស្របផ្នែកឧស្សាហកម្មជាទូទៅមួយថា អ្នកផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវផ្នែកសង្គម យ៉ាងហោចណាស់មិនគួរបង្កគ្រោះថ្នាក់នោះទេ ដូច្នេះពួកគេមានកាតព្វកិច្ចធានាថា ផលិតផល និងសេវាកម្មរបស់ពួកគេជៀសវាងបង្កគ្រោះថ្នាក់ដល់អតិថិជន។[101] នៅខណៈពេលដែល គំនិតផ្តួចផ្តើមខុសៗគ្នាត្រូវបានបង្កើតឡើង ការត្រួតពិនិត្យជាបឋមរបស់ស៊ីអេអូ បង្ហាញថា ការយល់ស្របជាទូទៅលើ GIIP សម្រាប់មីក្រូហិរញ្ញវត្ថុ តម្រូវឱ្យគ្រឹះស្ថានហិរញ្ញវត្ថុ

---

[98] AIP កថាខណ្ឌទី ៣១ (ខ)

[99] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ៩១

[100] នៅឆ្នាំ២០២០ របាយការណ៍របស់អ្នកជំនាញឯករាជ្យនៃអង្គការសហប្រជាជាតិស្តីពីបំណុលឯកជន និងសិទ្ធិមនុស្សបានរាយការណ៍ថា "នៅខណៈពេលដែលអត្ថប្រយោជន៍រយៈពេលខ្លីមួយចំនួននៃមីក្រូហិរញ្ញវត្ថុអាចត្រូវបានរកឃើញ វាក៏ជាប់ពាក់ព័ន្ធនឹងបំណុលដែលកើនឡើង ដែលបណ្តាលឱ្យមានភាពក្រីក្រកាន់តែខ្លាំង ការបែកបាក់គ្រួសារ និងសូម្បីតែការធ្វើអត្តឃាត"។ របាយការណ៍របស់អ្នកជំនាញឯករាជ្យនៃអង្គការសហប្រជាជាតិស្តីពីបំណុលឯកជន និងសិទ្ធិមនុស្ស របាយការណ៍របស់អ្នកជំនាញឯករាជ្យស្តីពីផលប៉ះពាល់នៃបំណុលបរទេស និងកាតព្វកិច្ចហិរញ្ញវត្ថុអន្តរជាតិដែលពាក់ព័ន្ធដទៃទៀតរបស់រដ្ឋស្តីពីការទទួលបានសិទ្ធិមនុស្សពេញលេញ ជាពិសេសសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ឆ្នាំ២០២០). A/HRC/43/45 នៅទំព័រទី១ និងកថាខណ្ឌទី៣២-៣៣។

[101] សូមមើល សៀវភៅណែនាំអំពីស្តង់ដារការការពារអតិថិជនរបស់ Cerise+SPTF នៅទីនេះ៖ https://tinyurl.com/ypf7b59v និង https://tinyurl.com/489cnhty.

យ៉ាងហោចណាស់ រួមបញ្ចូលស្តង់ដារការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ ជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្មសង្គមរបស់ពួកគេ។[102]

គ្រោះថ្នាក់ដែលត្រូវបានចោទប្រកាន់ដោយអ្នកដាក់ពាក្យគឺជាហានិភ័យ និងផលប៉ះពាល់សង្គម ដែលក្របខណ្ឌនិរន្តរភាពរបស់ IFC ព្យាយាមដោះស្រាយ។ មានភាពអាចជឿជាក់បានថា គ្រោះថ្នាក់ដែលត្រូវបានចោទប្រកាន់អាចត្រូវបានទប់ស្កាត់ បន្ធូរបន្ថយ ឬកាត់បន្ថយជាអប្បបរមា ប្រសិនបើ IFC បានពិចារណាអំពីបញ្ហាទាំងនេះជាផ្នែកមួយនៃការត្រួតពិនិត្យ E&S យ៉ាងប្រុងប្រយ័ត្ន និងតម្រូវឱ្យអតិថិជនរបស់ខ្លួនអនុវត្តវិធានការកាត់បន្ថយហានិភ័យ និងផលប៉ះពាល់ដែលពាក់ព័ន្ធ រួមទាំង GIIP ដែលពាក់ព័ន្ធនឹងការការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុដូចបានតម្រូវ ស្របតាមក្របខណ្ឌនិរន្តរភាព។[103]

### ង) លក្ខខណ្ឌតម្រូវនៃគោលនយោបាយដែលពាក់ព័ន្ធបន្ថែមទៀត

យោងតាមគោលនយោបាយស៊ីអេអូ ការវាយតម្លៃអំពីភាពអនុលោមរបស់ស៊ីអេអូត្រូវតែរួមបញ្ចូលការពិចារណាបន្ថែមជាច្រើនទៀត។ [104] នៅក្នុងសំណុំរឿងនេះ ស៊ីអេអូបានពិចារណាលក្ខខណ្ឌតម្រូវដែលពាក់ព័ន្ធចំនួនពីរបន្ថែមទៀត ដូចបានពណ៌នានៅខាងក្រោម។

#### ១ ការវិនិយោគដែលបានចាកចេញ

គោលនយោបាយស៊ីអេអូចែងថា "ចំពោះគម្រោង ឬអនុគម្រោងណាមួយ ដែលការចាកចេញរបស់ IFC/MIGA បានកើតឡើង នៅពេលដែលស៊ីអេអូបញ្ចប់ការវាយតម្លៃភាពអនុលោមរបស់ខ្លួន [ស៊ីអេអូនឹងពិចារណា] ថាតើការស៊ើបអង្កេតនឹងផ្តល់គុណតម្លៃជាក់លាក់ ទាក់ទងនឹងគណនេយ្យភាព ការរៀនសូត្រ ឬវិធានការដោះស្រាយ

---

[102] បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុសកល ឆ្នាំ២០០៨ និងវិបត្តិជាក់លាក់នៅក្នុងវិស័យដទៃទៀត ដូចជា កូនបំណុលធ្វើអត្តឃាតនៅ Andhra Pradesh ក្នុងឆ្នាំ២០១០ ជាដើម អ្នកដឹកនាំឧស្សាហកម្មបានទទួលស្គាល់តម្រូវការក្នុងការធានាឱ្យមានការព្យាបាលប្រកបដោយសុវត្ថិភាព និងទំនួលខុសត្រូវចំពោះអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ និងតាមរយៈយុទ្ធនាការ Smart បានបង្កើតគោលការណ៍ការពារអតិថិជន ដែលត្រូវបានទទួលយកយ៉ាងទូលំទូលាយថាជា ការអនុវត្តល្អបំផុតនៅក្នុងឧស្សាហកម្មហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្ន។ នៅឆ្នាំ២០២០ យុទ្ធនាការ Smart ត្រូវបានបញ្ឈប់ ហើយក្រុមការងារសមិទ្ធកម្មសង្គម (SPTF) និង Cerise បានបន្តគ្រប់គ្រងលើស្តង់ដារហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងកិច្ចការពារអតិថិជន និងបានបោះពុម្ពផ្សាយគន្លងការពារអតិថិជនរបស់ខ្លួន នៅឆ្នាំ២០២១។ សូមមើល៖ Biswas, Soutik "ការរាតត្បាតនៃការធ្វើអត្តឃាតដោយសារមីក្រូហិរញ្ញវត្ថុនៅប្រទេសឥណ្ឌា" *BBC News* ខែធ្នូ ឆ្នាំ២០១០ មាននៅ៖ https://bit.ly/3OMLOKD និងរបាយការណ៍របស់អ្នកជំនាញឯករាជ្យនៃអង្គការសហប្រជាជាតិស្តីពីបំណុលឯកជន និងសិទ្ធិមនុស្សរបាយការណ៍របស់អ្នកជំនាញឯករាជ្យស្តីពីផលប៉ះពាល់នៃបំណុលបរទេស និងកាតព្វកិច្ចហិរញ្ញវត្ថុអន្តរជាតិដែលពាក់ព័ន្ធដទៃទៀតរបស់រដ្ឋលើការទទួលបានសិទ្ធិមនុស្សពេញលេញ ជាពិសេសសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឆ្នាំ២០២០ A/HRC/43/45 នៅទំព័រទី១ និងកថាខណ្ឌទី ៣៣. អំពីយុទ្ធនាការ Smart សូមមើល https://bit.ly/45QtZkj. គោលការណ៍កិច្ចការពារអតិថិជនត្រូវបានចាត់ទុកថាជាស្តង់ដារអប្បបរមា ដែលអតិថិជនគួរតែរំពឹងថានឹងទទួលបាននៅពេលធ្វើអាជីវកម្មជាមួយអ្នកផ្តល់សេវាហិរញ្ញវត្ថុ។ ដោយត្រូវបានទាញចេញពីការងាររបស់អ្នកផ្តល់សេវា បណ្តាញអន្តរជាតិ និងសមាគមមីក្រូហិរញ្ញវត្ថុជាតិ មានការឯកភាពគ្នានៅក្នុងឧស្សាហកម្មបរិយាប័ន្នផ្នែកហិរញ្ញវត្ថុថា អ្នកផ្តល់សេវាហិរញ្ញវត្ថុគួរតែប្រកាន់ខ្ជាប់នូវគោលការណ៍ស្នូលទាំងនេះ។ សូមមើលឯកសារយោងនៅ៖ https://bit.ly/3IOamzr, https://bit.ly/3q7MjET និងការណែនាំលម្អិតអំពីគោលការណ៍កិច្ចការពារអតិថិជននៅទីនេះ៖ https://bit.ly/3WJ6uFi ព្រមទាំងស្តង់ដារការពារអតិថិជនរបស់ Cerise+SPTF មាននៅ៖ https://bit.ly/45FETZK.

[103] PS១ របស់ IFC តម្រូវថា ដំណើរការកំណត់ហានិភ័យ និងផលប៉ះពាល់របស់អតិថិជន IFC គួរតែ "មានសង្គតិភាពនឹងការអនុវត្តឧស្សាហកម្មល្អជាអន្តរជាតិ" (GIIP). PS១ កថាខណ្ឌទី៧

[104] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ៩២

ដែរឬទេ ទោះបីជាមានការចាកចេញរបស់ IFC/ MIGA ក៏ដោយ"។[105] គម្រោងចំនួនបី ក្នុងចំណោមគម្រោងទាំង ១៣ ដែលត្រូវបានរួមបញ្ចូលនៅក្នុងសំណុំរឿងនេះ ត្រូវបានដកចេញ ចាប់តាំងពីពេលដែលពាក្យបណ្ដឹងត្រូវបាន ដាក់ជូនស៊ីអេអូ នៅខែកុម្ភៈ ឆ្នាំ២០២២។ ការវិនិយោគដែលបានចាកចេញទាំងបី ទាក់ទងនឹងអម្រឹត និង ធនាគារ ហត្ថា ដែលជាអតិថិជនបច្ចុប្បន្នរបស់ IFC។[106]

ដោយអនុវត្តតាមគោលនយោបាយរបស់ខ្លួន ស៊ីអេអូសន្និដ្ឋានថា ការស៊ើបអង្កេតអំពីភាពអនុលោម ដែលរួម បញ្ចូលការវិនិយោគដែលបានចាកចេញទាំងបី នឹងផ្តល់គុណតម្លៃជាក់លាក់ ទាក់ទងនឹងគណនេយ្យភាព ការរៀន សូត្រ ឬវិធានការដោះស្រាយ ដោយមានហេតុផលដូចខាងក្រោម៖

- ស្រដៀងគ្នានេះដែរ ស្របតាមគោលបំណងរបស់ពួកគេ និងការប្រើប្រាស់ប្រាក់ចំណូលសម្រាប់ការ វិនិយោគសកម្មនៅអម្រឹត និងធនាគារ ហត្ថា ការវិនិយោគដែលបានចាកចេញទាំងបីនេះគ្របដណ្តប់លើ រយៈពេលខុសៗគ្នា ច្រើនជាងការវិនិយោគដែលមានភាពសកម្មនាពេលបច្ចុប្បន្ន។ ការរួមបញ្ចូលរយៈពេល ទាំងនេះនឹងធ្វើឱ្យមានការយល់ដឹងកាន់តែច្បាស់អំពីអភិក្រមនៃការវិវត្តរបស់ IFC ចំពោះការវិនិយោគ FI របស់ខ្លួន នៅកម្ពុជា ដោយពិចារណាលើនិន្នាការដែលកំពុងលេចឡើងនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ រួម ទាំង GIIP ផងដែរ។ ការរួមបញ្ចូលការវិនិយោគដែលបានចាកចេញ នៅក្នុងការស៊ើបអង្កេតភាពអនុលោម ទាក់ទងនឹងធនាគារ ហត្ថា នឹងអនុញ្ញាតឱ្យស៊ីអេអូពិនិត្យមើលទំនាក់ទំនងហិរញ្ញវត្ថុរបស់ IFC ជាមួយ ធនាគារ ហត្ថា ចាប់ពីឆ្នាំ២០១៧ មក ជំនួសឱ្យចាប់ពីឆ្នាំ២០២១ មក (នៅពេលដែលការវិនិយោគដែល មានភាពសកម្មនាពេលបច្ចុប្បន្នត្រូវបានអនុម័ត)។ ស្រដៀងគ្នានេះដែរ ការរួមបញ្ចូលការវិនិយោគនៅ អម្រឹត ដែលបានចាកចេញ នៅក្នុងការស៊ើបអង្កេតភាពអនុលោមនឹងអនុញ្ញាតឱ្យស៊ីអេអូពិនិត្យមើលការ ផ្តល់កម្ចី MSME របស់ IFC ដល់អម្រឹត ចាប់ពីឆ្នាំ២០១៨ មក ជំនួសឱ្យចាប់ពីឆ្នាំ២០២០ មក (នៅពេល ដែលកម្ចី MSME ដែលមានភាពសកម្មនាពេលបច្ចុប្បន្ន ត្រូវបានអនុម័ត)។ នៅខណៈពេលដែល IFC ក៏មានការវិនិយោគមូលធនសកម្មនៅក្នុងអម្រឹត (ឆ្នាំ២០១៤-បច្ចុប្បន្ន) ផងដែរនោះ លក្ខណៈ និង លក្ខខណ្ឌនៃការវិនិយោគមូលធន និងកម្ចី MSME (ឆ្នាំ២០១៨-២០២២ និង ឆ្នាំ២០២០-បច្ចុប្បន្ន) មាន ភាពខុសគ្នាខ្លាំង។ ការស៊ើបអង្កេតរបស់ស៊ីអេអូ ពាក់ព័ន្ធនឹងទម្រង់ទាំងពីរនៃការផ្តល់ហិរញ្ញប្បទានដល់ អតិថិជនតែមួយ ក្នុងរយៈពេលវែង នឹងផ្តល់ជូននូវការត្រួតពិនិត្យឡើងវិញកាន់តែគ្រប់ជ្រុងជ្រោយ អំពី

---

[105] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ៩២(ក)

[106] ជាពិសេស គម្រោងលេខ 41294 ពាក់ព័ន្ធនឹងអម្រឹត ដែលជាកម្ចីជាន់ខ្ពស់រហូតដល់ ៤០ លានដុល្លារអាមេរិក ដើម្បីគាំទ្រដល់ភាពរីកចម្រើនប្រកប ដោយនិរន្តរភាពនៃផលបត្រកម្ចីខ្នាតមីក្រូ ខ្នាតតូច និងមធ្យម របស់អម្រឹត ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០១៨ ត្រូវបានចាត់ថ្នាក់ជា FI-២ និងបានចេញនៅ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ និងគម្រោងលេខ 39167 និង 44211 ពាក់ព័ន្ធនឹងធនាគារ ហត្ថា។ គម្រោងទីមួយ (លេខ 39167) គឺជាកម្ចីជាន់ខ្ពស់ចំនួន ៦០ លានដុល្លារអាមេរិក ដើម្បីគាំទ្រដល់ភាពរីកចម្រើន និងការអភិវឌ្ឍន៍របស់ធនាគារ ហត្ថា ជាពិសេសការផ្តល់កម្ចីដល់អ្នកខ្ចីខ្នាតមីក្រូ និង SMEs ដែល ត្រូវបានអនុម័តក្នុងឆ្នាំ២០១៧ ត្រូវបានចាត់ថ្នាក់ជា FI-៣ និងបានចេញនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២។ គម្រោងទីពីរ (លេខ 44211) គឺជាកម្ចីជាន់ ខ្ពស់ចំនួន ២៥ លានដុល្លារអាមេរិក ដើម្បីគាំទ្រដល់ទុនបង្វិល និងកម្មវិធីផ្តល់កម្ចីដែលទាក់ទងនឹងពាណិជ្ជកម្មរបស់ធនាគារ ហត្ថា ដល់ MSME កម្ពុជា ដែលជាលទ្ធផលនៃកំណើន និងការវិវត្តនៃជំងឺរាតត្បាតសកល កូវីដ ១៩ ៣០ ភាគរយនៃ MSME នេះ ជា SMEs ដែលគ្រប់គ្រងដោយស្ត្រី ដែលត្រូវបាន អនុម័តក្នុងឆ្នាំ២០២០ ត្រូវបានចាត់ថ្នាក់ជា FI-៣ និងបានចេញនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។

ទំនាក់ទំនងហិរញ្ញវត្ថុរបស់ IFC ជាមួយអម្រឹត។ ការរួមបញ្ចូលការវិនិយោគដែលបានចាកចេញទាំងបី នឹងផ្តល់កញ្ចក់មួយនៃទិដ្ឋភាពដែលមានថាមវន្ត នៃការវិនិយោគរបស់ IFC ដែលនឹងជួយបង្កើនតម្លៃនៃការរៀនសូត្រ និងគណនេយ្យភាពនៃការស៊ើបអង្កេត។

- ការរួមបញ្ចូលការវិនិយោគដែលបានចាកចេញ នៅក្នុងការស៊ើបអង្កេត ក៏អាចពង្រីកឱកាសនៃវិធានការដោះស្រាយ សម្រាប់ដើមបណ្តឹង ដែលអាចទទួលរងគ្រោះថ្នាក់ក្នុងអំឡុងពេលដែលគម្រោងដែលបានចាកចេញទាំងនោះ មានភាពសកម្មផងដែរ ជាពិសេសដោយសារការវិនិយោគដែលបានចាកចេញទាំងបី គឺស្ថិតនៅក្រោមអតិថិជនបច្ចុប្បន្នរបស់ IFC។

## ២ សកម្មភាពដែលត្រូវបានស្នើដោយ IFC

គោលនយោបាយស៊ីអេអូចែងថា ស៊ីអេអូនឹងពិចារណា "ថាតើគណៈគ្រប់គ្រងបានផ្តល់សេចក្តីថ្លែងការណ៍អំពីវិធានការដោះស្រាយជាក់លាក់ដែរឬទេ និងថាតើ នៅក្នុងការវិនិច្ឆ័យរបស់ស៊ីអេអូ បន្ទាប់ពីបានពិចារណាអំពីទស្សនៈរបស់ដើមបណ្តឹង វិធានការដោះស្រាយដែលត្រូវបានស្នើឡើងទាំងនេះ ដោះស្រាយបញ្ហាដែលបានលើកឡើងដោយដើមបណ្តឹងបានយ៉ាងល្អ ដែរឬទេ"។[107]

គណៈគ្រប់គ្រង IFC បានស្នើបណ្តុំអភិក្រម និងសកម្មភាព ដើម្បីដោះស្រាយបញ្ហាដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្តឹងនេះ។ សំណើរបស់ IFC កំណត់គោលដៅនៅកម្រិតគម្រោង វិស័យ និងនិយ័តកម្ម និងមានបំណងគ្របដណ្តប់លើ "ភាពមិនប្រក្រតីជាក់លាក់តាមគម្រោង ដែលត្រូវបានចោទប្រកាន់ដោយដើមបណ្តឹង" ហានិភ័យនៃការសងសឹក អភិក្រមរបស់ IFC ចំពោះហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងបទប្បញ្ញត្តិកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ (FCP) នៅកម្ពុជា។[108] នៅខណៈពេលដែលស៊ីអេអូស្វាគមន៍ចំពោះឆន្ទៈរបស់ IFC ក្នុងការចូលរួមក្នុងសកម្មភាពទាំងនេះ ស៊ីអេអូសន្និដ្ឋានថា សកម្មភាពដែលបានស្នើឡើងទាំងនេះមិនបង្កើតបានជាសេចក្តីថ្លែងការណ៍អំពីវិធានការដោះស្រាយនោះទេ ហើយក៏មិនដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងបានយ៉ាងល្អដែរ ដោយមានហេតុផលដូចខាងក្រោម៖

- គណៈគ្រប់គ្រង IFC មិនពិចារណាថា ខ្លួនបានបរាជ័យក្នុងការអនុលោមតាមគោលនយោបាយ E&S របស់ខ្លួននោះទេ និងយល់ថា រាល់គ្រោះថ្នាក់ដែលទទួលរងដោយដើមបណ្តឹង មិនទាក់ទងនឹងកាតព្វកិច្ចនៅក្រោមក្របខណ្ឌនិរន្តរភាពនោះទេ។ ដូច្នេះ សកម្មភាពដែលខ្លួនស្នើ នឹងត្រូវអនុវត្តដោយឯករាជ្យពីដំណើរការភាពអនុលោមរបស់ស៊ីអេអូ និងកាតព្វកិច្ចរបស់ IFC ក្រោមក្របខណ្ឌនិរន្តរភាព។
- វិធានការដោះស្រាយ នៅក្នុងបរិបទនៃដំណើរការភាពអនុលោមរបស់ស៊ីអេអូ គួរតែឆ្លើយតបនឹងគ្រោះថ្នាក់ដែលបានបង្កឡើង ឬបានរួមចំណែក ដោយសារភាពបដិលោមតាមគោលនយោបាយ E&S របស់

[107] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ៩២ (ឃ)

[108] សូមមើលព័ត៌មានលម្អិតនៅក្នុងការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC នៅក្នុងឧបសម្ព័ន្ធទី៥ ខាងក្រោម

IFC។[109] តាមនិយមន័យ ការដោះស្រាយ គឺជាការឆ្លើយតបនឹងគ្រោះថ្នាក់ ដែលបានបង្កឡើង ឬរួមចំណែកដោយសារការបំពានកាតព្វកិច្ច។[110]

- តាមរយៈការបដិសេធកាតព្វកិច្ចណាមួយ នៅក្រោមក្របខណ្ឌនិរន្តរភាព ដើម្បីដោះស្រាយគ្រោះថ្នាក់ និងផលប៉ះពាល់ដែលត្រូវបានចោទប្រកាន់ដោយដើមបណ្តឹង គណៈគ្រប់គ្រង IFC ក៏ចង្អុលបង្ហាញថា ខ្លួនមិនបានគិតថា ខ្លួនមានទំនួលខុសត្រូវក្នុងការដោះស្រាយគ្រោះថ្នាក់ ដែលត្រូវបានចោទប្រកាន់នោះទេ។ ដូច្នេះ ស៊ីអេអូមិនអាចចាត់ទុកសកម្មភាពដែលបានស្នើឡើងជា សេចក្តីថ្លែងការណ៍អំពីវិធានការដោះស្រាយនោះទេ។
- បន្ថែមពីលើការមិនដោះស្រាយគ្រោះថ្នាក់ដែលត្រូវបានចោទប្រកាន់ទៀតនោះ សកម្មភាពទាំងនេះមិនបានដោះស្រាយបញ្ហាដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្តឹងបានយ៉ាងល្អនោះទេ ពីព្រោះពុំមានសកម្មភាពណាមួយដោះស្រាយបញ្ហាសំខាន់ ដែលបានលើកឡើងដោយដើមបណ្តឹងនោះទេ។ បញ្ហាទូទៅនេះគឺជាការចោទប្រកាន់អំពីកង្វះខាតការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន និងការត្រួតពិនិត្យ E&S យ៉ាងត្រឹមត្រូវ ដោយ IFC លើការវិនិយោគមីក្រូហិរញ្ញវត្ថុរបស់ខ្លួន ទាក់ទងនឹងផលប៉ះពាល់សង្គមអវិជ្ជមាន ដែលត្រូវបានតម្រូវដោយក្របខណ្ឌនិរន្តរភាពរបស់ IFC។

ពុំមានការពិចារណាបន្ថែមផ្សេងទៀត នៅក្នុងកថាខណ្ឌទី ៩២ នៃគោលនយោបាយស៊ីអេអូ ជាប់ពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះទេ។ ចំពោះភាពពេញលេញ ការវិភាគអំពីលក្ខខណ្ឌតម្រូវនៃគោលនយោបាយបន្ថែមនីមួយៗ ត្រូវបានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី៦។

## ៥. សេចក្តីសម្រេចរបស់ស៊ីអេអូ

ស៊ីអេអូនឹងបន្តការស៊ើបអង្កេតលើភាពអនុលោមភាពនៃការវិនិយោគរបស់ IFC នៅអេស៊ីលីដា, អម្រឹត, ធនាគារហត្ថា, Advans, North Haven Thai, MEF និង MIFA និងការវិនិយោគដោយប្រយោលនៅក្នុងប្រាសាក់ អិលអូអិលស៊ី និង ស្ថាបនា តាមរយៈ MEF និង MIFA ដោយផ្អែកលើមូលដ្ឋានថា ពាក្យបណ្តឹងបំពេញតាមលក្ខណវិនិច្ឆ័យនៃការវាយតម្លៃទាំងបី ដូចបានរៀបរាប់ខាងលើ។

---

[109] គោលនយោបាយស៊ីអេអូចែងថា "[...] អនុសាសន៍ [នឹងត្រូវធ្វើឡើងបន្ទាប់ពីការស៊ើបអង្កេតភាពអនុលោមបានរកឃើញភាពបដិលោម និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ និង] អាចទាក់ទងនឹងការដោះស្រាយភាពបដិលោមនៅកម្រិតគម្រោង ឬអនុគម្រោង និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ និង/ឬជំហាន ដែលចាំបាច់ដើម្បីទប់ស្កាត់ភាពបដិលោមនាពេលអនាគត ដែលពាក់ព័ន្ធ នៅក្នុងកាលៈទេសៈនេះ"។ គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ១១៣។

[110] UNGP ស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស អធិប្បាយអំពីគោលការណ៍ទី២៥. អភិក្រមរបស់ IFC ចំពោះវិធានការដោះស្រាយ ពិចារណាអំពីវិធានការដោះស្រាយដែល "ដោះស្រាយផលប៉ះពាល់ E&S អវិជ្ជមាន នៅក្នុងគម្រោង IFC/MIGA" ដោយសារភាពបដិលោមតាមលក្ខខណ្ឌតម្រូវ E&S របស់ IFC/MIGA"។ យោងតាមអភិក្រមរបស់ IFC "វិធានការដោះស្រាយដោយអតិថិជន និងភាគីពាក់ព័ន្ធដទៃទៀត នៅក្នុងស្ថានប្រព័ន្ធនៃដំណោះស្រាយ មានបំណងដោះស្រាយផលប៉ះពាល់ E&S អវិជ្ជមាន ស្របតាមស្តង់ដារសមិទ្ធកម្ម និងគ្រោះថ្នាក់ផ្នែក E&S ដែលពាក់ព័ន្ធ ដោយសារភាពបដិលោមតាមលក្ខខណ្ឌតម្រូវ E&S របស់ IFC/MIGA ហើយវិធានការទាំងនោះអាចមានទម្រង់ជាច្រើន។ ទម្រង់ទាំងនេះអាចរួមបញ្ចូលបដិទាន សំណង ការស្តារនីតិសម្បទា ការបំពេញតាម និងការធានា/ការសន្យាមិនធ្វើម្តងទៀត"។ អភិក្រមរបស់ IFC ចំពោះវិធានការដោះស្រាយ ទំព័រទី៣។

របាយការណ៍វាយតម្លៃនេះនឹងត្រូវបានចែករំលែកជាមួយក្រុមប្រឹក្សាភិបាល ប្រធានក្រុមធនាគារពិភពលោក គណៈគ្រប់គ្រង IFC អតិថិជន និងដើមបណ្តឹង។ ស៊ីអេអូ ក៏នឹងបោះពុម្ពផ្សាយរបាយការណ៍វាយតម្លៃនេះ និងការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC នៅលើវែបសាយត៍របស់ខ្លួនផងដែរ។[111]

លក្ខខណ្ឌយោងសម្រាប់ការស៊ើបអង្កេតភាពអនុលោម ត្រូវបានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៧។[112]

[111] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ១០៦

[112] ដោយសារការស៊ើបអង្កេតភាពអនុលោមនេះនឹងរួមបញ្ចូលគម្រោងលើសពីមួយ ស៊ីអេអូបានប្រឹក្សាយោបល់ជាមួយ IFC ក្នុងការរៀបចំ TOR ទាំងនេះ ដោយអនុវត្តតាមកថាខណ្ឌទី ១១៩ នៃគោលនយោបាយស៊ីអេអូ

## ឧបសម្ព័ន្ធទី១៖ អតិថិជន និងអតិថិជនបន្ត ដែលទាក់ទងនឹងសំណុំរឿងរបស់ IFC

### ធនាគារអេស៊ីលីដា

ធនាគារអេស៊ីលីដា [113] គឺជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។ អតីតអង្គការមិនមែនរដ្ឋាភិបាលជាតិ ដែលគាំទ្រការអភិវឌ្ឍន៍ និងឥណទានរបស់សហគ្រាសធុនមីក្រូ និងធុនតូច អេស៊ីលីដាគឺជាដៃគូរបស់ IFC តាំងពីឆ្នាំ១៩៩៨ មក។ IFC បានគាំទ្រដល់ការផ្លាស់ប្តូរអេស៊ីលីដាពី NGO ទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពាណិជ្ជកម្ម និងបន្ទាប់មកទៅជាធនាគារពាណិជ្ជ។ បច្ចុប្បន្ន អេស៊ីលីដា គឺជាអ្នកទទួលការវិនិយោគដោយផ្ទាល់របស់ IFC ចំនួនពីរ ដែលពាក់ព័ន្ធនឹងសំណុំរឿងនេះ (គម្រោងលេខ 44882 និង 42480)[114] ដែលមានភាពសកម្ម ហើយគម្រោងទាំងពីរបង្កើតកម្ចី ដែលគាំទ្រដល់កម្មវិធីផ្តល់កម្ចីដល់សហគ្រាសធុនមីក្រូ ធុនតូច និងមធ្យម (MSMEs)។ [115] លើសពីនេះទៀត IFC បានវិនិយោគទឹកប្រាក់ចំនួន ១៥ លានដុល្លារអាមេរិក សម្រាប់ភាគហ៊ុនមូលធន

**រូបភាពទី២៖ ទំនាក់ទនងហិរញ្ញវត្ថុ រវាង IFC និងអេស៊ីលីដា**




---

[113] វែបសាយត៍របស់ធនាគារអេស៊ីលីដា៖ https://www.acledabank.com.kh/kh/eng/ff_overview

[114] គម្រោងទាំងនេះមានភាពសកម្មនៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់ជូនស៊ីអេអូ។ ព័ត៌មានលម្អិតអំពីគម្រោងអេស៊ីលីដានីមួយៗ ដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿងនេះ មាននៅក្នុងឧបសម្ព័ន្ធទី២។

[115] គម្រោងចំនួនប្រាំផ្សេងទៀតនៅអេស៊ីលីដា កាលពីដំបូង ត្រូវបានរួមបញ្ចូលនៅក្នុងសំណុំរឿងនេះ (លេខ 32642 30607 34386 35963 និង 37594) ពីព្រោះវាត្រូវបានកត់ត្រាថាមានភាពសកម្ម នៅពេលដែលស៊ីអេអូធ្វើការសម្រេចចិត្តលើភាពសមស្រប នៅខែមេសា ឆ្នាំ២០២២។ ចាប់តាំងពីពេលនោះមក IFC បានបញ្ជាក់ប្រាប់ស៊ីអេអូថា គម្រោងចំនួនបួនដំបូងត្រូវបានចាកចេញមុនរយៈពេល ១៥ ខែ ដែលត្រូវបានអនុញ្ញាតដោយគោលនយោបាយស៊ីអេអូ ក្នុងការពិចារណាអំពីគម្រោងដែលត្រូវបានចាកចេញ (កថាខណ្ឌទី ៤៩ នៃគោលនយោបាយស៊ីអេអូ)។ គម្រោងលេខ 30607 ត្រូវបានចាកចេញនៅខែសីហា ឆ្នាំ២០១៨ លេខ 32642 ត្រូវបានចាកចេញនៅខែតុលា ឆ្នាំ២០១៩ លេខ 34386 ត្រូវបានចាកចេញនៅខែមិថុនា ឆ្នាំ២០១៨ និង លេខ 35963 បានចាកចេញនៅខែមិថុនា ឆ្នាំ២០២០។ ដូច្នេះ គម្រោងរបស់អេស៊ីលីដាទាំងបួននេះ នឹងត្រូវដកចេញពីការពិចារណានៅក្នុងសំណុំរឿងនេះ។ គម្រោងលេខ 37594 បានចាកចេញនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ដែលស្ថិតនៅក្នុងរយៈពេល ១៥ ខែ ដែលមានចែងនៅក្នុងគោលនយោបាយស៊ីអេអូសម្រាប់ការទទួលយកគម្រោងដែលបានចាកចេញជាសក្តានុពល។ ទោះបីជាយ៉ាងណាក៏ដោយ ការសម្រេចចិត្តលើភាពសមស្របរបស់ស៊ីអេអូបានកំណត់ការដកចេញនូវគម្រោងដែលបានចាកចេញ មុនពេលដែលពាក្យបណ្តឹងត្រូវបានដាក់ជូនស៊ីអេអូ។ ដូច្នេះ គម្រោងនេះ ដែល IFC បានបញ្ជាក់ថាបានចាកចេញនៅខែកុម្ភៈ ឆ្នាំ២០២១ នឹងមិនត្រូវបានពិចារណាថាជាផ្នែកមួយនៃការត្រួតពិនិត្យភាពអនុលោមនៅក្នុងសំណុំរឿងនេះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ដូចបានជូនដំណឹងអំពីការសម្រេចចិត្តលើភាពសមស្រប ក្នុងខែមេសា ឆ្នាំ២០២២ នៅខណៈពេលដែលស៊ីអេអូនឹងមិនត្រួតពិនិត្យភាពអនុលោមរបស់ IFC ទាក់ទងនឹងការវិនិយោគដែលបានចាកចេញទាំងនេះទេនោះ ស៊ីអេអូនឹងពិចារណាលើការវិនិយោគដែលបានចាកចេញទាំងអស់ដែលទាក់ទងនឹងសំណុំរឿងនេះ ជាផ្នែកមួយនៃបរិបទរបស់ពាក្យបណ្តឹង ដើម្បីធានាបាននូវការយល់ដឹងយ៉ាងពេញលេញអំពីទំនាក់ទំនងហិរញ្ញវត្ថុ និងទំនាក់ទំនងរបស់ IFC ជាមួយអតិថិជន និងអតិថិជនបន្តខុសៗគ្នា។

<table>
<tr>
<td>ចំនួន ៣,៣៨% នៅក្នុង North Haven Thai Private Equity (គម្រោងលេខ 38609)[116] ដែលបានទិញភាគហ៊ុនមូលធន ៣,៥ ភាគរយនៅអេស៊ីលីដា នៅខែមេសា ឆ្នាំ ២០២២ តាមរយៈការទិញភាគហ៊ុនបន្ទាប់បន្សំ។</td>
<td></td>
</tr>
<tr>
<td>

**អម្រឹត**

អម្រឹត[117] គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងជាក្រុមហ៊ុនបុត្តសម្ព័ន្ធរបស់ Advans Group ដែលជាអតិថិជនម្នាក់ទៀតរបស់ IFC។ វាផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាជនដែលមានចំណូលទាបដល់មធ្យម ព្រមទាំង MSMEs ដោយផ្តោតលើវិស័យកសិកម្ម និងតំបន់ជនបទ។ អម្រឹតត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩១ ដោយអង្គការមិនមែនរដ្ឋាភិបាលបារាំង (GRET) ដើម្បីផ្តល់ឥណទានខ្នាតមីក្រូដល់ប្រជាជននៅតាមជនបទ និងបានក្លាយជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលបានទទួលអាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា ក្នុងឆ្នាំ២០០១។ IFC មានទំនាក់ទំនងហិរញ្ញវត្ថុជាមួយអម្រឹត តាំងពីឆ្នាំ ២០១៤ មក តាមរយៈការវិនិយោគលើមូលធន និងកាន់កាប់ភាគហ៊ុនរបស់អម្រឹតចំនួន ១៩,៩ ភាគរយ (គម្រោងលេខ 34748)។ ចាប់តាំងពីពេលនោះមក វាបានផ្តល់កម្ចីបន្ថែម ដើម្បីគាំទ្រផលបត្រ MSME របស់អម្រឹត រួមទាំងកម្ចីចំនួនពីរ ដែលទាក់ទងនឹងពាក្យបណ្តឹងនេះ (គម្រោងលេខ 44231 និង 41294)[118] – កម្ចីមួយមានភាពសកម្ម និងគម្រោងមួយទៀតបានចាកចេញ។ IFC ក៏ផ្តល់កម្ចីហិរញ្ញវត្ថុដោយប្រយោលដល់អម្រឹត តាមរយៈការវិនិយោគរបស់ខ្លួននៅក្នុងមូលនិធិ MEF និង MIFA និងការកាន់កាប់ភាគហ៊ុន ១៦ ភាគរយ នៅក្នុង Advans S.A. (គម្រោងលេខ

</td>
<td>

**រូបភាពទី៣៖ ទំនាក់ទនងហិរញ្ញវត្ថុ រវាង IFC និងអម្រឹត**




</td>
</tr>
</table>

[116] North Haven Thai គឺជាមូលនិធិភាគហ៊ុនឯកជនទូទៅមួយ ដែលផ្តោតលើក្រុមហ៊ុនពាក់កណ្តាលទីផ្សារ នៅក្នុងប្រទេសថៃជាចម្បង។ មូលនិធិនេះត្រូវបានគ្រប់គ្រងដោយ Morgan Stanley Private Equity Asia។

[117] វេបសាយត៍របស់អម្រឹត៖ https://www.amret.com.kh/en/about-amret

[118] គម្រោងទាំងនេះមានភាពសកម្ម នៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់ជូនស៊ីអេអូ។ ចាប់តាំងពីពេលនោះមក គម្រោងលេខ ៤១២៩៤ បានចាកចេញនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២. គម្រោងលេខ ៣៤៧៤៨ នៅតែមានភាពសកម្ម។ ព័ត៌មានលម្អិតអំពីគម្រោងនីមួយៗរបស់អម្រឹត ដែលជាប់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនេះ មាននៅក្នុងឧបសម្ព័ន្ធទី២។

21856)[119] Advans គឺជាក្រុមហ៊ុនវិនិយោគទុន ដែលមានទីស្នាក់ការកណ្តាលនៅប្រទេសលុចសំបួរ ដែលកាន់កាប់ភាគហ៊ុនរបស់អម្រឹត ចំនួន ៥២,៧៨ ភាគរយ និងមានបំណងបង្កើតបណ្តាញគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងកំពុងរីកចម្រើន ដើម្បីផ្គត់ផ្គង់ MSMEs។

## ធនាគារ ហត្ថា

ធនាគារ ហត្ថា[120] គឺជាធនាគារពាណិជ្ជ ដែលបានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម ក្នុងខែសីហា ឆ្នាំ២០២០។ វាត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៤ ដោយ OCSD/OXFAM-Quebec ដែលជាអង្គការកាណាដា ដើម្បីផ្តល់ប្រាក់កម្ចីខ្នាតមីក្រូ ដល់ឃុំជនបទ នៅក្នុងខេត្តពោធិ៍សាត់ និងបានចុះបញ្ជីជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត (ហត្ថាកសិករ លីមីតធីត) សម្រាប់ការអភិវឌ្ឍន៍ និងឥណទានរបស់សហគ្រាសធុនមីក្រូ និងធុនតូចក្នុងឆ្នាំ២០០១។ ធនាគារ ហត្ថា គឺជាដៃគូរបស់ IFC តាំងពីឆ្នាំ២០១៥ មក និងបានទទួលការវិនិយោគ IFC ចំនួនបួន ដែលទាក់ទងនឹងសំណុំរឿងនេះ (គម្រោងលេខ 39167 44211 45535 និង #44742)។[121] ការវិនិយោគចំនួនពីរខាងក្រោយនៅមានភាពសកម្ម ហើយគម្រោងចំនួនពីរខាងដើម បានចាកចេញនៅខែមិថុនា ឆ្នាំ២០២២។ គម្រោងទាំងបួនគឺជាកម្ចីដើម្បីពង្រីកមូលបត្រ MSME របស់ធនាគារ ហត្ថា។ IFC ក៏បានផ្តល់កម្ចីហិរញ្ញវត្ថុដោយប្រយោលដល់អម្រឹត តាមរយៈការវិនិយោគនៅក្នុង MEF ផងដែរ។

**រូបភាពទី៤៖ ទំនាក់ទនងហិរញ្ញវត្ថុ រវាង IFC និង ធនាគារ ហត្ថា**




---

[119] វែបសាយត៍របស់ Advans៖ https://www.advansgroup.com/about-us/our-mission/

[120] វែបសាយត៍របស់ធនាគារ ហត្ថា៖ https://www.hatthabank.com/page/bank-profile

[121] គម្រោងទាំងនេះមានភាពសកម្មនៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់ជូនស៊ីអេអូ។ ចាប់តាំងពីពេលនោះមក គម្រោងលេខ ៣៩១៦៧ និង ៤៤២១១ បានចាកចេញនៅថ្ងៃទី១៥ និងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ រៀងៗគ្នា។ គម្រោងលេខ ៤៤៧៤២ និង ៤៥៥៣៥ នៅតែមានភាពសកម្ម។ ព័ត៌មានលម្អិតអំពីគម្រោងនីមួយៗរបស់ ធនាគារ ហត្ថា ដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿងនេះ មាននៅក្នុងឧបសម្ព័ន្ធទី២។

## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

អិលអូលអិលស៊ី គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាតាំងពីឆ្នាំ២០០៣។ វាត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៤ ជាកម្មវិធីឥណទាន ក្រោមការគ្រប់គ្រងរបស់សេវាកម្មសង្គ្រោះកាតូលិក មិនស្វែងរកប្រាក់ចំណេញ និងត្រូវបានបង្កើតជា ធនាគារភូមិ (ខេមបូឌា) អិលធីឌី (ធីភីស៊ី) ក្នុងឆ្នាំ២០០២។ នៅឆ្នាំ២០១៥ ធនាគារភូមិ (ខេមបូឌា) អិលធីឌី បានប្តូរឈ្មោះទៅជា អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី។[122] អិលអូអិលស៊ីគឺជាអតីតអតិថិជនផ្ទាល់របស់ IFC តាមរយៈកម្ចី ដើម្បីគាំទ្រ MSME នៅក្នុងវិស័យកសិកម្ម (គម្រោង IFC លេខ 34422)។ IFC បានចាកចេញពីគម្រោងនេះនៅឆ្នាំ២០១៧ ហើយបច្ចុប្បន្ន អិលអូអិលស៊ី គឺជាអតិថិជនបន្តមួយ តាមរយៈការវិនិយោគរបស់ IFC នៅក្នុង MEF និង MIFA។

**រូបភាពទី៥៖ ទំនាក់ទំនងហិរញ្ញវត្ថុ រវាង IFC និងអិលអូអិលស៊ី**




## ប្រាសាក់

ប្រាសាក់[123] បានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចាប់ពីឆ្នាំ២០០៣ មក និងជាគ្រឹះស្ថានទទួលប្រាក់បញ្ញើ ចាប់ពីឆ្នាំ២០១០ មក។ ដោយត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ ជាគម្រោងអភិវឌ្ឍន៍មួយ វា ដើមឡើយបានទទួលមូលនិធិពីសហភាពអឺរ៉ុប ដើម្បីជួយស្តារ និងគាំទ្រវិស័យកសិកម្មនៅតាមបណ្តាខេត្តចំនួនប្រាំមួយនៅកម្ពុជា។

ប្រាសាក់ធ្លាប់ជាអតិថិជនផ្ទាល់របស់ IFC តាមរយៈកម្ចីចំនួនពីរ (គម្រោងលេខ 36280 និង 38235) ដែលត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ភាពរីកចម្រើនផ្នែកទីផ្សាររបស់ប្រាសាក់ជាពិសេស ផ្តល់កម្ចីដល់អ្នកខ្ចី MSME។ IFC បានដកការវិនិយោគទាំងនេះចេញ កាលពីខែមីនា ឆ្នាំ២០២១ និងខែតុលា ឆ្នាំ២០២០ រៀងៗគ្នា ហើយប្រាសាក់ បច្ចុប្បន្ន គឺជាអតិថិជនបន្តតាមរយៈការវិនិយោគរបស់ IFC នៅក្នុង MEF។

**រូបភាពទី៦៖ ទំនាក់ទំនងហិរញ្ញវត្ថុ រវាង IFC និងប្រាសាក់**




[122] វេបសាយត៍របស់អិលអូអិលស៊ី៖ https://www.lolc.com.kh/en/an-overview-en

[123] វេបសាយត៍របស់ប្រាសាក់៖ https://www.prasac.com.kh/en/about/milestones/

## ធនាគារស្ថាបនា

ស្ថាបនា[124] គឺជាធនាគារពាណិជ្ជមួយ ដែលត្រូវបានបង្កើតឡើង ដើមដំបូង ជាអង្គការមិនមែនរដ្ឋាភិបាល ក្នុងឆ្នាំ១៩៩៥។ បន្ទាប់ពីបានផ្លាស់ប្តូរទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលផ្តល់មូលនិធិដល់ប្រជាពជន ដែលមានប្រាក់ចំណូលទាប ស្ថាបនាត្រូវបានទិញដោយធនាគារ Maruhan Japan Plc. ក្នុងឆ្នាំ២០១២។ នៅឆ្នាំ២០១៦ ធនាគារទាំងពីរនេះបានរួមបញ្ចូលគ្នាដើម្បីបង្កើតធនាគារ ស្ថាបនា ភីអិលស៊ី។ ស្ថាបនា គឺជាអតិថិជនបន្តរបស់ IFC តាមរយៈការវិនិយោគរបស់ IFC នៅក្នុង MIFA។

**រូបភាពទី៧៖ ទំនាក់ទនងហិរញ្ញវត្ថុ រវាង IFC និងស្ថាបនា**




## ឥណទានពង្រឹងមីក្រូហិរញ្ញវត្ថុ (MEF)

MEF គឺជាមូលនិធិសន្ទនិយភាពនៃមីក្រូហិរញ្ញវត្ថុជាសកល (គម្រោងលេខ 27827) ដែលត្រូវបានចាប់ផ្តើមដោយ IFC ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ KfW និងធនាគារអភិវឌ្ឍន៍អូទ្រីស (OeEB)[125] ដើម្បីឆ្លើយតបនឹងវិបត្តិសន្ទនិយភាព ឆ្នាំ២០០៨/២០០៩។ មូលនិធិនេះមានបំណងផ្តល់ហិរញ្ញប្បទានរយៈពេលខ្លី និងមធ្យមដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅទូទាំងពិភពលោក ដែលកំពុងជួបប្រទះការលំបាកក្នុងការធានាហិរញ្ញវត្ថុទីផ្សារ។ IFC បានវិនិយោគទឹកប្រាក់ចំនួន ១៥០ លានដុល្លារអាមេរិក នៅក្នុងភាគហ៊ុន B ដែលវាកាន់កាប់ ២១,៦ ភាគរយនៃ MEF។ ការវិនិយោគនេះត្រូវបានអនុម័តក្នុងឆ្នាំ២០០៩ និងត្រូវបានចាត់ថ្នាក់ជា FI ក្រោមគោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ របស់ IFC កាលពីមុន។

**រូបភាពទី៨៖ ទំនាក់ទនងហិរញ្ញវត្ថុ រវាង IFC និង MEF និង អតិថិជនបន្ត**




## មូលនិធិគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុលអាស៊ី (MIFA)

MIFA ត្រូវបានចាប់ផ្តើមដោយ IFC KfW និង BlueOrchard Finance ដើម្បីបង្កើនលទ្ធភាពទទួលហិរញ្ញវត្ថុរបស់អ្នកខ្ចីប្រាក់

**រូបភាពទី៩៖ ទំនាក់ទនងហិរញ្ញវត្ថុ រវាង IFC និង MIFA និង អតិថិជនបន្ត**

---

[124] វែបសាយត៍របស់ស្ថាបនា៖ https://www.sathapana.com.kh/about-sathapana/

[125] MEF គឺជាយានសម្រាប់គោលបំណងពិសេស ដែលត្រូវបានបង្កើតឡើងនៅលុចសំបួរ។ វែបសាយត៍៖ https://www.mef-fund.com/mission.php

| | |
|---|---|
| ខ្នាតមីក្រូ និងគ្រួសារដែលមានប្រាក់ចំណូលទាបនៅអាស៊ីបូព៌ា អាស៊ីខាងត្បូង និងអាស៊ីកណ្តាល (គម្រោង IFC លេខ 31467)។ [126] IFC បានអនុម័តលើការវិនិយោគប្រាក់ចំនួន ២០ លានដុល្លារអាមេរិកនៅក្នុងភាគហ៊ុនបន្ថែម នៅឆ្នាំ ២០១២ ដែល IFC កាន់កាប់ភាគហ៊ុន ១០,២៦ ភាគរយនៅក្នុង MIFA។ ការវិនិយោគនេះត្រូវបានអនុម័តក្នុងឆ្នាំ២០១២ និងត្រូវបានចាត់ថ្នាក់ជា FI ក្រោមគោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ របស់ IFC កាលពីមុន។ |  |

[126] យោងតាមការបង្ហាញរបស់ IFC "MIFA នឹង៖ i) ផ្តល់ហិរញ្ញប្បទានបំណុល ផ្អែកលើទីផ្សារ — ដោយផ្តោតលើរូបិយបណ្ណក្នុងស្រុក និងការផ្តល់ហិរញ្ញប្បទានរយៈពេលវែង – ដល់អង្គភាពហិរញ្ញវត្ថុ ដែលផ្តល់សេវាដល់អាជីវកម្មខ្នាតមីក្រូ ("គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ" ឬ "MFIs") ដោយផ្តោតលើការចូលទៅកាន់ MFIs ខ្នាតតូចជាង និងមានការអភិវឌ្ឍន៍តិចជាង ii) ជួយបង្កើតមីក្រូហិរញ្ញវត្ថុជា ទ្រព្យសកម្មមួយប្រភេទ រួមជាមួយអ្នកវិនិយោគសំខាន់ៗ និងបង្កើនមូលនិធិម្ចាស់ជំនួយ ដែលមានដើមទុនឯកជន និង iii) គាំទ្រការកសាងសមត្ថភាព នៅក្នុងចំណោមអង្គភាពហិរញ្ញវត្ថុ ដែលផ្តល់សេវាដល់អង្គភាពខ្នាតមីក្រូ"។ មូលនិធិនេះត្រូវបានគ្រប់គ្រងដោយ BlueOrchard Finance ដែលជាអ្នកគ្រប់គ្រងការវិនិយោគមីក្រូហិរញ្ញវត្ថុពាណិជ្ជកម្មឈានមុខគេលើពិភពលោក។

## ឧបសម្ព័ន្ធទី២៖ ទិដ្ឋភាពទូទៅអំពីគម្រោងវិនិយោគរបស់ IFC ដែលទាក់ទងនឹងសំណុំរឿង

| | ធនាគារ | លេខគម្រោងរបស់ IFC | ស្ថានភាព | ព័ត៌មានលម្អិតអំពីគម្រោង |
|---|---|---|---|---|
| ១ | អេស៊ីលីដា | ៤៤៨៨២ | សកម្ម | កម្ចីជាន់ខ្ពស់ចំនួន ១៦៩ លានដុល្លារអាមេរិក ដើម្បីគាំទ្រអេស៊ីលីដា ក្នុងការពង្រីកកម្មវិធីផ្តល់កម្ចីរបស់ខ្លួន ទៅកាន់សហគ្រាសធុនតូច និងមធ្យម (SME) ដោយតម្រូវឱ្យ ៥០ ភាគរយនៃ SME ដែលទទួល ត្រូវបានគ្រប់គ្រងដោយស្ត្រី។ ត្រូវបានអនុម័តនៅឆ្នាំ២០២១ ត្រូវបានចាត់ថ្នាក់ជា FI-២។ |
| ២ | អេស៊ីលីដា | ៤២៤៨០ | សកម្ម | កម្ចីបន្ទាប់បន្សំរហូតដល់ ១១០ លានដុល្លារអាមេរិក ដើម្បីគាំទ្រដល់យុទ្ធសាស្ត្រនៃភាពរីកចម្រើនរបស់អេស៊ីលីដា ដោយផ្តោតលើឌីជីថលូបនីយកម្ម និងការផ្តល់កម្ចីដល់ SMEs និង SMEs ដែលគ្រប់គ្រងដោយស្ត្រី ត្រូវបានអនុម័តនៅឆ្នាំ២០១៦ និងត្រូវបានចាត់ថ្នាក់ជា FI-២។ |
| ៣ | អម្រឹត | ៣៤៧៤៨ | សកម្ម | ការវិនិយោគមូលធនចំនួន ១៧,៥ លានដុល្លារអាមេរិក សម្រាប់ភាគហ៊ុន ១៩,៩៩ ភាគរយនៅអម្រឹត និងកម្ចីជាន់ខ្ពស់ចំនួន ១០ លានដុល្លារអាមេរិក ដើម្បីគាំទ្រដល់អម្រឹត ក្នុងការផ្លាស់ប្តូរ និងផែនការអភិវឌ្ឍន៍របស់អម្រឹត។ ត្រូវបានអនុម័តនៅឆ្នាំ២០១៤ និងត្រូវបានចាត់ថ្នាក់ជា FI-២។ |
| ៤ | អម្រឹត | ៤៤២៣១ | សកម្ម | កម្ចីជាន់ខ្ពស់ចំនួន ៣៥ លានដុល្លារអាមេរិក ដើម្បីគាំទ្រកម្មវិធីផ្តល់កម្ចីរបស់អម្រឹតដល់ MSMEs នៅកម្ពុជា ដោយមានលក្ខខណ្ឌតម្រូវថា អ្នកទទួល ៣០ ភាគរយជា MSMEs ដែលគ្រប់គ្រងដោយស្ត្រី។ ត្រូវបានចាប់ផ្តើមដំណើរការដើម្បីឆ្លើយតបនឹងជំងឺរាតត្បាតសកល កូវីដ ១៩ ត្រូវបានអនុម័តនៅឆ្នាំ២០២០ ត្រូវបានចាត់ថ្នាក់ជា FI-៣។ |
| ៥ | អម្រឹត | ៤១២៩៤ | បានចាកចេញ | កម្ចីជាន់ខ្ពស់ ដែលមានទឹកប្រាក់រហូតដល់ ១០ លានដុល្លារអាមេរិក ដើម្បីគាំទ្រដល់ភាពរីកចម្រើនប្រកបដោយនិរន្តរភាពនៃផលបត្រកម្ចីខ្នាតមីក្រូ ខ្នាតតូច និងមធ្យម របស់អម្រឹត។ ត្រូវបានអនុម័តនៅឆ្នាំ២០១៨ ត្រូវបានចាត់ថ្នាក់ជា FI-២ និងបានចាកចេញនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២។ |
| ៦ | ធនាគារហត្ថា | ៤៥៥៣៥ | សកម្ម | កម្ចីជាន់ខ្ពស់ ដែលមានទឹកប្រាក់រហូតដល់ ៧០ លានដុល្លារអាមេរិក ដើម្បីគាំទ្រដល់ផលបត្រ MSME របស់ធនាគារ ហត្ថា និងគាំទ្រដល់លទ្ធភាពទទួលបានហិរញ្ញវត្ថុ ក្នុងអំឡុងពេលមានជំងឺរាតត្បាតសកល។ ត្រូវបានអនុម័តនៅឆ្នាំ២០២១ និងត្រូវបានចាត់ថ្នាក់ជា FI-២។ |
| ៧ | ធនាគារហត្ថា | ៤៤៧៤២ | សកម្ម | កម្ចីបន្ទាប់បន្សំ ដែលមានទឹកប្រាក់រហូតដល់ ៤០ លានដុល្លារអាមេរិក ដើម្បីពង្រឹងភាពធន់របស់ធនាគារហត្ថា ក្នុងអំឡុងពេលមានជំងឺរាតត្បាតសកល កូវីដ ១៩ និងគាំទ្រដល់យុទ្ធសាស្ត្ររយៈពេលវែងក្នុងការបង្កើនហិរញ្ញប្បទានដល់ MSMEs ជាចម្បង រួមទាំងក្រុមហ៊ុនដែលគ្រប់គ្រងដោយស្ត្រីផងដែរ។ ត្រូវបានអនុម័តនៅឆ្នាំ២០២១ និងត្រូវបានចាត់ថ្នាក់ជា FI-២។ |
| ៨ | ធនាគារហត្ថា | ៣៩១៦៧ | បានចាកចេញ | កម្ចីជាន់ខ្ពស់ចំនួន ៥ លានដុល្លារអាមេរិក ដើម្បីគាំទ្រដល់ភាពរីកចម្រើន និងការអភិវឌ្ឍន៍របស់ធនាគារហត្ថា ជាពិសេសការផ្តល់កម្ចីដល់អ្នកខ្ចីខ្នាតមីក្រូ និង SMEs។ ត្រូវបានអនុម័តនៅឆ្នាំ២០១៧ ត្រូវបានចាត់ថ្នាក់ជា FI-៣ និងបានចាកចេញនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២។ |
| ៩ | ធនាគារហត្ថា | ៤៤២១១ | បានចាកចេញ | កម្ចីជាន់ខ្ពស់ចំនួន ២៥ លានដុល្លារអាមេរិក ដើម្បីគាំទ្រដល់ទុនបង្វិល និងកម្មវិធីផ្តល់កម្ចីដែលទាក់ទងនឹងពាណិជ្ជកម្ម ដល់ MSMEs កម្ពុជា ក្នុងអំឡុងពេលមានជំងឺរាតត្បាតសកល កូវីដ ១៩ ដោយមានលក្ខខណ្ឌតម្រូវថា អ្នកទទួល ៣០ ភាគរយនៃ MSMEs ត្រូវបានគ្រប់គ្រងដោយស្ត្រី។ ត្រូវបានអនុម័តនៅឆ្នាំ២០២០ ត្រូវបានចាត់ថ្នាក់ជា FI-៣ និងបានចាកចេញនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។ |
| ១០ | MEF | ២៧៨២៧ | សកម្ម | ការវិនិយោគមូលធនចំនួន ១៥០ លានដុល្លារអាមេរិក នៅក្នុងភាគហ៊ុន B នៃ MEF–កាន់កាប់ ២១,៦ ភាគរយ។ ត្រូវបានអនុម័តនៅឆ្នាំ២០០៩ និងត្រូវបានចាត់ថ្នាក់ជា FI។ |

| | | | | |
|---|---|---|---|---|
| ១១ | MIFA | ៣១៤៦៧ | សកម្ម | ការវិនិយោគមូលធនចំនួន ២០ លានដុល្លារអាមេរិក នៅក្នុងភាគហ៊ុនបន្ថែម ដែលស្មើនឹងការចូលរួមចំនួន ១០,២៦ ភាគរយ នៅក្នុង MIFA។ ត្រូវបានអនុម័តនៅឆ្នាំ២០១២ និងត្រូវបានចាត់ថ្នាក់ជា FI។ |
| ១២ | Advans S.A. | ២១៨៥៦ | សកម្ម | ការវិនិយោគមូលធនចំនួន ២,១៨ លានដុល្លារអាមេរិក ស្មើនឹងភាគហ៊ុនចំនួន ១៥,៩៩ ភាគរយ នៅក្នុង Advans S.A. ជាក្រុមហ៊ុនឯកទេសផ្នែកដើមទុនក្នុងការចាប់ផ្តើមអាជីវកម្ម និងការផ្តល់ហិរញ្ញទានដទៃទៀតដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប។ ត្រូវបានអនុម័តនៅឆ្នាំ ២០០៤ និងត្រូវបានចាត់ថ្នាក់ជា FI។ |
| ១៣ | North Haven Thai | ៣៨៦០៩ | សកម្ម | ការវិនិយោគមូលធនចំនួន ១៥ លានដុល្លារអាមេរិក ស្មើនឹងភាគហ៊ុនចំនួន ៣,៣៨ ភាគរយ នៅក្នុង North Haven Thai ដែលជាមូលនិធិភាគហ៊ុនឯកជនមួយ។ ត្រូវបានអនុម័តនៅឆ្នាំ២០១៨ ត្រូវបានចាត់ថ្នាក់ជា FI-២។ |

## ឧបសម្ព័ន្ធទី៣៖ ការអនុវត្តឧស្សាហកម្មល្អជាអន្តរជាតិសម្រាប់ការវិនិយោគប្រកបដោយទំនួលខុសត្រូវនៅក្នុងវិស័យហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្ន

ការអនុវត្តឧស្សាហកម្មល្អជាអន្តរជាតិ (GIIP) សម្រាប់ការវិនិយោគប្រកបដោយទំនួលខុសត្រូវនៅក្នុងវិស័យហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្ន ណែនាំថា អ្នកផ្តល់កម្ចី និងអ្នកវិនិយោគ រួមទាំងគ្រឹះស្ថានហិរញ្ញវត្ថុអភិវឌ្ឍន៍ ដូចជា IFC ជាដើម គួរតែពិនិត្យមើល ត្រួតពិនិត្យឡើងវិញ កាត់បន្ថយ និងពិនិត្យតាមដានហានិភ័យនៃកិច្ចការពារអ្នកប្រើប្រាស់ ដែលទាក់ទងនឹងការវិនិយោគ FI របស់ពួកគេ។ ឧទាហរណ៍អំពីការអនុវត្តល្អបង្ហាញថា ជំហានទាំងនេះមានដូចខាងក្រោម៖

- **ការត្រួតពិនិត្យជាបឋម៖** វិនិយោគិនគួរតែអនុវត្តការពិនិត្យឡើងវិញជាបឋមលើគំរូអាជីវកម្មរបស់អ្នកផ្តល់សេវាហិរញ្ញវត្ថុ (FSP) បរិបទប្រទេស (រួមទាំងទិដ្ឋភាពនានា ដូចជាភស្តុតាងនៃការប្រកួតប្រជែងខ្លាំងនៅលើទីផ្សារ) បរិយាកាសផ្នែកនិយ័តកម្ម និងកត្តាពាក់ព័ន្ធដទៃទៀត ដើម្បីកំណត់បញ្ហាការការពារអ្នកប្រើប្រាស់ជាសក្តានុពលដែលទាក់ទងនឹងការអនុវត្តរបស់ពួកគេ។
- **ការវាយតម្លៃហានិភ័យ៖** វិនិយោគិនគួរតែវាយតម្លៃកម្រិត និងលក្ខណៈហានិភ័យនៃការការពារអ្នកប្រើប្រាស់ដែលទាក់ទងនឹងការអនុវត្តក្នុងការផ្តល់កម្ចីរបស់ FSP។ ការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ននេះគួរតែរួមបញ្ចូលការត្រួតពិនិត្យឡើងវិញលើគោលនយោបាយ និងការអនុវត្តរបស់អ្នកផ្តល់សេវា ទាក់ទងនឹងការបង្ហាញ ការប្រព្រឹត្តិចំពោះអតិថិជនដោយយុត្តិធម៌ ឯកជនភាពនៃទិន្នន័យ និងយន្តការបណ្តឹងសារទុក្ខ និងសំណងគ្រោះថ្នាក់។ គន្លងនៃការការពារអតិថិជន (និងពីមុន យុទ្ធនាការ Smart) ផ្តល់ ស្តង់ដារឧស្សាហកម្ម សម្រាប់ការការពារអតិថិជន រួមជាមួយសេចក្តីពណ៌នាលម្អិតអំពីការអនុវត្ត និងសូចនាករសម្រាប់ស្តង់ដារនីមួយៗ។ ឧទាហរណ៍ទាក់ទងនឹងបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងនេះ ការវាយតម្លៃហានិភ័យគួរតែត្រួតពិនិត្យឡើងវិញ ថាតើ៖
    - តម្រូវការវត្ថុបញ្ចាំ និងអ្នកធានារបស់អ្នកផ្តល់សេវាមិនបង្កើតការលំបាកធ្ងន់ធ្ងរដល់អតិថិជនទេ។ ដើម្បីបំពេញតាមស្តង់ដារនេះ អ្នកផ្តល់សេវាគួរតែបង្កើតបញ្ជីទ្រព្យសកម្ម ដែលមិនអាចដាក់ធានាជាវត្ថុបញ្ចាំបានទេ និងរួមបញ្ចូលវត្ថុនានាដែលអាចបង្កើតការលំបាកធ្ងន់ធ្ងរ ឬការបាត់បង់សមត្ថភាពស្វែងរកប្រាក់ចំណូលដ៏សំខាន់សម្រាប់អតិថិជន។ លើសពីនេះទៀត ការវាយតម្លៃវត្ថុបញ្ចាំរបស់អ្នកផ្តល់សេវាគួរតែផ្អែកលើតម្លៃទីផ្សារ/តម្លៃលក់បន្ត ដែលអាចផ្ទៀងផ្ទាត់បាន ហើយគណៈកម្មាធិការឥណទាន ឬការអនុម័តកម្រិតពីរ គួរតែផ្ទៀងផ្ទាត់ការវាយតម្លៃវត្ថុបញ្ចាំនោះ។ ទីបី តម្រូវការអប្បបរមារបស់អ្នកផ្តល់សេវាសម្រាប់វត្ថុបញ្ចាំមិនគួរលើសពីពីរដងនៃចំនួនប្រាក់កម្ចីទេ ហើយវត្ថុបញ្ចាំជាសាច់ប្រាក់មិនគួរលើសពី ២០ ភាគរយនៃចំនួនប្រាក់កម្ចី។ ទីបួន ប្រសិនបើអ្នកផ្តល់សេវាប្រមូលយកឯកសារកម្មសិទ្ធិ ឯកសារទាំងនេះគួរតែត្រូវបានប្រគល់ជូនអតិថិជនវិញ នៅពេលដែលកម្ចីត្រូវបានសង។
    - គោលនយោបាយប្រមូលប្រាក់របស់អ្នកផ្តល់សេវា ការពារសិទ្ធិរបស់អតិថិជនក្នុងការទទួលបានការប្រព្រឹត្តិចំពោះពួកគេដោយការគោរព ដោយរួមបញ្ចូលបញ្ជីការអនុវត្តក្នុងការប្រមូលបំណុលដែលសមស្រប និងមិនសមរម្យ រួមទាំងការអនុវត្តក្នុងការរឹបអូសវត្ថុបញ្ចាំ និងកាលវិភាគដំណើរការការប្រមូលប្រាក់ ដែលទុកពេលវេលាជូនអ្នកប្រមូលបំណុល ដើម្បីកំណត់អំពីមូលហេតុដែលអតិថិជនខកខានមិនបានសង និងទុកពេលឲ្យអតិថិជនស្វែងរកដំណោះស្រាយ។ លើសពីនេះទៀត អ្នកផ្តល់សេវាគួរតែជូនដំណឹងដល់អតិថិជនមុនពេលរឹបអូសវត្ថុបញ្ចាំ ដើម្បីឲ្យអតិថិជនព្យាយាមដោះស្រាយការខក

ខាន។ ជាចុងក្រោយ អ្នកផ្ដល់សេវាគួរតែហាមឃាត់ការលក់វត្ថុបញ្ចាំរបស់អតិថិជនទៅកាន់ខ្លួនឯង បុគ្គលិករបស់ខ្លួន ឬសាច់ញាតិរបស់ពួកគេ ឬទៅឱ្យភាគីទីបី ដែលពាក់ព័ន្ធ នៅក្នុងដំណើរការរឹបអូស។

- **ផែនការកាត់បន្ថយ/សកម្មភាព៖** វិនិយោគិនគួរតែបង្កើតផែនការដើម្បីដោះស្រាយហានិភ័យនៃការការពារអ្នកប្រើប្រាស់ដែលបានកំណត់។ នេះអាចរួមបញ្ចូលការផ្ដល់អនុសាសន៍ដើម្បីផ្លាស់ប្ដូរគោលនយោបាយ និង/ឬការអនុវត្តរបស់អ្នកផ្ដល់សេវា នៅក្នុងផ្នែកនានាដែលមានកង្វល់ (ផ្អែកលើស្ដង់ដារឧស្សាហកម្ម) និងការកំណត់លក្ខខណ្ឌសម្រាប់ការវិនិយោគ។ លើសពីនេះទៀត វិនិយោគិនអាចផ្ដល់ជំនួយបច្ចេកទេស ដើម្បីបង្កើនសមត្ថភាពរបស់អ្នកផ្ដល់សេវា ដើម្បីដោះស្រាយហានិភ័យជូនអ្នកប្រើប្រាស់។
- **លក្ខខណ្ឌតម្រូវនៃកិច្ចសន្យា៖** វិនិយោគិនគួរតែរួមបញ្ចូលលក្ខខណ្ឌតម្រូវនៃកិច្ចសន្យាជាក់លាក់ ដែលធ្វើឱ្យ FSPs មានកាតព្វកិច្ចទទួលយកការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។
- **ការពិនិត្យតាមដាន៖** វិនិយោគិនគួរតែតម្រូវឱ្យ FSPs រាយការណ៍ជាទៀងទាត់ ចំពោះការបំពេញតាមលក្ខខណ្ឌតម្រូវនៃកិច្ចសន្យារបស់ពួកគេ ដើម្បីដោះស្រាយហានិភ័យនៃការការពារអ្នកប្រើប្រាស់ដែលត្រូវបានកំណត់។
- **ការកសាងសមត្ថភាព៖** អ្នកផ្ដល់កម្ចីអាចពិចារណាបណ្ដុះបណ្ដាលអតិថិជន FSP អំពីការអនុវត្តផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ជាទូទៅ និងការអនុវត្តល្អបំផុតនៃកិច្ចការពារអ្នកប្រើប្រាស់ជាពិសេស។

**ប្រភព៖** សៀវភៅណែនាំអំពីស្ដង់ដារនៃកិច្ចការពារអតិថិជន ពី Cerise + ក្រុមការងារការពារសង្គម (SPTF) មាននៅ ទីនេះ គោលការណ៍ការពារអតិថិជនពីយុទ្ធនាការ Smart និង CGAP - មគ្គុទ្ទេសក៍ណែនាំផ្នែកបច្ចេកទេសសម្រាប់វិនិយោគិន ស្ដីពីការអនុវត្តគោលការណ៍ការពារអតិថិជន មាននៅ ទីនេះ។

# ឧបសម្ព័ន្ធទី ៤៖ ពាក្យបណ្តឹងដែលត្រូវបានលុបចោល

** សម្គាល់៖ ពាក្យបណ្តឹងច្បាប់ដើមត្រូវបានដាក់នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ មាន ៦៥ ទំព័រ (កំណត់សម្គាល់នៅជើងទំព័រ ចំនួន៤៣៨) រួមទាំងឧបសម្ព័ន្ធ ចំនួន១២។ ផ្នែកនានានៃពាក្យបណ្តឹងច្បាប់ដើម និងឧបសម្ព័ន្ធទាំង ១២ ត្រូវបានលុបចោល ដូចបានចង្អុលបង្ហាញនៅទីនេះ ដើម្បីរក្សាការសម្ងាត់ និងសុវត្ថិភាពរបស់ដើមបណ្តឹង។*

ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២

***តាមរយៈអ៊ីមែលតែប៉ុណ្ណោះ៖*** ***CAO@worldbankgroup.org***

លោកស្រីអគ្គនាយក Janine Ferretti

*ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ នៃក្រុមធនាគារពិភពលោក*

២១២១ វុក្ខវិថី Pennsylvania, NW Washington, DC ២០៤៣៣

**តប៖ ពាក្យបណ្តឹងពាក់ព័ន្ធនឹងការវិនិយោគគម្រោងរបស់ IFC ទៅលើ អេស៊ីលីដា អម្រឹត ប្រាសាក់ អិលអូ អិលស៊ី ធនាគារស្ថាបនា និង ធនាគារហត្ថា**

លោកស្រីអគ្គនាយក Janine Ferretti ជាទីគោរព!

1. [ត្រូវបានលុបចោល][1]
2. [ត្រូវបានលុបចោល][2]
3. [ត្រូវបានលុបចោល][3]
4. [ត្រូវបានលុបចោល]
5. ទោះបីជាមានភស្តុតាងជាច្រើនឆ្នាំ ដែលចងក្រងឯកសារអំពីវិស័យដែលឆ្អែតរួចទៅហើយ និងមានការ ំពាក់បំណុលច្រើនហួសប្រមាណ រួមជាមួយនឹងហានិភ័យសង្គម[4] ក៏ដោយ IFC បានបន្តវិនិយោគទឹកប្រាក់រាប់រយលានដុល្លារទៅក្នុងស្ថាប័នហិរញ្ញវត្ថុ ដែលមានរាយនាមនៅក្នុងពាក្យបណ្តឹងនេះ ហើយម្តងហើយម្តងទៀត មិនបានអនុវត្តការត្រួតពិនិត្យឲ្យបានគ្រប់គ្រាន់លើការវិនិយោគទាំងនោះ។ លើសពីនេះ

---

[1] ការខូចខាតដែលរងគ្រោះដោយដើមបណ្តឹងគឺទាក់ទងដោយផ្ទាល់ទៅនឹងគម្រោងសកម្មចំនួន ១៩ (ឬបានចាកចេញនាពេលថ្មីៗនេះ ក្នុងរយៈពេល ១៥ ខែ) ដែលមានរាយនាមនៅក្នុងតារាង នៅចំណុចទី៥។ ទោះបីជាយ៉ាងណាក៏ដោយ ការទាមទាររបស់ដើមបណ្តឹងគឺ តំណាងឲ្យបញ្ហាជាប្រព័ន្ធជាមួយនឹងការវិនិយោគលើគម្រោង IFC នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុរបស់កម្ពុជា ដូច្នេះហើយ បញ្ជីឈ្មោះពេញលេញនៃគម្រោងរបស់ IFC ទាំង ២៦ ដែលមានភាពសកម្ម (ឬត្រូវបានចាកចេញនាពេលថ្មីៗនេះ ក្នុងរយៈពេល ១៥ ខែ) ជាមួយ MFI និងធនាគារចំនួនប្រាំពីរ អាចត្រូវបានរកឃើញនៅក្នុងឧបសម្ព័ន្ធ ក ដើម្បីបង្ហាញអំពីវិសាលភាព និងភាពធ្ងន់ធ្ងរនៃការខូចខាតទាំងនេះ។

[2] [ត្រូវបានលុបចោល]

[3] [ត្រូវបានលុបចោល]

[4] *សូមមើល ឧ.* Juan Pablo Bohoslavsky អ្នកជំនាញឯករាជ្យផ្នែកផលប៉ះពាល់នៃបំណុលបរទេស និងកាតព្វកិច្ចហិរញ្ញវត្ថុអន្តរជាតិដែលពាក់ព័ន្ធដទៃទៀតរបស់រដ្ឋ លើការទទួលបានសិទ្ធិមនុស្សពេញលេញ *របាយការណ៍ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សស្តីពីបំណុលឯកជន និងសិទ្ធិមនុស្ស* A/HRC/៤៣/៤៥ (ថ្ងៃទី៣ ខែមករា ឆ្នាំ២០២០) នៅកថាខណ្ឌ ៣២-៣៣ (ដោយកត់សម្គាល់ថា ការផ្តល់កម្ចីច្រើនពេក និងការខ្ចីប្រាក់ច្រើនពេក បាននាំឱ្យមានវិបត្តិមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងវិធីដែលគម្រោងមីក្រូឥណទាន ជាទូទៅ តែងតែមាន "ផលប៉ះពាល់ផ្ទុយពីអ្វីដែលចង់បាន") (របាយការណ៍អ្នកជំនាញឯករាជ្យនៃអង្គការសហប្រជាជាតិស្តីពីបំណុលឯកជន និងសិទ្ធិមនុស្ស)។

ទៀត IFC មិនបានធ្វើការត្រួតពិនិត្យឲ្យបានគ្រប់គ្រាន់លើប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គមរបស់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុនៃអតិថិជន IFC របស់ខ្លួន ដែលច្បាស់ណាស់ថា មិនគ្រប់គ្រាន់ក្នុងការដោះស្រាយការអនុវត្តផ្តល់កម្ចីដ៏ឃោឃៅ និងបោកបញ្ឆោត ការផ្តល់កម្ចីដោយគ្មានការទទួលខុសត្រូវ ក្នុងទម្រង់ជាកម្ចីលើសចំនួនកំណត់ និងការបង្ខិតបង្ខំ និងការគំរាមកំហែងពីមន្ត្រីឥណទាន ដែលត្រូវបានប្រើប្រាស់ដើម្បីគេចពីប្រព័ន្ធច្បាប់កម្ពុជា និងការទទួលកម្មសិទ្ធិដីធ្លីរបស់សហគមន៍ និងបុគ្គល ស្របពេលជាមួយគ្នានោះ បង្កការខូចខាតផ្នែកសង្គមផ្សេងទៀតលើដើមបណ្តឹង។ ជាលទ្ធផលនៃការខកខានរបស់ IFC ក្នុងការវាយតម្លៃហានិភ័យនៃការវិនិយោគលើអ្នកផ្តល់សេវាមីក្រូឥណទាននៅកម្ពុជា និងការត្រួតពិនិត្យអតិថិជនរបស់ខ្លួន ដើម្បីធានាបាននូវភាពអនុលោមតាមស្តង់ដារសមិទ្ធកម្មរបស់ IFC ដើមបណ្តឹងបានរាយការណ៍អំពីការគំរាមកំហែង និងការបំភិតបំភ័យ ការបង្ខំឲ្យលក់ដីជនជាតិដើមភាគតិច ការបាត់បង់ផ្ទះសម្បែង និងមុខរបរចិញ្ចឹមជីវិត ការបរិភោគអាហារតិច និងមានគុណភាពមិនល្អ និងការបញ្ឈប់ការសិក្សារបស់កុមារ ដើម្បីបញ្ជូនពួកគេទៅធ្វើការ ដែលទាំងអស់នេះផ្ទុយពីស្តង់ដារសមិទ្ធកម្មរបស់ IFC។

6. [ត្រូវបានលុបចោល][5] [6] [7]

7. ពាក្យបណ្តឹងនេះត្រូវបានរៀបចំឡើងដោយមានជំនួយពី អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) និងអង្គការសមធម៌កម្ពុជា (EC)។ អង្គការ លីកាដូ គឺជាអង្គការជាតិសិទ្ធិមនុស្សកម្ពុជាមួយដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩២ និងឈានមុខគេក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីការពារសិទ្ធិស៊ីវិល នយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ចនៅកម្ពុជា។ លីកាដូ បន្តធ្វើជាអ្នកស្វែងរកមតិគាំទ្រសម្រាប់ប្រជាជនកម្ពុជា និងជាអ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្សពីការិយាល័យកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងការិយាល័យនៅតាមបណ្តាខេត្តចំនួន ១៣។ អង្គការសមធម៌កម្ពុជា គឺជាអង្គការជាតិសិទ្ធិមនុស្សកម្ពុជា ដែលមានគោលដៅផ្លាស់ប្តូរគំរូនៃការអភិវឌ្ឍន៍របស់ប្រទេសទៅជាប្រព័ន្ធមួយ ដែលគោរព ការពារ និងបំពេញសិទ្ធិមនុស្សរបស់ប្រជាជនកម្ពុជាគ្រប់រូប។

8. [ត្រូវបានលុបចោល]

9. ពាក្យបណ្តឹងនេះមានរចនាសម្ព័ន្ធដូចតទៅ៖ **ផ្នែកទី I** កំណត់ទំនាក់ទំនងហិរញ្ញវត្ថុរវាង IFC និងធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា ដែលមានរាយនាមនៅក្នុងពាក្យបណ្តឹងនេះ **ផ្នែកទី II** រៀបរាប់លម្អិតអំពីអង្គហេតុនៃករណីរបស់ដើមបណ្តឹង និងការខូចខាតផ្នែកសង្គម ដែលត្រូវបានទទួលរង ជាលទ្ធផលនៃគម្រោង IFC ទាំងនេះ **ផ្នែកទី III** ផ្តល់ទិដ្ឋភាពទូទៅអំពីក្របខណ្ឌនិរន្តរភាពរបស់ IFC និងការបំបែកជាផ្នែកតូចៗនៅក្នុងការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន និងការត្រួតពិនិត្យរបស់ IFC **ផ្នែកទី IV** រៀបរាប់លម្អិតអំពីរបៀបដែលកង្វះខាតការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន និងការត្រួតពិនិត្យរបស់ IFC នាំឱ្យមានការខូចខាតជាក់លាក់ចំពោះដើមបណ្តឹង ដែលបំពានលើស្តង់ដារសមិទ្ធកម្មផ្នែកសង្គម និងបរិស្ថានរបស់ IFC ផ្ទាល់ **ផ្នែកទី V** ពន្យល់អំពីរបៀបដែលកង្វះខាតការត្រួតពិនិត្យរបស់ IFC បណ្តាលឲ្យមានធាតុចេញនៃ

---

[5] [ត្រូវបានលុបចោល]

[6] [ត្រូវបានលុបចោល]

[7] [ត្រូវបានលុបចោល]

គម្រោង ដែលបំពានលើបញ្ញត្តិជាច្រើននៃច្បាប់កម្ពុជា និង**ផ្នែកទី** VI រាយធាតុចេញដែលស្នើសុំដោយដើមបណ្ដឹង។

10. ឯកសារខាងក្រោម ត្រូវបានភ្ជាប់មកជាមួយ ដើម្បីគាំទ្រដល់ពាក្យបណ្ដឹងនេះ។

    a) [ត្រូវបានលុបចោល]
    b) [ត្រូវបានលុបចោល]
    c) [ត្រូវបានលុបចោល]
    d) [ត្រូវបានលុបចោល]
    e) [ត្រូវបានលុបចោល]
    f) [ត្រូវបានលុបចោល]
    g) [ត្រូវបានលុបចោល]
    h) [ត្រូវបានលុបចោល]
    i) [ត្រូវបានលុបចោល]
    j) [ត្រូវបានលុបចោល]
    k) [ត្រូវបានលុបចោល]
    l) [ត្រូវបានលុបចោល]

## សេចក្ដីផ្ដើម

11. វិស័យមីក្រូហិរញ្ញវត្ថុរបស់កម្ពុជាមានភាពរីកចម្រើនគួរឱ្យភ្ញាក់ផ្អើល ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដោយសារអ្នកវិនិយោគអន្តរជាតិបានបូមប្រាក់រាប់ពាន់លានដុល្លារចូលទៅក្នុងទីផ្សារ ដែលខ្វះខាតការការពារអតិថិជនប្រកបដោយប្រសិទ្ធភាព។ ប្រជាជនកម្ពុជាជាប់ជំពាក់ប្រាក់ម្ចីមីក្រូហិរញ្ញវត្ថុជាង ១១,៨ ពាន់លានដុល្លារអាមេរិក ដែលភាគច្រើនតម្រូវឲ្យបណ្ណកម្មសិទ្ធិដីធ្លីជាវត្ថុបញ្ចាំ ដូច្នេះវាបង្កហានិភ័យយ៉ាងខ្លាំងដល់សន្តិសុខនៃកម្មសិទ្ធិដីធ្លីរបស់ប្រជាជនក្រីក្របំផុត និងងាយរងគ្រោះបំផុតនៅក្នុងប្រទេសកម្ពុជា។[8] ប្រជាជនកម្ពុជាកំពុងតស៊ូនៅក្រោមបំណុលដែលមិនអាចសងបំណុលបាន រួមជាមួយទំហំមីក្រូឥណទានជាមធ្យមខ្ពស់បំផុតនៅក្នុងពិភពលោក ចំនួន ៤.២៨០,៩ ដុល្លារអាមេរិក។[9] នៅក្នុងរបាយការណ៍ខែកញ្ញា ឆ្នាំ២០២១ របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ គេបានកត់សម្គាល់ថា "[i] ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ប្រជាជនកម្ពុជាបានងាកទៅរកគម្រោងហិរញ្ញប្បទានខ្នាតមីក្រូកាន់តែខ្លាំងឡើង ដើម្បីបំពេញតម្រូវការមូលដ្ឋានរបស់ពួកគេ ការសងកម្ចីជាមធ្យមសម្រាប់គ្រួសារកម្ពុជានៅពេលនេះ ស្មើនឹង ១៨២ ដុល្លារអាមេរិក/ខែ។ ដោយដីធ្លីគឺជាទម្រង់ទូទៅបំផុតនៃវត្ថុបញ្ចាំសម្រាប់ធានាកម្ចី ការបាត់បង់ទ្រព្យសម្បត្តិនៅក្នុងចំណោមអ្នកដែលមិនអាចទូទាត់ប្រាក់ គឺអាចព្យាករណ៍បាន"។ តួលេខនៃការសងកម្ចីជាមធ្យមចំនួន ១៨២ ដុល្លារអាមេរិកនេះ អាចប្រៀបធៀបនឹងប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា ដែលមានចំនួន ១៩២ ដុល្លារអាមេរិក ក្នុងឆ្នាំ

---

[8] អង្គការលីកាដូ អង្គការសមធម៌កម្ពុជា **សិទ្ធិទទួលបានការជួយសង្គ្រោះ** នៅចំណុចទី ៣ (ខែមិថុនា ឆ្នាំ២០២១)

[9] *Id.*

២០១០[10] ក៏ដូចជាប្រាក់ចំណូលប្រចាំខែជាមធ្យម ដែលមានចំនួនត្រឹមតែ ៩៦[11] ដុល្លារអាមេរិក ប៉ុណ្ណោះ។ ដូច្នេះ អ្នកខ្ចីនៅកម្ពុជា ជាមធ្យម ជំពាក់បំណុលមីក្រូឥណទានប្រហែលពីរដងនៃប្រាក់ចំណូល ដែលពួកគេរកបានក្នុងមួយខែៗ ហើយប្រាក់កម្ចីទាំងនេះ ភាគច្រើនត្រូវបានដាក់បញ្ចាំដោយបណ្ណកម្មសិទ្ធិដីធ្លីរបស់អ្នកខ្ចី។

12. ទីផ្សារដែលធ្វើនិយ័តកម្មមិនគ្រប់គ្រាន់ និងមានសភាពឆ្អែតខ្លាំងពេក បានជំរុញឱ្យមានការផ្តល់កម្ចីដ៏ឃោរឃៅ និងការអនុវត្តការប្រមូលប្រាក់ដោយបំពាន ដោយមន្ត្រីឥណទាននៃមីក្រូហិរញ្ញវត្ថុរបស់អតិថិជន IFC ដែលដាក់សម្ពាធលើអ្នកខ្ចី – ភាគច្រើនជាអនក្ខរជន ឬមានការលំបាកក្នុងការអានភាសាខ្មែរ – ក្នុងការទទួលយកកម្ចីលើសចំនួនកំណត់ ដែលធានាដោយបណ្ណកម្មសិទ្ធិដីធ្លី។ ការតស៊ូនៅក្រោមបន្ទុកបំណុលដ៏ច្រើនសន្ធឹកសន្ធាប់ពីមីក្រូឥណទាន ដែលផ្តល់មូលនិធិដោយ IFC អ្នកខ្ចីត្រូវប្រឈមនឹងការខូចខាតផ្នែកសង្គមជាច្រើន ដែលបំពានលើស្តង់ដារសមិទ្ធកម្មរបស់ IFC រួមទាំងផលប៉ះពាល់អវិជ្ជមាន និងការដកហូតដីធ្លីនៅក្នុងសហគមន៍ជនជាតិដើមភាគតិច ការបង្ខំឲ្យលក់ដីធ្លីខុសច្បាប់ ការធ្វើចំណាកស្រុកដោយបង្ខំ ការបរិភោគអាហារតិច និងពលកម្មកុមារ។[12] នៅក្នុងស្ថានភាពបរាជ័យ និងភាពងាយរងគ្រោះដោយសារវិបត្តិសេដ្ឋកិច្ច ដូចជា ការធ្លាក់ចុះនៃសេដ្ឋកិច្ច ដែលបណ្តាលមកពីជំងឺកូវីដ-១៩ ជាដើមនោះ អ្នកខ្ចីជាច្រើននាក់មិនបានទូទាត់កម្ចីរបស់ពួកគេបានទាន់ពេលវេលា និងត្រូវបានបង្ខំឱ្យលក់ដីធ្លីជាលក្ខណៈឯកជន ដើម្បីសងបំណុលរបស់ពួកគេ ដោយមន្ត្រីឥណទាននៃ MFI និងធនាគារ ដែលតាមធម្មតា ផ្លូវរំលំដំណើរការតាមផ្លូវច្បាប់ជាផ្លូវការក្នុងការអនុវត្តតាមលំនាំដើម ដែល MFI ចាត់ទុកថាមានភាពយឺតយ៉ាវ និងមានតម្លៃថ្លៃ។ ដោយត្រូវបានបដិសេធចំពោះការចូលរួមរបស់ពួកគេនៅក្នុងតុលាការ អ្នកខ្ចីត្រូវបានគេទុកចោល ដោយគ្មានឱកាសប្រឈមមុខនឹងការអនុវត្តការផ្តល់កម្ចីដែលគ្មានសីលធម៌របស់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុ និងទិដ្ឋភាពនានានៃកិច្ចព្រមព្រៀងកម្ចីមូលដ្ឋាន ដែលអាចធ្វើឱ្យកិច្ចសន្យាទាំងនោះអសុពលភាពនោះទេ។

13. នៅក្នុងវិបត្តិបំណុលនេះ មីក្រូហិរញ្ញវត្ថុគឺជាផ្នែកមួយនៃកើនឡើងផលបត្រកម្ចីរបស់ IFC។[13] ទោះបីជាយ៉ាងណាក៏ដោយ ការខូចខាតផ្នែកសង្គម ដែលទទួលរងដោយអ្នកខ្ចី និងដើមបណ្តឹងនៅក្នុងករណីនេះ បានចង្អុលបង្ហាញអំពីភាពបរាជ័យជាប្រព័ន្ធរបស់ IFC ក្នុងការអនុវត្តក្របខណ្ឌបរិស្ថាន និងសង្គមចំពោះគម្រោងមីក្រូហិរញ្ញវត្ថុរបស់ខ្លួនឱ្យបានត្រឹមត្រូវ។

---

[10] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃប្រទេសកម្ពុជា ប្រកាសលេខ ៣០៣/២០ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០២១ (ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ២០២០)។

[11] វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការនៃប្រទេសកម្ពុជា របាយការណ៍ស្ទង់មតិអំពីសេដ្ឋកិច្ចសង្គមកម្ពុជា ឆ្នាំ២០១៩/២០ នៅ ១១៣ តារាងទី៣ (ខែធ្នូ ឆ្នាំ២០២០) *មាននៅ* https://www.nis.gov.kh/nis/CSES/Final%២0Report%២0of%២0Cambodia%២0Socio-Economic%២0 Survey%202019-20_EN.pdf (៣៩១.០០០ គឺប្រហែល ៩៦ ដុល្លារអាមេរិក)។

[12] *សូមមើល id. ទូទៅ*

[13] *សូមមើល ឧ.* IFC "កម្ចីជាក្រុមចំនួន ៦៥ លានដុល្លារ របស់ IFC ជួយពង្រីកការផ្តល់កម្ចីមីក្រូហិរញ្ញប្បទាននៅកម្ពុជា" ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ https://pressroom.ifc.org/all/pages/PressDetail.aspx?ID=24965 (ដោយលើកឡើងថា IFC មានបំណងពង្រីកកម្ចីមីក្រូហិរញ្ញវត្ថុនៅកម្ពុជាឲ្យមានចំនួនអ្នកខ្ចីលើសពី ៨៤៥.០០០ នាក់ ដែលខ្លួនមាន តាមរយៈ MFIs តែបួនប៉ុណ្ណោះ នៅពាក់កណ្តាលឆ្នាំ២០១៥)។ *សូមមើល*IFC ជាទូទៅ ការចាប់ផ្តើមក្នុងទំហំតូច ដើម្បីឱកាសដ៏អស្ចារ្យ៖ មេរៀនដែលបានរៀនសូត្រពីគម្រោងមីក្រូហិរញ្ញវត្ថុរយៈពេល ២០ឆ្នាំ នៅ IFC (ឆ្នាំ២០១៥) https://openknowledge.worldbank.org/handle/10986/21795។

## I. ពាក្យបណ្តឹងទាក់ទងនឹងគម្រោងរបស់ IFC នៅក្នុងទម្រង់នៃការវិនិយោគសកម្ម និងដែលបានចេញនាពេលថ្មីៗនេះ នៅក្នុងធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា

14. ស៊ីអេអូ មានសិទ្ធិអំណាចក្នុងការស៊ើបអង្កេតលើការទាមទារនៅក្នុងពាក្យបណ្តឹងនេះ ពីព្រោះការទាមទារទាំងនោះទាក់ទងនឹងគម្រោង IFC ដែលមានភាពសកម្ម និងទើបបានចាកចេញនាពេលថ្មីៗនេះ។ អង្គហេតុនៅក្នុងពាក្យបណ្តឹងនេះ និងឧបសម្ព័ន្ធ ជាពិសេសឧបសម្ព័ន្ធ ក បង្ហាញយ៉ាងច្បាស់អំពីទំនាក់ទំនងដោយផ្ទាល់រវាងគម្រោង IFC ក្នុងទម្រង់ជាកម្ចី និងការវិនិយោគដទៃទៀតទៅលើអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុ រួមទាំងធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs) នៅកម្ពុជា និងការខូចខាតដែលបណ្តាលមកពីការប្រើប្រាស់មូលនិធិនៃគម្រោងទាំងនោះដោយអតិថិជនរបស់ IFC។

15. អ្នកផ្តល់កម្ចីខ្នាតមីក្រូ និងខ្នាតតូច ដែលមានបញ្ហានៅក្នុងពាក្យបណ្តឹងនេះ រួមមាន ធនាគារ អេស៊ីលីដា ភីអិលស៊ី (អេស៊ីលីដា), អម្រឹត ភីអិលស៊ី (អម្រឹត), គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក (ប្រាសាក់), អិលអូអិលស៊ី ខេមបូឌា (អិលអូអិលស៊ី), ធនាគារ ស្ថាបនា ភីអិលស៊ី (ស្ថាបនា) និង ធនាគារ ហត្ថា (ហត្ថា) (អតីត ហត្ថាកសិករ លីមីតធីត ឬ HKL)។ យ៉ាងហោចណាស់ ចាប់តាំងពីឆ្នាំ២០០០ មក IFC បានអនុម័តគម្រោងជាមួយអ្នកផ្តល់កម្ចីទាំងនេះ (អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC) ក្នុងទម្រង់ជាកម្ចី ការវិនិយោគ និងការគាំទ្រដទៃទៀត ដើម្បីផ្តល់ហិរញ្ញប្បទានដល់សកម្មភាពផ្តល់កម្ចី ដែលកំណត់អាទិភាពលើមីក្រូហិរញ្ញវត្ថុរបស់ IFC។ តារាងខាងក្រោមផ្តល់ជូននូវទិដ្ឋភាពទូទៅត្រួសៗអំពីការវិនិយោគផ្ទាល់របស់គម្រោង IFC ដែលមានភាពសកម្ម ទៅកាន់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC ឬការវិនិយោគលើគម្រោងដែលបានចាកចេញក្នុងរយៈពេល ១៥ ខែ ទាក់ទងនឹងការទាមទាររបស់ដើមបណ្តឹង។ បញ្ជីពេញលេញនៃការវិនិយោគលើគម្រោង IFC ដែលមានភាពសកម្ម និងបានចាកចេញនាពេលថ្មីៗនេះ ជាមួយអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដទៃទៀតនៅក្នុងប្រទេសកម្ពុជា[14] - ២៦ គម្រោង ដែលមានទឹកប្រាក់វិនិយោគសរុបជាង ៩៦០ លានដុល្លារអាមេរិក - អាចស្វែងរកបាននៅក្នុងឧបសម្ព័ន្ធ ក។

| **អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC** | **គម្រោងសកម្ម** | **គម្រោងដែលបានចាកចេញនាពេលថ្មីៗនេះ** |
|---|---|---|
| អេស៊ីលីដា | លេខ ៤២៤៨០ – FI-២ – SME<br>លេខ ៣៧៥៩៤ – FI-២ – SME<br>លេខ ៣៥៩៦៣ – FI-២ – SME<br>លេខ ៣៤៣៨៦ – FI-២ – SME<br>លេខ ៣០៦០៧ – FI – មីក្រូ និង SME<br>លេខ ៣២៦៤២ – FI-២ – មីក្រូ | |
| អម្រឹត | លេខ ៣៤៧៤៨ – FI-២ – មូលធន<br>លេខ ៤១២៩៤ – FI-២ – មីក្រូ | លេខ ៣៧៥០៥ – FI-២ – មីក្រូ |
| ប្រាសាក់ | | លេខ ៣៦២៨០ – FI-២ – មីក្រូ<br>លេខ ៣៨២៣៥ – FI-២ – មីក្រូ |

[14] IFC មានការវិនិយោគសកម្មនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រឌីត ភីអិលស៊ី តាមរយៈ MEF។

| | | |
|---|---|---|
| ធនាគារ ហត្ថា | លេខ ៣៦២៤២ – FI-៣ – MSME<br>លេខ ៣៨២៣៩ – FI-៣ – មីក្រូ<br>លេខ ៣៩១៦៧ – FI-៣ – មីក្រូ<br>លេខ ៤១២២៣ – FI-៣ – មីក្រូ<br>លេខ ៤៤៧៤២ – FI-២ – MSME<br>លេខ ៤៥៥៣៥ – FI-២ – MSME | |

16. បន្ថែមពីលើជំនួយដោយផ្ទាល់របស់ IFC ទៅកាន់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC ទៀតនោះ IFC ក៏ផ្តល់ជំនួយដល់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC ជាច្រើន តាមរយៈអតិថិជនអន្តរការីហិរញ្ញវត្ថុចំនួនពីរ៖ ឥណទានពង្រឹងមីក្រូហិរញ្ញវត្ថុ (MEF) និងមូលនិធិគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុលអាស៊ី (MIFA)។ MEF ត្រូវបានសហស្ថាបនាដោយ IFC និង KfW ក្នុងឆ្នាំ២០០៩ ក្នុងគោលបំណងតែមួយគត់គឺ ដើម្បីផ្តល់មូលនិធិដល់ MFIs នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍[15] ហើយ IFC នៅតែជាម្ចាស់ភាគហ៊ុន "B"។[16] ប្រទេសកម្ពុជាមានការផ្តល់កម្ចីរបស់ MEF ច្រើនជាងគេលំដាប់ទីបី។[17] IFC និង KfW ក៏បានបង្កើត MIFA ដើម្បីផ្តល់ហិរញ្ញប្បទាន និងជំនួយដល់ MFIs ផងដែរ។ MIFA បច្ចុប្បន្នត្រូវបានគ្រប់គ្រងដោយគណៈគ្រប់គ្រងការវិនិយោគ BlueOrchard។[18] IFC បច្ចុប្បន្ន ផ្តល់មូលនិធិដល់ MIFA រហូតដល់ ២០ លានដុល្លារអាមេរិក នៅក្នុងភាគហ៊ុនបំពេញបន្ថែម តាមរយៈគម្រោងលេខ ៣១៤៦៧។[19]

17. អនុគម្រោងនៃអន្តរការីហិរញ្ញវត្ថុទាំងនេះ ជាមួយអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC ក៏មានសិទ្ធិទទួលបានការត្រួតពិនិត្យឡើងវិញដោយស៊ីអេអូផងដែរ។[20] ការវិនិយោគរបស់ IFC នៅក្នុង MEF និង MIFA ប្រាកដណាស់ គឺដើម្បីគោលបំណងតែមួយគត់របស់មីក្រូហិរញ្ញវត្ថុ[21] ដូច្នេះ កម្ចីរបស់ MEF និង MIFA ទៅកាន់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC ស្ថិតនៅក្នុងវិសាលភាពនៃការវិនិយោគរបស់ IFC។ ដូចបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ ក MEF និង MIFA បានធ្វើការវិនិយោគបន្ទាប់បន្សំ និងការវិនិយោគជាច្រើននៅក្នុងអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC ជាច្រើននាក់ ដូច្នេះ បានបង្កើតជាទំនាក់ទំនងដ៏សំខាន់មួយរវាងអតិថិជន IFC និងអតិថិជនបន្ត។ MEF កំពុងផ្តល់កម្ចីរហូតដល់ ២៦,១ លានដុល្លារអាមេរិកដល់ ប្រាសាក់ អិលអូអិលស៊ី និងស្ថាបនា នៅខណៈពេលដែល MIFA កំពុងផ្តល់កម្ចីរហូតដល់ ៣០ លានដុល្លារអាមេរិកដល់ អិលអូអិលស៊ី និងស្ថាបនា។

[15] MEF វិនិយោគិន https://www.mef-fund.com/investors.php.

[16] *Id.*, MEF ព្រឹត្តិបត្រព័ត៌មាន (ខែមិថុនា ឆ្នាំ២០២១) https://www.mef-fund.com/downloads/factsheets/2021/MEF_Factsheet_June 2021.pdf.

[17] MEF របាយការណ៍ប្រចាំឆ្នាំ២០២០ នៅចំណុចទី ១៦។

[18] ព័ត៌មាន និងបណ្ដុំទិន្នន័យអំពីគម្រោងរបស់ IFC គម្រោងលេខ ៣១៤៦៧៖ សេចក្តីសង្ខេបអំពីព័ត៌មាននៃការវិនិយោគ អ្នកឧបត្ថម្ភគម្រោង និងម្ចាស់ភាគហ៊ុនធំៗនៃក្រុមហ៊ុនរបស់គម្រោង https://disclosures.ifc.org/project-detail/SPI/31467/mifa-debt-fund.

[19] *Id.* នៅចំណាយសរុបរបស់គម្រោង និងចំនួនទឹកប្រាក់ និងលក្ខណៈនៃការវិនិយោគរបស់ IFC។

[20] *សូមមើល* ស៊ីអេអូ គោលនយោបាយយន្តការគណនេយ្យភាពឯករាជ្យ IFC/MIGA (ស៊ីអេអូ) នៅកថាខណ្ឌ ៤១ (ក) ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១.

[21] *សូមមើល ឧ.* ព័ត៌មាន និងបណ្ដុំទិន្នន័យអំពីគម្រោងរបស់ IFC គម្រោងលេខ ៣១៤៦៧៖ សេចក្តីសង្ខេបអំពីព័ត៌មាននៃការវិនិយោគ ទិដ្ឋភាពទូទៅនៃគម្រោង https://disclosures.ifc.org/project-detail/SPI/31467/mifa-debt-fund.

| **អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC** | **គម្រោងដែលមានភាពសកម្ម** | **គម្រោងដែលបានចាកចេញនាពេលថ្មីៗនេះ** |
|---|---|---|
| ប្រាសាក់ | #២៧៨២៧ – FI – កម្ចី MEF | |
| អិលអូអិលស៊ី | #៣១៤៦៧ – FI – កម្ចី MIFA | #២៧៨២៧ – FI – កម្ចី MEF |
| ស្ថាបនា | #៣១៤៦៧ – FI – កម្ចី MIFA | #២៧៨២៧ – FI – កម្ចី MEF |

18. នៅកម្រិតដែល គម្រោង ឬអនុគម្រោងណាមួយរបស់ IFC ពាក់ព័ន្ធនឹងពាក្យបណ្តឹងនេះ បានផ្តោតយកចិត្តទុកដាក់ គោលបំណងតែមួយគត់ ក្នុងការផ្តល់កម្ចីដល់សហគ្រាសធុនតូចខ្លាំង ឬធុនតូច (MSMEs ឬ SMEs) ជាជាងសម្រាប់សកម្មភាពមីក្រូហិរញ្ញវត្ថុនីមួយៗនោះ កម្ចីដែលទទួលបានដោយដើមបណ្តឹងស្ថិតនៅក្នុងរង្វង់នៃគោលបំណងនេះ។ ទោះបីជាដើមបណ្តឹងបានទទួលកម្ចីជាលក្ខណៈបុគ្គលក៏ដោយ ក៏លក្ខណៈមិនផ្លូវការនៃសហគ្រាសធុនតូច និងធុនមីក្រូនៅកម្ពុជា រួមផ្សំជាមួយនិយមន័យប្រូកស៊ីផ្ទាល់ខ្លួនរបស់ IFC មានន័យថា នៅក្នុងបរិបទនេះ កម្ចីរបស់ដើមបណ្តឹងបានបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់ផ្តល់កម្ចីដល់ MSMEs/SMEs ដូច្នេះវាស្ថិតនៅក្នុងវិសាលភាពនៃគម្រោង និងអនុគម្រោងរបស់ IFC។

19. រាល់គម្រោង និងអនុគម្រោងរបស់ IFC ទាំងអស់ ដែលមានបញ្ហានៅក្នុងពាក្យបណ្តឹងនេះ មានបំណងផ្តល់មីក្រូហិរញ្ញវត្ថុ ឬកម្ចីដល់សហគ្រាសធុនមីក្រូ ឬធុនតូច (MSME ឬ SME)។ IFC កំណត់និយមន័យសហគ្រាសធុនមីក្រូថាជា សហគ្រាសដែលបំពេញតាមលក្ខណវិនិច្ឆ័យពីរក្នុងចំណោមលក្ខណវិនិច្ឆ័យចំនួនបីដូចតទៅ៖ មានបុគ្គលិកតិចជាង ១០ នាក់ មានទ្រព្យសកម្មសរុបតិចជាង ១០០.០០០ ដុល្លារអាមេរិក ឬការលក់ប្រចាំឆ្នាំមានចំនួនតិចជាង ១០០.០០០ ដុល្លារអាមេរិក។[22] ម្យ៉ាងវិញទៀត សហគ្រាសក៏មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសហគ្រាសធុនមីក្រូផងដែរ ប្រសិនបើវាស្ថិតនៅក្នុងប្រូកស៊ីនៃទំហំកម្ចីដែលពាក់ព័ន្ធ៖ កម្ចីតិចជាង ១០.០០០ ដុល្លារអាមេរិក។[23] ដូច្នេះ ស្របតាមនិយមន័យប្រូកស៊ី កម្ចីដែលមានចំនួនតិចជាង ១០.០០០ ដុល្លារអាមេរិក ទាក់ទងនឹងសកម្មភាពសេដ្ឋកិច្ចរបស់អ្នកខ្ចី មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាកម្ចីដល់សហគ្រាសធុនមីក្រូ។[24] និយមន័យប្រូកស៊ី – កំណត់និយមន័យសហគ្រាសធុនមីក្រូដោយផ្អែកលើចំនួនទឹកប្រាក់កម្ចីដែលទទួលបានដោយអ្នកខ្ចី – ទំនងជាត្រូវបានអនុម័ត ដោយទទួលស្គាល់ការពិតថា បទពិសោធន៍របស់អ្នកខ្ចីគឺ "មានការប្រែប្រួល និងស្មុគស្មាញ" – ឧទាហរណ៍ កម្ចីខ្នាតមីក្រូ និងមីក្រូឥណទានជាច្រើន អាចទាក់ទង "ទាំងដោយផ្ទាល់ និងដោយប្រយោល នឹងប្រភពប្រាក់ចំណូល និង

---

[22] IFC និយមន័យអំពីវិស័យគោលដៅរបស់ IFC https://www.ifc.org/wps/wcm/connect/industry_ext_content/ifc_external_corporate_site/financial+institutions/priorities/ifcs+definitions+of+targeted+sectors.

[23] *Id.*

[24] *សូមមើល* IFC ព្រឹត្តិបត្រព័ត៌មាន៖ ការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម ជាសកល នៅ ១ ក.១ (ឆ្នាំ២០១៤) មាននៅ https://www.smefinanceforum.org/sites/default/files/2014MSME%2BFactsheet-Global_1.pdf ("ទីផ្សារហិរញ្ញវត្ថុជាសកលរបស់ IFC បានចាត់ថ្នាក់អ្នកខ្ចីបន្តរបស់អតិថិជនរបស់ខ្លួនតាមនិយមន័យដូចតទៅ៖ (១) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ៖ ប្រសិនបើកម្ចីដើមមានចំនួន < ១០.០០០ ដុល្លារ") *សូមមើលផងដែរ*នូវ ក្រុមធនាគារពិភពលោក ការស្ទង់មតិអំពីបរិយាប័ន្នហិរញ្ញវត្ថុ និងការការពារអ្នកប្រើប្រាស់ជាសកល នៅ ២៣ និងតារាង ៣.៤ (ឆ្នាំ ២០១៧) (រាយការណ៍ថា នៅក្នុង ៦៤ ភាគរយនៃយុត្តាធិការដែលត្រូវបានស្ទង់មតិ ប្រើនិយមន័យ "មីក្រូហិរញ្ញវត្ថុ" ដែលត្រូវបានកំណត់ដោយតម្លៃ/ចំនួនទឹកប្រាក់របស់ផលិតផល ហើយនៅក្នុង ៧៧ ភាគរយនៃយុត្តាធិការទាំងនោះ ពាក្យនេះត្រូវបានកំណត់ដោយអតិថិជនគោលដៅ រួមទាំងបុគ្គលដែលមានប្រាក់ចំណូលទាបផងដែរ)។ [ការស្ទង់មតិ GFICP របស់ធនាគារពិភពលោកឆ្នាំ ២០១៧ នៅខាងក្រោម]។

បំណុលជាច្រើនផ្សេងទៀត″។[25] លើសពីនេះទៀត និយមន័យប្រូកស៊ីរបស់ IFC មានសង្គតិភាពនឹងនិន្នាការនៃនិយមន័យរបស់ផលិតផលនានានៅក្នុងវិស័យនេះ ដូចបានរាយការណ៍ដោយធនាគារពិភពលោក។ មីក្រូហិរញ្ញវត្ថុត្រូវបានកំណត់និយមន័យតាមតម្លៃ/ចំនួនផលិតផល នៅក្នុង ៦៤ ភាគរយនៃយុត្តាធិការដែលត្រូវបានស្ទង់មតិ។[26]

20. [ត្រូវបានលុបចោល][27] [28] [29] [30] [31]

21. ការប្រើប្រាស់ចុងក្រោយនៃផលិតផលហិរញ្ញវត្ថុ នៅក្នុងករណីនេះ កម្ចីមីក្រូហិរញ្ញវត្ថុ មិនមែនជាធាតុផ្សំនៃនិយមន័យអំពីវិស័យគោលដៅរបស់ IFC នោះទេ។[32] ដូច្នេះ របៀបដែលមូលនិធិត្រូវបានប្រើប្រាស់ចុងក្រោយដោយអ្នកខ្ចី គឺមិនពាក់ព័ន្ធនឹងការពិចារណាថាតើកម្ចីស្ថិតនៅក្នុងនិយមន័យមីក្រូហិរញ្ញវត្ថុ និង MSME របស់ IFC ដែរឬអត់នោះទេ។

22. [ត្រូវបានលុបចោល][33] [34] [35]

23. [ត្រូវបានលុបចោល]

24. [ត្រូវបានលុបចោល]

## A. គម្រោងរបស់ IFC ជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី (អេស៊ីលីដា)

---

[25] *សូមមើល* Maryann Bylander ‶ឥណទានជាការទប់ទល់៖ ការគិតឡើងវិញអំពីមីក្រូឥណទាននៅក្នុងបរិបទនៃប្រទេសកម្ពុជា″ *Oxford Development Studies* ច្បាប់ទី៤៣ លេខ ៤ (ឆ្នាំ២០១៥) នៅ ៥៤០; IFC ការវាយតម្លៃអំពីការរួមចំណែករបស់វិស័យឯកជនក្នុងការបង្កើតការងារ៖ ការសិក្សាអំពីប្រភពបើកចំហរបស់ IFC គ្មានកាលបរិច្ឆេទ http://documents1.worldbank.org/curated/en/602291468183841622/pdf/819960BRI0Meas00Box379851B00PUBLIC0.pdf (‶MFIs ប្រហែលជាអាចពុំមានព័ត៌មានអំពីលក្ខណវិនិច្ឆ័យចាំបាច់សម្រាប់អ្នកខ្ចីគ្រប់រូបនោះទេ″); *សូមមើលផងដែរ* នូវ ការស្ទង់មតិ GFICP ឆ្នាំ២០១៧ របស់ធនាគារពិភពលោក កំណត់សម្គាល់ខាងលើ លេខ ២៤ នៅ ២២-២៣, ឧបសម្ព័ន្ធ ក នៅ ៥៨ (ចូរកត់សម្គាល់អំពីការប្រែប្រួលដ៏សំខាន់នៅក្នុងនិយមន័យ ‶មីក្រូហិរញ្ញវត្ថុ″ ‶មីក្រូឥណទាន″ និងផលិតផលដែលពាក់ព័ន្ធ នៅក្នុងវិស័យនេះ ជាសកល រួមទាំងប្រទេសកម្ពុជា ផងដែរ និងថា ៣០ ភាគរយនៃយុត្តាធិការដែលត្រូវបានស្ទង់មតិ ពុំមាននិយមន័យផ្លូវការសម្រាប់ពាក្យទាំងនោះទេ)។

[26] ការស្ទង់មតិ GFICP ឆ្នាំ២០១៧ របស់ធនាគារពិភពលោក *supra* note ២៤ នៅចំណុចទិ ២៣ និងតារាង ៣.៤។

[27] IFC និយមន័យអំពីវិស័យគោលដៅរបស់ IFC https://www.ifc.org/wps/wcm/connect/industry_ext_content/ifc_external_corporate_site/financial+institutions/priorities/ifcs+definitions+of+targeted+sectors

[28] [ត្រូវបានលុបចោល]

[29] [ត្រូវបានលុបចោល]

[30] *Infra* ផ្នែកទី II.

[31] *Id.*

[32] *សូមមើល* IFC និយមន័យអំពីវិស័យគោលដៅរបស់ IFC https://www.ifc.org/wps/wcm/connect/industry_ext_content/ifc_external_corporate_site/financial+institutions/priorities/ifcs+definitions+of+targeted+sectors.

[33] [ត្រូវបានលុបចោល]

[34] Adrien Chorn និង Jonathan Stromseth ‶ជំងឺកូវីដ-១៩ មកកាន់ប្រទេសកម្ពុជា″ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ https://www.brookings.edu/blog/order-from-chaos/2021/05/19/covid-19-comes-to-cambodia/.

[35] សូមមើល *Id.*

25. [ត្រូវបានលុបចោល][36] [37] [38]

26. [ត្រូវបានលុបចោល]

27. [ត្រូវបានលុបចោល][39] [40] [41]

## B. គម្រោងរបស់ IFC ជាមួយ អម្រឹត ភីអិលស៊ី (អម្រឹត)

28. [ត្រូវបានលុបចោល]

29. [ត្រូវបានលុបចោល]

30. [ត្រូវបានលុបចោល][42] [43] [44] [45] [46] [47]

31. [ត្រូវបានលុបចោល][48]

## C. គម្រោងរបស់ IFC ជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក (ប្រាសាក់)

32. [ត្រូវបានលុបចោល]

33. [ត្រូវបានលុបចោល]

34. [ត្រូវបានលុបចោល]

35. [ត្រូវបានលុបចោល]

## D. គម្រោងរបស់ IFC ជាមួយ អិលអូអិលស៊ី ខេមបូឌា (អិលអូអិលស៊ី)

36. [ត្រូវបានលុបចោល]

---

[36] [ត្រូវបានលុបចោល]

[37] Milford Bateman *ការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីធ្វើឲ្យលទ្ធភាពទទួលបានមីក្រូឥណទាននៅកម្ពុជាមានភាពប្រសើរឡើង៖ ចូរប្រុងប្រយ័ត្នចំពោះអ្វីដែលអ្នកចង់បាន* ឯកសារសន្និសីទសម្រាប់ឆ្នាំ២០២០ សន្និសីទធនាគារពិភពលោកស្តីពីដីធ្លី និងភាពក្រីក្រ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ នៅ ១០ *មាននៅ* https://www.researchgate.net/publication/340558285_Land_Titling_Improves_Access_to_Microcredit_in_Cambodia_Be_Careful_What_You_Wish_For.

[38] *សូមមើល* របាយការណ៍ប្រចាំឆ្នាំ២០២០ របស់អេស៊ីលីដា នៅ ១១៣ (៣៥.១ (c)) *មាននៅ* https://www.acledabank.com.kh/kh/assets/pdf_zip/ACLEDA%២0Bank%២0-%២0Annual%២0Report%២0២0២0.pdf.

[39] [ត្រូវបានលុបចោល]

[40] *Infra* ផ្នែកទី II.

[41] *សូមមើល* ឧបសម្ព័ន្ធ ក.

[42] របាយការណ៍ប្រចាំឆ្នាំ២០២០ របស់ អម្រឹត នៅ ១៣ *មាននៅ* https://www.amret.com.kh/storage/app/uploads/Annual-Report/English_2020.pdf?_t=1624933328.

[43] Advans SA "ម្ចាស់ភាគហ៊ុនយោង" *មាននៅ* https://www.advansgroup.com/about-us/our-governance/.

[44] *Id.*

[45] [ត្រូវបានលុបចោល]

[46] *Infra* ផ្នែកទី II.

[47] [ត្រូវបានលុបចោល]

[48] ព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាសរបស់ MEF ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ នៅ ៤ https://www.mef-fund.com/downloads/factsheets/2020/MEF_Factsheet_March2020.pdf.

37. [ត្រូវបានលុបចោល]

38. [ត្រូវបានលុបចោល]

39. [ត្រូវបានលុបចោល]

## E. គម្រោងរបស់ IFC ជាមួយ ធនាគារ ហត្ថា អតីតហៅថា ហត្ថាកសិករ លីមីធីត

40. [ត្រូវបានលុបចោល]

41. [ត្រូវបានលុបចោល]

42. [ត្រូវបានលុបចោល][49] [50]

43. [ត្រូវបានលុបចោល]

## F. គម្រោងរបស់ IFC ជាមួយ ធនាគារ ស្ថាបនា ភីអិលស៊ី (ស្ថាបនា)

44. [ត្រូវបានលុបចោល]

45. [ត្រូវបានលុបចោល][51]

46. [ត្រូវបានលុបចោល][52]

47. [ត្រូវបានលុបចោល]

48. [ត្រូវបានលុបចោល]

## II. ពាក្យបណ្ដឹងនេះស្ថិតនៅក្នុងអាណត្តិរបស់ស៊ីអេអូ ពីព្រោះដើមបណ្ដឹងបានរងផលប៉ះពាល់ពីបញ្ហាសង្គម ដែលទាក់ទងនឹងការវិនិយោគលើគម្រោងរបស់ IFC

49. [ត្រូវបានលុបចោល]

50. [ត្រូវបានលុបចោល]

51. [ត្រូវបានលុបចោល][53] [54] [55]

52. [ត្រូវបានលុបចោល][56]

---

[49] [ត្រូវបានលុបចោល]

[50] [ត្រូវបានលុបចោល]

[51] ធនាគារ ស្ថាបនា របាយការណ៍ប្រចាំឆ្នាំ២០២០ នៅ ៤៤ (២០២០) *មាននៅ* https://www.sathapana.com.kh/about- sathapana/about-us/annual-report/.

[52] [ត្រូវបានលុបចោល]

[53] [ត្រូវបានលុបចោល]

[54] [ត្រូវបានលុបចោល]

[55] [ត្រូវបានលុបចោល]

[56] [ត្រូវបានលុបចោល]

53. [ត្រូវបានលុបចោល]

54. [ត្រូវបានលុបចោល]

55. [ត្រូវបានលុបចោល][57] [58] [59] [60]

56. [ត្រូវបានលុបចោល][61] [62] [63] [64]

57. [ត្រូវបានលុបចោល][65]

58. [ត្រូវបានលុបចោល]

59. [ត្រូវបានលុបចោល]

60. [ត្រូវបានលុបចោល][66] [67] [68] [69] [70] [71] [72] [73]

61. [ត្រូវបានលុបចោល]

62. [ត្រូវបានលុបចោល]

63. [ត្រូវបានលុបចោល]

64. [ត្រូវបានលុបចោល]

65. [ត្រូវបានលុបចោល]

66. [ត្រូវបានលុបចោល]

---

[57] [ត្រូវបានលុបចោល]
[58] [ត្រូវបានលុបចោល]
[59] [ត្រូវបានលុបចោល]
[60] [ត្រូវបានលុបចោល]
[61] [ត្រូវបានលុបចោល]
[62] [ត្រូវបានលុបចោល]
[63] [ត្រូវបានលុបចោល]
[64] [ត្រូវបានលុបចោល]
[65] [ត្រូវបានលុបចោល]
[66] [ត្រូវបានលុបចោល]
[67] [ត្រូវបានលុបចោល]
[68] [ត្រូវបានលុបចោល]
[69] [ត្រូវបានលុបចោល]
[70] [ត្រូវបានលុបចោល]
[71] [ត្រូវបានលុបចោល]
[72] [ត្រូវបានលុបចោល]
[73] [ត្រូវបានលុបចោល]

67. [ត្រូវបានលុបចោល][74] [75] [76] [77] [78] [79]

68. [ត្រូវបានលុបចោល]

69. [ត្រូវបានលុបចោល]

70. [ត្រូវបានលុបចោល]

71. [ត្រូវបានលុបចោល][80] [81] [82] [83] [84] [85] [86] [87]

72. [ត្រូវបានលុបចោល]

73. [ត្រូវបានលុបចោល]

74. [ត្រូវបានលុបចោល][88] [89] [90] [91] [92] [93] [94] [95] [96] [97] [98]

75. [ត្រូវបានលុបចោល]

76. [ត្រូវបានលុបចោល]

77. [ត្រូវបានលុបចោល]

---

[74] [ត្រូវបានលុបចោល]
[75] [ត្រូវបានលុបចោល]
[76] [ត្រូវបានលុបចោល]
[77] [ត្រូវបានលុបចោល]
[78] [ត្រូវបានលុបចោល]
[79] [ត្រូវបានលុបចោល]
[80] [ត្រូវបានលុបចោល]
[81] [ត្រូវបានលុបចោល]
[82] [ត្រូវបានលុបចោល]
[83] [ត្រូវបានលុបចោល]
[84] [ត្រូវបានលុបចោល]
[85] [ត្រូវបានលុបចោល]
[86] [ត្រូវបានលុបចោល]
[87] [ត្រូវបានលុបចោល]
[88] [ត្រូវបានលុបចោល]
[89] [ត្រូវបានលុបចោល]
[90] [ត្រូវបានលុបចោល]
[91] [ត្រូវបានលុបចោល]
[92] [ត្រូវបានលុបចោល]
[93] [ត្រូវបានលុបចោល]
[94] [ត្រូវបានលុបចោល]
[95] [ត្រូវបានលុបចោល]
[96] [ត្រូវបានលុបចោល]
[97] [ត្រូវបានលុបចោល]
[98] [ត្រូវបានលុបចោល]

78. [ត្រូវបានលុបចោល][99] [100] [101] [102]

79. [ត្រូវបានលុបចោល][103]

80. [ត្រូវបានលុបចោល][104]

81. [ត្រូវបានលុបចោល][105] [106] [107]

82. [ត្រូវបានលុបចោល]

83. [ត្រូវបានលុបចោល]

84. [ត្រូវបានលុបចោល]

85. [ត្រូវបានលុបចោល]

86. [ត្រូវបានលុបចោល][108]

87. [ត្រូវបានលុបចោល]

## III. កង្វះខាតការត្រួតពិនិត្យរបស់ IFC បណ្តាលឲ្យការចាត់ថ្នាក់ហានិភ័យមិនបានត្រឹមត្រូវ និងការត្រួតពិនិត្យគម្រោងមិនបានគ្រប់គ្រាន់ ដែលនាំឱ្យមានផលប៉ះពាល់អវិជ្ជមានលើសង្គម

88. IFC បានបំពានកាតព្វកិច្ចរបស់ខ្លួន នៅក្រោមក្របខណ្ឌបរិស្ថាន និងសង្គមរបស់ខ្លួនផ្ទាល់ ក្នុងការអនុវត្តការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នមុនពេលអនុវត្តគម្រោង និងការត្រួតពិនិត្យគម្រោងរបស់អតិថិជន IFC ឱ្យបានគ្រប់គ្រាន់ ដោយខកខានមិនបានដោះស្រាយរបាយការណ៍ជាច្រើនឆ្នាំ រួមទាំងការសិក្សាដែលធ្វើឡើងដោយ IFC ទាក់ទងនឹងវិបត្តិមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងការខូចខាតដល់សង្គម ដែលពាក់ព័ន្ធ។ ដូច្នេះ គម្រោងផ្តល់កម្ចីខ្នាតមីក្រូរបស់ IFC ដែលមានរាយនាមនៅក្នុងផ្នែកទី I ទី II និងឧបសម្ព័ន្ធ ក បានបន្តគ្រោងការណ៍ផ្តល់កម្ចីបែបឃោឃៅជាបន្តបន្ទាប់ ដែលពន្លឿនការដកហូតដីធ្លីរបស់ប្រជាជនកម្ពុជាដែលងាយរងគ្រោះបំផុត រួមទាំងសហគមន៍ជនជាតិដើមភាគតិចផងដែរ។ កង្វះខាតការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន និងការត្រួតពិនិត្យគម្រោងមីក្រូហិរញ្ញវត្ថុរបស់ IFC ឲ្យបានគ្រប់គ្រាន់ បង្កលក្ខណៈឱ្យមានការខូចខាតដល់សង្គមដែលពាក់ព័ន្ធ ប្រឆាំងនឹងដើមបណ្តឹង និងសហគមន៍របស់ពួកគេ បន្តកើតឡើង

---

[99] [ត្រូវបានលុបចោល]

[100] [ត្រូវបានលុបចោល]

[101] [ត្រូវបានលុបចោល]

[102] [ត្រូវបានលុបចោល]

[103] [ត្រូវបានលុបចោល]

[104] [ត្រូវបានលុបចោល]

[105] [ត្រូវបានលុបចោល]

[106] [ត្រូវបានលុបចោល]

[107] [ត្រូវបានលុបចោល]

[108] [ត្រូវបានលុបចោល]

ដោយពុំមានការថយចុះនោះទេ ដែលផ្ទុយនឹងស្តង់ដារសមិទ្ធកម្មរបស់ IFC និងរំលោភលើបញ្ជីផាត់ចេញនៃសកម្មភាពហាមឃាត់។

89. ការវិនិយោគរបស់ IFC ដែលត្រូវបានដកស្រង់នៅក្នុងផ្នែកទី I និងឧបសម្ព័ន្ធ ក នៃពាក្យបណ្តឹងនេះ ត្រូវបានអនុម័ត ក្រោយថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ និងយោងតាមគោលនយោបាយស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម (គោលនយោបាយ E&S) ឆ្នាំ ២០១២ របស់ IFC ស្តង់ដារសមិទ្ធកម្មទាំងប្រាំបី (សម្រាប់ប្រតិបត្តិការដែលមានហានិភ័យខ្ពស់)[109] និងគោលនយោបាយស្តីពីសិទ្ធិទទួលបានព័ត៌មាន។ លើសពីនេះទៀត បញ្ជីផាត់ចេញរបស់ IFC (ឆ្នាំ២០០៧) ជាពិសេស បទប្បញ្ញត្តិទាក់ទងនឹងអន្តរការីហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនឹងមីក្រូហិរញ្ញវត្ថុ អនុវត្តចំពោះរាល់គម្រោងរបស់ IFC និងហាមឃាត់សកម្មភាព ដែលពាក់ព័ន្ធនឹងពលកម្មកុមារដែលការខូចខាត និងសកម្មភាពដែលប៉ះពាល់ដល់ដីធ្លីជនជាតិដើមភាគតិច ដោយគ្មានការយល់ព្រមពេញលេញជាលាយលក្ខណ៍អក្សរពីពួកគេ។ គោលនយោបាយ E&S កំណត់ការប្តេជ្ញាចិត្តរបស់ IFC នៅក្នុងគម្រោង នៅខណៈពេលដែលស្តង់ដារសមិទ្ធកម្មបង្កើតទំនួលខុសត្រូវរបស់អតិថិជន។ ក្របខណ្ឌនិរន្តរភាពរបស់ IFC ត្រូវបានបង្កើតឡើងដើម្បីជានា និងកែលម្អធាតុចេញផ្នែកបរិស្ថាន និងសង្គមនៃគម្រោង IFC[110] និងដោយពិចារណាលើគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស។

90. អន្តរការីហិរញ្ញវត្ថុ ដូចជា អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC[111] ត្រូវបានតម្រូវឱ្យបង្កើត និងដំណើរការប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) ដែលមានសង្គតិភាពនឹងស្តង់ដារសមិទ្ធកម្មទី១ និងសមស្របតាមកម្រិតនៃហានិភ័យផ្នែកបរិស្ថាន និងសង្គម នៅក្នុងផលប័ត្ររបស់ខ្លួន និងសកម្មភាពអាជីវកម្មនាពេលអនាគត។[112] បន្ទាប់មក អតិថិជននៃអន្តរការីហិរញ្ញវត្ថុ ត្រូវបានតម្រូវឲ្យកំណត់ ជៀសវាង ឬកាត់បន្ថយ និងពិនិត្យតាមដានហានិភ័យផ្នែកបរិស្ថាន និងសង្គម (E&S) ដែលពាក់ព័ន្ធនឹងគម្រោង IFC។[113] អន្តរការីហិរញ្ញវត្ថុ ដូចជា អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC តាមធម្មតា ត្រូវបានចាត់ថ្នាក់ជា FI-២ (ដែលបង្ហាញអំពីហានិភ័យផ្នែកបរិស្ថាន ឬសង្គមនៅកម្រិតមធ្យម) និងត្រូវបានតម្រូវឱ្យអនុវត្តលក្ខខណ្ឌតម្រូវដែលពាក់ព័ន្ធនៃស្តង់ដារសមិទ្ធកម្ម ២ ដល់ ៧[114] ចំពោះប្រតិបត្តិការ ដែលមានហានិភ័យខ្ពស់តែប៉ុណ្ណោះ។[115]

91. មានតម្លាភាពដែលមានកម្រិត ទាក់ទងនឹងកិច្ចព្រមព្រៀង និងការត្រួតពិនិត្យការវិនិយោគរបស់ IFC ESMS របស់អតិថិជនអន្តរការីហិរញ្ញវត្ថុរបស់ IFC និងការពិនិត្យតាមដាន និងរាយការណ៍របស់អតិថិជន

---

[109] IFC គោលនយោបាយស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម (ឆ្នាំ២០១២) នៅកថាខណ្ឌទី ៣៥ [តទៅនេះគឺ គោលនយោបាយ E&S របស់ IFC]។

[110] *Id.* នៅកថាខណ្ឌ ១–២, ៦–១២។

[111] *សូមមើល* IFC កត់សម្គាល់ការបកស្រាយអំពីអន្តរការីហិរញ្ញវត្ថុ (ឆ្នាំ២០១២ កំណែ ខែវិច្ឆិកា ឆ្នាំ២០១៨) នៅកថាខណ្ឌ IN១ [តទៅ ហៅថា កំណត់សម្គាល់ការបកស្រាយរបស់ FI]។

[112] គោលនយោបាយ E&S របស់ IFC កំណត់សម្គាល់ខាងលើទី ១០៩ នៅកថាខណ្ឌ ៣៧; កំណត់សម្គាល់ការបកស្រាយរបស់ FI កំណត់សម្គាល់ខាងលើទី ១១១ នៅកថាខណ្ឌ IN៣៣, IN៣៥។

[113] *Id.*

[114] ស្តង់ដារសមិទ្ធកម្មទី១ បន្តអនុវត្តចំពោះអន្តរការីហិរញ្ញវត្ថុ ដែលវាបង្កើតលក្ខខណ្ឌតម្រូវអប្បបរមាសម្រាប់ ESMS។

[115] *សូមមើល* គោលនយោបាយ E&S របស់ IFC កំណត់សម្គាល់ខាងលើទី ១០៩ នៅកថាខណ្ឌ ៣, ៣៥; កំណត់សម្គាល់ការបកស្រាយរបស់ FI កំណត់សម្គាល់ខាងលើទី ១១១ នៅកថាខណ្ឌ IN១០, IN១២, IN១៣។

ទាំងនោះ ដោយសារឯកសារនេះមិនមែនជាអ្វីដែលសាធារណជនដឹងច្បាស់បំផុតនោះទេ។ ព័ត៌មាន និងបណ្តុំទិន្នន័យអំពីគម្រោងតាមអនឡាញរបស់ IFC ផ្តល់ជូននូវសេចក្តីសង្ខេបអំពីព័ត៌មានមួយចំនួន ប៉ុន្តែមិនផ្តល់ជូនព័ត៌មានដទៃទៀតទេ – ជាពិសេសការខកខានក្នុងការបង្ហាញព័ត៌មានមួយចំនួន ដែលអាចមានសារសំខាន់ក្នុងការកំណត់ភាពអនុលោមរបស់ IFC តាមបញ្ញត្តិនៃគោលនយោបាយរបស់ខ្លួន។ កង្វះតម្លាភាពនេះបង្កើតបានជាឧបសគ្គដែលមិនចាំបាច់ដល់ដើមបណ្តឹង ដែលមានសក្តានុពល ហើយវាផ្ទុយពីចេតនា និងគោលការណ៍នៃគោលនយោបាយស្តីពីលទ្ធភាពទទួលបានព័ត៌មានរបស់ IFC។[116] បញ្ហាប្រឈមទាំងនេះត្រូវបានសម្គាល់ឃើញ និងដោះស្រាយដោយក្រុមត្រួតពិនិត្យឡើងវិញពីខាងក្រៅ របស់ IFC និងអ្នកជំនាញផ្នែកវិនិយោគហិរញ្ញវត្ថុ ដែលរៀបចំឡើងជាពិសេស ដើម្បីត្រួតពិនិត្យឡើងវិញលើគណនេយ្យភាព E&S របស់ IFC និងតួនាទីរបស់ស៊ីអេអូនៅក្នុងករណីនេះ។[117] ក្រុមត្រួតពិនិត្យឡើងវិញពីខាងក្រៅ បានកត់សម្គាល់ជាពិសេសអំពីរបៀបដែលកំណើនការវិនិយោគនៅក្នុងអន្តរការីហិរញ្ញវត្ថុបានបង្ហាញអំពីបញ្ហាប្រឈមសម្រាប់ស៊ីអេអូ ក្នុងការកំណត់សិទ្ធិទទួលបានចំពោះពាក្យបណ្តឹងដែលទាក់ទងនឹងអតិថិជនអន្តរការីហិរញ្ញវត្ថុ និងបានផ្តល់អនុសាសន៍ឱ្យ IFC បង្កើនតម្លាភាពនៃផលប័ត្រ ដែលផ្តល់មូលនិធិដោយ IFC និងអនុគម្រោងនានា។[118]

92. IFC ត្រូវបានតម្រូវឱ្យធ្វើការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នយ៉ាងទូលំទូលាយមុនពេលអនុម័តគម្រោង រួមទាំងការកំណត់ប្រភេទហានិភ័យផ្នែកបរិស្ថាន និងសង្គមនៃគម្រោងផងដែរ ដើម្បី "បង្ហាញអំពីទំហំនៃហានិភ័យ និងផលប៉ះពាល់ដែលអាចកើតមាន"។[119] ចំណាត់ថ្នាក់បរិស្ថាន និងសង្គមគួរតែឆ្លុះបញ្ចាំងអំពីកម្រិតនៃហានិភ័យ និងផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម លក្ខខណ្ឌតម្រូវសម្រាប់ការបង្ហាញ ស្របតាមគោលនយោបាយស្តីពីសិទ្ធិទទួលបានព័ត៌មានរបស់ IFC និងចំណាត់ថ្នាក់ហានិភ័យខុសៗគ្នាសម្រាប់ការវិនិយោគនៅក្នុងអន្តរការីហិរញ្ញវត្ថុ (ផ្អែកលើមាត្រដ្ឋានហានិភ័យពីកម្រិតខ្ពស់ទៅកម្រិតទាបពី FI-១ ទៅ FI-៣) ដោយផ្អែកលើលក្ខណៈទូទៅ ទំហំ និងប្រភេទការវិនិយោគ ព្រមទាំងផលប៉ះពាល់តាមវិស័យ ដូចជា ហានិភ័យផ្នែកបរិស្ថាន និងសង្គម ជាដើម។[120] ចំពោះការវិនិយោគលើអន្តរការីហិរញ្ញវត្ថុ IFC កំណត់ប្រភេទហានិភ័យ ដោយផ្អែកលើហានិភ័យផ្នែកបរិស្ថាន និងសង្គម ដែលទាក់ទងនឹងការប្រើប្រាស់ចុងក្រោយ ដែលត្រូវបានបញ្ជាក់ ដូចជា ការផ្តល់កម្ចីខ្នាតមីក្រូ ជាដើម។[121] ចំពោះប្រតិបត្តិការដែលមានស្រាប់ នេះនឹងរួមបញ្ចូលផលប៉ះពាល់នៃប្រតិបត្តិការ ដែលខ្លួនបានដឹង។[122]

93. ការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នមុនពេលអនុវត្តគម្រោង ដែលត្រូវបានតម្រូវ របស់ IFC ក៏រួមបញ្ចូលការពិនិត្យឡើងវិញលើ ESMS របស់អតិថិជន សមត្ថភាពអនុវត្ត និងចន្លោះប្រហោងនៅសមិទ្ធកម្ម ធៀបនឹង

---

[116] សូមមើល IFC គោលនយោបាយស្តីពីលទ្ធភាពទទួលបានព័ត៌មាន (ឆ្នាំ២០១២) នៅ ១–២, ៦–៨, ១៣។

[117] ការត្រួតពិនិត្យពីខាងក្រៅលើគណនេយ្យភាព E&S របស់ IFC/MIGA រួមទាំងតួនាទី និងប្រសិទ្ធភាពរបស់ស៊ីអេអូះ របាយការណ៍ និងអនុសាសន៍ ខែមិថុនា ឆ្នាំ២០២០ នៅកថាខណ្ឌ ២៧ [តទៅ ហៅថា ការត្រួតពិនិត្យពីខាងក្រៅរបស់ IFC]។

[118] *Id.*

[119] គោលនយោបាយ E&S របស់ IFC កំណត់សម្គាល់ខាងលើទី ១០៩ នៅកថាខណ្ឌ ៣៤; IFC កំណត់សម្គាល់នៃការបកស្រាយអំពីការចាត់ថ្នាក់បរិស្ថាន និងសង្គម (២០១២) នៅកថាខណ្ឌ IN៦ [តទៅ ហៅថា កំណត់សម្គាល់របស់ IFC ស្តីពីការចាត់ថ្នាក់ E&S]។

[120] IFC គោលនយោបាយស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម នៅកថាខណ្ឌ ៤០ ៤២ និង ក.៩ ៤៤។

[121] *Id.* នៅកថាខណ្ឌ ៤៤។

[122] *Id.* នៅកថាខណ្ឌ ៤២។

លក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធកម្មផងដែរ។[123] ការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នត្រូវតែសមស្របតាមលក្ខណៈ មាត្រដ្ឋាន និងដំណាក់កាលនៃសកម្មភាពអាជីវកម្ម និងរួមបញ្ចូលមួយផ្នែកនៃ "ការត្រួតពិនិត្យឡើងវិញលើព័ត៌មានដែលមានទាំងអស់ កំណត់ត្រា និងឯកសារ ទាក់ទងនឹង...ហានិភ័យសង្គម និងផលប៉ះពាល់នៃសកម្មភាពអាជីវកម្ម"។[124] លើសពីនេះទៀត ការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នអាចត្រូវបានពង្រីកបន្ថែម ដើម្បីគ្របដណ្តប់លើសកម្មភាពអាជីវកម្មដទៃទៀត ដែលជាផ្នែកមួយនៃការពិចារណាលើការគ្រប់គ្រងហានិភ័យរបស់ IFC។[125] ប្រសិនបើមានផលប៉ះពាល់សង្គមសំខាន់ៗ ទាក់ទងនឹងសកម្មភាពអាជីវកម្ម រួមទាំងផលប៉ះពាល់អវិជ្ជមានពីអតីតកាល ឬបច្ចុប្បន្ន ដែលបណ្តាលមកពីអ្នកដទៃទៀតផងដែរ IFC មានកាតព្វកិច្ចធ្វើការជាមួយអតិថិជនរបស់ IFC ដើម្បីកំណត់វិធានការដោះស្រាយដែលអាចអនុវត្តបាន។[126] IFC ត្រូវបានតម្រូវបន្ថែមទៀត ឱ្យកំណត់សកម្មភាពបំពេញបន្ថែមណាមួយ ដើម្បីធានាថាសកម្មភាពអាជីវកម្មបំពេញតាមស្តង់ដារសមិទ្ធកម្ម ដែលជាលក្ខខណ្ឌចាំបាច់នៃការវិនិយោគ ឬបដិសេធការវិនិយោគថ្មីៗ ជាមួយអតិថិជនដែលមានស្រាប់ ដែលមានសមិទ្ធកម្មមានផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម តិចជាងសេចក្តីពេញចិត្ត។[127]

94. IFC ត្រូវបានតម្រូវបន្ថែមទៀតឲ្យត្រួតពិនិត្យអតិថិជនអន្តរការីហិរញ្ញវត្ថុតាមរយៈការត្រួតពិនិត្យការអនុវត្ត ESMS របស់ពួកគេ ក្នុងអំឡុងពេលអនុវត្តគម្រោង។[128]

### ក. ទិដ្ឋភាពទូទៅនៃការខូចខាតផ្នែកសង្គម ដែលបណ្តាលមកពីគម្រោងរបស់ IFC នៅក្នុងវិស័យដែលមានហានិភ័យខ្ពស់

95. ដើមបណ្តឹងគឺជាជនរងគ្រោះនៃការផ្តល់កម្ចីដ៏ឃោរឃៅ និងការអនុវត្តផ្តល់កម្ចីបោកប្រាស់ ក្នុងលក្ខណៈជាផ្នែកមួយនៃអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC ។ មនុស្សជាច្រើនត្រូវបានបង្ខិតបង្ខំ និងគំរាមកំហែងឲ្យលក់ដីធ្លីរបស់ពួកគេ និង/ឬទទួលយកកម្ចីបន្ថែម ដើម្បីសងកម្ចីរបស់ពួកគេ។ វិធីសាស្ត្រទាំងនេះមានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងដល់ដើមបណ្តឹង រួមទាំងអសន្តិសុខស្បៀងអាហារ ពលកម្មកុមារ ការធ្វើចំណាកស្រុកដោយបង្ខំ ការកើនឡើងនៃបំណុល ការបាត់បង់ដីធ្លីជនជាតិដើមភាគតិច និងការបាត់បង់មុខរបរចិញ្ចឹមជីវិត ដែលផ្ទុយពីស្តង់ដារសមិទ្ធកម្ម និងបញ្ជីផាត់ចេញរបស់ IFC និងការដកហូតពីដើមបណ្តឹងនូវសិទ្ធិមនុស្សកម្រិតមូលដ្ឋានបំផុតរបស់ពួកគេ។ ដូច្នេះ ការវិនិយោគលើគម្រោងម្តងហើយម្តងទៀតរបស់ IFC ជាមួយអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC ដើម្បីគាំទ្រដល់វិស័យមីក្រូហិរញ្ញវត្ថុ មានទំនាក់ទំនងនឹងកម្រៃជើងសារ និងការបន្តការរំលោភបំពានទាំងនេះ។ ទំនាក់ទំនងរវាងគម្រោងរបស់ IFC និងការខូចខាតផ្នែកសង្គម ដែលទទួលរងដោយដើមបណ្តឹង បង្កើតបានជាសិទ្ធិអំណាចរបស់ស៊ីអេអូ ក្នុងការស៊ើបអង្កេតលើបញ្ហានៅក្នុងពាក្យបណ្តឹងនេះ។

---

[123] *Id.* នៅកថាខណ្ឌ ១២ ២៥-២៨ ៣៤.

[124] គោលនយោបាយ E&S របស់ IFC កំណត់សម្គាល់ខាងលើ ទី ១០៩ នៅកថាខណ្ឌ ១២ ២៨ ៣៥.

[125] *Id.* នៅកថាខណ្ឌ ២៦.

[126] *Id.* នៅកថាខណ្ឌ ២៦.

[127] គោលនយោបាយ E&S របស់ IFC កំណត់សម្គាល់ខាងលើទី ១០៩ នៅកថាខណ្ឌ ២៨; កំណត់សម្គាល់អំពីការបកស្រាយរបស់ FI កំណត់សម្គាល់ខាងលើ ទី ១១១ នៅកថាខណ្ឌ IN៤.

[128] គោលនយោបាយ E&S របស់ IFC កំណត់សម្គាល់ខាងលើទី ១០៩ នៅកថាខណ្ឌ ៤៦.

96. ការអនុវត្តដោយបំពានគឺជារឿងធម្មតានៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា និងតំណាងឱ្យបទ-ពិសោធន៍របស់អ្នកខ្ចីប្រាក់ជាច្រើននាក់។[129] ដូចត្រូវបានចងក្រងជាឯកសារបានយ៉ាងល្អ អស់រយៈពេលជាច្រើនឆ្នាំ ការរួមបញ្ចូលគ្នានៃការជ្រៀតចូលទីផ្សារកម្រិតខ្ពស់ តិត្ថិភាពកម្រិតខ្ពស់ កង្វះខាតការការពារអ្នកប្រើប្រាស់ និងការអនុវត្តច្បាប់ដែលមានស្រាប់នៅថ្នាក់ជាតិ មិនបានគ្រប់គ្រាន់ បានជំរុញបន្ថែមនូវយុទ្ធសាស្ត្រដែលមានការឈ្លានពាន និងឃោរឃៅ ដោយ MFI និងមន្ត្រីឥណទានរបស់ធនាគារ។[130] មន្ត្រីឥណទាន ជាញឹកញាប់ បើកឡានចូលទៅក្នុងភូមិ និងស្វែងរកអតិថិជន ដោយផ្តល់ជូនពួកគេនូវកម្ចី MSME កាន់តែច្រើនឡើងៗ ដើម្បី "សង" កម្ចីដែលមានស្រាប់ ដោយពុំមានការវាយតម្លៃប្រាក់ចំណូល ឬសមត្ថភាពរបស់អ្នកខ្ចីក្នុងការសងកម្ចីនោះទេ។[131] មន្ត្រីឥណទានចាប់អារម្មណ៍លើការធានាប័ណ្ណកម្មសិទ្ធដីធ្លីរបស់អ្នកខ្ចីជាវត្ថុបញ្ចាំច្រើនជាង – ត្រូវបានតម្រូវជាប្រចាំ ដើម្បីឱ្យអ្នកខ្ចីទទួលបានកម្ចី។ ទាក់ទងនឹងគោលនយោបាយ អ្នកផ្តល់កម្ចីនៅក្នុងប្រទេសកម្ពុជាតែងតែទម្លាក់តម្លៃដីធ្លីដែលប្រើជាវត្ថុបញ្ចាំ ដើម្បីធានាថាតម្លៃវត្ថុបញ្ចាំលើសពីតម្លៃនៃប្រាក់កម្ចី ហើយស្ថាប័នកាន់កាប់ និងបន្តកាន់កាប់បណ្ណកម្មសិទ្ធិដីធ្លីរបស់អ្នកខ្ចី។ អ្នកខ្ចីរងគ្រោះតាមរយៈការខូចខាតផ្នែកសង្គមជាបន្តបន្ទាប់ ក្នុងការប៉ុនប៉ងសងកម្ចីដែលមិនមាននិរន្តរភាព រួមទាំងការបរិភោគអាហារតិច និងមានគុណភាពមិនល្អ និងការបញ្ឈប់កុមារពីសាលារៀន ហើយបញ្ជូនពួកគេទៅធ្វើការ។ នៅពេលអ្នកខ្ចីខកខានមិនបានបង់ប្រាក់សូម្បីតែពីរបីថ្ងៃ មន្ត្រីឥណទានប្រើយុទ្ធសាស្ត្រក្រៅប្រព័ន្ធតុលាការ និងមានការបង្ខិតបង្ខំ រួមទាំងការបៀតបៀនអ្នកខ្ចីនៅផ្ទះ និងគំរាមកោះហៅអ្នកខ្ចីនៅចំពោះមុខអាជ្ញាធរមូលដ្ឋាន ដើម្បីបង្ខំអ្នកខ្ចីឱ្យលក់ដីធ្លីរបស់ពួកគេមុនពេលកំណត់ នៅក្រៅដំណើរការផ្លូវច្បាប់ជាផ្លូវការ ដែល MFIs និងធនាគារ យល់ថា មានតម្លៃថ្លៃ និងមានភាពយឺតយ៉ាងក្នុងការដំណើរការ។ ប្រជាជនកម្ពុជាមួយលាននាក់ រួមទាំងជនជាតិដើមភាគតិចផងដែរ បានក្លាយជាគ្មានដីធ្លីក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ នៅខណៈពេលដែលបំណុលជាមធ្យមបានកើនឡើង ៨៥ ភាគរយ។[132] នៅខែមករា ឆ្នាំ២០២០ អ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិស្តីពីផលប៉ះពាល់នៃបំណុលបរទេសលើសិទ្ធិមនុស្ស បានទទួលស្គាល់ផលប៉ះពាល់សង្គមអវិជ្ជមាន ដែលបណ្តាលមកពីគម្រោងកម្ចីខ្នាតមីក្រូដ៏ឃោរឃៅ ដោយកត់សម្គាល់ថា "បំណុលឯកជនអាចជាបុព្វហេតុ និងជាផលវិបាកនៃការរំលោភសិទ្ធិមនុស្ស"។[133]

97. នៅក្នុងការត្រួតពិនិត្យ ឆ្នាំ២០១៥ របស់ខ្លួន លើក្របខណ្ឌការពារអ្នកប្រើប្រាស់នៅកម្ពុជាសម្រាប់ទីផ្សារ

---

[129] អង្គការលីកាដូ និងអ្នកដទៃទៀត សិទ្ធិទទួលបានការជួយសង្គ្រោះ កំណត់សម្គាល់ខាងលើ ទី៨ នៅ ២.

[130] *សូមមើល* IFC ការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា នៅ ២៩-៣៣ (ឆ្នាំ២០១៥).

[131] *សូមមើល* មជ្ឈមណ្ឌលមីក្រូហិរញ្ញវត្ថុ អង្គការ GOOD RETURN និងអ្នកដទៃទៀត។ ការសិក្សាអំពីការជំពាក់បំណុលច្រើនពេកនៅកម្ពុជា II៖ របាយការណ៍ចុងក្រោយ នៅ ៦២ (ខែតុលា ឆ្នាំ២០១៧) [តទៅ ហៅថា ការសិក្សា OID នៅកម្ពុជា II]; Microfinance Index of Market Outreach & Saturation (MIMOSA) កម្ពុជា៖ ទំហំនៃការខ្ចីប្រាក់ និងកម្ចីជាច្រើន នៅ ២-៣ (ខែមិថុនា ឆ្នាំ២០១៦) [តទៅ ហៅថា សារាចរពិសេស ឆ្នាំ២០១៦ របស់ MIMOSA].

[132] Tran Techseng និង Michael Dickison VOD ការបាត់បង់ដីធ្លី កំណត់ត្រាអំពីការកើនឡើងនៃបំណុលនៅក្នុងការស្ទង់មតិសេដ្ឋកិច្ចសង្គមចុងក្រោយបង្អស់ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ https://vodenglish.news/land-loss-debt-rise-recorded-in-latest-socio-economic-survey/ (ដកស្រង់ការស្ទង់មតិសេដ្ឋកិច្ចសង្គមកម្ពុជានៃវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការនៃប្រទេសកម្ពុជា សម្រាប់ឆ្នាំ២០១៩-២០២០).

[133] របាយការណ៍អ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិស្តីពីបំណុលបរទេស និងសិទ្ធិមនុស្ស កំណត់សម្គាល់ខាងលើ លេខ ៤ នៅក្នុងសេចក្តីសង្ខេប។

ហិរញ្ញវត្ថុ IFC បានសង្កេតឃើញហានិភ័យអ្នកប្រើប្រាស់សំខាន់ៗជាច្រើននៅក្នុងវិស័យហិរញ្ញវត្ថុ រួមមានការជំពាក់បំណុលច្រើនពេក លក្ខខណ្ឌទីផ្សារដែលមានការឈ្លានពាន ការផ្តល់ប្រាក់លើកទឹកចិត្តដល់មន្ត្រីឥណទាន ដែលជះឥទ្ធិពលអវិជ្ជមានដល់អ្នកខ្ចី ដោយលើកទឹកចិត្តដល់ការផ្តល់កម្ចីដែលមានការឈ្លានពាន ទោះបីជាមានបញ្ហា "ភាពសមស្រប និងលទ្ធភាពក្នុងការទូទាត់" ក៏ដោយ កង្វះខាតស្តង់ដារទូលំទូលាយនៃវិស័យជាអប្បបរមា សម្រាប់ "ការពិតក្នុងការផ្តល់កម្ចី" និងការអនុវត្តការលក់ ដែលជំរុញឱ្យមាន "ការបន្ទាបភាពប្រកួតប្រជែង ពាក់ព័ន្ធនឹងនៃអាកប្បកិរិយាប្រកបដោយសីលធម៌" កង្វះខាតយន្តការសម្រាប់វិវាទអ្នកប្រើប្រាស់ផ្ទៃក្នុង និងខាងក្រៅ កង្វះខាតការពិនិត្យតាមដាន និងការរាយការណ៍អំពីពាក្យបណ្តឹងរបស់អ្នកប្រើប្រាស់ សក្តានុពលសម្រាប់ការអនុវត្តការផ្តល់កម្ចីមិនសមរម្យ និងដោយបង្ខំ និងសក្តានុពលសម្រាប់ការផ្តល់កម្ចីដ៏ឃោរឃៅ ជាពិសេស ដែលអ្នកផ្តល់កម្ចីដោយគ្មានសតិសម្បជញ្ញៈដឹងថាមានលទ្ធភាពខ្ពស់នៃការពន្យាពេល ដែលអាចធ្វើឱ្យអ្នកផ្តល់កម្ចីអាចកាន់កាប់វត្ថុបញ្ចាំដ៏មានតម្លៃ ដែលមានតម្លៃខ្ពស់ជាងចំនួនទឹកប្រាក់កម្ចី។[134] របាយការណ៍នេះបានសន្និដ្ឋានថា គ្រប់វិស័យទាំងអស់ "នឹងទទួលបានអត្ថប្រយោជន៍ពីការអនុម័តជាឯកតោភាគីលើស្តង់ដារកិច្ចការពារអ្នកប្រើប្រាស់ ជាពិសេសនៅក្នុងផ្នែកការបង្ហាញ ការដោះស្រាយវិវាទ និងការពិនិត្យតាមដានការប្រព្រឹត្តិទៅរបស់ទីផ្សារ"។

98. ដូចបានពិភាក្សានៅក្នុងផ្នែកខាងក្រោម ទំហំ និងប្រភេទការខូចខាត ដែលដើមបណ្តឹងបានជួបប្រទះនិយាយម៉្យាងទៀត គឺអាចទស្សន៍ទាយបានទាំងស្រុង។ វិស័យមីក្រូហិរញ្ញវត្ថុ និងការផ្តល់កម្ចី MSME នៅកម្ពុជា បង្ហាញអំពីហានិភ័យសង្គមសំខាន់ៗ ដែលមានស្រាប់ ចំពោះបុគ្គល និងសហគមន៍ដែលងាយរងគ្រោះ។

**ការវិភាគអំពីការខកខានរបស់ IFC ក្នុងការអនុវត្តការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នឲ្យបានគ្រប់គ្រាន់ ដែលបណ្តាលឱ្យមានការចាត់ថ្នាក់ហានិភ័យទាបនៃសកម្មភាពមីក្រូហិរញ្ញវត្ថុ និង MSME របស់ខ្លួន នៅក្នុងប្រទេសកម្ពុជា មិនបានសមស្រប**

99. [ត្រូវបានលុបចោល][135] [136]

100. លើសពីនេះទៀត ទិន្នន័យរបស់ធនាគារពិភពលោក ធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិបង្ហាញថា ក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ អ្នកផ្តល់កម្ចីខ្នាតមីក្រូ ដែលបានទទួលការគាំទ្រដោយផ្ទាល់ពី IFC បានបង្កើនផលប័ត្រកម្ចីរបស់ពួកគេ ក្នុងអត្រាខ្ពស់ជាង GDP សម្រាប់មនុស្សម្នាក់ ឬការកើនឡើងនៃប្រាក់ចំណូលគ្រួសារជាមធ្យម។ នេះបាននាំឲ្យមានវិបត្តិ ដែលកម្ពុជាកំពុងជួបប្រទះនៅពេលនេះ ដែលទំហំកម្ចីខ្នាតមីក្រូជាមធ្យមមានទំហំធំជាងប្រាក់ចំណូលប្រចាំឆ្នាំ ឬប្រាក់ចំណូលជាមធ្យម ច្រើនដង។

---

[134] IFC ការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា កំណត់សម្គាល់ខាងលើទី ១៣០ នៅ ២៩-៣៣.

[135] [ត្រូវបានលុបចោល]

[136] [ត្រូវបានលុបចោល]




*ទិន្នន័យអំពី GDP ក្នុងមនុស្សមួយនាក់ពីធនាគារពិភពលោក។ ទិន្នន័យអំពីប្រាក់ចំណូលជាមធ្យមពីការស្ទង់មតិសេដ្ឋកិច្ចសង្គមកម្ពុជា។ ទិន្នន័យអំពីផលបត្រពីធនាគារជាតិកម្ពុជា។*

101. ការវិនិយោគរបស់ IFC ដែលត្រូវបានកំណត់នៅក្នុងផ្នែកទី I ស្ទើរតែទាំងអស់ ត្រូវបានចាត់ថ្នាក់ជា FI-២ ក្រោមហេតុផលថា "មានភាពទំនងនៅកម្រិតទាប ដែលអ្នកខ្ចីបន្តនឹងប្រឈមនឹងហានិភ័យ និងផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គមសំខាន់ៗ លើសុខភាព និងសុវត្ថិភាពរបស់សហគមន៍ សុខភាព និងសុវត្ថិភាពការងារ បរិស្ថាន ជនជាតិដើមភាគតិច ជីវចម្រុះ ឬកេរ្តិ៍តំណែលវប្បធម៌ ក៏ដូចជាការចូលរួមនៅក្នុងការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត ដើម្បីទទួលបានជំនួយពីប្រាក់ចំណូលនៃកម្ចីនេះ"។[137] ដូច្នេះ អតិថិជន IFC ទាំងនោះ គ្រាន់តែត្រូវបានតម្រូវឱ្យអនុវត្តស្តង់ដារសមិទ្ធកម្មចំពោះប្រតិបត្តិការដែលមានហានិភ័យខ្ពស់ ដូចបានកំណត់ដោយអតិថិជន IFC តែប៉ុណ្ណោះ។[138]

102. ការចាត់ថ្នាក់ម្តងហើយម្តងទៀតនៃកម្ចីរបស់ IFC ដែលផ្តល់ជូនគ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជា ក្នុងគោលបំណងធ្វើសកម្មភាពផ្នែកមីក្រូហិរញ្ញវត្ថុ និងផ្តល់កម្ចីដល់ SME ថាមាន "ហានិភ័យទាប" បង្ហាញអំពីភាពបរាជ័យយ៉ាងខ្លាំង និងមហន្តរាយនៃការអនុវត្តការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នឱ្យបានគ្រប់គ្រាន់លើហានិភ័យសង្គម ដែលពាក់ព័ន្ធ និង ESMS របស់អតិថិជន IFC ដែលជាផ្នែកមួយនៃដំណើរការត្រួតពិនិត្យមុនពេលអនុវត្តគម្រោង ផ្ទុយពីគោលនយោបាយ និងនីតិវិធីរបស់ IFC ផ្ទាល់។ ការចាត់ថ្នាក់ហានិភ័យរបស់ IFC ពុំមានសង្គតិភាពនឹងការស្រាវជ្រាវដ៏សន្ធឹកសន្ធាប់ពីប្រភពអន្តរជាតិសាធារណៈ និងឯកជនក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ រួមទាំងការស្រាវជ្រាវនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងរបាយការណ៍ដែលធ្វើឡើងដោយ IFC ដោយផ្ទាល់ផងដែរ។

a) នៅខែមិថុនា ២០១៦ អង្គការសន្ទស្សន៍មីក្រូហិរញ្ញវត្ថុនៃការផ្សព្វផ្សាយ និងតិត្ថិភាពទីផ្សារ

---

[137] *សូមមើល ឧ.* ព័ត៌មាន និងបណ្តុំទិន្នន័យអំពីគម្រោងរបស់ IFC គម្រោងលេខ ៤២៤៨0 សេចក្តីសង្ខេបអំពីព័ត៌មាននៃការវិនិយោគ (SII) ភាពសមហេតុផលនៃការចាត់ថ្នាក់ផ្នែកបរិស្ថាន និងសង្គម https://disclosures.ifc.org/project-detail/SII/42480/acleda-subdebt-3.

[138] សូមមើល *id.*

(MIMOSA) បានបោះពុម្ពសារាចរពិសេសមួយស្តីពីទំហំការខ្ចី និងកម្ចីជាច្រើននៅក្នុងប្រទេសកម្ពុជា។ MIMOSA បានរាយការណ៍ថា ចាប់ពីឆ្នាំ២០០៤ ដល់ ឆ្នាំ២០១៤ ទំហំកម្ចីនៅក្នុងប្រទេសកម្ពុជាបានកើនឡើងលឿនជាងប្រាក់ចំណូលរបស់អ្នកខ្ចីបួនដង ហើយទំហំកម្ចីមានចំនួនច្រើនជាងកម្ចីនៅក្នុងប្រទេសដទៃទៀតយ៉ាងខ្លាំង។ សារាចរនេះបានកត់សម្គាល់បន្ថែមទៀតថា ការកើនឡើងនៃទំហំកម្ចីមានទំនាក់ទំនងទៅវិញទៅមកនឹងការជ្រៀតចូលនៃប្រាក់កម្ចីដែលមានកម្រិតខ្ពស់ និងទំនងជាត្រូវបានជំរុញមួយផ្នែកដោយ MFIs ដែលផ្តល់កម្ចីដល់អ្នកខ្ចីក្នុងទឹកប្រាក់កាន់តែច្រើន ក្នុងបំណង "សង" កម្ចីដែលមានស្រាប់។[139] MIMOSA បានធ្វើសេចក្តីសន្និដ្ឋាននៅក្នុងឆ្នាំ២០១៦ ថា ការជំពាក់បំណុលច្រើនពេកអាចកើតឡើងយ៉ាងខ្លាំងក្លា នៅក្នុងទីផ្សារមីក្រូហិរញ្ញវត្ថុកម្ពុជា។[140] ទោះបីជាយ៉ាងនេះក្តី នៅចន្លោះឆ្នាំ២០១៦ ដល់ ឆ្នាំ២០២១ IFC បានអនុម័តលើគម្រោងយ៉ាងតិច ១៦ គម្រោង ដល់អ្នកផ្តល់កម្ចីខ្នាតមីក្រូនៅកម្ពុជា ដែលមានចំនួនសរុបជាង ៤៣៨ លានដុល្លារអាមេរិក។

b) អ្នកសិក្សាជាច្រើននាក់បានបោះពុម្ពអត្ថបទអស់រយៈពេលជាច្រើនឆ្នាំ ដែលជូនដំណឹងជាមុនថា MFIs កំពុងឈានទៅរកការដកហូតដីធ្លីពីជនក្រីក្រ។[141] អ្នកសិក្សាដ៏លេចធ្លោម្នាក់ផ្នែកវិបត្តិមីក្រូឥណទាន លោក Milford Bateman ត្រូវបានអញ្ជើញឱ្យចូលរួមធ្វើបទបង្ហាញអំពីឯកសារស្តីពីការផ្តល់ប័ណ្ណកម្មសិទ្ធដីធ្លី និងមីក្រូឥណទាននៅកម្ពុជា នៅក្នុងសន្និសីទធនាគារពិភពលោក ឆ្នាំ២០២០ ស្តីពីដីធ្លី និងភាពក្រីក្រ ដែលបានកត់ត្រាលម្អិតអំពីកំណើននៃការផ្តល់កម្ចីដោយគ្មានភាពកោតក្រែង និងបានសន្និដ្ឋានថា "លក្ខខណ្ឌប្រកួតប្រជែងយ៉ាងខ្លាំងនៅកម្ពុជា" បានបង្កការខូចខាតជាច្រើន ដោយមិនតិចទេ ដែលជួយរុញច្រានឲ្យប្រាក់ចំណូលជាមធ្យមក្នុងស្រុកធ្លាក់ចុះ និងសហគ្រិនបរាជ័យជាច្រើននាក់ធ្លាក់ក្នុងបំណុលយ៉ាងខ្លាំងក្លា"។ Bateman បានផ្តល់ទិដ្ឋភាពទូទៅយ៉ាងលម្អិតនៃឯកសារយោងនៃការសិក្សា ដែលកត់ត្រាអំពីកំណើននៃការដកហូតដីធ្លីនៅក្នុងចំណោមជនក្រីក្រនៃប្រទេសកម្ពុជា ដោយសារការអនុវត្តរបស់ MFI ក្នុងការតម្រូវឲ្យដាក់កម្មសិទ្ធិដីធ្លីជាវត្ថុបញ្ចាំ និងការអនុវត្តដោយបង្ខំ ដែលត្រូវបានប្រើប្រាស់ដើម្បីបង្ខំឱ្យមានការលក់ដីធ្លីមុនពេលកំណត់។[142]

c) លទ្ធផលនៃការសិក្សាអំពីការជំពាក់បំណុលច្រើនហួសប្រមាណ នៅក្នុងទីផ្សារមីក្រូហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា ត្រូវបានចេញផ្សាយនៅខែតុលា ឆ្នាំ២០១៧។ ការសិក្សានេះត្រូវបានផ្តល់

---

[139] MIMOSA ២០១៦ *សារាចរពិសេស* កំណត់សម្គាល់ខាងលើ លេខ ១៣១ នៅ ២–៣.

[140] *Id.* at ៤. គួរកត់សម្គាល់ថា របកគំហើញទាំងនេះត្រូវបានធ្វើឡើងនៅពេលដែលវិស័យមីក្រូហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា មានតម្លៃ ៤ ពាន់លានដុល្លារអាមេរិក បច្ចុប្បន្នវិស័យនេះមានតម្លៃជាង ១១ ពាន់លានដុល្លារអាមេរិក។

[141] អង្គការលីកាដូ ការខូចខាតទ្រព្យបញ្ចាំ៖ ការបាត់បង់ដីធ្លី និងការរំលោភបំពាននៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ នៅ ២ ក.១០ (ឆ្នាំ ២០១៩) មាននៅ https://www.mficambodia.com/reports/Report-CollateralDamage-២០១៩-en.pdf (ដកស្រង់ពីអត្ថបទ ឆ្នាំ២០១៧ របស់ Milford Bateman).

[142] Milford Bateman *ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីបង្កើនលទ្ធភាពទទួលបានមីក្រូឥណទាននៅកម្ពុជា៖ ចូរប្រុងប្រយ័ត្នចំពោះអ្វីដែលអ្នកចង់បាន* (ឆ្នាំ ២០២០) ត្រៀមសម្រាប់ការធ្វើបទបង្ហាញនៅសន្និសិទធនាគារពិភពលោក ឆ្នាំ២០២០ ស្តីពីដីធ្លី និងភាពក្រីក្រ មាននៅ ១០–១១ ១៦ ២៦–៣០. សន្និសិទចូលរួមដោយផ្ទាល់ ត្រូវបានលុបចោលដោយសារជំងឺរាតត្បាតសកល កូវីដ-១៩ ប៉ុន្តែឯកសាររបស់ Bateman ត្រូវបានបោះពុម្ពផ្សាយនៅលើវែបសាយត៍របស់សន្និសិទធនាគារពិភពលោក។

មូលនិធិដោយ BMZ OikoCredit KFW (ដែលត្រូវបានបង្កើតឡើង និងសហការផ្តល់មូលនិធិដល់មូលនិធិគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុលអាស៊ី (MIFA) ជាមួយ IFC) និង BlueOrchard (ដែលគ្រប់គ្រង MIFA)។ ការសិក្សានេះបានរាយការណ៍អំពីសូចនាករសំខាន់ៗជាច្រើនសម្រាប់វិបត្តិមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដោយកត់សម្គាល់ថា អត្រានៃការជ្រៀតចូលទៅក្នុងទីផ្សារដោយវិធានការមួយចំនួន បានលើសពីចំណុចកំណត់សម្រាប់លំនាំដើម[143] និងតាមរយៈការគណនាអត្រាតិត្ថិភាពទីផ្សារ ដែលមានកម្រិតខ្ពស់ដល់ ៥៩ ទៅ ៨២ ភាគរយ[144] ចង្អុលបង្ហាញថា វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាស្ថិតនៅ "ដំណាក់កាលសំខាន់" និង "ងាយរងគ្រោះដោយវិបត្តិយ៉ាងខ្លាំង"[145]។ ការសិក្សាបានរៀបរាប់បន្ថែមអំពីបញ្ជីវែងមួយនៃការផ្តល់កម្ចី ដែលមានកង្វល់នៃ "ការប្រព្រឹត្តមិនត្រឹមត្រូវ" រួមទាំងលក្ខខណ្ឌតម្រូវតាមទម្លាប់ ក្នុងការកាន់កាប់ប័ណ្ណកម្មសិទ្ធិដីធ្លីជាវត្ថុបញ្ចាំ និងផលប៉ះពាល់សង្គមអវិជ្ជមានដែលពាក់ព័ន្ធ ពីគ្រោងការណ៍មីក្រូហិរញ្ញវត្ថុជារួម រួមទាំងការបរិភោគអាហារតិច និងមានគុណភាពមិនល្អផងដែរ។[146]

d) នៅឆ្នាំ២០១៨ IMF បានធ្វើការវាយតម្លៃផ្ទៃក្នុងអំពីស្ថានភាពមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងបានកត់សម្គាល់អំពី "ការកើនឡើងនៃសារសំខាន់ជាប្រព័ន្ធនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFI) បន្តបង្កហានិភ័យដល់ស្ថេរភាពហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច"។[147]

e) នៅខែមករា ២០១៩ ធនាគារពិភពលោកបានចេញផ្សាយកំណត់សម្គាល់គោលនយោបាយស្តីពីប្រទេសកម្ពុជា និងបានព្រមានថា "ហានិភ័យកំពុងកើនឡើងចំពោះ MFIs និងសេដ្ឋកិច្ចកម្ពុជាជាទូទៅ ដែលមួយផ្នែក ឆ្លុះបញ្ចាំងអំពីការអនុវត្តក្នុងការផ្តល់កម្ចីកាន់តែធូររលុង"។[148] កំណត់សម្គាល់នេះបានដកស្រង់អំពីកំណើននៃទំហំកម្ចីជាមធ្យមលើសពីដប់ដង ក្នុងរយៈពេលត្រឹមតែប្រាំឆ្នាំ[149] និងថាកម្រិតបំណុលគ្រួសារមានការកើនឡើងយ៉ាងខ្លាំង។[150] ធនាគារពិភពលោកបានសន្និដ្ឋានថា ការកើនឡើងដែលពាក់ព័ន្ធទាំងនេះអាចបណ្តាលមកពីការប្រកួតប្រជែងយ៉ាងខ្លាំងនៅក្នុងវិស័យនេះ ជាក់ស្តែងមកពីទីផ្សារដែលមានតិត្ថិភាពខ្លាំង និងបានកត់សម្គាល់ថា "ក្នុងករណីភាគច្រើន គ្រឿងលើកទឹកចិត្តត្រូវបានផ្តល់ជូនមន្ត្រីឥណទាន ដោយផ្អែកលើទំហំនៃការផ្តល់កម្ចី ដោយមិនគិតពីគុណភាព ឬហានិភ័យនោះទេ"។[151] ធនាគារពិភពលោកបានអំពាវនាវ

---

[143] ការសិក្សាអំពី OID នៅកម្ពុជា II កំណត់សម្គាល់ខាងលើ លេខ ១៣១ នៅ ៣០.

[144] *Id.* នៅ ៣១.

[145] *Id.* នៅ ៣២.

[146] *Id.* at ៥០, ៦២–៦៣.

[147] "បុគ្គលិក IMF បំពេញបេសកកម្មនៃមាត្រា ៤ នៅកម្ពុជា នៅឆ្នាំ២០១៨" មូលនិធិរូបិយវត្ថុអន្តរជាតិ ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ https://www.imf.org/en/News/Articles/2018/10/02/PR18371Cambodia.

[148] ក្រុមធនាគារពិភពលោក មីក្រូហិរញ្ញវត្ថុ និងសុខមាលភាពគ្រួសារ៖ កំណត់សម្គាល់អំពីគោលនយោបាយកម្ពុជា (ខែមករា ឆ្នាំ២០១៩) នៅ ៦ [តទៅ ហៅថា កំណត់សម្គាល់អំពីគោលនយោបាយកម្ពុជារបស់ WB].

[149] *Id.*

[150] Id. នៅ ១១.

[151] Id. នៅ ១១.

ឱ្យមានការកែលម្អការអនុវត្តក្នុងការផ្តល់កម្ចី និងការត្រួតពិនិត្យ ដើម្បីកាត់បន្ថយហានិភ័យ។[152]

f) IFC ក៏បានទទួលស្គាល់យ៉ាងច្បាស់លាស់ផងដែរថា "ភាពតានតឹងជាសក្តានុពលរវាងលទ្ធភាពទទួលបានប្រាក់ចំណេញផ្នែកពាណិជ្ជកម្ម និងគោលបំណងផ្នែកសង្គមរបស់អង្គការ" ទាមទារឱ្យមានការកែលម្អអភិបាលកិច្ចក្នុងផ្ទះរបស់អតិថិជន។[153]

g) នៅខែសីហា ឆ្នាំ២០១៩ អង្គការលីកាដូបានបោះពុម្ពផ្សាយ*ការខូចខាតទ្រព្យបញ្ចាំ៖ ការបាត់បង់ដីធ្លី និងការរំលោភបំពាននៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា* ដែលបានរៀបរាប់លម្អិតអំពីបទសម្ភាសន៍ជាមួយនាយកប្រតិបត្តិនៃ MFIs កម្ពុជាចំនួនពីរ។ នាយកប្រតិបត្តិបានបញ្ជាក់ថា ប័ណ្ណកម្មសិទ្ធដីធ្លីត្រូវបានទាមទារជាប្រចាំ ដោយ MFIs ធំៗទាំងអស់ និងថា អ្នកខ្ចី ក្រោយមក ត្រូវបានបង្ខិតបង្ខំឱ្យលក់ដីធ្លីរបស់ពួកគេមុនពេលកំណត់ នៅក្រៅដំណើរការតាមផ្លូវច្បាប់ជាផ្លូវការសម្រាប់លំនាំដើម។ បន្ថែមពីលើការជៀសវាងដំណើរការតាមផ្លូវច្បាប់ដែលមានតម្លៃថ្លៃ និងមានភាពយឺតយ៉ាវទៀតនោះ នាយកប្រតិបត្តិ MFI មួយរូបបានទទួលស្គាល់ថា តាមរយៈការបង្ខំអ្នកខ្ចីឱ្យលក់ដីធ្លីមុនពេលកំណត់ MFIs អាចកាត់បន្ថយចំនួនថ្ងៃដែលកម្ចីហួសកាលកំណត់ ដូច្នេះហើយអាចរៀបចំអត្រាប្រាក់កម្ចីមិនដំណើរការឱ្យមានកម្រិតទាប។[154]

h) នៅខែមករា ឆ្នាំ២០២០ អ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិស្តីពីផលប៉ះពាល់នៃបំណុលបរទេស និងកាតព្វកិច្ចហិរញ្ញវត្ថុអន្តរជាតិដែលពាក់ព័ន្ធដទៃទៀតរបស់រដ្ឋលើការទទួលបានសិទ្ធិមនុស្សពេញលេញយ៉ាងពេញលេញ បានលើកឡើងអំពីកង្វល់នៃការរំលោភសិទ្ធិមនុស្ស ទាក់ទងនឹងបំណុលឯកជន និងវិស័យមីក្រូហិរញ្ញវត្ថុរបស់កម្ពុជា ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។[155]

i) នៅខែមីនា ឆ្នាំ២០២០ MIMOSA បានចេញផ្សាយរបាយការណ៍ទីពីរ ស្តីពីវិស័យមីក្រូហិរញ្ញវត្ថុរបស់កម្ពុជា និងត្រូវបានចាត់តាំងដោយ IFC។ របាយការណ៍នេះ "បានរកឃើញបញ្ហាធ្ងន់ធ្ងរនៅក្នុងវិស័យកម្ចីខ្នាតមីក្រូរបស់កម្ពុជា" ដោយកត់សម្គាល់អំពីការកើនឡើងនៃទំហំកម្ចី ការបង្កើនបែបបទ ការជ្រៀតចូលទីផ្សារខ្ពស់ និងកិច្ចការពារអ្នកប្រើប្រាស់ និងបទប្បញ្ញត្តិមិនល្អ។[156] លើសពីនេះទៀត របាយការណ៍នេះបានដាក់ចំណាត់ថ្នាក់តិត្ថិភាពទីផ្សាររបស់កម្ពុជានៅកម្រិតតិត្ថិភាពខ្ពស់បំផុត ដែលអាចធ្វើឱ្យប្រទេសនេះក្លាយជាប្រទេសតែមួយគត់ក្នុងចំណោមប្រទេសទាំង ១១ ប្រទេស ដែលត្រូវបានវាយតម្លៃដោយ MIMOSA ថាឈានដល់កម្រិតនោះ។[157]

---

[152] កំណត់សម្គាល់អំពីគោលនយោបាយកម្ពុជារបស់ WB កំណត់សម្គាល់ខាងលើ លេខ ១៤៨ នៅ ៧.

[153] IFC ស្ថាប័នមីក្រូហិរញ្ញវត្ថុ https://www.ifc.org/wps/wcm/connect/topics_ext_content/ifc_external_corporate_site/ifc+cg/topics/microfinance+institutions.

[154] អង្គការ លីកាដូ ការខូចខាតទ្រព្យបញ្ចាំ កំណត់សម្គាល់ខាងលើ លេខ ១៤១ នៅ ៦–៧.

[155] របាយការណ៍អ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិស្តីពីបំណុលបរទេស និងសិទ្ធិមនុស្ស កំណត់សម្គាល់ខាងលើ លេខ ៤ នៅកថាខណ្ឌ ៣៣–៣៤.

[156] MIMOSA របាយការណ៍ស្តីពីប្រទេសកម្ពុជា (ខែមីនា ឆ្នាំ២០២០) នៅ ៦–៧ [របាយការណ៍ MIMOSA ដែលត្រូវបានចាត់តាំងដោយ IFC ឆ្នាំ ២០២០].

[157] *Id.* នៅ ៧.

j) នៅខែឧសភា និងខែមិថុនា ឆ្នាំ២០២០ អង្គការលីកាដូបានបោះពុម្ពផ្សាយរបាយការណ៍ចំនួនពីរបន្ថែមទៀត ដែលចងក្រងឯកសារការធ្វើចំណាកស្រុកដោយបង្ខំ និងការរំលោភសិទ្ធិមនុស្សនៅក្នុងវិស័យកាត់ដេរនៅកម្ពុជា ដែលបណ្តាលមកពីការអនុវត្តក្នុងការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុដោយបង្ខំ និងយ៉ាងឃោរឃៅ។[158]

103. [ត្រូវបានលុបចោល][159 160 161 162]

104. [ត្រូវបានលុបចោល][163 164 165]

105. [ត្រូវបានលុបចោល][166 167]

106. ការខកខានរបស់ IFC ក្នុងការឆ្លើយតបនឹងការខូចខាតផ្នែកសង្គម ដែលត្រូវបានរាយការណ៍យ៉ាងទូលំទូលាយ ទាក់ទងនឹងការវិនិយោគគម្រោងរបស់ខ្លួន **[ត្រូវបានលុបចោល]** ថែមទាំងពុំមានសង្គតិភាពនឹងគោលនយោបាយច្បាស់លាស់របស់ IFC លើការវាយតម្លៃហានិភ័យផ្នែកបរិស្ថាន និងសង្គមនៅក្នុងការវិនិយោគលើអន្តរការីហិរញ្ញវត្ថុ។ នៅក្នុងកំណត់សម្គាល់ការបកស្រាយអំពីអន្តរការីហិរញ្ញវត្ថុ IFC ចែងថា ហានិភ័យគម្រោងអាស្រ័យលើហានិភ័យតាមបរិបទនៅក្នុងប្រទេស ឬតំបន់ និងបានដកស្រង់ជាពិសេសចំពោះវិវាទដីធ្លី បញ្ហាជាប្រព័ន្ធ និងវិធានការរបស់រដ្ឋាភិបាលជាប្រវត្តិសាស្ត្រ។[168]

107. [ត្រូវបានលុបចោល][169 170]

108. សក្តានុពលនៃផលប៉ះពាល់សង្គមជាអវិជ្ជមាន ដែលកើតឡើងក្នុងទ្រង់ទ្រាយធំ មកពីការផ្តល់កម្ចីខ្នាតមីក្រូ គឺជាហានិភ័យដែលអាចព្យាករណ៍បាន ដែលត្រូវបានទទួលស្គាល់ដោយយន្តការគណនេយ្យភាព

---

[158] *ជាទូទៅ សូមមើល* អង្គការលីកាដូ ការបណ្តេញចេញ៖ បទពិសោធន៍របស់ភូមិមួយ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការធ្វើចំណាកស្រុកឆ្លងដែន (ឧសភា ឆ្នាំ២០២០) មាននៅ https://www.mficambodia.com/; ជំរុញឱ្យមានការជំពាក់បំណុល៖ ការជំពាក់បំណុលច្រើនពេកនៅក្នុងវិស័យកាត់ដេររបស់កម្ពុជា (ខែមិថុនា ឆ្នាំ២០២០) មាននៅ https://www.mficambodia.com/.

[159] [ត្រូវបានលុបចោល]

[160] [ត្រូវបានលុបចោល]

[161] [ត្រូវបានលុបចោល]

[162] [ត្រូវបានលុបចោល]

[163] [ត្រូវបានលុបចោល]

[164] កំណត់សម្គាល់ខាងលើ នៅកថាខណ្ឌ ៩១.

[165] *Cf.* ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ស៊ីអេអូ) Honduras/Dinant-០១/សំណើរបស់អនុប្រធានស៊ីអេអូ សេចក្តីសង្ខេបអំពីរបកគំហើញនៃសវនកម្មរបស់ស៊ីអេអូនៅលើវែបសាយត៍ ដែលថា "IFC បានដឹង ឬគួរតែដឹងអំពីសំណុំនៃការចោទប្រកាន់ជាសាធារណៈ និងការយល់ឃើញជាអវិជ្ជមាន ទាក់ទងនឹងអតិថិជនរបស់ខ្លួន ដែលមានសារសំខាន់លើសពីអ្វី ដែលត្រូវពិចារណានៅក្នុងដំណើរការនៃការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នលើសុចរិតភាពរបស់ខ្លួន" https://web.archive.org/web/20210610060830/http://www.cao-ombudsman.org/cases/case_detail.aspx?id=188។ ឯកសារច្បាប់ដើមពីករណី Dinant រួមបញ្ចូលគ្នាចំនួនបី ត្រូវបានលុបចេញពីវែបសាយត៍របស់ស៊ីអេអូ នៅពេលណាមួយ នៅចន្លោះខែមិថុនា ឆ្នាំ២០២១ ដល់ ខែតុលា ឆ្នាំ២០២១.

[166] [ត្រូវបានលុបចោល]

[167] [ត្រូវបានលុបចោល]

[168] IFC FI Interpretation Note, *supra* note ១១១, at para. IN៨–IN៩.

[169] [ត្រូវបានលុបចោល]

[170] [ត្រូវបានលុបចោល]

ធនាគារដទៃទៀត គួរតែត្រូវបានជូនដំណឹងនៅកម្រិតអប្បបរមានៃការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន ដែលត្រូវបានតម្រូវសម្រាប់ការវិនិយោគរបស់ IFC។ ឧទាហរណ៍៖ ក្រុមប្រឹក្សាត្រួតពិនិត្យភាពអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី បានធ្វើការត្រួតពិនិត្យឡើងវិញលើការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នរបស់ធនាគារមុនពេលអនុវត្តគម្រោង ទាក់ទងនឹងការចេញថវិកាជាង ៤២ លានដុល្លារអាមេរិក ជូនរាជរដ្ឋាភិបាលកម្ពុជា សម្រាប់គម្រោងស្តារផ្លូវរថភ្លើងឡើងវិញ។[171] ជាផ្នែកមួយនៃគម្រោងនេះ ផែនការតាំងទីលំនៅថ្មី និងសំណង ត្រូវបានបង្កើតឡើង ដែលរួមមានការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់គ្រួសារដែលផ្លាស់ប្តូរទីលំនៅថ្មីទៅកាន់ទីតាំងមួយក្នុងចំណោមទីតាំងទាំងប្រាំ។[172] អ្នកផ្តល់កម្ចីដ៏ឃោឃៅបានកំណត់គោលដៅលើគ្រួសារដែលមានប័ណ្ណកម្មសិទ្ធិដីធ្លី ការផ្តល់កម្ចីលើសចំនួនកំណត់ និងការទាមទារឲ្យមានប័ណ្ណកម្មសិទ្ធិដីធ្លីដែលទើបតែទិញថ្មីៗ ជាវត្ថុបញ្ចាំ។[173] ដូច្នេះ គ្រួសារទាំងឡាយបានមើលឃើញថា ពួកគេស្ថិតនៅក្រោមបំណុលដែលមិនអាចសងរួច ហើយប្រឈមមុខនឹងទិដ្ឋភាពដែលអាចមើលឃើញយ៉ាងច្បាស់ ដែលជៀសមិនផុតពីការបាត់បង់ដីធ្លីរបស់ពួកគេ។[174] ដូច្នេះ ក្រុមការងារត្រួតពិនិត្យភាពអនុលោមបានរកឃើញថា បំណុលគឺជាផលប៉ះពាល់សង្គម ដែលអាចព្យាករណ៍បាន នៃគម្រោង និងថាទិដ្ឋភាពមួយចំនួន ដូចជា ការប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីធ្លីជាវត្ថុបញ្ចាំសម្រាប់កម្ចី ក៏អាចព្យាករណ៍បានដែរ។[175] ដូច្នេះ គណៈកម្មការត្រួតពិនិត្យភាពអនុលោម បានសន្និដ្ឋានថា ធនាគារអភិវឌ្ឍន៍អាស៊ីមិនបានអនុវត្តការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នឲ្យបានគ្រប់គ្រាន់នៅក្នុងការធ្វើផែនការគម្រោង និងបានបង្កប់ន័យថា បញ្ហាទាំងនេះអាចត្រូវបានដោះស្រាយតាមរយៈគ្រោងការណ៍ឥណទាន ដែលត្រូវបានរៀបចំរចនាសម្ព័ន្ធដើម្បីការពារប្រឆាំងនឹងការអនុវត្តក្នុងការផ្តល់កម្ចីដែលបង្កគ្រោះថ្នាក់។[176] ទង្វើរបស់ IFC គឺស្រដៀងគ្នា ពាក់ព័ន្ធនឹងការវិនិយោគ ដែលមានបញ្ហា នៅក្នុងពាក្យបណ្តឹងនេះ។ ការចាត់ប្រភេទហានិភ័យទាបសម្រាប់ការវិនិយោគរបស់ IFC បង្ហាញដោយតុល្យភាពថា ការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នមុនពេលអនុវត្តគម្រោងរបស់ IFC មិនបានពិចារណាឲ្យបានគ្រប់គ្រាន់អំពីការខូចខាតផ្នែកសង្គមយ៉ាងទូលំទូលាយ និងអាចព្យាករណ៍បាន ពាក់ព័ន្ធនឹងកម្ចីមីក្រូហិរញ្ញវត្ថុកាលពីមុន និងនាពេលបច្ចុប្បន្នរបស់ IFC នោះទេ។ IFC ហាក់បីដូចជាមិនអើពើនឹងហានិភ័យដែលអាចព្យាករណ៍បាន ដែលត្រូវបានទទួលស្គាល់ដោយក្រុមត្រួតពិនិត្យភាពអនុលោមរបស់ ADB ថា អ្នកផ្តល់កម្ចីដ៏ឃោឃៅនឹងផ្តល់កម្ចីលើសចំនួនកំណត់ ជាថ្នូរនឹងប័ណ្ណកម្មសិទ្ធិដីធ្លីដែលជាវត្ថុបញ្ចាំ ដែលជំរុញឱ្យមានការជំពាក់បំណុល និងការដកហូតដីធ្លី។[177] ហានិភ័យដែលអាចព្យាករណ៍បានគឺ ផ្ទុយពីគោលដៅ និងគោលការណ៍នៃគោលនយោបាយនិរន្តរភាព E&S របស់ IFC ផ្ទាល់ ប៉ុន្តែ IFC មិនបានខិតខំប្រឹងប្រែងយ៉ាងជាក់ស្តែង[178] ក្នុង

[171] ធនាគារអភិវឌ្ឍន៍អាស៊ី របាយការណ៍ចុងក្រោយស្តីពីសំណើរបស់ក្រុមការងារត្រួតពិនិត្យភាពអនុលោម លេខ ២០១២/២ នៅកថាខណ្ឌ ៦ ៩ ១៤ ខែមករា ឆ្នាំ២០១៤ [តទៅ ហៅថា របាយការណ៍ត្រួតពិនិត្យភាពអនុលោមនៃគម្រោងផ្លូវរថភ្លើងរបស់ ADB].

[172] *Id.* នៅកថាខណ្ឌ ៨.

[173] *Id.* នៅកថាខណ្ឌ ១១

[174] *Id.* នៅ ៧២–៧៣.

[175] របាយការណ៍ត្រួតពិនិត្យភាពអនុលោមនៃគម្រោងផ្លូវរថភ្លើងរបស់ ADB កំណត់សម្គាល់ខាងលើ លេខ ១៧១ នៅ ៧២–៧៣.

[176] *Id.*

[177] *សូមមើល id.*

[178] ផ្អែកលើការត្រួតពិនិត្យព័ត៌មានដែលអាចស្វែងរកបានជាសាធារណៈនៅលើវេបសាយត៍របស់ IFC ដែលត្រូវបានកត់សម្គាល់នៅខាងលើ មិនបាន

ការកែសម្រួលការចាត់ថ្នាក់ហានិភ័យ ឬអនុម័តលក្ខខណ្ឌនៅក្នុងកិច្ចព្រមព្រៀងកម្ចី ដើម្បីកែលម្អការអនុវត្តក្នុងការផ្តល់កម្ចី ដូចដែលបានស្នើឡើងដោយក្រុមប្រឹក្សាត្រួតពិនិត្យភាពអនុលោម របស់ ADB នោះទេ។[179] ដូច្នេះ ការខកខានរបស់ IFC ក្នុងការអនុវត្តការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នមុនពេលអនុវត្តគម្រោងឱ្យបានគ្រប់គ្រាន់ និងការបរាជ័យដែលពាក់ព័ន្ធ ក្នុងការចាត់ថ្នាក់ហានិភ័យឲ្យបានសមស្របធានាឱ្យមានការស៊ើបអង្កេតដោយស៊ីអេអូ។

109. ស៊ីអេអូ ធ្លាប់បានទទួលស្គាល់ នៅពេលដែល IFC បានបរាជ័យក្នុងការពិចារណាអំពីបរិបទជាក់លាក់របស់ប្រទេស និងបានពឹងផ្អែកដោយខុសឆ្គង លើការសន្មតមិនត្រឹមត្រូវអំពីកម្រិតហានិភ័យក្នុងការវិនិយោគ ក្នុងអំឡុងពេលត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នមុនពេលអនុវត្តគម្រោង។ នៅក្នុងសវនកម្មរបស់ខ្លួន ទាក់ទងនឹងសំណុំពាក្យបណ្តឹង ដែលដាក់ដោយសហគមន៍ឥណ្ឌូនេស៊ីនៅក្នុងមូលដ្ឋាន ទាក់ទងនឹង The Wilmar Group ដែលជាក្រុមហ៊ុនកសិអាជីវកម្មដ៏ធំមួយ ដែលមានឯកទេសខាងប្រេងដូង និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់វាគឺ PT Asiatic Persada ស៊ីអេអូ បានសន្និដ្ឋានថា IFC មិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធកម្មរបស់ខ្លួនមួយផ្នែក ដោយការខកខានមិនបានវាយតម្លៃអំពីខ្សែសង្វាក់ផ្គត់ផ្គង់ពេញលេញ ទាក់ទងនឹងការវិនិយោគ។ ស៊ីអេអូ បានកត់សម្គាល់ថា ភាពខុសគ្នានៃវិសាលភាពក្នុងការត្រួតពិនិត្យ E&S សម្រាប់ប្រភេទហានិភ័យខុសៗគ្នា គឺសន្ទឹកសន្ធាប់ និងជាក់ស្តែង វាមានន័យថា សម្ពាធពាណិជ្ជកម្មខាងក្នុង និងខាងក្រៅសំខាន់ៗ អាចបង្វែរដំណើរការនៃការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន និងការចាត់ថ្នាក់របស់ IFC ឆ្ពោះទៅទទួលបានប្រភេទហានិភ័យទាបបាន។[180] ជាពិសេស "ការបកស្រាយដ៏តូចចង្អៀតអំពីផលប៉ះពាល់នៃការវិនិយោគ – ដោយមានការយល់ដឹងយ៉ាងពេញលេញអំពីទំនាក់ទំនងកាន់តែទូលំទូលាយនោះ – ពុំមានសង្គតិភាពនឹងតួនាទី ដែលត្រូវបានអះអាង របស់ IFC នោះទេ។[181] ស៊ីអេអូ បានសន្និដ្ឋានបន្ថែមទៀតថា "ការសន្មតមិនត្រឹមត្រូវ ត្រូវបានធ្វើឡើង អំពីផលប៉ះពាល់នៃប្រភេទផលិតផលហិរញ្ញវត្ថុមួយចំនួន... *ដោយគ្មានការពិចារណាត្រឹមត្រូវអំពីវិស័យ និងបរិបទប្រទេសនៃការវិនិយោគនោះទេ។ ... IFC គួរតែពិចារណាអំពីផលប៉ះពាល់នៃការវិនិយោគរបស់ខ្លួន ជាជាងការបកស្រាយដ៏តូចចង្អៀតអំពីលំហូរហិរញ្ញវត្ថុជាក់លាក់"*។[182] IFC បានប្រព្រឹត្តកំហុសដដែលៗ ម្តងហើយម្តងទៀត ចំពោះការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នមុនពេលអនុវត្តគម្រោងនៃគម្រោងមីក្រូហិរញ្ញវត្ថុរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ដោយធ្វើប្រតិបត្តិការពីទីតាំងដើមដែលមីក្រូហិរញ្ញវត្ថុមានហានិភ័យទាប និងមិនបានពិចារណាអំពីភស្តុតាងជាក់លាក់តាមប្រទេស នៃការខូចខាតផ្នែកសង្គម ដែលបណ្តាលមកពីគម្រោងមីក្រូហិរញ្ញវត្ថុរបស់ IFC នោះទេ ដូចបានអនុវត្តនៅកម្ពុជា។ ដូច្នេះ IFC បានពិចារណាតិចតួចអំពីហានិភ័យ E&S ទាក់ទងនឹងការផ្តល់កម្ចីខ្នាតមីក្រូ និង

---

បង្ហាញឲ្យបានគ្រប់គ្រាន់នូវព័ត៌មានលម្អិតសំខាន់ៗ ពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងនៃគម្រោង និងលក្ខខណ្ឌដែលត្រូវបានអនុវត្តចំពោះអតិថិជនរបស់ IFC ដែលពុំមានសង្គតិភាពនឹងគោលនយោបាយស្តីពីលទ្ធភាពទទួលបានព័ត៌មានរបស់ IFC នោះទេ។

[179] *សូមមើល* របាយការណ៍ត្រួតពិនិត្យភាពអនុលោមនៃគម្រោងផ្លូវរថភ្លើងរបស់ ADB កំណត់សម្គាល់ខាងលើ លេខ ១៧១ នៅកថាខណ្ឌ ២០៦ និងទំព័រ ៧៣.

[180] ស៊ីអេអូ Wilmar Trading (IFC លេខ ២០៣៤៨) និងដទៃទៀត របាយការណ៍ស្តីពីការពិនិត្យតាមដាន និងការបញ្ចប់សវនកម្ម ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ នៅ ៨–៩.

[181] *Id.* នៅ ៩.

[182] *Id.* (បន្ថែមការសង្កត់ធ្ងន់)

បានព្រងើយកន្តើយនឹងការខូចខាតផ្នែកសង្គមដែលពាក់ព័ន្ធជាច្រើន ដែលនាំឱ្យមានការចាត់ថ្នាក់ហានិភ័យទាបមិនបានត្រឹមត្រូវ។

110. ការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នមិនបានគ្រប់គ្រាន់របស់ IFC ចំពោះកម្រិតហានិភ័យ ដែលពាក់ព័ន្ធនឹងគម្រោងមីក្រូហិរញ្ញវត្ថុរបស់ខ្លួននៅកម្ពុជា គឺស្រដៀងគ្នានឹងការត្រួតពិនិត្យតិចតួចខ្លាំងពេក មុនពេលអនុវត្តគម្រោង ដែលស៊ីអេអូ បានរិះគន់នៅក្នុងករណី Dinant ដែរ។ សំណុំពាក្យបណ្ដឹង ដែលបានចោទប្រកាន់ថា Corporacion Dinant ក្រុមហ៊ុនប្រេងដូង និងស្បៀងអាហារ នៅ Honduran បានប្រើអំពើហិង្សា និងកងកម្លាំងសន្តិសុខឯកជន និងសាធារណៈ ដើម្បីបណ្ដេញកសិករចេញដោយបង្ខំ និងថា IFC មិនបានកំណត់ និងឆ្លើយតបនឹងហានិភ័យសង្គម នៅក្នុងបរិបទបណ្ដោះអាសន្ន និងបរិបទជាក់លាក់តាមប្រទេសនោះទេ។[183] បន្ទាប់ពីបានធ្វើសវនកម្ម ស៊ីអេអូ បានសន្និដ្ឋានថា ការត្រួតពិនិត្យមុនពេលអនុវត្តគម្រោងរបស់ IFC គឺមិន "សមស្របនឹងហានិភ័យ" នោះទេ ដោយផ្អែកលើភស្តុតាងដែលមានស្រាប់ អំពីលក្ខខណ្ឌរបស់ប្រទេស និងថា IFC គួរតែបានដឹងអំពីការចោទប្រកាន់ជាសាធារណៈ ដែលលើសពីអ្វីដែលត្រូវបានយកមកពិចារណានៅក្នុងដំណើរការនៃការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន។[184] ដូច្នេះ ស៊ីអេអូ បានសន្និដ្ឋានថា IFC បានប្រើនិយមន័យតូចចង្អៀតខ្លាំងពេក នៃហានិភ័យ E&S របស់គម្រោង និងបានចាត់ថ្នាក់កម្រិតទាប ដោយមិនត្រឹមត្រូវ។[185] ក្នុងករណីនេះ ស្រដៀងគ្នានេះដែរ IFC ក៏មិនយកចិត្តទុកដាក់លើការចោទប្រកាន់ជាសាធារណៈអំពីហានិភ័យសង្គមជាក់លាក់ចំពោះប្រទេសនៃគម្រោងដែរ **[ត្រូវបានលុបចោល]**។[186] គួរកត់សម្គាល់ថា ព័ត៌មានដែលអាចស្វែងរកបានជាសាធារណៈចំពោះ IFC នៅទីនេះ បានលើកឡើងអំពីការខូចខាតផ្នែកសង្គមនៅទូទាំងវិស័យ[187] ដែលមិនត្រឹមតែបង្ហាញអំពីភាពធ្ងន់ធ្ងរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកម្រិតនៃហានិភ័យ ដែលទាក់ទងនឹងគម្រោងមីក្រូហិរញ្ញវត្ថុរបស់ IFC នៅក្នុងប្រទេសកម្ពុជាផងដែរ។ ព័ត៌មានដែលមាន គ្របដណ្ដប់លើការវិវឌ្ឍន៍សហសម័យ[188] ព្រមទាំងរយៈពេលកាន់តែវែង[189] និងបានផ្ដល់ភស្តុតាងដែលថា ការខូចខាតផ្នែកសង្គមមានទំនាក់ទំនងនឹងបញ្ហាជាប្រព័ន្ធ ជាជាងករណីដាច់ដោយឡែក។ ដូច្នេះ ការទទួចម្ដងហើយម្ដងទៀតរបស់ IFC លើការចាត់ថ្នាក់ហានិភ័យទាបនៃ FI-២ សម្រាប់គម្រោងមីក្រូហិរញ្ញវត្ថុ ស្រដៀងគ្នា គឺជាការកំណត់និយមន័យដ៏តូចចង្អៀតយ៉ាងខ្លាំងនៃហានិភ័យ E&S របស់គម្រោង ដែលបណ្ដាលឱ្យមានការចាត់ថ្នាក់មិនត្រឹមត្រូវ។

---

183 ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ស៊ីអេអូ) Honduras/Dinant-0១/សំណើរបស់អនុប្រធានស៊ីអេអូ សេចក្ដីសង្ខេបនៅលើវេបសាយត៍ https://web.archive.org/web/២0២១0៦១00៦0៨៣0/http://www.cao-ombudsman.org/cases/case_detail.aspx?id=១៨៨.

184 *Id.*

185 *Id.*

186 [ត្រូវបានលុបចោល]

187 អង្គការឃ្លាំមើលសិទ្ធិមនុស្ស ធនាគារពិភពលោក៖ ស៊ើបអង្កេតអំពីកម្ចីខ្នាតមីក្រូរបស់កម្ពុជា ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២0២0 https://www.hrw.org/news/២0២0/១២/១៤/world-bank-investigate-cambodias-micro-loans. *ជាទូទៅ សូមមើល* អង្គការលីកាដូ ការខូចខាតវត្ថុបញ្ចាំ កំណត់សម្គាល់ខាងលើ លេខ ១៤១.

188 អង្គការឃ្លាំមើលសិទ្ធិមនុស្ស ធនាគារពិភពលោក៖ ស៊ើបអង្កេតអំពីកម្ចីខ្នាតមីក្រូរបស់កម្ពុជា ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២0២0 https://www.hrw.org/news/២0២0/១២/១៤/world-bank-investigate-cambodias-micro-loans.

189 កំណត់សម្គាល់ខាងលើ ផ្នែក III.ខ. នៅកថាខណ្ឌ ១0២.

111. IFC បានរៀបចំរចនាសម្ព័ន្ធឡើងវិញនូវចំណាត់ថ្នាក់ហានិភ័យផ្នែកបរិស្ថាន និងសង្គមរបស់ខ្លួន នៅឆ្នាំ ២០០៦ និងម្តងទៀតនៅឆ្នាំ២០១២ ដើម្បីធានាថា ការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នបានផ្តល់ព័ត៌មានអំពីការចាត់ថ្នាក់ហានិភ័យយ៉ាងត្រឹមត្រូវ។[190] ការអនុវត្តនៃការចាត់ថ្នាក់កម្ចីមីក្រូហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន ភាគច្រើនជា FI-២ ដោយពុំមានការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នឲ្យបានគ្រប់គ្រាន់ ចំពោះកម្រិត និងទំហំនៃហានិភ័យសង្គម ទាក់ទងនឹងគម្រោង ដែលដំណើរការផ្ទុយពីកំណែទម្រង់ទាំងនេះ និងគោលបំណងដែលនៅពីក្រោយក្របខណ្ឌនៃការចាត់ថ្នាក់ហានិភ័យនោះទេ។ លើសពីនេះទៀត ការចាត់ថ្នាក់ ដែលធ្វើឡើងដោយគ្មានការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន បង្ហាញឱ្យឃើញនូវចន្លោះប្រហោងនៃការការពារ នៅក្នុងក្របខណ្ឌ E&S របស់ IFC ទាក់ទងនឹងគម្រោងមីក្រូហិរញ្ញវត្ថុ។ នៅខណៈពេលដែលឧបករណ៍មួយចំនួន ដែលមានទំនាក់ទំនងនឹងការចាត់ថ្នាក់ហានិភ័យខ្ពស់យ៉ាងត្រឹមត្រូវនៃ FI-១ ដូចជា ការកំណត់ E&S មុនពេលអនុវត្តអនុគម្រោងរបស់អ្នកខ្ចីនីមួយៗនោះ គឺមិនសមរម្យ ឬមិនអាចដំណើរការបាន នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនោះ IFC ត្រូវតែកែសម្រួលក្របខណ្ឌ E&S របស់ខ្លួន ដើម្បីស្វែងរកឧបករណ៍ដែលត្រឹមត្រូវ ដើម្បីវាយតម្លៃ និងគ្រប់គ្រងហានិភ័យនៅក្នុងគម្រោងទាំងនោះ – មិនត្រូវព្រងើយកន្តើយចំពោះហានិភ័យសង្គមទាំងស្រុងនោះទេ។ ការមិនយកចិត្តទុកដាក់ដោយចេតនា ឬដោយធ្វេសប្រហែស ចំពោះហានិភ័យសង្គមច្បាស់លាស់ និងបានបង្ហាញអំពីការខូចខាតផ្នែកសង្គម ដែលទាក់ទងនឹងការវិនិយោគរបស់ខ្លួន គឺផ្ទុយពីបេសកកម្ម តួនាទី និងទំនួលខុសត្រូវដែលបានបញ្ជាក់ របស់ IFC។[191] ស៊ីអេអូ បានដោះស្រាយបញ្ហាបែបនេះនៅឆ្នាំ២០១០ ដោយធ្វើការវិភាគលើអន្តរការីហិរញ្ញវត្ថុរបស់ IFC និងការវិនិយោគដទៃទៀត និងបានសន្និដ្ឋានថា មានចន្លោះប្រហោងដ៏ធំ រវាងគោលនយោបាយស្តីពីនិរន្តរភាពបរិស្ថាន និងសង្គមរបស់ IFC និងការអនុវត្តរបស់អតិថិជន។[192] អនុសាសន៍របស់ស៊ីអេអូ លើចន្លោះប្រហោងទាំងនេះ បានរួមចំណែកដល់ការកែសម្រួលក្របខណ្ឌ E&S នៅឆ្នាំ២០១២ ដែលជួយសម្របសម្រួលបេសកកម្មរបស់ IFC និងកែលម្អធាតុចេញផ្នែកសង្គម និងបរិស្ថាននៃគម្រោងរបស់វា។ ចន្លោះប្រហោងនៃគោលនយោបាយ និងលទ្ធផលដែលបង្កការខូចខាតផ្នែកសង្គមដែលត្រូវបានបង្ហាញនៅក្នុងពាក្យបណ្តឹងនេះ គាំទ្រដល់ការស៊ើបអង្កេតមួយទៀតរបស់ស៊ីអេអូលើគោលនយោបាយរបស់ IFC។

### គ. ការវិភាគអំពីភាពខកខានរបស់ IFC ក្នុងការធ្វើការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នឲ្យបានគ្រប់គ្រាន់លើ ESMS របស់អតិថិជន

112. លក្ខខណ្ឌតម្រូវនៃការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នមុនពេលអនុវត្តគម្រោងរបស់ IFC រួមមាន ការត្រួតពិនិត្យគ្រប់ជ្រុងជ្រោយលើការមិនពិចារណាអំពីកម្រិតនៃហានិភ័យផ្នែកបរិស្ថាន និងសង្គមនៅក្នុង ESMS របស់អតិថិជន។ អតិថិជនអន្តរការីហិរញ្ញវត្ថុត្រូវបានត្រូវបានតម្រូវឲ្យបង្កើត និងដំណើរការ ESMS ដែលមានសង្គតិភាពនឹងកម្រិតនៃហានិភ័យផ្នែកបរិស្ថាន និងសង្គមនៅក្នុងផលបត្ររបស់ពួកគេ និងបញ្ចូល

---

[190] IFC កំណត់សម្គាល់បកស្រាយអំពីការចាត់ថ្នាក់ផ្នែកបរិស្ថាន និងសង្គម (២០១២) នៅកថាខណ្ឌ IN៣ ប្រអប់ទី១ IN៦ និង ក.៥.

[191] *សូមមើល* គោលនយោបាយ E&S របស់ IFC កំណត់សម្គាល់ខាងលើ លេខ ១០៩ នៅកថាខណ្ឌ ៨ ៩ ១៩ ២០ ២១ ២៣ ៤៦.

[192] ស៊ីអេអូ កំណត់សម្គាល់អំពីការប្រឹក្សា៖ ការត្រួតពិនិត្យគោលនយោបាយរបស់ IFC និងស្តង់ដារសមិទ្ធកម្មស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម ស្តីពីការបង្ហាញព័ត៌មាន នៅ ២០–២១ (២០១០)។

គោលការណ៍នានានៃស្តង់ដារសមិទ្ធកម្មទី១។[193] អន្តរការីហិរញ្ញវត្ថុ ដែលមានសកម្មភាពអាជីវកម្ម ដែលបង្ហាញអំពីហានិភ័យផ្នែកបរិស្ថាន ឬសង្គមកម្រិតមធ្យមទៅខ្ពស់ នឹងតម្រូវឱ្យមានសកម្មភាពអាជីវកម្មដែលមានហានិភ័យខ្ពស់ ដើម្បីអនុវត្តលក្ខខណ្ឌតម្រូវដែលពាក់ព័ន្ធនៃស្តង់ដារសមិទ្ធកម្ម ដែល ESMS ត្រូវតែបានបង្កើតឡើងដើម្បីដោះស្រាយ។[194] នៅក្នុងការត្រួតពិនិត្យឡើងវិញលើចន្លោះប្រហោងនៅក្នុងគោលនយោបាយរបស់ IFC និងសមិទ្ធកម្មផ្នែកបរិស្ថាន និងសង្គមរបស់អតិថិជនអន្តរការីហិរញ្ញវត្ថុនៅក្នុងឆ្នាំ២០១០ ស៊ីអេអូ បានសន្និដ្ឋានថា "IFC ចាំបាច់ត្រូវធ្វើការវាយតម្លៃអំពីការប្តេជ្ញាចិត្តរបស់អតិថិជន [អន្តរការីហិរញ្ញវត្ថុ] របស់ខ្លួនចំពោះការគ្រប់គ្រងហានិភ័យ [ផ្នែកបរិស្ថាន និងសង្គម] ដែលជាការត្រួតពិនិត្យលើការវិនិយោគដ៏សំខាន់មួយ"។[195] ដោយមានការបន្ត និងការកើនឡើងនៃការខូចខាតផ្នែកសង្គម ទាក់ទងនឹងការវិនិយោគ ដែលបានកំណត់នៅក្នុងផ្នែកទី I ពុំមានការចង្អុលបង្ហាញថា IFC បានវាយតម្លៃឡើងវិញលើការប្តេជ្ញាចិត្ត ឆន្ទៈ ឬសមត្ថភាពនៅក្នុងស្ថាប័នរបស់អតិថិជនអន្តរការីហិរញ្ញវត្ថុរបស់ខ្លួន ចំពោះការគ្រប់គ្រងប្រចាំថ្ងៃលើហានិភ័យ និងផលប៉ះពាល់សង្គមកម្រិតខ្ពស់ មុនពេលអនុម័តការវិនិយោគបន្ថែមទៀតនោះទេ។

113. ការកើនឡើងនៃការវិនិយោគមីក្រូហិរញ្ញវត្ថុរបស់ IFC បានបង្ហាញអំពីចន្លោះប្រហោងនៅក្នុងក្របខណ្ឌ E&S នាពេលបច្ចុប្បន្ន ដែលវាមិនស្របនឹងផលបត្រដែលត្រូវបានកែប្រែរបស់ IFC នោះទេ។ ដូចបានកត់សម្គាល់នៅក្នុងសេចក្តីថ្លែងការណ៍ជាបឋម IFC បានបង្កើនការវិនិយោគលើមីក្រូហិរញ្ញវត្ថុ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដែលនាំមកនូវការផ្លាស់ប្តូរជនដែលរងផលប៉ះពាល់ដោយគម្រោង IFC ពីជនរងគ្រោះនៃសកម្មភាពអតិថិជនបន្តរបស់ IFC ទៅជាអតិថិជនបន្តរបស់ IFC ដោយផ្ទាល់វិញ។ នៅក្នុងក្របខណ្ឌបច្ចុប្បន្នរបស់ IFC ចំពោះអន្តរការីហិរញ្ញវត្ថុ អតិថិជនរបស់ IFC ទទួលខុសត្រូវចំពោះការអនុវត្តស្តង់ដារសមិទ្ធកម្មរបស់ IFC និងបញ្ជីផាត់ចេញចំពោះសកម្មភាពអាជីវកម្មរបស់ខ្លួន និងអតិថិជនបន្តរបស់ខ្លួន។ លើសពីនេះទៀត ក្រោមការចាត់ថ្នាក់ហានិភ័យ FI-២ ដែលត្រូវបានអនុវត្តជាញឹកញាប់ចំពោះការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុ អតិថិជនរបស់ IFC មានឆន្ទានុសិទ្ធិជាពិសេស ក្នុងការសម្រេចចិត្តថាតើគម្រោងណាមួយ (ប្រសិនបើមាន) ដែលគួរអនុវត្តតាមស្តង់ដារសមិទ្ធកម្ម។[196] អតិថិជនអន្តរការីហិរញ្ញវត្ថុរបស់ IFC នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ដែលពាក្យបណ្តឹងនេះបានបង្ហាញរួចហើយថា កំពុងចូលរួមនៅក្នុងការអនុវត្តក្នុងការផ្តល់កម្ចី និងការប្រមូលប្រាក់ដោយគ្មានសីលធម៌យ៉ាងទូលំទូលាយ កំពុងផ្តោតលើសកម្មភាពរបស់អតិថិជនបន្តជាជាងសកម្មភាពរបស់ពួកគេផ្ទាល់។ សកម្មភាពរបស់អ្នកខ្ចី MFI ដូចជា ការធ្វើកសិកម្ម មិនបង្កការខូចខាតផ្នែកបរិស្ថាន និងសង្គមធ្ងន់ធ្ងរនោះទេ វាគឺជាសកម្មភាពអាជីវកម្មរបស់អតិថិជន ដែលមិនត្រួតពិនិត្យការងាររបស់ខ្លួនឯង។ អតិថិជនរបស់ IFC **[ត្រូវបានលុបចោល]** បានបង្ហាញបញ្ហាជាមូលដ្ឋាននេះ នៅពេលពណ៌នាអំពី ESMS របស់ខ្លួន។ **[ត្រូវបានលុបចោល]** បានលើកឡើងថា ESMS ផ្ទៃក្នុងរបស់វា ត្រួតពិនិត្យសកម្មភាពអាជីវកម្មរបស់អ្នកខ្ចី ដើម្បី

---

[193] *សូមមើល* គោលនយោបាយ E&S របស់ IFC កំណត់សម្គាល់ខាងលើ លេខ ១០៩ នៅកថាខណ្ឌ ៣៥.

[194] *សូមមើល id.*

[195] *Id.* at ២១.

[196] ស្តង់ដារសមិទ្ធកម្មអនុវត្តចំពោះគម្រោង "ដែលមានហានិភ័យខ្ពស់" ប៉ុន្តែអតិថិជន IFC កំណត់គម្រោងណាមួយ (ប្រសិនបើមាន)

កំណត់ហានិភ័យ E&S និងប្រឆាំងនឹងបញ្ជីផាត់ចេញ។[197] ទោះបីជាយ៉ាងណាក៏ដោយ ពួកគេមិនធ្វើការត្រួតពិនិត្យជាក់ស្តែងលើសកម្មភាពរបស់ពួកគេផ្ទាល់ ដើម្បីកំណត់ហានិភ័យ E&S នោះទេ និងបណ្តាលឲ្យមានការខូចខាតដល់អ្នកខ្ចី។ លើសពីនេះទៀត ចន្លោះប្រហោងក្នុងការពិនិត្យតាមដាន និងការត្រួតពិនិត្យនេះមានសារសំខាន់ ដែលអ្នកខ្ចីមីក្រូហិរញ្ញវត្ថុមិនមែនជាអតិថិជនបន្ត តាមបែបប្រពៃណី។ អ្នកខ្ចីមីក្រូហិរញ្ញវត្ថុ ភាគច្រើន មិនមែនជាអាជីវកម្មដែលបានចុះបញ្ជីនោះទេ ដូច្នេះហើយពួកគេត្រូវការការការពារ និងការពិនិត្យតាមដានបន្ថែមទៀត ដើម្បីធានាថា គម្រោង IFC មិនមានផលប៉ះពាល់ ដែលបង្កការខូចខាតដល់សង្គម។

114. លើសពីនេះទៀត IFC ធ្លាប់បង្ហាញកង្វល់អំពីគោលនយោបាយរបស់អន្តរការីហិរញ្ញវត្ថុ ដែលអាចធ្វើឲ្យមន្ត្រីឥណទានចូលរួមនៅក្នុងការអនុវត្តនៃការផ្តល់កម្ចីដែលគ្មានទំនួលខុសត្រូវ ចូលរួមនៅក្នុងប្រតិបត្តិការដែលមានហានិភ័យខ្ពស់ និងបង្កើតព័ត៌មានមិនត្រឹមត្រូវអំពីសមិទ្ធកម្មនៃកម្ចីផងដែរ។ នៅក្នុងការត្រួតពិនិត្យកិច្ចការពារអ្នកប្រើប្រាស់នៅកម្ពុជា ក្នុងឆ្នាំ ២០១៥ IFC បានបង្ហាញកង្វល់អំពីប្រាក់រង្វាន់ដែលផ្តល់ជូនមន្ត្រីឥណទាន ដោយផ្អែកលើចំនួនទឹកប្រាក់នៃឥណទាន ដែលត្រូវបានផ្តល់ជូន ឬសម្រាប់ការបន្តថែរក្សាអត្រានៃការសងកម្ចីយឺតយ៉ាវ ដែលត្រូវបានរាយការណ៍ នៅពីក្រោមកម្រិតមួយចំនួន។[198] IFC បានទទួលស្គាល់ថា ប្រព័ន្ធលើកទឹកចិត្តនេះអាចនាំឱ្យមន្ត្រីឥណទានធ្វើប្រតិបត្តិការដែលមានហានិភ័យកាន់តែខ្ពស់ និង "អនុវត្តការប្រមូលប្រាក់ដែលកាន់តែឈ្លានពាន និងមិនសមរម្យ"។[199] IFC បានបញ្ចប់ដោយ ការអំពាវនាវឱ្យមានការពិនិត្យតាមដាន និងសវនកម្ម ដែលមានភាពប្រសើរឡើង និងមានភាពសកម្ម នៅក្នុង ESMS របស់អន្តរការីហិរញ្ញវត្ថុ។[200] ទោះបីជាយ៉ាងណាក៏ដោយ ការរាយការណ៍ជាសាធារណៈពីវិស័យនេះ ក្នុងរយៈពេលបួនឆ្នាំ បន្ទាប់ពីរបាយការណ៍របស់ IFC បានបញ្ជាក់ថា ការអនុវត្តក្នុងការផ្តល់កម្ចី និងការប្រមូលប្រាក់ដ៏ឃោរឃៅ និងឈ្លានពាននៅតែបន្ត ដែលបង្ហាញថា IFC មានភាពបរាជ័យក្នុងការរួមបញ្ចូលការកែលម្អទាំងនេះទៅក្នុង ESMS អតិថិជនរបស់ខ្លួនឱ្យបានត្រឹមត្រូវ។ នៅក្នុងរបាយការណ៍ ឆ្នាំ២០១៩ *ការខូចខាតវត្ថុបញ្ចាំ [ត្រូវបានលុបចោល]* អង្គការលីកាដូ បានរាយការណ៍ថា នាយកប្រតិបត្តិ MFI បច្ចុប្បន្ន និងអតីតនាយកប្រតិបត្តិ MFI ពីររូប បានបញ្ជាក់ថា អាជ្ញាធរភូមិ និងឃុំនៅក្នុងមូលដ្ឋាន ដើរតួជាអ្នកអនុវត្តច្បាប់ជូន MFIs ក្នុងការដាក់សម្ពាធលើអតិថិជនឱ្យទទួលយកមធ្យោបាយណាមួយ ដែលចាំបាច់ដើម្បីសងកម្ចី។[201] នាយកប្រតិបត្តិ MFI បានបញ្ជាក់បន្ថែមទៀតថា MFIs តែងតែដាក់សម្ពាធលើអ្នកខ្ចីឲ្យលក់ដីធ្លីរបស់ពួកគេជាលក្ខណៈឯកជនដើម្បីសង កម្ចី ដោយនាយកប្រតិបត្តិមួយរូបបានបញ្ជាក់ថា "តម្លៃដីធ្លីគឺជាកត្តាសំខាន់បំផុតតែមួយគត់សម្រាប់ទីផ្សារ MFI នៅពេលនេះ"។[202] ការរាយការណ៍យ៉ាងទូលំទូលាយអំពីការកើនឡើងនៃទំហំ និងកម្រិតនៃការខូចខាតដល់សង្គម បង្ហាញអំពីភាពមិនគ្រប់គ្រាន់របស់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជា

---

[197] [ត្រូវបានលុបចោល]

[198] IFC ការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា កំណត់សម្គាល់ខាងលើ លេខ ១៣០ នៅ ៧.

[199] *id.*

[200] សូមមើល *id.*

[201] លីកាដូ ការខូចខាតវត្ថុបញ្ចាំ កំណត់សម្គាល់ខាងលើ លេខ ១៤១ នៅ ៧.

[202] *id.*

អតិថិជនរបស់ IFC ក្នុងការកំណត់ និងជៀសវាងហានិភ័យដល់សង្គម **[ត្រូវបានលុបចោល]**។ ចំណុចនេះបញ្ជាក់ថា IFC បរាជ័យក្នុងការតាមដាន និងពិចារណាឱ្យបានគ្រប់គ្រាន់នូវហានិភ័យដ៏សំខាន់មួយ ដែលពួកគេបានដឹង ទាក់ទងនឹង ESMS របស់អន្តរការីហិរញ្ញវត្ថុ នៅពេលអនុម័តកម្ចីជាបន្តបន្ទាប់។

115. ការខកខានរបស់ IFC ក្នុងការអនុវត្តការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នមុនពេលអនុវត្តគម្រោងឱ្យបានគ្រប់គ្រាន់ នៅក្នុងករណីទាំងនេះ គឺស្រដៀងគ្នានឹងការចោទប្រកាន់របស់ IFC អំពីកង្វះខាតការប្រុងប្រយ័ត្នយ៉ាងសមស្រប ពាក់ព័ន្ធនឹងការវិនិយោគ ដែលស្ថិតនៅក្រោមការស៊ើបអង្កេតនៅក្នុងសាជីវកម្មធនាគារពាណិជ្ជ Rizal។ នៅ Rizal សម្ព័ន្ធសហគមន៍មួយបានដាក់ពាក្យបណ្ដឹងទៅកាន់ស៊ីអេអូតាងនាមឲ្យសហគមន៍នានា មកពី ១៩ តំបន់ នៅប្រទេសហ្វីលីពីន ទាក់ទងនឹងការវិនិយោគលើគម្រោង IFC នៅក្នុងសាជីវកម្មធនាគារពាណិជ្ជ Rizal ដែលជាលទ្ធផល បានផ្ដល់ហិរញ្ញប្បទានដល់រោងចក្រថាមពលធ្យូងថ្មសកម្ម ឬដែលបានស្នើឡើង ចំនួន ១៩ រោងចក្រ។ សហគមន៍បានចោទប្រកាន់អំពីផលប៉ះពាល់ E&S យ៉ាងធ្ងន់ធ្ងរពីអនុគម្រោង និងថា ESMS របស់ Rizal មិនគ្រប់គ្រាន់សម្រាប់ដោះស្រាយហានិភ័យខ្ពស់នៃការខូចខាតទាំងនោះ។ ទោះបីជាការវិនិយោគរបស់ Rizal ត្រូវបានចាត់ថ្នាក់ថាមានហានិភ័យខ្ពស់ជាងការវិនិយោគនៅក្នុងពាក្យបណ្ដឹងនេះក៏ដោយ ក៏ស្ដង់ដារសម្រាប់ការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នមុនពេលវិនិយោគរបស់ IFC លើ ESMS របស់អតិថិជនគឺ ដូចគ្នាៈ IFC ត្រូវតែត្រួតពិនិត្យសមត្ថភាពរបស់អតិថិជនក្នុងការអនុវត្តលក្ខខណ្ឌតម្រូវរបស់ IFC និងកំណត់ត្រាតាមដានការអនុវត្ត ESMS រហូតមកដល់បច្ចុប្បន្ន។[203] នៅ Rizal ស៊ីអេអូ បានសម្រេចចិត្តធ្វើការស៊ើបអង្កេតពេញលេញលើការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នរបស់ IFC និងសំណួរអំពីភាពអនុលោមដទៃទៀត ដោយសន្និដ្ឋានថា មានកង្វល់យ៉ាងខ្លាំងក្លា ទាក់ទងនឹងធាតុចេញ E&S នៃការវិនិយោគ Rizal របស់ IFC។ ដើម្បីគាំទ្រការសម្រេចចិត្តរបស់ខ្លួន ស៊ីអេអូ បានកត់សម្គាល់ថាៈ (i) ការចោទប្រកាន់ជាក់លាក់អំពីផលប៉ះពាល់អវិជ្ជមាន ដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្ដឹង (ii) ចំនួនរោងចក្រថាមពលធ្យូងថ្ម ដែលកំពុងទទួលបានហិរញ្ញប្បទាន (iii) ទម្រង់ហានិភ័យ E&S របស់គម្រោង និង (iv) សំណួរទាក់ទងនឹងសមត្ថភាពរបស់អតិថិជនក្នុងការអនុវត្ត ESMS ឲ្យបានគ្រប់គ្រាន់។[204] ប្រាកដណាស់ ភាពធ្ងន់ធ្ងរ និងទំហំនៃការខូចខាតបរិស្ថាន និងសង្គមជាក់ស្ដែង ឬជាសក្ដានុពល បង្កើតជាសំណួរទាក់ទងនឹងភាពគ្រប់គ្រាន់នៃ ESMS ដើម្បីការពារប្រឆាំងនឹងហានិភ័យទាំងនោះ និងធានាឱ្យមានការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នដោយហ្មត់ចត់ដោយ IFC។ ស្រដៀងនេះដែរ ការវិនិយោគរបស់ IFC ដែលមានបញ្ហានៅក្នុងពាក្យបណ្ដឹងនេះ ទាក់ទងនឹងគម្រោងមួយចំនួនធំ (កម្ចីមីក្រូហិរញ្ញវត្ថុ) ដែលពាក់ព័ន្ធនឹងការខូចខាតដល់សង្គមជាក់ស្ដែង ឬជាសក្ដានុពលដ៏ធ្ងន់ធ្ងរ (ពោលគឺ ការដកហូតដីធ្លីរបស់ជនជាតិដើមភាគតិច) ជាច្រើន (នៅទូទាំងប្រទេសកម្ពុជា)។ ភស្តុតាងនៃការខូចខាតដល់សង្គម ដូចបានកត់សម្គាល់ខាងលើនៅក្នុងផ្នែកទី II ជាពិសេសការកើនឡើងនៃភាពធ្ងន់ធ្ងរនៃការខូចខាតទាំងនោះ បង្កើតជាសំណួរដ៏ធ្ងន់ធ្ងរទាក់ទងនឹងភាពគ្រប់គ្រាន់នៃ ESMS របស់អតិថិជន IFC ដែលធានាឱ្យមានការស៊ើបអង្កេត

---

[203] ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ស៊ីអេអូ) ការវាយតម្លៃភាពអនុលោម ទៅលើការវិនិយោគរបស់ IFC នៅក្នុងសាជីវកម្មធនាគារពាណិជ្ជ Rizal ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩ នៅ ១២ (ដកស្រង់ពីនីតិវិធីត្រួតពិនិត្យផ្នែកបរិស្ថាន និងសង្គម កថាខណ្ឌ ៧.២.១៦–១៧).

[204] *Id.* at ១៤–១៥.

របស់ស៊ីអេអូ លើការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន មុនពេលអនុវត្តគម្រោងរបស់ IFC។

### D. ការវិភាគអំពីភាពបរាជ័យរបស់ IFC ក្នុងការត្រួតពិនិត្យសមិទ្ធកម្ម និងការអនុវត្ត ESMS របស់អតិថិជន IFC ឲ្យបានគ្រប់គ្រាន់

116. ក្របខណ្ឌ E&S តម្រូវឲ្យ IFC ត្រួតពិនិត្យការងាររបស់អន្តរការីហិរញ្ញវត្ថុនៅក្នុងការវិនិយោគទាំងមូល តាមរយៈការត្រួតពិនិត្យតាមកាលកំណត់ លើដំណើរការ និងលទ្ធផលនៃការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នផ្នែកបរិស្ថាន និងសង្គមរបស់អតិថិជន និងការអនុវត្ត ESMS របស់ពួកគេ។[205] លើសពីនេះទៀត IFC នឹងត្រួតពិនិត្យជាទៀងទាត់លើគំរូការវិនិយោគផ្សេងទៀតរបស់អន្តរការីហិរញ្ញវត្ថុ ជាពិសេសសម្រាប់សកម្មភាពអាជីវកម្មដែលមានហានិភ័យបរិស្ថាន និងសង្គមខ្ពស់។[206] ការត្រួតពិនិត្យរបស់ IFC អាចរួមបញ្ចូលការចុះទៅមើលប្រតិបត្តិការរបស់អន្តរការីហិរញ្ញវត្ថុ ព្រមទាំងអ្នកទទួលកម្ចីផងដែរ ជាពិសេសចំពោះអនុគម្រោង ដែលមានហានិភ័យខ្ពស់។[207] IFC នឹងធ្វើការជាមួយអតិថិជនរបស់ខ្លួន ដើម្បីដោះស្រាយរាល់ចំណុចខ្សោយនៅក្នុង ESMS របស់ពួកគេ។[208]

117. កាលពីជិត ១០ ឆ្នាំមុន ស៊ីអេអូបានបង្ហាញកង្វល់ពាក់ព័ន្ធនឹងទីផ្សារហិរញ្ញវត្ថុរបស់ IFC ជាពិសេស អន្តរការីហិរញ្ញវត្ថុ ការវិនិយោគ និងចន្លោះប្រហោងរវាងគោលនយោបាយស្តីពីបរិស្ថាន និងសង្គមរបស់ IFC និងជាតុចេញនានា។ នៅក្នុងសវនកម្មប្រតិបត្តិការទីផ្សារហិរញ្ញវត្ថុទូទាំងវិស័យ ក្នុងឆ្នាំ២០១២ រួមទាំងការវិនិយោគរបស់អន្តរការីហិរញ្ញវត្ថុផងដែរ ស៊ីអេអូ បានកត់សម្គាល់ថា "សកម្មភាពរបស់ IFC... កំពុងបង្កើតហានិភ័យដែលមានការកើនឡើងជាសក្តានុពលចំពោះ IFC នៅក្នុងកម្រិត ដែល [ការវិនិយោគ] អាចបណ្តាលឲ្យមានការខូចខាតផ្នែកបរិស្ថាន និងសង្គម"។[209] ស៊ីអេអូបានបញ្ជាក់ថា ហានិភ័យនេះបណ្តាលមកពីការខកខានមិនបានត្រួតពិនិត្យការងារ ដែលរកឃើញ "ថាការផ្តោតរបស់ IFC លើការបង្កើត [ESMS] ជាផលិតផលដែលត្រូវបានតម្រូវតាមច្បាប់ – ជំនួសឲ្យ ជាផ្នែកមួយនៃដំណើរការគ្រប់គ្រងការផ្លាស់ប្តូរកាន់តែសំខាន់ – បង្កើតហានិភ័យ... [ESMS] អាចក្លាយជាចំណុចបញ្ចប់ដោយខ្លួនឯង (លំហាត់ abox-ticking ជាជាងមធ្យោបាយនៃការពង្រឹងលទ្ធផលនៃសមិទ្ធកម្ម [ផ្នែកបរិស្ថាន និងសង្គម] នៅក្នុងការអនុវត្តជាក់ស្តែង"។[210] ស៊ីអេអូ បានបន្តថា ការត្រួតពិនិត្យការងាររបស់អតិថិជន IFC គឺ ផ្តោតលើថាតើ ESMS ត្រូវបានអនុវត្តឬទេ ប៉ុន្តែខ្វះខាតឧបករណ៍សម្រាប់វាស់ស្ទង់ការអនុវត្ត E&S ជាក់ស្តែង ដើម្បីបញ្ជាក់ថា ពុំមានការខូចខាត។[211] ស៊ីអេអូ បានធ្វើរបាយការណ៍ពិនិត្យតាមដាន

---

[205] គោលនយោបាយ E&S របស់ IFC កំណត់សម្គាល់ខាងលើ លេខ ១០៩ នៅកថាខណ្ឌ ៤៥. *Cf.* គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស គោលការណ៍ទី ១៩ និង សេចក្តីអធិប្បាយ (២០១១) (របកគំហើញពីការវាយតម្លៃអំពីផលប៉ះពាល់ គួរតែផ្តល់ព័ត៌មានអំពីវិធានការសមស្រប រួមទាំងដំណើរការនៃការត្រួតពិនិត្យផងដែរ); គោលការណ៍ណែនាំរបស់ OECD សម្រាប់សហគ្រាសពហុជាតិ នៅកថាខណ្ឌ ១៩–២០ (ឆ្នាំ២០១១).

[206] គោលនយោបាយ E&S របស់ IFC កំណត់សម្គាល់ខាងលើ លេខ ១០៩ នៅកថាខណ្ឌ ៤៥.

[207] *Id.*

[208] *Id.*

[209] ស៊ីអេអូ របាយការណ៍សវនកម្ម៖ សវនកម្មលើគំរូការវិនិយោគរបស់ IFC នៅក្នុងអន្តរការីហិរញ្ញវត្ថុដែលជាតតិយជន នៅ ៩ (ឆ្នាំ២០១២) [ស៊ីអេអូ ឆ្នាំ២០១២ របាយការណ៍សវនកម្ម FI].

[210] *Id.* at ៣៧.

[211] *Id.* at ៣៦.

ចំនួនបី ដើម្បីតាមដានដំណើរការសវនកម្ម ហើយនាពេលថ្មីៗនេះ នៅឆ្នាំ២០១៧ បានបន្តព្រមានអំពីខកខានមិនត្រួតពិនិត្យដោយ IFC លើអតិថិជន FI។ នៅក្នុងរបាយការណ៍ពិនិត្យតាមដាន ឆ្នាំ២០១៧ ស៊ីអេអូ បានចាត់ថ្នាក់ការត្រួតពិនិត្យរបស់ IFC លើការវិនិយោគរបស់អន្តរការីហិរញ្ញវត្ថុថា មិនល្អ នៅ ១៣ ចំណុច នៅលើមាត្រដ្ឋានភាពអនុលោម ៣៥ ចំណុច ដែលបញ្ជាក់ថា នៅក្នុងករណី ដែលត្រូវបានត្រួតពិនិត្យភាគច្រើន "ការត្រួតពិនិត្យការងាររបស់ IFC មិនបានបញ្ជាក់ថា [អតិថិជនអន្តរការីហិរញ្ញវត្ថុ] កំពុងអនុវត្ត ESMS ដែលបំពេញតាមលក្ខខណ្ឌតម្រូវរបស់ IFC នោះទេ"។[212]

118. ការបន្ត និងការកើនឡើងនៃការខូចខាតសង្គម ដែលមានភស្តុតាង នៅក្នុងពាក្យបណ្តឹងនេះ បង្ហាញថាការត្រួតពិនិត្យរបស់ IFC លើអតិថិជន MFI របស់ខ្លួននៅក្នុងប្រទេសកម្ពុជាមានបញ្ហាដូចៗគ្នា។ ជាការឆ្លើយតបទៅនឹងលិខិតរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ទៅកាន់ IFC នៅឆ្នាំ២០២០ ទាក់ទងនឹងការខូចខាតសង្គមនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ អ្នកគ្រប់គ្រងជាន់ខ្ពស់របស់ IFC សម្រាប់ប្រទេសកម្ពុជា ឡាវ និងវៀតណាម គ្រាន់តែបានលើកឡើងថា "យើង...ពិនិត្យតាមដានភាពអនុលោមរបស់អតិថិជនរបស់យើងចំពោះ គោលការណ៍ [ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ] ទាំងនេះ" និងបានយោងដល់កម្មវិធីទីប្រឹក្សាដើម្បីបង្កើនការយល់ដឹងអំពីហិរញ្ញប្បទានដែលមានហានិភ័យខ្ពស់។[213] ជាការឆ្លើយតបអង្គការឃ្លាំមើលសិទ្ធិមនុស្សបានចង្អុលបង្ហាញថា IFC មិនបានបញ្ជាក់អំពីរបៀបដោះស្រាយជាមួយបដិលោមភាពរបស់អតិថិជនរបស់ខ្លួននោះទេ។[214] IFC ក៏មិនបានលើកឡើងអំពីការទទួលយកដ៏គួរឱ្យរំខានរបស់នាយកប្រតិបត្តិ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា ដែលទទួលស្គាល់ថាពួកគេមានចេតនាចូលរួមនៅក្នុងការអនុវត្តនៃការផ្តល់កម្ចីដ៏ឃោឃៅ រួមទាំងការស្វែងរកបណ្ណកម្មសិទ្ធិជាវត្ថុបញ្ចាំ ហើយបន្ទាប់មកដាក់សម្ពាធលើអ្នកខ្ចីឱ្យលក់ដីធ្លីនៅក្រៅប្រព័ន្ធតុលាការ ដកហូតកម្មសិទ្ធិដីធ្លីរបស់សហគមន៍ និងជនជាតិដើមភាគតិច។[215] ផ្ទុយទៅវិញ IFC បានបន្តបន្ទាបហានិភ័យនៃការវិនិយោគលើមីក្រូហិរញ្ញវត្ថុ ដូច្នេះជំរុញឱ្យមានទំនួលខុសត្រូវលើការសម្រេចចិត្តលើពេលវេលាដែលត្រូវអនុវត្តស្តង់ដារសមិទ្ធកម្ម—ថាតើប្រតិបត្តិការណាមួយដែលមានហានិភ័យខ្ពស់—ចំពោះអតិថិជន IFC ទាំងនោះ **[ត្រូវបានលុបចោល]**។ គំរូ និងការអនុវត្តយ៉ាងទូលំទូលាយនៃការផ្តល់កម្ចីដោយគ្មានទំនួលខុសត្រូវ និងដោយបង្ខំ ដែលនាំឱ្យប៉ះពាល់ដល់សង្គមយ៉ាងខ្លាំង ដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្តឹងនេះ បង្ហាញថា IFC អស់រយៈពេលជាច្រើនឆ្នាំមកហើយ បានបរាជ័យក្នុងការត្រួតពិនិត្យអតិថិជន MFI របស់ខ្លួននៅកម្ពុជា និងដោះស្រាយរាល់ចំណុចខ្វះខាតនៅក្នុងគោលនយោបាយត្រួតពិនិត្យរបស់ IFC។

---

212 ស៊ីអេអូ របាយការណ៍ពិនិត្យតាមដាន៖ របាយការណ៍ពិនិត្យតាមដានលើកទីបីលើការឆ្លើយតបរបស់ IFC ទៅនឹងសវនកម្មរបស់ស៊ីអេអូលើគំរូនៃការវិនិយោគរបស់ IFC លើអន្តរការីហិរញ្ញវត្ថុដែលជាតតិយជន នៅ ៧ ១១-១២ (ឆ្នាំ២០១៧).

213 [ត្រូវបានលុបចោល]. លើសពីនេះទៀត យើងមិនអាចរកឃើញព័ត៌មានអំពីគម្រោងណាមួយ ទាក់ទងនឹង "សេវាទីប្រឹក្សា" ទាំងនេះនៅក្នុងព័ត៌មាន និងបណ្ណុំទិន្នន័យអំពីគម្រោងរបស់ IFC ឬនៅក្នុងព័ត៌មានដែលអាចស្វែងរកបានជាសាធារណៈនៅលើវេបសាយត៍របស់ IFC នោះទេ។

214 អង្គការឃ្លាំមើលសិទ្ធិមនុស្ស *ធនាគារពិភពលោក៖ ស៊ើបអង្កេតអំពីកម្ចីខ្នាតមីក្រូរបស់ប្រទេសកម្ពុជា* ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ https://www.hrw.org/news/២០២០/១២/១៤/world-bank-investigate-cambodias-micro-loans.

215 សូមមើល អង្គការលីកាដូ ការខូចខាតវត្ថុបញ្ចាំ កំណត់សម្គាល់ខាងលើលេខ ១៤១ នៅ ៦–៧.

119. [ត្រូវបានលុបចោល][216] [217]

120. [ត្រូវបានលុបចោល]

121. ជារួម IFC បានបរាជ័យក្នុងការអនុវត្តការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នឲ្យបានគ្រប់គ្រាន់ ទាក់ទងនឹងសមិទ្ធកម្មផ្នែកសង្គមនៃការវិនិយោគរបស់ខ្លួនទាំងមុន និងក្នុងអំឡុងពេលអនុវត្តគម្រោង ផ្ទុយទៅវិញ IFC បន្តវិនិយោគយ៉ាងច្រើននៅក្នុងវិស័យដែលទទួលខុសត្រូវចំពោះការខូចខាតយ៉ាងទូលំទូលាយ និងមានឯកសារត្រឹមត្រូវ ចំពោះបុគ្គល និងសហគមន៍ដែលងាយរងគ្រោះ។ លើសពីនេះទៀត IFC បានបរាជ័យក្នុងការវាយតម្លៃ រៀបចំរចនាសម្ព័ន្ធ និងត្រួតពិនិត្យការវិនិយោគរបស់ខ្លួន ស្របតាមគោលនយោបាយ នីតិវិធី និងស្តង់ដារ ដែលអាចអនុវត្តបាន របស់ IFC។ ភាពយូរអង្វែងនៃការបរាជ័យទាំងនេះ ទោះបីជាមានការសវនកម្ម និងការត្រួតពិនិត្យកាលពីមុនក៏ដោយ គាំទ្រថា នៅតែមានចន្លោះប្រហោងដ៏ធំនៅក្នុងក្របខណ្ឌ E&S របស់ IFC និងគោលនយោបាយ និងនីតិវិធីដែលពាក់ព័ន្ធ ដែលត្រូវតែដោះស្រាយ ដើម្បីកែលម្អការសមិទ្ធកម្មផ្នែកសង្គមនៃការវិនិយោគមីក្រូហិរញ្ញវត្ថុរបស់ IFC។

## IV. បញ្ហានេះស្ថិតនៅក្រោមអាណត្តិរបស់ស៊ីអេអូ ដោយសារកង្វះខាតការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ននិងការត្រួតពិនិត្យរបស់ IFC ដែលបណ្តាលឲ្យមានគម្រោងបង្កការខូចខាតផ្នែកសង្គមចំពោះដើមបណ្តឹង ដែលបំពានលើស្តង់ដារសមិទ្ធកម្ម និងបញ្ជីផាត់ចេញរបស់ IFC ផ្ទាល់

122. បទពិសោធន៍របស់ដើមបណ្តឹងបង្ហាញអំពីផលប៉ះពាល់អវិជ្ជមាននៃសង្គម ពាក់ព័ន្ធនឹងសកម្ម-ភាពអាជីវកម្មដែលគ្មានសីលធម៌ និងបង្ខិតបង្ខំរបស់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC តាមរយៈគម្រោងមីក្រូហិរញ្ញវត្ថុដែលផ្តល់ហិរញ្ញប្បទានដោយ IFC នៅក្នុងប្រទេសកម្ពុជា។ ការខូចខាតដែលត្រូវបានកំណត់នៅក្នុងពាក្យបណ្តឹងនេះគឺ ផ្ទុយនឹងបេសកកម្ម យុទ្ធសាស្ត្រវិនិយោគ និង ក្របខណ្ឌ E&S របស់ IFC។ ហេតុការណ៍ ដែលត្រូវបានរាយការណ៍ អំពីពលកម្មកុមារ និងផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច គឺជាការរំលោភបំពានយ៉ាងច្បាស់លាស់លើបញ្ជីផាត់ចេញរបស់ IFC។ ផលប៉ះពាល់អវិជ្ជមាននៃសង្គមដទៃទៀត ដែលត្រូវបានរាយការណ៍ដោយដើមបណ្តឹង រួមទាំងការបរិភោគអាហារតិច និងមានគុណភាពមិនល្អ និងការដកហូតដីធ្លី គឺអសង្គតិភាពនឹងស្តង់ដារសមិទ្ធកម្មរបស់ IFC ដែលបង្ហាញទាំងកម្រិត និងភាពធ្ងន់ធ្ងរនៃការខូចខាត ដែលទាក់ទងនឹងគម្រោងរបស់ IFC។

123. ស្តង់ដារសមិទ្ធកម្មរបស់ IFC ណែនាំអតិថិជនដោយផ្ទាល់ អំពីរបៀបជៀសវាង កាត់បន្ថយ និងគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់សង្គម និងបរិស្ថានអវិជ្ជមាននៅក្នុងសកម្មភាពគម្រោង។[218] អតិថិជនអន្តរការីហិរញ្ញវត្ថុរបស់ IFC ត្រូវបានតម្រូវឱ្យអនុវត្តស្តង់ដារសមិទ្ធកម្មចំពោះសកម្មភាពដែលមានហានិភ័យខ្ពស់តែប៉ុណ្ណោះ។[219] ទោះបីជាយ៉ាងណាក៏ដោយ ការខូចខាតដល់សង្គមខុសៗគ្នា ដែលទទួលរងដោយ

---

[216] [ត្រូវបានលុបចោល]

[217] [ត្រូវបានលុបចោល]

[218] IFC ស្តង់ដារសមិទ្ធកម្ម ទី១៖ ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម (ឆ្នាំ២០១២) នៅកថាខណ្ឌ ១ [តទៅហៅថា PS1].

[219] កំណត់សម្គាល់អំពីការបកស្រាយរបស់ FI កំណត់សម្គាល់ខាងលើលេខ ១១១ នៅកថាខណ្ឌ IN១០, IN១២, IN១៣.

ដើមបណ្ដឹង ស្ថិតនៅក្នុងវិសាលភាពនៃស្តង់ដារសមិទ្ធកម្មយ៉ាងតិចប្រាំក្នុងចំណោមស្តង់ដារសមិទ្ធកម្មទាំងប្រាំបីរបស់ IFC រួមទាំងការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និងផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិចផងដែរ។ ការខូចខាតទាំងនោះបង្ហាញថា ការវិនិយោគមីក្រូហិរញ្ញវត្ថុរបស់ IFC នៅក្នុងបរិយាកាសគ្មានការគ្រប់គ្រង យោយៅ និងមានការបំពាននៅកម្ពុជា នាពេលបច្ចុប្បន្ន គឺជាសកម្មភាពដែលមានហានិភ័យខ្ពស់។ ដូច្នេះ កម្រិតនៃហានិភ័យ និងផលប៉ះពាល់សង្គមគឺជាកត្តាដែល IFC បានកំណត់ថា មានកង្វល់ខ្លាំងបំផុតនៅក្នុងគម្រោងរបស់ខ្លួន ហើយលក្ខខណ្ឌកម្ចី និង ESMS របស់អតិថិជនគួរតែត្រូវបានកំណត់ និងជៀសវាង កាត់បន្ថយ និងគ្រប់គ្រងហានិភ័យទាំងនេះឲ្យបានសមស្រប។

124. លើសពីនេះទៀត បញ្ជីផាត់ចេញរបស់ IFC អនុវត្តចំពោះរាល់ហិរញ្ញប្បទានទាំងអស់ និងកំណត់បញ្ជីគម្រោងដែលត្រូវបានហាមឃាត់ ដែលមិនអាចប្រើមូលនិធិរបស់ IFC បាន។ នៅពេលវិនិយោគលើសកម្មភាពមីក្រូហិរញ្ញវត្ថុ បញ្ជីហាមឃាត់បានរួមបញ្ចូលគម្រោង ឬសកម្មភាព ដែលពាក់ព័ន្ធនឹងពលកម្មកុមារដែលមានគ្រោះថ្នាក់ និងសកម្មភាពដែលប៉ះពាល់ដល់ដីធ្លី ដែលត្រូវបានកាន់កាប់ ឬទាមទារដោយជនជាតិដើមភាគតិច ដោយគ្មានការយល់ព្រមជាឯកសារពេញលេញរបស់ពួកគេ។

**ស្តង់ដារសមិទ្ធកម្មទី១៖ ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម**

125. ការខូចខាតផ្នែកសង្គមដ៏ធ្ងន់ធ្ងរជាច្រើន ដែលទទួលរងដោយដើមបណ្ដឹង ដែលផ្ទុយពីស្តង់ដារសមិទ្ធកម្មជាក់លាក់ជាច្រើនរបស់ IFC បង្ហាញថា អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC បានបរាជ័យក្នុងការបង្កើត និងអនុវត្ត ESMS ឲ្យបានគ្រប់គ្រាន់ ដែល IFC បានបរាជ័យក្នុងការពិចារណាឱ្យបានត្រឹមត្រូវនៅក្នុងការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន និងការត្រួតពិនិត្យរបស់ខ្លួន។ ស្តង់ដារសមិទ្ធកម្ម ទី១ អនុវត្តចំពោះរាល់គម្រោង ដែលមានហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម ដោយមិនគិតពីការចាត់ថ្នាក់ហានិភ័យនោះទេ។[220] ស្តង់ដារសមិទ្ធកម្ម ទី១ ផ្តល់មគ្គុទ្ទេសក៍ណែនាំដល់អតិថិជនរបស់ IFC អំពីការបង្កើត (i) ការវាយតម្លៃប្រកបដោយសមាហរណកម្ម ដើម្បីកំណត់អំពីផលប៉ះពាល់បរិស្ថាន និងសង្គម និងហានិភ័យដែលពាក់ព័ន្ធនឹងគម្រោង (ii) ឥទ្ធិពលនៃការចូលរួមរបស់សហ គមន៍ និងការពិគ្រោះយោបល់អំពីសកម្មភាពគម្រោង និង (iii) ការគ្រប់គ្រងរបស់អតិថិជន IFC លើសមិទ្ធកម្មផ្នែកបរិស្ថាន និងសង្គម នៅក្នុងគម្រោងទាំងមូល។[221] ស្តង់ដារសមិទ្ធកម្ម ទី១ អនុវត្តចំពោះរាល់គម្រោង ដែលមានហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម។[222] អន្តរការីហិរញ្ញវត្ថុនៅពេលបង្កើត និងដំណើរការ ESMS របស់ពួកគេ គួរតែរួមបញ្ចូលស្តង់ដារសមិទ្ធកម្ម ទី១។[223]

---

[220] *សូមមើល* PS1 កំណត់សម្គាល់ខាងលើ លេខ ២១៨ នៅកថាខណ្ឌ ៤.

[221] *Id.* នៅកថាខណ្ឌ ៣.

[222] *Id.* នៅកថាខណ្ឌ ៤.

[223] *សូមមើល* គោលនយោបាយ E&S កំណត់សម្គាល់ខាងលើ លេខ ១១០ នៅកថាខណ្ឌ ៣៥.

126. [ត្រូវបានលុបចោល][224] [225] [226] [227]

127. [ត្រូវបានលុបចោល][228] [229] [230] [231] [232] [233]

128. យន្តការបណ្តឹងសារទុក្ខត្រូវតែបង្កើតឡើងសម្រាប់សហគមន៍ដែលរងផលប៉ះពាល់ ដើម្បីជួយសម្រួលដល់ដំណោះស្រាយនៃកង្វល់នានា តាមរយៈដំណើរការភ្លាមៗ អាចយល់បាន និងមានតម្លាភាព។[234] អតិថិជនរបស់ IFC ទទួលបន្ទុកផ្តល់ព័ត៌មានដល់សហគមន៍ដែលរងផលប៉ះពាល់អំពីយន្តការបណ្តឹងសារទុក្ខដែលមាន។[235]

129. [ត្រូវបានលុបចោល][236] [237] [238]

130. [ត្រូវបានលុបចោល][239] [240] [241]

## (a) **អេស៊ីលីដា**

131. ព័ត៌មានលម្អិតអំពី ESMS របស់អេស៊ីលីដា មិនត្រូវបានបង្ហាញជាសាធារណៈនោះទេ ហើយរបាយការណ៍ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គមសម្រាប់ឆ្នាំ២០២០ របស់អេស៊ីលីដា មិនបានលើកឡើងអំពីការវាយតម្លៃ ឬការគ្រប់គ្រងហានិភ័យ E&S ពីសកម្មភាពមីក្រូហិរញ្ញវត្ថុរបស់ខ្លួននោះទេ។[242] អេស៊ីលីដាបានស្ទង់មតិសំណាកដែលត្រូវបានជ្រើសរើសដោយចៃដន្យនៃអ្នកខ្ចី ដែលជា SME ចំនួន ២.១៧២ នាក់ អំពីស្ថានភាពប្រាក់ចំណូលតាមការយល់ឃើញរបស់ពួកគេ នៅចន្លោះខែធ្នូ ឆ្នាំ២០២០ រហូតដល់

---

[224] PS1 កំណត់សម្គាល់ខាងលើ លេខ ២១៨ នៅកថាខណ្ឌ ៧.

[225] "ត្រូវបានកំណត់ថាជាការអនុវត្តជំនាញវិជ្ជាជីវៈ ភាពឧស្សាហ៍ព្យាយាម ភាពប្រុងប្រយ័ត្ន និងការគិតទុកជាមុន ដែលនឹងមានការរំពឹងទុកយ៉ាងសមហេតុផលពីអ្នកវិជ្ជាជីវៈដែលមានជំនាញ និងមានបទពិសោធន៍ ដែលចូលរួមនៅក្នុងប្រភេទការងារដូចគ្នា ក្រោមកាលៈទេសៈដូចគ្នា ឬស្រដៀងគ្នា នៅទូទាំងពិភពលោក..." *Id.* at ៣ n.១០.

[226] *Id.* នៅកថាខណ្ឌ ៧.

[227] *Id.*

[228] *Id.* នៅកថាខណ្ឌ ១៣.

[229] PS1 កំណត់សម្គាល់ខាងលើ លេខ ២១៨ នៅកថាខណ្ឌ ១៤–១៥.

[230] *Id.* នៅកថាខណ្ឌ ១៧.

[231] *Id.* នៅកថាខណ្ឌ ២២.

[232] *Id.* នៅកថាខណ្ឌ ២៥.

[233] PS1 កំណត់សម្គាល់ខាងលើ លេខ ២១៨ នៅកថាខណ្ឌ ២៣.

[234] PS1 កំណត់សម្គាល់ខាងលើ លេខ ២១៨ នៅកថាខណ្ឌ ២៣.

[235] *សូមមើល id.*

[236] [ត្រូវបានលុបចោល]

[237] [ត្រូវបានលុបចោល]

[238] [ត្រូវបានលុបចោល]

[239] [ត្រូវបានលុបចោល]

[240] [ត្រូវបានលុបចោល]

[241] [ត្រូវបានលុបចោល]

[242] *សូមមើល*ធនាគារអេស៊ីលីដា របាយការណ៍ប្រចាំឆ្នាំ ២០២០ នៅទំព័រ ៣៨–៤២ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ https://www.acledabank.com.kh/kh/assets/pdf_zip/ACLEDA%20Bank%20-%20Annual%20Report%202020.pdf. សូចនាករសមិទ្ធកម្មផ្នែកសង្គម ដែលត្រូវបានកំណត់ដោយអេស៊ីលីដាគឺ ផលធៀបយេនឌ័រ និងការបណ្តុះបណ្តាលនិយោជិករបស់ខ្លួនតែប៉ុណ្ណោះ។*Id.* នៅ ៣៨.

ខែមករា ឆ្នាំ២០២១ តែប៉ុណ្ណោះ និងបានលើកឡើងថា ១៥,៦១ ភាគរយ យល់ថា ពួកគេមានជីវភាពអន់ថយជាងពីមុន។[243] ការស្ទង់មតិរបស់អេស៊ីលីដាមិនបានពិចារណាអំពីហានិភ័យ E&S ដែលពាក់ព័ន្ធនោះទេ រួមទាំងហានិភ័យចំពោះប្រជាជនដែលត្រូវការពារ ដូចជា ជនជាតិដើមភាគតិច ជាដើម។ ផ្ទុយទៅវិញ កិច្ចសម្ភាសន៍ដែលត្រូវបានធ្វើឡើងដោយអង្គការមិនរដ្ឋាភិបាលឯករាជ្យ ដូចជា អង្គការលីកាដូ ជាមួយអ្នកខ្ចីអេស៊ីលីដា បានចងក្រងជាឯកសារអំពីផលប៉ះពាល់អវិជ្ជមានផ្នែកសង្គមជាច្រើន រួមទាំងផលប៉ះពាល់ដែលពាក់ព័ន្ធនឹងស្តង់ដារសមិទ្ធកម្មផងដែរ។[244] វេបសាយត៍របស់អេស៊ីលីដា រួមបញ្ចូលទម្រង់អនឡាញ ដើម្បីដាក់បណ្តឹងសារទុក្ខ និងចែងថា ពាក្យបណ្តឹងទាក់ទងនឹងសកម្មភាពរបស់អេស៊ីលីដា ក៏អាចដាក់ជូនតាមអ៊ីមែល តាមរយៈខ្សែទូរសព្ទបន្ទាន់ ឬដោយផ្ទាល់ នៅការិយាល័យអេស៊ីលីដាបានដែរ។[245] របាយការណ៍ប្រចាំឆ្នាំ២០២០ ពុំមានព័ត៌មានទាក់ទងនឹងយន្តការបណ្តឹងសារទុក្ខ នៅក្រៅពេលវេលាកំណត់ ក្នុងការដាក់ពាក្យបណ្តឹង និងទទួលបានការឆ្លើយតប ហើយក៏មិនបានរៀបរាប់អំពីហេតុការណ៍នៃពាក្យបណ្តឹង ឬដំណោះស្រាយនោះដែរ។[246]

132. នៅឆ្នាំ២០១៩ ជាលក្ខខណ្ឌមួយនៃគម្រោងលេខ ៤២៤៨0 IFC បានផ្តល់កម្ចីបន្ទាប់បន្សំដល់អេស៊ីលីដា រហូតដល់ ៦០ លានដុល្លារអាមេរិក ដោយផ្តោតលើ SMEs និង SMEs ដែលគ្រប់គ្រងដោយស្ត្រី IFC បានតម្រូវឱ្យអេស៊ីលីដា "កែលម្អ ESMS ដើម្បីធ្វើវិសោធនកម្មវិសាលភាពនៃការអនុវត្តស្តង់ដារសមិទ្ធកម្ម"។[247] លក្ខខណ្ឌនេះបង្កប់នូវការទទួលស្គាល់អំពីបញ្ហាក្នុងការកំណត់ និងការគ្រប់គ្រងរបស់អេស៊ីលីដាចំពោះផលប៉ះពាល់សង្គមដែលបង្កការខូចខាត ដោយសារសកម្មភាពផ្តល់កម្ចីដល់ SME របស់ខ្លួន។ ទោះបីជាយ៉ាងណាក៏ដោយ ពីរឆ្នាំកន្លះក្រោយមក ពុំមានព័ត៌មានជាសាធារណៈអំពីរបៀបដែលអេស៊ីលីដាបានវាយតម្លៃ និងកែលម្អ ESMS របស់ខ្លួន ឬថាតើខ្លួនបានអនុលោមតាមលក្ខខណ្ឌនេះ ដែលពោរពេញដោយអត្ថន័យនោះទេ។ មូលដ្ឋានទិន្នន័យអំពីគម្រោងរបស់ IFC គ្រាន់តែដាក់ "កាលបរិច្ឆេទបញ្ចប់តាមការរំពឹងទុក" គឺនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០១៩ ដែលត្រូវ "ដំឡើងកម្រិត ESMS"។[248] ផ្ទុយទៅវិញ ការខូចខាតសង្គម ដែលដើមបណ្តឹង [ត្រូវបានលុបចោល] ទទួលរង បន្ទាប់ពីបានខ្ចីប្រាក់ ទាក់ទងនឹងគម្រោង IFC នេះ ដែលរួមមាន ការអនុវត្តក្នុងការផ្តល់កម្ចីដោយគ្មានសីលធម៌ ការអនុវត្តក្នុងការប្រមូលប្រាក់ដោយបំពាន ការបាត់បង់មុខរបរចិញ្ចឹមជីវិត និងពលកម្មកុមារ គាំទ្រដល់ការសន្និដ្ឋានថា បញ្ហានៅតែបន្តកើតមាន នៅក្នុងការកំណត់ និងការគ្រប់គ្រងរបស់អេស៊ីលីដាចំពោះផលប៉ះពាល់សង្គម ដែលបង្កការខូចខាត។ **[ត្រូវបានលុបចោល]**[249] ដូច្នេះ ការខកខានរបស់ IFC ក្នុង

---

[243] *Id.* នៅ ៤១.

[244] [ត្រូវបានលុបចោល]

[245] ធនាគារអេស៊ីលីដា ទម្រង់ពាក្យបណ្តឹង https://www.acledabank.com.kh/kh/eng/cu_complaintform.

[246] *Cf.* IFC កំណត់សម្គាល់អំពីការអនុវត្តល្អ ការដោះស្រាយបណ្តឹងសារទុកពីសហគមន៍ដែលរងផលប៉ះពាល់ដោយសារគម្រោង ខែកញ្ញា ឆ្នាំ ២០០៩ នៅ ៧–២៧ [តទៅ ហៅថា កំណត់សម្គាល់អំពីការអនុវត្តរបស់ IFC ចំពោះបណ្តឹងសារទុក្ខ].

[247] ព័ត៌មាន និងបណ្តុំទិន្នន័យអំពីគម្រោងរបស់ IFC គម្រោងលេខ ៤២៤៨0 សេចក្តីសង្ខេបអំពីព័ត៌មាននៃការវិនិយោគ (SII) ភាពសមហេតុផលក្នុងការចាត់ថ្នាក់ផ្នែកបរិស្ថាន និងសង្គម/ហានិភ័យ និងការកាត់បន្ថយ ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម https://disclosures.ifc.org/project-detail/SII/42480/acleda-subdebt-III.

[248] *Id.* នៅ វិធានការកាត់បន្ថយ/ផែនការសកម្មភាពបរិស្ថាន និងសង្គម (ESAP).

[249] [ត្រូវបានលុបចោល]

ការត្រួតពិនិត្យគម្រោងឱ្យបានគ្រប់គ្រាន់ និងភាពអនុលោមតាមលក្ខខណ្ឌកម្ចីរបស់អតិថិជន អនុញ្ញាតឱ្យមានការបន្តការខូចខាតដែលទាក់ទងនឹងគម្រោង រួមទាំងពលកម្មកុមារផងដែរ។

133. [ត្រូវបានលុបចោល][250] [251] [252] [253]

## (b) **អម្រឹត**

134. ព័ត៌មានលម្អិតអំពី ESMS របស់អម្រឹត មិនត្រូវបានបង្ហាញជាសាធារណៈដោយ MFI ឬ IFC នោះទេ។ ផ្នែក "ការគ្រប់គ្រងសមិទ្ធកម្មសង្គម" នៅលើវែបសាយត៍របស់អម្រឹត ផ្តល់ទិដ្ឋភាពទូទៅអំពីគោលការណ៍កិច្ចការពារអតិថិជនរបស់យុទ្ធនាការ Smart ដែលអម្រឹតបានប្រើជាគោលការណ៍ណែនាំសម្រាប់កិច្ចការពារអ្នកប្រើប្រាស់។[254] របាយការណ៍ប្រចាំឆ្នាំ២០២០ របស់អម្រឹត ផ្តល់ទិដ្ឋភាពទូទៅអំពីទិដ្ឋភាពមួយចំនួននៃ ESMS របស់ខ្លួន។[255] អម្រឹត រៀបរាប់យ៉ាងទូលំទូលាយអំពីការត្រួតពិនិត្យកម្ចី សម្រាប់ហានិភ័យ E&S ដោយមិនបានបញ្ជាក់ ឧទាហរណ៍ ទិន្នន័យមូលដ្ឋាន កម្រិតនៃភាពលម្អិត និងវិសាលភាពលទ្ធផល ឬនីតិវិធី និងផែនការ ដែលត្រូវបាន ឬអាចត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយ ឬកាត់បន្ថយហានិភ័យដែលត្រូវបានកំណត់នោះទេ។[256] លើសពីនេះទៀត អម្រឹតរាយការណ៍តែការត្រួតពិនិត្យកម្ចីដែលមានចំនួនលើស ១០.០០០ ដុល្លារអាមេរិក សម្រាប់ហានិភ័យ E&S[257] ទោះបីជាការត្រួតពិនិត្យ និងការតាមដានសកម្មភាពផ្តល់កម្ចីខ្នាតមីក្រូ (កម្ចីក្រោម ១០,០០០ ដុល្លារអាមេរិក) គឺជាលក្ខខណ្ឌតម្រូវនៃកិច្ចព្រមព្រៀងវិនិយោគលើគម្រោង IFC របស់អម្រឹតក៏ដោយ[258] ហើយអម្រឹតបានចេញកម្ចីបុគ្គលយ៉ាងតិច ២.៨៤៨ នៅឆ្នាំ២០២០។[259] របាយការណ៍ប្រចាំឆ្នាំ២០២០ របស់អម្រឹត ចែងថា MFI អនុលោមតាមគោលការណ៍ណែនាំ CPP សម្រាប់ "ការដាក់ឲ្យប្រើប្រាស់ប្រព័ន្ធដែលមានប្រសិទ្ធភាពដើម្បីទទួល និងដោះស្រាយពាក្យបណ្តឹងរបស់អតិថិជន"[260] ទោះបីជាយ៉ាងណាក៏ដោយ ពុំមានព័ត៌មានទាក់ទងនឹងការដាក់ពាក្យបណ្តឹងជាសាធារណៈនៅលើវែបសាយត៍របស់អម្រឹតទេ ហើយរបាយការណ៍ប្រចាំឆ្នាំមិនបានពន្យល់ថាតើមានយន្តការបណ្តឹងសារទុក្ខអ្វីខ្លះ ឬមិនបានផ្តល់ទិន្នន័យទាក់ទងនឹងពាក្យ

---

[250] [ត្រូវបានលុបចោល]

[251] [ត្រូវបានលុបចោល]

[252] [ត្រូវបានលុបចោល]

[253] សូមមើល IFC កំណត់សម្គាល់ការណែនាំលេខ ១៖ ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១២ នៅកថាខណ្ឌ ១៦ [តទៅ ហៅថា កំណត់សម្គាល់ការណែនាំអំពី PS1].

[254] អម្រឹត ការគ្រប់គ្រងសមិទ្ធកម្មសង្គម https://www.amret.com.kh/en/environmental-social-performance.

[255] អម្រឹត របាយការណ៍ប្រចាំឆ្នាំ២០២០ នៅ ៤៧–៥២, https://www.amret.com.kh/en/annual-reports.

[256] *សូមមើល id.* នៅ ៤៨.

[257] *ប្រៀបធៀប id.* នៅ ៤៨ (កម្ចី ១២.៨២៦ ត្រូវបានត្រួតពិនិត្យ ដើម្បីស្វែងរកហានិភ័យ E&S) *និង* អម្រឹត ការគ្រប់គ្រងសមិទ្ធកម្មសង្គម https://www.amret.com.kh/en/environmental-social-performance (*សំណើសុំកម្ចីចំនួន ១២.៨២៦ ដែលមានទំហំកម្ចីលើស ១០,០០០ ដុល្លារ* ត្រូវបានត្រួតពិនិត្យ ដើម្បីស្វែងរក E&S) (បញ្ជាក់បន្ថែម).

[258] *សូមមើល ឧ.* ព័ត៌មាន និងបណ្តុំទិន្នន័យអំពីគម្រោងរបស់ IFC គម្រោងលេខ ៣៤៧៤៨៖ សេចក្តីសង្ខេបអំពីព័ត៌មាននៃការវិនិយោគ (SII) ភាពសមហេតុផលក្នុងការចាត់ថ្នាក់ផ្នែកបរិស្ថាន និងសង្គម/ហានិភ័យ និងការកាត់បន្ថយ https://disclosures.ifc.org/project-detail/SII/៣៤៧៤៨/amret-mfi-equity.

[259] *សូមមើល* អម្រឹត របាយការណ៍ប្រចាំឆ្នាំ២០២០ កំណត់សម្គាល់ខាងលើ លេខ ២៥៥ នៅ ២៦ "ផលបត្រកម្ចី"

[260] *Id.* នៅ ៥២.

បណ្តឹង ដែលបានទទួល និងបានដោះស្រាយនោះទេ។ សេចក្តីសង្ខេបអំពីការត្រួតពិនិត្យផ្នែកបរិស្ថាន និងសង្គមរបស់ IFC និងផែនការសកម្មភាពផ្នែកបរិស្ថាន និងសង្គម ដែលពាក់ព័ន្ធ មិនអាចស្វែងរកបានជាសាធារណៈនោះទេ។[261]

135. **[ត្រូវបានលុបចោល]** កង្វះខាតការអនុវត្ត ឬការអនុវត្តឱ្យបានគ្រប់គ្រាន់ ដើម្បីដោះស្រាយការប្រព្រឹត្តិដោយបំពាន ដែលបានប្រព្រឹត្តដោយមន្ត្រីអម្រឹតជាច្រើននាក់ ជាច្រើនលើកច្រើនសារ បង្ហាញថា អម្រឹតខ្វះខាត ESMS គ្រប់ជ្រុងជ្រោយ។ លើសពីនេះទៀត អវត្តមានយន្តការបណ្តឹងសារទុក្ខដែលមានប្រសិទ្ធភាព រួមជាមួយការស៊ើបអង្កេត ដំណោះស្រាយ និងទិដ្ឋភាពនៃការពិនិត្យតាមដាន[262] ឬការខកខានមិនបានអនុវត្តយន្តការទាំងនោះ គាំទ្របន្ថែមទៀតថា អម្រឹតមិនបានអនុវត្ត ឬពង្រឹងការអនុវត្ត ESMS ឲ្យបានគ្រប់គ្រាន់នោះទេ។ ដូច្នេះ ការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នមុនពេលអនុវត្តគម្រោង និងការត្រួតពិនិត្យគម្រោងរបស់ IFC ខកខានមិនបានវាយតម្លៃការខូចខាតសង្គមជាបន្តបន្ទាប់ ពាក់ព័ន្ធនឹងការវិនិយោគរបស់អម្រឹតឲ្យបានគ្រប់គ្រាន់នោះទេ។

### (c) **អិលអូអិលស៊ី**

136. ព័ត៌មានលម្អិតអំពី ESMS របស់អិលអូអិលស៊ីមិនត្រូវបានបង្ហាញជាសាធារណៈដោយ MFI ឬ IFC នោះទេ។ របាយការណ៍ប្រចាំឆ្នាំ ២០២០ របស់អិលអូអិលស៊ី បានយោងត្រួសៗដល់គោលការណ៍ណែនាំ E&S ដែលចែងថា ការកំណត់ហានិភ័យត្រូវបានអនុវត្តចំពោះកម្ចីដែលមានទឹកប្រាក់ចំនួន ៣០.០០០ ដុល្លារអាមេរិកឡើង តែប៉ុណ្ណោះ។[263] ការផ្តល់មូលនិធិរបស់អិលអូអិលស៊ីមួយចំនួន បានមកពីមូលនិធិគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុលអាស៊ី (MIFA) ដែល IFC កាន់កាប់ភាគហ៊ុន និងជាវិនិយោគិនធំ។ ការវិនិយោគលើមូលធនរបស់ IFC និងកម្ចីចំនួន ២០ លានដុល្លារអាមេរិក ដែលត្រូវបានចេញនៅឆ្នាំ២០២១ (គម្រោង IFC លេខ ៣១៤៦៧) តម្រូវឲ្យ MFIs ដែលបានទទួលការគាំទ្រមានដំណើរការគ្រប់គ្រាន់សម្រាប់ "រាល់ការវិនិយោគ" នឹងត្រូវត្រួតពិនិត្យ និងដំណើរការ ដើម្បីបញ្ចៀសការគាំទ្រសកម្មភាពនៅលើបញ្ជីផាត់ចេញនៃមីក្រូហិរញ្ញវត្ថុ"។[264] វេបសាយត៍របស់អិលអូអិលស៊ី រួមបញ្ចូលតំណភ្ជាប់មួយ ដើម្បីដាក់ពាក្យបណ្តឹងជាភាសាអង់គ្លេស ប៉ុន្តែទំព័រជាភាសាខ្មែររបស់វាប្រើប្រាស់ពាក្យ ដែលបកប្រែថា "គំនិត" ជាមតិត្រឡប់ដ៏ទូទៅមួយ ដែលខុសពីពាក្យជាភាសាខ្មែរថា "ពាក្យបណ្តឹង"។ ចុចតំណភ្ជាប់ដើម្បីបើកចូលទៅកាន់ទម្រង់ផ្តល់មតិយោបល់ជាទូទៅ មានសសេរអក្សរកាត់ និងមិនបានផ្តល់ព័ត៌មានបន្ថែមណាមួយ ទាក់ទងនឹងដំណើរការ ចិរវេលា ការការពារប្រឆាំងការដាក់ទោស និងតម្លាភាព។ តំណភ្ជាប់នេះមិនបង្ហាញនៅលើប្រាវស៊ីមួយចំនួន ដូចជា Firefox ជាដើម។[265]

---

[261] *សូមមើល ឧ.* ព័ត៌មាន និងបណ្តុំទិន្នន័យអំពីគម្រោងរបស់ IFC គម្រោងលេខ ៣៧៥០៥៖ សេចក្តីសង្ខេបអំពីព័ត៌មាននៃការវិនិយោគ (SII) ផែនការសកម្មភាពបរិស្ថាន និងសង្គម (ESAP), https://disclosures.ifc.org/project-detail/SII/៣៧៥០៥/amret-ab-loan.

[262] *សូមមើល* កំណត់សម្គាល់អំពីការអនុវត្តរបស់ IFC ចំពោះបណ្តឹងសារទុក កំណត់សម្គាល់ខាងលើ លេខ ២៤៦ នៅ ២–៤, ៧–២៧.

[263] អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី របាយការណ៍ប្រចាំឆ្នាំ២០២០ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ នៅ ២៩, https://www.lolc.com.kh/en/annual- reports-investor-relation.

[264] ព័ត៌មាន និងបណ្តុំទិន្នន័យអំពីគម្រោងរបស់ IFC គម្រោងលេខ ៣១៤៦៧៖ សេចក្តីសង្ខេបអំពីព័ត៌មាននៃការវិនិយោគ (SII) បញ្ហា-ប្រភេទបរិស្ថាន និងសង្គម https://disclosures.ifc.org/project-detail/SPI/៣១៤៦៧/mifa-debt-fund (បញ្ជាក់បន្ថែម).

[265] *សូមមើល* អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី មតិយោបល់ https://www.lolc.com.kh/en/comment.

137. គម្រោងដែលផ្តល់មូលនិធិដោយ IFC នៅក្នុងអិលអូអិលស៊ី មួយផ្នែកបានមកតាមរយៈមូលនិធិគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុលអាស៊ី (MIFA) ដែលត្រូវបានតម្រូវឲ្យបង្កើត និងអនុវត្ត ESMS ជាលក្ខខណ្ឌនៃការវិនិយោគរបស់ IFC។[266] ពុំមានព័ត៌មានដែលអាចស្វែងរកបានជាសាធារណៈ ទាក់ទងនឹង ESMS សម្រាប់ MIFA ហើយរបាយការណ៍តាមកាលកំណត់ ដែលពួកគេត្រូវដាក់ជូន IFC ក៏ពុំមានជាសាធារណៈដែរ។

138. [ត្រូវបានលុបចោល] [267] [268] [269] [270] [271] ការខកខានរបស់អិលអូអិលស៊ីក្នុងការបង្កើតឲ្យបានត្រឹមត្រូវ និងអនុវត្ត ESMSឲ្យបានគ្រប់គ្រាន់ និងការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នរបស់ IFC មិនបានគិតគូរអំពីភាពខ្វះខាតបែបនេះមុនពេលអនុវត្តគម្រោង និងនៅក្នុងការត្រួតពិនិត្យគម្រោងទាំងមូលនោះទេ បានបង្កការខូចខាតជាបន្តបន្ទាប់ [ត្រូវបានលុបចោល] ក្នុងការរំលោភលើបញ្ជីផាត់ចេញ និងស្តង់ដារសមិទ្ធកម្មរបស់ IFC [ត្រូវបានលុបចោល]។

(d) **ស្ថាបនា**

139. ព័ត៌មានលម្អិតអំពី ESMS របស់ស្ថាបនា មិនត្រូវបានបង្ហាញជាសាធារណៈដោយ MFI ឬ IFC នោះទេ។ របាយការណ៍ប្រចាំឆ្នាំ២០២០ របស់ស្ថាបនា សំដៅលើគោលនយោបាយស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម ដែលតាមរបាយការណ៍ បានរួមបញ្ចូលស្តង់ដារសមិទ្ធកម្ម និងបញ្ជីផាត់ចេញ ទាក់ទងនឹងសកម្មភាពហាមឃាត់ ក៏ដូចជាការពិចារណាលើហានិភ័យ E&S នៅក្នុងគោលនយោបាយឥណទានរបស់ខ្លួនផងដែរ។[272] ព័ត៌មានលម្អិតជាក់លាក់ ទាក់ទងនឹងស្តង់ដារសមិទ្ធកម្ម សកម្មភាពហាមឃាត់ នីតិវិធី ការអនុវត្ត និងការគាំទ្រ ព្រមទាំងវិធានការកាត់បន្ថយ មិនមានបង្ហាញជាសាធារណៈទេ។ របាយការណ៍ប្រចាំឆ្នាំបង្ហាញតែយេនឌ័រ និងប្រាក់ចំណូលជាសូចនាករនៃសមិទ្ធកម្មសង្គមតែប៉ុណ្ណោះ[273] ពុំមានព័ត៌មានដែលផ្តល់ជូន ថាតើសូចនាករការខូចខាតសង្គមអ្វីខ្លះត្រូវបានពិនិត្យតាមដាន ប្រសិនបើមាន។ ពុំមានព័ត៌មានទាក់ទងនឹងយន្តការបណ្តឹងសារទុក្ខ ឬការដាក់ពាក្យបណ្តឹងនៅលើវែបសាយត៍របស់ស្ថាបនានោះទេ ហើយតំណភ្ជាប់សម្រាប់ដាក់ពាក្យបណ្តឹងត្រូវបានលាក់នៅក្នុងទម្រង់មតិត្រឡប់ទូទៅ ដែលជាភាសាខ្មែរ ពាក្យ "បណ្តឹង" មិនត្រូវបានបកប្រែជាភាសាខ្មែរថា "ពាក្យបណ្តឹង" នោះទេ ប៉ុន្តែផ្ទុយទៅវិញ វាត្រូវបានបកប្រែជា "ការបង្ហាញការមិនពេញចិត្ត"។[274]

140. [ត្រូវបានលុបចោល][275]

---

266 *Id.*

267 [ត្រូវបានលុបចោល]

268 [ត្រូវបានលុបចោល]

269 [ត្រូវបានលុបចោល]

270 [ត្រូវបានលុបចោល]

271 [ត្រូវបានលុបចោល]

272 ធនាគារស្ថាបនា របាយការណ៍ប្រចាំឆ្នាំ ២០២០ កំណត់សម្គាល់ខាងលើ លេខ ៥១.

273 *Id.* នៅ ៤៤–៤៥.

274 ធនាគារស្ថាបនា ការសួរសំណួរ មតិត្រឡប់ https://www.sathapana.com.kh/inquiry/.

275 [ត្រូវបានលុបចោល]

141. គម្រោងដែលត្រូវបានផ្តល់មូលនិធិដោយ IFC នៅក្នុងស្ថាបនា មួយផ្នែក ត្រូវបានដំណើរការតាមរយៈមូលនិធិគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុលអាស៊ី (MIFA) ដែលត្រូវបានតម្រូវឲ្យបង្កើត និងអនុវត្ត ESMS ជាលក្ខខណ្ឌនៃការវិនិយោគរបស់ IFC។[276] ពុំមានព័ត៌មានជាសាធារណៈ ពាក់ព័ន្ធនឹង ESMS សម្រាប់ MIFA ហើយរបាយការណ៍តាមកាលកំណត់ ដែលត្រូវបានតម្រូវឲ្យដាក់ជូន IFC ក៏មិនមានជាសាធារណៈដែរ។

142. **[ត្រូវបានលុបចោល]**[277] [278] ការខកខានរបស់ IFC ក្នុងការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន និងការត្រួតពិនិត្យគម្រោង ដើម្បីកំណត់ចន្លោះប្រហោងនៅក្នុង ESMS របស់ស្ថាបនា បានបង្កការខូចខាតជាបន្តបន្ទាប់ និងនៅក្នុងការត្រួតពិនិត្យគម្រោងទាំងមូលនោះទេ បានបង្កការខូចខាតជាបន្តបន្ទាប់ **[ត្រូវបានលុបចោល]**។

### (e) **ធនាគារ ហត្ថា**

143. ព័ត៌មានលម្អិតអំពី ESMS របស់ធនាគារហត្ថា មិនត្រូវបានបង្ហាញជាសាធារណៈដោយ MFI ឬ IFC នោះទេ។ របាយការណ៍ប្រចាំឆ្នាំ២០២០ របស់ធនាគារ ហត្ថា មិនបានសំដៅយោងទៅដល់ ESMS របស់ខ្លួនទេ។[279] សូចនាករសមិទ្ធកម្មសង្គមដែលត្រូវបានលើកឡើង មានតែ យេនឌ័រ ការគ្របដណ្តប់នៅជនបទ និងអត្រាក្នុងការថែរក្សាអតិថិជនតែប៉ុណ្ណោះ។[280] ពុំមានព័ត៌មានទាក់ទងនឹងយន្តការបណ្តឹងសារទុក្ខសម្រាប់តំណាងភ្ជាប់ ដើម្បីបំពេញពាក្យបណ្តឹងនៅលើវេបសាយត៍របស់ហត្ថា។ ជាលក្ខខណ្ឌនៃគម្រោង IFC ជាច្រើន ធនាគារហត្ថាត្រូវបានតម្រូវឲ្យថែរក្សា ESMS ដែលមានស្រាប់ ពីព្រោះ "តួនាទី និងទំនួលខុសត្រូវមានភាពសមស្របយ៉ាងទូលំទូលាយនឹងហានិភ័យនៃការផ្តល់កម្ចី SME ដែលមានស្រាប់"។[281]

144. **[ត្រូវបានលុបចោល]**[282] ការខកខានរបស់ IFC ក្នុងការដាក់បង្ហាញចំណុចខ្វះខាតនៃ ESMS ទាំងនោះ នៅក្នុងការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នមុនពេលអនុវត្តគម្រោង ឬការត្រួតពិនិត្យគម្រោង នាំឱ្យមូលនិធិ IFC ត្រូវបានប្រើប្រាស់ក្នុងសកម្មភាពដែល **[ត្រូវបានលុបចោល]**។

145. ព័ត៌មានតិចតួចដែលមានជាសាធារណៈ នៅលើ ESMS របស់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC បង្ហាញថា ពួកគេមិនបានបង្កើត អនុវត្ត ថែទាំ ឬធ្វើបច្ចុប្បន្នភាព ESMS ដែលរួមបញ្ចូលលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធកម្ម ទី១ បានយ៉ាងគ្រប់គ្រាន់នោះទេ។ ការខូចខាត ដែលត្រូវបានកំណត់ដោយដើមបណ្តឹងនៅក្នុងករណីនេះបង្ហាញថា ESMS របស់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC ដូចបានអនុវត្ត មិនបានកំណត់ ដោះស្រាយ ទប់ស្កាត់ ឬកាត់បន្ថយការខូចខាត

---

[276] *Id.*

[277] [ត្រូវបានលុបចោល]

[278] [ត្រូវបានលុបចោល]

[279] *ជាទូទៅ សូមមើល* ធនាគារ ហត្ថា របាយការណ៍ប្រចាំឆ្នាំ ២០២០ (ឆ្នាំ ២០២០) មាននៅ https://www.hatthabank.com/publication/reports.

[280] *Id.* នៅ ៥.

[281] ព័ត៌មាន និងបណ្តុំទិន្នន័យអំពីគម្រោងរបស់ IFC គម្រោងលេខ ៤៤៧៤២៖ សេចក្តីសង្ខេបអំពីព័ត៌មាននៃការវិនិយោគ (SII) ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS), https://disclosures.ifc.org/project-detail/SII/៤៤៧៤២/htb-sub-debt.

[282] [ត្រូវបានលុបចោល]

សង្គមធ្ងន់ធ្ងរ ដែលបង្កឡើងដោយសកម្មភាពអាជីវកម្មរបស់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC ឱ្យបានគ្រប់គ្រាន់នោះទេ។

**បញ្ជីផាត់ចេញរបស់ IFC និងស្តង់ដារសមិទ្ធកម្ម ទី២៖ ការងារ និងលក្ខខណ្ឌការងារ - ពលកម្មកុមារ**

146. និន្នាការនៃការផ្តល់កម្ចីដ៏ឃោឃៅ និងការអនុវត្តការប្រមូលប្រាក់ដោយបំពាន ដែលអនុវត្តដោយអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC ដែលត្រូវបានបង្ហាញដោយបទពិសោធន៍របស់ដើមបណ្តឹង បានជំរុញឱ្យមានពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា។ [ត្រូវបានលុបចោល] ដើមបណ្តឹងងាកទៅរកពលកម្មកុមារ ដើម្បីសងកម្ចីដែលផ្តល់ហិរញ្ញប្បទានដោយ IFC។ អន្តរការីហិរញ្ញវត្ថុត្រូវបានហាមឃាត់មិនឱ្យប្រើប្រាស់មូលនិធិ IFC ដែលត្រូវបានកំណត់សម្រាប់មីក្រូហិរញ្ញវត្ថុនៅក្នុងសកម្មភាពដែលពាក់ព័ន្ធនឹងទម្រង់គ្រោះថ្នាក់ ឬកេងប្រវ័ញ្ចពលកម្មដោយបង្ខំ ឬពលកម្មកុមារដែលបង្កគ្រោះថ្នាក់។[283]

ពលកម្មដោយបង្ខំ មានន័យថា រាល់ការងារ ឬសេវាកម្ម ដែលមិនបានអនុវត្តដោយស្ម័គ្រចិត្ត ដែលត្រូវបានទាញចេញពីបុគ្គលម្នាក់ ដែលស្ថិតក្រោមការគំរាមកំហែងដោយបង្ខំ ឬការពិន័យ។[284]

147. ស្តង់ដារសមិទ្ធកម្ម ២ ធ្វើការហាមឃាត់ស្រដៀងគ្នាចំពោះអតិថិជនរបស់ IFC ពីការជួលកុមារឲ្យប្រើកម្លាំងពលកម្មរបស់ពួកគេផ្ទាល់ នៅក្រោមកិច្ចសន្យា ឬនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ "តាមមធ្យោបាយណាមួយ"។[285] ការហាមឃាត់នេះផ្អែកលើច្បាប់អន្តរជាតិ រួមទាំងអនុសញ្ញារបស់អង្គការអន្តរជាតិស្តីពីការងារ[286] និងលិខិតូបករណ៍របស់អង្គការសហប្រជាជាតិផងដែរ។[287] ដូច្នេះ "ពលកម្មកុមារ" ត្រូវបានកំណត់និយមន័យស្របតាមនិយមន័យអន្តរជាតិ ដែលត្រូវបានទទួលយក ថាជា ការងារទាំងឡាយណាដែលធ្វើឲ្យកុមារឃ្លាតឆ្ងាយពីកុមារភាព សក្តានុពល និងសេចក្តីថ្លៃថ្នូររបស់ពួកគេ និងដែលបង្កគ្រោះថ្នាក់ដល់ការអភិវឌ្ឍផ្លូវកាយ និងផ្លូវចិត្ត។[288] ជាពិសេស "ពលកម្មកុមារ" សំដៅលើការងារដែលមានគ្រោះថ្នាក់ផ្លូវចិត្ត ផ្លូវកាយ សង្គម ឬសីលធម៌ និងបង្កគ្រោះថ្នាក់ដល់កុមារ និងរំខានដល់ការសិក្សារបស់ពួកគេតាមរយៈ៖ (i) ការធ្វើឲ្យពួកគេឃ្លាតឆ្ងាយពីឱកាសចូលរៀន (ii) ធ្វើឲ្យពួកគេមានកាតព្វកិច្ចត្រូវឈប់រៀនមុនពេលកំណត់ និង (iii) តម្រូវឱ្យពួកគេព្យាយាមរួមបញ្ចូលគ្នារវាងការចូលរៀនជាមួយការងារដែលមានរយៈពេលវែង និងមានបន្ទុកធ្ងន់។[289] ការហាមឃាត់លើទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ រួមទាំងការងារដែលមានគ្រោះថ្នាក់ ត្រូវបានបញ្ជាក់ដោយអ្នកជំនាញ ILO ថា អនុវត្តចំពោះកុមារ

---

[283] បញ្ជីផាត់ចេញរបស់ IFC https://www.ifc.org/wps/wcm/connect/topics_ext_content/ifc_external_corporate_site/sustainability-at-ifc/company-resources/ifcexclusionlist.

[284] *Id.*

[285] IFC ស្តង់ដារសមិទ្ធកម្ម ទី២៖ ការងារ និងលក្ខខណ្ឌការងារ (ឆ្នាំ២០១២) នៅកថាខណ្ឌ ៤-៧ [តទៅ ហៅថា PS2].

[286] អនុសញ្ញា ILO លេខ ៨៧ ៩៨ ២៩ ១០៥ ១៣៨ ១៨២ ១០០ ១១១.

[287] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធកុមារ មាត្រា ៣២.១; អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការការពារពលករចំណាកស្រុកទាំងអស់ និងសមាជិកគ្រួសាររបស់ពួកគេ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច និងសង្គម មាត្រា ១០.

[288] *សូមមើល* អនុសញ្ញា ILO លេខ ១៣៨ ស្តីពីអាយុអប្បបរមា (នៃការបំពេញការងារ) (ឆ្នាំ១៩៧៣); អង្គការអន្តរជាតិខាងការងារ ពលកម្មកុមារ https://www.ilo.org/ipec/facts/lang--en/index.htm.

[289] *Id.*

គ្រប់រូប ដែលមានអាយុក្រោម ១៨ ឆ្នាំ។[290]

148. ស្មារតីនៃស្តង់ដារសមិទ្ធកម្ម ទី២ គឺធានាថា គម្រោង IFC ដែលជំរុញកំណើនសេដ្ឋកិច្ច គួរតែដំណើរការតាមរបៀបដែលប្រព្រឹត្តិចំពោះកម្មករដោយស្មើភាព និងផ្តល់ជូនពួកគេនូវលក្ខខណ្ឌការងារប្រកបដោយសុវត្ថិភាព និងសុខភាពល្អ។[291] ដូច្នេះ ការអនុវត្ត PS2 នៅក្នុងបរិបទនៃពាក្យបណ្តឹងនេះ នឹងមានសង្គតិភាពនឹងចេតនានោះ និងស្រដៀងគ្នានឹងការពិនិត្យតាមដាន និងដោះស្រាយហានិភ័យនៃពលកម្មកុមារនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ទាំងមូល។[292]

149. ការអនុវត្តក្នុងការផ្តល់កម្ចីដ៏ឃោឃៅ កម្ចីលើសចំនួនកំណត់ និងការអនុវត្តក្នុងការប្រមូលប្រាក់ដោយបំពាន ដែលត្រូវបានអនុវត្តដោយអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC បានបង្កើតវដ្តបំណុលដែលមិនអាចសងបាន ដល់អ្នកខ្ចី ដែលជាមូលដ្ឋាននៃ "កាតព្វកិច្ចបំណុលមិនអាចសងបាន" ដែលត្រូវបានហាមឃាត់ ស្របតាមស្តង់ដារសមិទ្ធកម្ម ទី២។ ការសងបំណុលដ៏ច្រើនលើសលប់ធ្វើឱ្យឪពុកម្តាយអ្នកខ្ចីមិនអាចបង់ថ្លៃសេវាដែលទាក់ទងនឹងការអប់រំកូនរបស់ពួកគេបាន[293] ហើយលើសពីនេះទៀត បង្ខំកូនរបស់ពួកគេឱ្យធ្វើការងារដែលមានគ្រោះថ្នាក់[294] ដើម្បីសងប្រាក់ទៅអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC ដូច្នេះហើយ ជាចុងក្រោយ នឹងសងប្រាក់ទៅ IFC។ ដូច្នេះគម្រោងវិនិយោគរបស់ IFC នៅទីបំផុត បង្កើតកាតព្វកិច្ចបំណុលមិនអាចសងបាន ដែលជំរុញឲ្យមានពលកម្មកុមារនៅកម្ពុជា។

150. ទំនាក់ទំនងទៅវិញទៅមករវាងបំណុល MFI ដែលមិនអាចសងបាន និងពលកម្មកុមារ ជាពិសេសការងារដែលមានគ្រោះថ្នាក់ ត្រូវបានចងក្រងឯកសារយ៉ាងល្អនៅក្នុងប្រទេសកម្ពុជា និងត្រូវបានកត់សម្គាល់ដោយអង្គការអន្តរជាតិខាងការងារ[295] និងរដ្ឋាភិបាលបរទេសក្នុងការប្រឹក្សាធុរកិច្ចរបស់ពួកគេទាក់ទងនឹងការវិនិយោគដែលមានហានិភ័យខ្ពស់នៅកម្ពុជា។[296] អង្គការលីកាដូបានចងក្រងឯកសារសមាគមនៅក្នុងរបាយការណ៍ដំបូងរបស់ខ្លួន អំពីផលប៉ះពាល់សង្គមអវិជ្ជមាន នៃវិស័យមីក្រូហិរញ្ញវត្ថុ

---

[290] ILO ការសង្កេតមើលមតិយោបល់របស់អ្នកជំនាញលើការអនុវត្តអនុសញ្ញា និងអនុសាសន៍ (ឆ្នាំ២០១៣); អនុសញ្ញា ILO លេខ ១៨២ ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (ឆ្នាំ១៩៩៩).

[291] *សូមមើល* IFC កំណត់ត្រាណែនាំអំពីស្តង់ដារសមិទ្ធកម្ម ទី២៖ ការងារ និងលក្ខខណ្ឌការងារ (ឆ្នាំ២០១២) នៅកថាខណ្ឌ ១.

[292] *Id.* កថាខណ្ឌ ៧២.

[293] សាលារដ្ឋនៅប្រទេសកម្ពុជា មិនតម្រូវឲ្យបង់ថ្លៃសាលាទេ ប៉ុន្តែ ជាញឹកញាប់ មានថ្លៃសេវាបន្ថែម ទាក់ទងនឹងការអប់រំរបស់កុមារ។

[294] អង្គការលីកាដូ ការខូចខាតវត្ថុបញ្ចាំ កំណត់សម្គាល់ខាងលើ លេខ ១៤១ នៅ ៩.

[295] *សូមមើល* ILO កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) ការអនុវត្តល្អដើម្បីដោះស្រាយពលកម្មកុមារនៅកម្ពុជា នៅ ២២ (២០១៤) *មាននៅ* https://www.ilo.org/ipec/Informationresources/WCMS_IPEC_PUB_27255/lang--en/index.htm (ចូរកត់សម្គាល់ថា "ពលកម្មកុមារមានកម្រិតខ្ពស់ជាពិសេសនៅក្នុងគ្រួសារចំណាកស្រុក ដែលគ្មានដីធ្លី ដែលត្រូវលក់ដីធ្លីរបស់ពួកគេ ដើម្បីទូទាត់បំណុល").

[296] ក្រសួងការបរទេសនៃសហរដ្ឋអាមេរិក ទីប្រឹក្សាធុរកិច្ចកម្ពុជាស្តីពីការវិនិយោគដែលមានហានិភ័យខ្ពស់ និងអន្តរកម្ម សេចក្តីប្រកាសព័ត៌មាន ថ្ងៃទី ១០ ឆ្នាំ២០២១ https://www.state.gov/cambodia-business-advisory-on-high-risk-investments-and- interactions/; *សូមមើល* ក្រសួងការងារនៃសហរដ្ឋអាមេរិក ឆ្នាំ ២០២០ របកគំហើញអំពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ៖ ប្រទេសកម្ពុជា នៅ ២–៣ (ឆ្នាំ២០២១) *មាននៅ* https://www.dol.gov/sites/dolgov/files/ILAB/child_labor_reports/tda2020/Cambodia.pdf; ក្រសួងការបរទេសនៃសហរដ្ឋអាមេរិក ប្រទេសកម្ពុជា របាយការណ៍សិទ្ធិមនុស្ស ឆ្នាំ២០១៩ នៅ ២៩ (២០២០) មាននៅ https://www.state.gov/wp-content/uploads/2020/02/CAMBODIA-2019-HUMAN-RIGHTS-REPORT.pdf.

របស់កម្ពុជា នៅឆ្នាំ២០១៩ [ត្រូវបានលុបចោល][297] ដោយកត់សម្គាល់ថាបំណុលដ៏ច្រើន ជាញឹកញាប់នាំឲ្យមានការបញ្ឈប់កុមារមិនឲ្យទៅសាលារៀន ដើម្បីទៅធ្វើការនៅក្នុងស្រុក ឬធ្វើចំណាកស្រុកទៅធ្វើការ។[298] កុមារដែលធ្វើចំណាកស្រុកទៅកាន់ទីក្រុងតែម្នាក់ឯង ជាញឹកញាប់ ទៅធ្វើការងារតាមផ្ទះ ឬនៅក្នុងឧស្សាហកម្មសំណង់ បានយល់ឃើញថា ពួកគេកំពុងធ្វើការងារដែលមានគ្រោះថ្នាក់ ដែលធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យនៃការជួញដូរ ការរងរបួស និងការកេងប្រវ័ញ្ចកាន់តែខ្លាំង។[299] បំណុល MFI ក៏បានជំរុញកុមារឱ្យធ្វើការងារគ្រោះថ្នាក់នៅក្នុងវិស័យកសិកម្មផងដែរ ដូចជា ការបាញ់ថ្នាំសម្លាប់សត្វល្អិតនៅឯចម្ការចេក ឬបើមិនដូច្នេះទេ ប៉ះពាល់នឹងសារធាតុគីមីគ្រោះថ្នាក់។[300] នៅខណៈពេលដែលបំណុលឯកជន ជាពិសេស បំណុលរបស់ MFIs ត្រូវបានកត់សម្គាល់ជាពិសេសថាជា កត្តាជំរុញឲ្យមានពលកម្មកុមារនៅកម្ពុជា ជាទូទៅ ការលំបាកផ្នែកសេដ្ឋកិច្ចត្រូវបានផ្សារភ្ជាប់នឹងហេតុការណ៍ដែលកុមារចាកចេញពីសាលារៀនទៅស្វែងរកការងារធ្វើ នៅក្នុងគម្រោងអភិវឌ្ឍន៍ដទៃទៀតផងដែរ ដូចជា គម្រោងផ្លូវរថភ្លើងរបស់ ADB ជាដើម។[301] ដូច្នេះ ភាពទំនងនៃពលកម្មកុមារ ដែលជាសកម្មភាពហាមឃាត់ នៅក្រោមបញ្ជីផាត់ចេញរបស់ IFC និងជាកម្មវត្ថុនៃការណែនាំរបស់ស្តង់ដារសមិទ្ធកម្ម ទី២ បានកើតឡើងក្នុងកម្រិតខ្ពស់ និងអាចកំណត់បានយ៉ាងងាយស្រួល។ **[ត្រូវបានលុបចោល]**[302] ដូច្នេះ អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC បានបរាជ័យម្តងហើយម្តងទៀត នៅក្នុងការកំណត់ប្រតិបត្តិការទាំងនេះឱ្យបានត្រឹមត្រូវ ថាមានហានិភ័យខ្ពស់ និងអនុវត្តស្តង់ដារសមិទ្ធកម្មទៅតាមនោះ។[303] កង្វះខាត ESMS យ៉ាងសមស្រប និងការបំពានលើបញ្ជីផាត់ចេញរបស់អតិថិជន គួរតែត្រូវបានកត់សម្គាល់ និងលើកឡើងនៅក្នុងការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នមុនពេលអនុវត្តគម្រោង និងការត្រួតពិនិត្យការងាររបស់អតិថិជន។

151. [ត្រូវបានលុបចោល][304]

### ស្តង់ដារសមិទ្ធកម្ម ទី៤៖ សុខភាព សុវត្ថិភាព និងសន្តិសុខសហគមន៍

152. ការខូចខាតសង្គមអវិជ្ជមាន ដែលកើតចេញពីគម្រោងកម្ចីខ្នាតមីក្រូ ដែលផ្តល់ហិរញ្ញប្បទានដោយ IFC នៅក្នុងប្រទេសកម្ពុជា រួមមាន អសន្តិសុខស្បៀង និងការគំរាមកំហែងបន្ថែមទៀតចំពោះសុខភាព ដែលបណ្តាលមកពីកម្រិតបំណុលឯកជនដែលមិនស្ថិតស្ថេរ។ [ត្រូវបានលុបចោល] ដើមបណ្តឹងបានងាក

---

[297] [ត្រូវបានលុបចោល]

[298] អង្គការលីកាដូ ការខូចខាតវត្ថុបញ្ចាំ កំណត់សម្គាល់ខាងលើ លេខ ១៤១ នៅ ៩.

[299] *Id.*

[300] ចាន់ ម៉ិយហុង ស៊ិន ណារិន និងអ្នកដទៃទៀត "កម្មករ រួមទាំងកុមារមិនគ្រប់អាយុ ប្រឈមនឹងសារធាតុគីមីគ្រោះថ្នាក់ ដើម្បីចិញ្ចឹមជីវិតនៅក្នុងចម្ការចេកនៃប្រទេសកម្ពុជា" CamboJA News ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ https://cambojanews.com/workers- including-underage-children-brave-dangerous-chemicals-to-make-a-living-at-cambodias-banana-plantations/; *សូមមើល* អនុសញ្ញា ILO លេខ ១៨២ ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ មាត្រា ៥(៣) (១៩៩៩) (រាយនាមការងារនៅក្នុងវិស័យកសិពាណិជ្ជកម្មនៅក្នុងចំណោមការងារដែលមានទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ).

[301] របាយការណ៍ត្រួតពិនិត្យភាពអនុលោមនៃគម្រោងផ្លូវរថភ្លើងរបស់ ADB កំណត់សម្គាល់ខាងលើ លេខ ១៧១ នៅកថាខណ្ឌ ៤០ ៤២.

[302] [ត្រូវបានលុបចោល]

[303] [ត្រូវបានលុបចោល]

[304] [ត្រូវបានលុបចោល]

ទៅបរិភោគអាហារតិច និងមានគុណភាពមិនល្អ ដើម្បីខិតខំប្រឹងប្រែងបំពេញតាមការទូទាត់កម្ចីរបស់ពួកគេ។[305] ចំពោះសកម្មភាពដែលមានហានិភ័យខ្ពស់ អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC មានកាតព្វកិច្ចវាយតម្លៃហានិភ័យ និងផលប៉ះពាល់ដល់សុខភាព និងសុវត្ថិភាពនៅក្នុងវដ្តគម្រោងទាំងមូល និងបង្កើតវិធានការទប់ស្កាត់ និងកាត់បន្ថយ។[306] ហានិភ័យសុខភាពត្រូវបានបកស្រាយយ៉ាងទូលំទូលាយ ដោយពិចារណាលើការណែនាំផ្សេងទៀត ហើយនឹងរាប់បញ្ចូលទាំងអសន្តិសុខស្បៀងផងដែរ។[307] លើសពីនេះទៀត អសន្តិសុខស្បៀងត្រូវបានផ្សារភ្ជាប់ថាជាកត្តាជំរុញឲ្យមានការបំពានលើស្តង់ដារសមិទ្ធកម្ម និងសកម្មភាពហាមឃាត់ដទៃទៀត ដូចជា ពលកម្ម ជាដើម។[308]

153. ទំនាក់ទំនងទៅវិញទៅមករវាងបំណុលកម្រិតខ្ពស់ និងការបរិភោគអាហារតិច និងមានគុណភាពមិនល្អ[309] មានភាពរឹងមាំ ដោយអាហារមានចំណែក ៦៤–៦៦ ភាគរយនៃការប្រើប្រាស់ថវិកានៅក្នុងគ្រួសារកម្ពុជា។[310] នៅក្នុងការវាយតម្លៃអំពីភាពក្រីក្រ ឆ្នាំ២០១៣ ធនាគារពិភពលោកបានកត់សម្គាល់ថាប្រទេសកម្ពុជាមានការវិវត្តយឺតយ៉ាវក្នុងការប្រយុទ្ធប្រឆាំងនឹងកង្វះអាហារូបត្ថម្ភ មួយផ្នែកបណ្តាលមកពីគុណភាពអាហារមិនល្អ។[311] អសន្តិសុខស្បៀងក៏ជាកត្តាជំរុញដ៏ខ្លាំងក្លានៃកង្វះអាហារូបត្ថម្ភរបស់កុមារផងដែរ ដែលកាលពីមុន ត្រូវបានប៉ាន់ប្រមាណថា ជាមូលហេតុឫសគល់ ដែលនាំឱ្យមានករណីមរណភាពកុមារ ជាង ៦០ ភាគរយ នៅកម្ពុជា។[312] រង្វាស់កង្វះអាហារូបត្ថម្ភរបស់កុមារ រួមទាំង ភាពក្រិសក្រិន ភាពស្គមស្គាំង មិនគ្រប់ទម្ងន់ និងកង្វះមីក្រូជីវជាតិ មានកម្រិតខ្ពស់នៅក្នុងប្រទេសកម្ពុជា ទោះបីជាមានកំណើនសេដ្ឋកិច្ចជាច្រើនឆ្នាំក៏ដោយ។[313] ការបរិភោគអាហារតិច និងមានគុណភាពមិនល្អ ក៏បណ្តាលឱ្យស្ត្រីខ្វះអាហារូបត្ថម្ភ ដែលជះឥទ្ធិពលអវិជ្ជមានដល់សុខភាព និងផលិតភាពផ្ទាល់របស់ស្ត្រី ក៏ដូចជាអាហារូបត្ថម្ភ និងការអភិវឌ្ឍន៍របស់កុមារនាពេលអនាគតផងដែរ។[314]

154. ភាពលំបាកដែលប្រឈមមុខនៅក្នុងការទទួលបានអាហារូបត្ថម្ភ និងការអប់រំល្អ នៅក្នុងឆ្នាំដំបូងៗនៃជីវិតអាចរំខានដល់ការអភិវឌ្ឍន៍ខួរក្បាល សុខភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស ផលប៉ះពាល់ដែលអាចបន្តពេញមួយជីវិតនៅក្នុងទម្រង់នៃការបញ្ចប់ការសិក្សាថ្នាក់ទាប ប្រាក់ចំណូលរបស់មនុស្សពេញវ័យ

---

305 [ត្រូវបានលុបចោល]

306 IFC ស្តង់ដារសមិទ្ធកម្ម ទី៤៖ សុខភាព សុវត្ថិភាព និងសន្តិសុខសហគមន៍ (ឆ្នាំ២០១២) នៅកថាខណ្ឌ ៥ [តទៅ ហៅថា PS4].

307 *Cf.* IFC, កំណត់សម្គាល់ការណែនាំអំពីស្តង់ដារសមិទ្ធកម្ម ទី៤៖ សុខភាព សុវត្ថិភាព និងសន្តិសុខសហគមន៍ (២០១២) នៅគន្លងនិទ្ទេសពន្យល់ទំព័រ ១៦ (ដោយកត់សម្គាល់ថា លក្ខខណ្ឌតម្រូវរបស់ PS4 គឺផ្អែកលើគោលការណ៍នានា នៅក្នុងគោលការណ៍ណែនាំ ដែលរួមបញ្ចូល ការណែនាំរបស់ IFC ស្តីពីការវាយតម្លៃផលប៉ះពាល់ផ្នែកសុខភាព ការណែនាំដោយ INDEPTH អំពីការវាយតម្លៃសុខភាព និងប្រជាសាស្ត្រនៅតាមរយៈបណ្តោយ និងប្រព័ន្ធរបស់អង្គការសុខភាពពិភពលោកសម្រាប់វាស់វែងអាយុជីវិតដែលបាត់បង់ដោយសារសុខភាពមិនល្អ)។

308 *សូមមើល* OHCHR ព្រឹត្តិបត្រព័ត៌មាន លេខ ៣៤៖ សិទ្ធិទទួលបានស្បៀងអាហារគ្រប់គ្រាន់ នៅ ៦ (២០១០) ("កុមាររងគ្រោះដោយសារភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ ងាយរងគ្រោះដោយសារការជួលឲ្យធ្វើការនៅក្នុងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដើម្បីរស់រានមានជីវិត").

309 អង្គការលីកាដូ សិទ្ធិទទួលបានការជួយសង្គ្រោះ កំណត់សម្គាល់ខាងលើ លេខ ៨ នៅ ៤.

310 *សូមមើល* ធនាគារពិភពលោក ការវាយតម្លៃអំពីភាពក្រីក្រនៅកម្ពុជា ឆ្នាំ ២០១៣ (២០១៣) នៅ ៨ ប្រអប់ ១.

311 ធនាគារពិភពលោក ការវាយតម្លៃអំពីភាពក្រីក្រនៅកម្ពុជា (២០១៣) នៅ XVIII.

312 ធនាគារពិភពលោក បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា៖ ការអភិវឌ្ឍន៍ និងការក្រឡេកមើលសេដ្ឋកិច្ចនាពេលថ្មីៗនេះ បញ្ហាដែលត្រូវបានជ្រើសរើស៖ សុខភាព និងអាហារូបត្ថម្ភរបស់កុមារតូច នៅ ៣៩ (ខែឧសភា ឆ្នាំ២០១៩) (ដកស្រង់ពីទិន្នន័យពីឆ្នាំ២០១០).

313 *សូមមើល id.* នៅ ៣–៦ ៣៧.

314 *សូមមើល* ធនាគារពិភពលោក បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា កំណត់សម្គាល់ខាងលើ លេខ ៣១២ នៅ ៣៧–៣៨.

នៅកម្រិតទាប ការកើនឡើងនៃចំណាយលើសុខភាព និងភាពទំនងនៃការកើតជំងឺមិនឆ្លងរ៉ាំរ៉ៃ កម្រិតខ្ពស់ សម្រាប់មនុស្សពេញវ័យ។[315] កុមារដែលត្រូវបានចិញ្ចឹមក្រោមបន្ទុកនៃបំណុលឯកជនកម្រិតខ្ពស់ ដែលបណ្តាលមកពីការអនុវត្តក្នុងការផ្តល់ប្រាក់កម្ចីគ្មានសីលធម៌ – ការអប់រំមិនពេញលេញ កង្វះអាហារូបត្ថម្ភត្រឹមត្រូវ សុខភាពមិនល្អ – នឹងមានផលិតភាពតិចជាងគេ ៤៩ ភាគរយ ក្នុងនាមជាមនុស្សពេញវ័យម្នាក់[316] ដែលធ្វើឲ្យវដ្តនៃភាពក្រីក្រ និងការខ្ចីប្រាក់ខ្នាតមីក្រូកើតឡើងម្តងហើយម្តងទៀត។

155. [ត្រូវបានលុបចោល][317] [318] [319] [320]

**ស្តង់ដារសមិទ្ធកម្ម ទី៥៖ ការទិញដីធ្លី និងការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត**

156. ការអនុវត្តការផ្តល់ប្រាក់កម្ចីដោយគ្មានសីលធម៌ ដែលប្រើប្រាស់ដោយអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC កំណត់គោលដៅលើដីធ្លីរបស់អ្នកខ្ចី ដែលជាញឹកញាប់ គឺជាទ្រព្យសម្បត្តិតែមួយគត់សម្រាប់ជនក្រីក្រ ដោយរួមបញ្ចូលគ្នានៃកម្ចីលើសចំនួនកំណត់រួមជាមួយការអនុវត្តក្នុងការប្រមូលប្រាក់ដោយបំពាន ដើម្បីបង្កើតហានិភ័យខ្ពស់នៃការអនុវត្តតាមលំនាំដើម និងការលក់ដីធ្លីដោយបង្ខំ ដែលដកហូតកម្មសិទ្ធិ និងបណ្តេញប្រជាជន ដែលងាយរងគ្រោះបំផុតរបស់កម្ពុជា។ [**ត្រូវបានលុបចោល**] ដើមបណ្តឹងបានរាយការណ៍ថា ត្រូវបានបង្ខំដោយអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC ឱ្យលក់ដីរបស់ពួកគេនៅក្រៅដំណើរការរឹបអូសតាមផ្លូវច្បាប់ ដើម្បីសងកម្ចីរបស់ពួកគេ។[321] ស្តង់ដារសមិទ្ធកម្ម ទី៥ ទទួលស្គាល់ថា ការទិញដីធ្លីដែលទាក់ទងនឹងគម្រោង និងការរឹតត្បិតលើការប្រើប្រាស់ដីធ្លី រួមទាំងអស្សាមិករណ៍តាមផ្លូវច្បាប់ ឬការរឹតត្បិតលើសិទ្ធិដីធ្លី អាចមានផលប៉ះពាល់អវិជ្ជមានដល់សង្គម រួមទាំងការផ្លាស់ទីលំនៅផ្នែករូបវន្ត និងសេដ្ឋកិច្ចផងដែរ។[322] ដោយសារហេតុផលទាំងនោះ ស្តង់ដារការសមិទ្ធកម្ម ទី៥ រួមបញ្ចូលគោលបំណងក្នុងការកាត់បន្ថយការផ្លាស់ទីលំនៅថ្មីជាអប្បបរមា ដោយស្វែងរកការរៀបចំគម្រោងជំនួស និងជៀសវាងការបណ្តេញចេញដោយបង្ខំ និងវិធីផ្សេងៗទៀត។[323] IFC បញ្ជាក់បន្ថែមទៀតថា ស្តង់ដារសមិទ្ធកម្ម ទី៥ គួរតែត្រូវបានអនុវត្តដោយអតិថិជន នៅពេលណាដែលផលប៉ះពាល់របស់គម្រោងលើដីធ្លី ឬការចូលប្រើប្រាស់ទ្រព្យសម្បត្តិបានប្រែជាអវិជ្ជមានយ៉ាងខ្លាំង ដោយមិនគិតថាតើមានការទិញ ឬការរឹតត្បិតលើដីធ្លីយ៉ាងជាក់ស្តែងដែរឬអត់នោះទេ។[324]

---

315 *Id.* នៅ ៣៦៩.

316 *សូមមើល id.* នៅ ៣៤.

317 *សូមមើល* របាយការណ៍ត្រួតពិនិត្យភាពអនុលោមនៃគម្រោងផ្លូវរថភ្លើងរបស់ ADB កំណត់សម្គាល់ខាងលើ លេខ ១៧១ នៅកថាខណ្ឌ ៤០.

318 *ជាទូទៅ សូមមើល* យន្តការពិគ្រោះយោបល់ និងស៊ើបអង្កេតដោយឯករាជ្យ (MICI) Inter-Am. ធនាគារអភិវឌ្ឍន៍ ការកំណត់អនុស្សរណៈសមស្រប MICI-BID-HA-២០១៧-០១១៤ ខែសីហា ឆ្នាំ២០១៩ *មាននៅ* https://www.accountabilitycounsel.org/wp-content/uploads/2019/08/mici-bid-ha-2017-0114-determination-of- elegibility-memorandum-english.pdf.

319 *Cf.* អង្គការស្បៀងអាហារ និងកសិកម្មរបស់អង្គការសហប្រជាជាតិ គោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចដែលមានទំនួលខុសត្រូវលើការកាន់កាប់ដីធ្លី ជលផល និងព្រៃឈើនៅក្នុងបរិបទនៃសន្តិសុខស្បៀងជាតិ នៅ ១២.៤ (២០១២) *មាននៅ* https://www.fao.org/tenure/voluntary-guidelines/en/ [តទៅ ហៅថា គោលការណ៍ណែនាំដោយស្ម័គ្រចិត្តរបស់ FAO ស្តីពីសិទ្ធិកាន់កាប់ដីធ្លី].

320 [ត្រូវបានលុបចោល]

321 [ត្រូវបានលុបចោល]

322 IFC ស្តង់ដារសមិទ្ធកម្ម ទី៥៖ ការទិញដីធ្លី និងការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត (២០១២) នៅកថាខណ្ឌ ១–២ ៥ [តទៅ ហៅថា PS5].

323 IFC កំណត់សម្គាល់ការណែនាំអំពីស្តង់ដារសមិទ្ធកម្ម ទី៥៖ ការទិញដីធ្លី និងការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត៖ (២០១២) នៅ ២–៣.

324 PS5 កំណត់សម្គាល់ខាងលើ លេខ ៣២២ នៅកថាខណ្ឌ ៧.

អភិក្រមនេះមានសង្គតិភាពនឹងបទដ្ឋានដែលកំពុងលេចឡើង ទាក់ទងនឹងសិទ្ធិកាន់កាប់ដីធ្លី ឧទាហរណ៍នៅក្នុងគោលការណ៍ណែនាំដោយស្ម័គ្រចិត្តរបស់អង្គការស្បៀងអាហារ និងកសិកម្មរបស់អង្គការសហប្រជាជាតិ។[325] ច្បាប់កម្ពុជារឹតត្បិតអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុ ដែលជាអតិថិជនរបស់ IFC មិនឲ្យក្លាយជាម្ចាស់កម្មសិទ្ធិដីធ្លី ដែលធានាកម្ចីណាមួយនោះទេ[326] [**ត្រូវបានលុបចោល**][327]

157. អ្នកជំនាញផ្នែកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានទទួលស្គាល់ទំនាក់ទំនងរវាងហិរញ្ញប្បទានដីធ្លី និងការពង្រីកឥណទាន និងបំណុលឯកជន ដែលធ្វើឱ្យ "គ្រួសារនីមួយៗងាយរងគ្រោះដោយសារការអនុវត្តក្នុងការផ្តល់កម្ចីដ៏ឃោរឃៅ និងការប្រែប្រួលនៃទីផ្សារ ដែលជាលទ្ធផលនៃភាពមិនច្បាស់លាស់នៃលំនៅដ្ឋានដែលមិនធ្លាប់មានពីមុនមក"។[328] អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីលំនៅឋានសមរម្យ[329] បានរិះគន់ជាពិសេសអំពីរបៀបដែលការផ្តល់ហិរញ្ញប្បទានដីធ្លីជាយានដែលនាំឲ្យមានការបណ្តេញចេញ និងការផ្លាស់ទីលំនៅថ្មីយ៉ាងទូលំទូលាយ ហើយបានអំពាវនាវឱ្យមានការកែលម្អគណនេយ្យភាពសិទ្ធិមនុស្សនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ ដោយកត់សម្គាល់ថា "សហគមន៍នៅលើពិភពលោកមិនអាចទទួលយកភាពភ័យខ្លាចបានទេ" ដោយ ភាពស្មុគស្មាញនៃកិច្ចការ។[330] អ្នករាយការណ៍ពិសេសក៏បានរិះគន់អំពីយុទ្ធសាស្រ្តនៃការស្តីបន្ទោសអ្នកខ្ចី ដែលបានរងគ្រោះដោយសារការខូចខាតទាំងនោះ[331] ដែលផ្តោតលើបំណុលខ្លាំងពេក ដោយមិនបានដោះស្រាយតម្រូវការកំណែទម្រង់ជាប្រព័ន្ធនោះទេ[332] និងទំនោរក្នុងការផ្តល់អាទិភាពដល់ការគាំទ្រស្ថាប័នហិញ្ញវត្ថុច្រើនជាងការឆ្លើយតបនឹងតម្រូវការរបស់ជនដែលសិទ្ធិទទួលបានលំនៅឋានសមរម្យរបស់ពួកគេកំពុងប្រឈមនឹងហានិភ័យ។[333]

---

[325] គោលការណ៍ណែនាំដោយស្ម័គ្ររបស់ FAO ស្តីពីសិទ្ធិកាន់កាប់ដីធ្លី កំណត់សម្គាល់ខាងលើ លេខ ៣១៩ នៅ ១២.៤ ១២.១៥.

[326] *សូមមើល* ច្បាប់ភូមិបាល មាត្រា ២១០ ២២១ NS/RKM/០៨០១/១៤ (២០០១) (ការបកប្រែជាភាសាអង់គ្លេសមិនផ្លូវការ *មាននៅ* http://huskyandpartners.com/images///Law%20Library/Real%20Property%20and%20Construction/20190604-Law%20on%20the%20Land_2001_Kh_En.pdf.pdf.

[327] Infra ផ្នែក IV នៅកថាខណ្ឌ ១៨០.

[328] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីលំនៅឋានសមរម្យ ដែលជាសមាសធាតុមួយនៃសិទ្ធិទទួលបានស្តង់ដាររស់នៅសមរម្យ និងសិទ្ធិមិនរើសអើងនៅក្នុងបរិបថនេះ ត្រូវបានបញ្ជូនទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ នៅកថាខណ្ឌ ៥ ឯកសារ UN លេខ A/HRC/៣៤/៥១ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ https://www.ohchr.org/EN/Issues/Housing/Pages/AnnualReports.aspx [តទៅហៅថា របាយការណ៍អ្នករាយការណ៍ពិសេសស្តីពីលំនៅឋានសមរម្យ ឆ្នាំ២០១៧

[329] *Cf.* កំណត់សម្គាល់ការណែនាំអំពីស្តង់ដារសមិទ្ធកម្ម ទី៥ របស់ IFC កំណត់សម្គាល់ខាងលើ លេខ ៣២៣ នៅកថាខណ្ឌ ១៤ (សន្តិសុខនៃសិទ្ធិកាន់កាប់ដីធ្លីគឺជាសមាសធាតុដ៏សំខាន់នៃទីលំនៅសមរម្យ").

[330] របាយការណ៍អ្នករាយការណ៍ពិសេសស្តីពីលំនៅឋានសមរម្យ ឆ្នាំ២០១៧ កំណត់សម្គាល់ខាងលើ លេខ ៣២៨ នៅកថាខណ្ឌ ៦ ៩. សូមមើល *id.* នៅកថាខណ្ឌ ៦៥ ("សេចក្តីសម្រេចរបស់សាជីវកម្មហិរញ្ញវត្ថុជាសកល ស្ថាប័ន និងក្រុមហ៊ុនមូលធនឯកជន ពាក់ព័ន្ធនឹងការទទួលបានឥណទាន ការទាមទារសិទ្ធិជាម្ចាស់ និងអាទិភាពនៃការអភិវឌ្ឍន៍ មានផលប៉ះពាល់ដោយផ្ទាល់លើភាពគ្មានផ្ទះសម្បែង ការបណ្តេញចេញ និងសិទ្ធិទទួលបានលំនៅឋានសមរម្យ")។

[331] *សូមមើល id.* នៅកថាខណ្ឌ ៥៨ (ដោយកត់សម្គាល់ថា ការខូចខាត ដែលទាក់ទងនឹងការទាមទារសិទ្ធិកាន់កាប់ដីធ្លី និងការបណ្តេញចេញ ជាទូទៅផ្ទុយនឹងច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ).

[332] *សូមមើល id.* នៅកថាខណ្ឌ ២២.

[333] *Id.* នៅកថាខណ្ឌ ៦៧.

158. [ត្រូវបានលុបចោល][334] [335] [336] [337]

159. [ត្រូវបានលុបចោល]

160. លើសពីនេះទៀត មានការបង្ខំឱ្យលក់ដីធ្លីឯកជនរបស់ដើមបណ្ដឹង ដូច្នេះហើយមិនមែនជាប្រតិបត្តិការដោយស្ម័គ្រចិត្តនោះទេ ហើយដើមបណ្ដឹងត្រូវបានដកហូតសិទ្ធិទទួលបានដំណោះស្រាយតាមផ្លូវច្បាប់ថែមទៀត។ ស្តង់ដារសមិទ្ធកម្ម ទី៥ មិនអនុវត្តចំពោះប្រតិបត្តិការដីធ្លីដោយស្ម័គ្រចិត្តឡើយ រួមទាំងប្រតិបត្តិការទីផ្សារ ដែលអ្នកលក់ពុំមានកាតព្វកិច្ចលក់ផងដែរ[338] ទោះបីជាយ៉ាងណាក៏ដោយ ដូចបានបង្ហាញយ៉ាងច្បាស់តាមរយៈការគំរាមកំហែង **[ត្រូវបានលុបចោល]** ដើមបណ្ដឹង វត្តមាននៃការបង្ខំនៅក្នុងករណីរបស់ពួកគេ គាំទ្រថា អ្នកខ្ចីត្រូវបានគេធ្វើឲ្យមានអារម្មណ៍ថា ពួកគេមានកាតព្វកិច្ចលក់ដីធ្លីរបស់ពួកគេ ជាជាងការចាប់ផ្ដើមដំណោះស្រាយតាមផ្លូវច្បាប់។ **[ត្រូវបានលុបចោល]**

161. ដូច្នេះ ស្តង់ដារសមិទ្ធកម្ម ទី ៥ គួរតែត្រូវបានយកមកពិចារណាដោយអតិថិជនរបស់ IFC និង IFC មុន និងក្នុងអំឡុងពេលអនុវត្តគម្រោងមីក្រូហិរញ្ញវត្ថុ និងការវិនិយោគណាមួយ។ រាល់ការវិនិយោគគួរតែត្រូវបានរៀបចំរចនាសម្ព័ន្ធ ដោយមានលក្ខខណ្ឌនានាដែលឆ្លុះបញ្ចាំងអំពីការរឹតត្បិតទូទៅលើដីធ្លី នៅពេលដែលត្រូវបានប្រើប្រាស់ជាវត្ថុបញ្ចាំង និងលទ្ធភាពដ៏ខ្ពស់ ដែលអ្នកខ្ចីអាចនឹងមានកំហុសឆ្គងចំពោះកម្ចីរបស់ពួកគេ និងត្រូវបានបង្ខំឲ្យលក់ជាលក្ខណៈឯកជន ដោយសារការអនុវត្តក្នុងការផ្ដល់កម្ចីដ៏ឃោឃៅ និងការប្រមូលប្រាក់ដោយបំពាន ដែលរីករាលដាលដល់វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា។ បើទោះបីជាផែនការសកម្មភាពតាំងទីលំនៅតាមស្តង់ដារ មិនមែនជាដំណោះស្រាយសមស្របចំពោះគម្រោងមីក្រូហិរញ្ញវត្ថុក៏ដោយ ប៉ុន្តែហានិភ័យខ្ពស់ដូចគ្នានៃការខូចខាតសង្គមនឹងកើតឡើង ដែលទាមទារឲ្យមានលក្ខខណ្ឌសមស្របលើការវិនិយោគ និងស្របតាមការណែនាំ ដែលបានកែប្រែជាអប្បបរមា លើស្តង់ដារសមិទ្ធកម្ម ទី៥ ដូចបានអនុវត្តតាមរយៈអន្តរការីហិរញ្ញវត្ថុនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។

**បញ្ជីផាត់ចេញរបស់ IFC និងស្តង់ដារសមិទ្ធកម្ម ទី៧៖ ជនជាតិដើមភាគតិច**

162. ការខូចខាតសង្គមជាច្រើនដែលទាក់ទងនឹងសកម្មភាពគម្រោងរបស់អ្នកផ្ដល់សេវាមីក្រូហិរញ្ញវត្ថុ ដែលជាអតិថិជនរបស់ IFC បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ជនជាតិដើមភាគតិចរបស់កម្ពុជា នៅក្នុងការរំលោភលើបញ្ជីផាត់ចេញរបស់ IFC និងផ្ទុយពីស្តង់ដារសមិទ្ធកម្ម ទី៧។ [ត្រូវបានលុបចោល] ដើមបណ្ដឹង ក្នុងករណីនេះ បានរាយការណ៍ថា ត្រូវបានបង្ខំឱ្យលក់ ឬ "បញ្ចាំ" ដីជនជាតិដើមភាគតិច –នៅពេលខ្លះ ទៅឱ្យអ្នកទិញដែលនៅខាងក្រៅសហគមន៍ជនជាតិដើមភាគតិច – ក្រោមការបង្ខំពីអ្នកផ្ដល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC។[339] បញ្ជីផាត់ចេញរបស់ IFC ហាមឃាត់ការប្រើប្រាស់

---

334 កំណត់សម្គាល់ការណែនាំអំពីស្តង់ដារសមិទ្ធកម្ម ទី៥ របស់ IFC កំណត់សម្គាល់ខាងលើ លេខ ៣២៣ នៅកថាខណ្ឌ ១៤.

335 [ត្រូវបានលុបចោល]

336 របាយការណ៍ត្រួតពិនិត្យភាពអនុលោមនៃគម្រោងផ្លូវរថភ្លើងរបស់ ADB កំណត់សម្គាល់ខាងលើ លេខ ១៧១ នៅ vi–vii.

337 កំណត់សម្គាល់ការណែនាំអំពីស្តង់ដារសមិទ្ធកម្ម ទី៥ របស់ IFC កំណត់សម្គាល់ខាងលើ លេខ ៣២៣ នៅកថាខណ្ឌ ២៨.

338 PS5 កំណត់សម្គាល់ខាងលើ លេខ ៣២២ នៅកថាខណ្ឌ ៦.

339 [ត្រូវបានលុបចោល]

ហិរញ្ញប្បទានរបស់ IFC នៅក្នុងសកម្មភាពអាជីវកម្ម ដែលប៉ះពាល់ដល់ដីដែលជាកម្មសិទ្ធិ ឬត្រូវបានទាមទារ ក្រោមការវិនិច្ឆ័យរបស់ជនជាតិដើមភាគតិច ដោយពុំមានការយល់ព្រមជាឯកសារពេញលេញពីប្រជាជនទាំងនោះទេ។[340] ស្តង់ដារសមិទ្ធកម្ម ទី៧ កំណត់ថា ផលប៉ះពាល់អវិជ្ជមានលើសហគមន៍ជនជាតិដើមភាគតិច គួរតែត្រូវបានជៀសវាង និងកាត់បន្ថយជាអប្បបរមា តាមដែលអាចធ្វើបាន។[341] ជនជាតិដើមភាគតិចត្រូវតែទទួលបានការស្តារឡើងវិញ និងសំណង យ៉ាងសមរម្យតាមវប្បធម៌ សម្រាប់ផលប៉ះពាល់អវិជ្ជមានណាមួយ។[342] អតិថិជនរបស់ IFC ដែលសកម្មភាពអាជីវកម្មរបស់ពួកគេមានផលប៉ះពាល់អវិជ្ជមានចំពោះជនជាតិដើមភាគតិច ត្រូវបានតម្រូវឲ្យអនុវត្តដំណើរការនៃការពិគ្រោះយោបល់ដែលមានព័ត៌មានគ្រប់គ្រាន់ និងការចូលរួមជាមួយសហគមន៍ ហើយនៅក្នុងករណីមួយចំនួនទទួលបានការយល់ព្រមដោយសេរី ជាមុន និងមានព័ត៌មានគ្រប់គ្រាន់ ពីជនជាតិដើមភាគតិច។[343]

163. [ត្រូវបានលុបចោល][344] [345] [346]

164. សិទ្ធិរបស់ជនជាតិដើមភាគតិចត្រូវបានទទួលស្គាល់យ៉ាងច្បាស់លាស់ដោយសហគមន៍អន្តរជាតិ និងផ្តល់មគ្គុទ្ទេសក៍ណែនាំអំពីការអនុវត្តលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិដទៃទៀត "ដែលបង្ហាញអំពីការអនុវត្តជាសកលនៃលិខិតូបករណ៍ទាំងនោះ និងជាសញ្ញានៃការលេចចេញនូវច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងវិស័យសិទ្ធិជនជាតិដើមភាគតិច"។[347] ជនជាតិដើមភាគតិចមានសិទ្ធិលើដីធ្លី ទឹកដី និងធនធាន ដែលខ្លួនមានតាមប្រពៃណី កាន់កាប់ ឬប្រើប្រាស់ ឬទទួលបានវិធីផ្សេងទៀត។[348] សិទ្ធិលើទឹកដី និងទ្រព្យសម្បត្តិរបស់ពួកគេមានលក្ខណៈធម្មតា និងមានអត្ថិភាពនៅក្រៅបណ្ណកម្មសិទ្ធិរបស់រដ្ឋណាមួយ។[349] ជនជាតិដើមភាគតិច ជាញឹកញាប់ ជាប្រជាជនដែលគេមិនអើពើ និងងាយរងគ្រោះបំផុត និងងាយរងគ្រោះជាពិសេស ប្រសិនបើដីធ្លី និងធនធានរបស់ពួកគេត្រូវបានផ្លាស់ប្តូរ ទន្ទ្រាន ឬរិចរិលយ៉ាងខ្លាំង។[350] អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិជនជាតិដើមភាគតិចបានថ្លែងថា "កំណើនសេដ្ឋកិច្ច ឬការអភិវឌ្ឍន៍ជាតិមិនអាចប្រើជាមូលដ្ឋានសម្រាប់ការរំលោភលើទឹកដី និងសិទ្ធិវប្បធម៌របស់ជនជាតិដើមភាគតិច ដោយគ្មានការយល់ព្រមបានទេ។ នេះត្រូវបានបំពេញបន្ថែមដោយលក្ខណៈនៃសិទ្ធិទូទៅរបស់ប្រជាជនគ្រប់រូប នៅក្នុងការសម្រេចចិត្តដោយខ្លួនឯង ការហាមឃាត់ការរើសអើងពូជសាសន៍ និងការពិតដែលថា ការការពារពួកគេគឺជាបញ្ហាមួយនៃផលប្រយោជន៍

---

[340] បញ្ជីផាត់ចេញរបស់ IFC https://www.ifc.org/wps/wcm/connect/topics_ext_content/ifc_external_corporate_site/sustainability-at-ifc/company-resources/ifcexclusionlist.

[341] IFC ស្តង់ដារសមិទ្ធកម្ម ទី៧៖ ជនជាតិដើមភាគតិច (២០១២) នៅកថាខណ្ឌ ៩ [តទៅ ហៅថា PS7].

[342] *Id.*

[343] *Id.* នៅកថាខណ្ឌ ១០–១៤ PS1 កំណត់ត្រាការណែនាំ កំណត់ត្រាខាងលើ លេខ ២៥៣ នៅកថាខណ្ឌ ៣២.

[344] [ត្រូវបានលុបចោល]

[345] [ត្រូវបានលុបចោល]

[346] [ត្រូវបានលុបចោល]

[347] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ នៅកថាខណ្ឌ ១៤. ឯកសារ UN លេខ A/HRC/៣៣/៤២ ថ្ងៃទី១១ ខែសីហា ២០១៦.

[348] សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច មាត្រា ២៦ (១) ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៧.

[349] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជនជាតិដើមភាគតិច កំណត់សម្គាល់ខាងលើលេខ ៣៤៧ នៅកថាខណ្ឌ ១៦.

[350] PS7 កំណត់សម្គាល់ខាងលើ លេខ ៣៤១ នៅកថាខណ្ឌសេចក្តីផ្តើមទី១.

សាធារណៈ"។[351]

165. ការដកហូត និងការរិចរិលដីរបស់ជនជាតិដើមភាគតិច មានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងលើស្ថានភាពហិរញ្ញវត្ថុ ការអប់រំ និងសុខភាពរបស់ពួកគេ។[352] សន្តិសុខនៃកម្មសិទ្ធិដីធ្លីកំពុងស្ថិតក្រោមការគំរាមកំហែងរួចហើយ នៅក្នុងប្រទេសកម្ពុជា៖ សិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិចត្រូវបាន "រំលោភបំពានឥតឈប់ឈរ" ហើយដីធ្លីរបស់ជនជាតិដើមភាគតិច ជាញឹកញាប់ ត្រូវបានផ្តល់ឲ្យផលប្រយោជន៍ឯកជនសម្រាប់ការអភិវឌ្ឍន៍។[353] អង្គការសង្គមស៊ីវិលបានសម្តែងការព្រួយបារម្ភថា នៅក្នុងប្រទេសកម្ពុជា ការបង្ខំឲ្យជនជាតិដើមភាគតិចចាកចេញពីដីធ្លីរបស់ពួកគេ "កំពុងតែបំបែកពួកគេជាក្រុមដោយឡែក"។[354] [ត្រូវបានលុបចោល][355]

166. ការអនុវត្តច្បាប់ចំពោះការទទួលយកប័ណ្ណកម្មសិទ្ធិដីធ្លីជាវត្ថុបញ្ចាំ និងការអនុវត្តតាមលំនាំដើមនៃការតម្រូវឲ្យមានបណ្ណកម្មសិទ្ធិដីធ្លីសម្រាប់កម្ចីខ្នាតមីក្រូ មានលក្ខណៈអសកម្មចំពោះការការពារតាមផ្លូវច្បាប់ ដែលត្រូវបានផ្តល់ជូន ដើម្បីថែរក្សាសិទ្ធិដីធ្លី និងប្រពៃណីវប្បធម៌របស់ជនជាតិដើមភាគតិច។ ឧទាហរណ៍ នៅឆ្នាំ២០១៤ ជនជាតិដើមភាគតិចសាម័រជាច្រើននាក់បានដាក់ពាក្យបណ្តឹងទៅកាន់យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទាក់ទងនឹងជំនួយបច្ចេកទេសត្រួតគ្នា និងហិរញ្ញប្បទានឥតសំណង ដែលទាក់ទងនឹងការប្រើប្រាស់សិទ្ធិជួលដីធ្លីរបស់ជនជាតិដើមភាគតិចតាមបែបប្រពៃណី ជាវត្ថុបញ្ចាំនៅអន្តរការីហិរញ្ញវត្ថុដែលជាអតិថិជនរបស់ ADB។ ពាក្យបណ្តឹងនេះបានលើកឡើងអំពីកង្វល់ជាច្រើន ទាក់ទងនឹងផលប៉ះពាល់សង្គមនៃគម្រោងលើជនជាតិដើមភាគតិច និងការកំណត់បុគ្គល និងការផ្តាច់ខ្លួននៃដីទំនៀមទម្លាប់ ដោយកត់សម្គាល់ថា ដីធ្លីគឺជាទិដ្ឋភាពដ៏សំខាន់មួយនៃអត្តសញ្ញាណសាម័រ ហើយ "ប្រព័ន្ធកាន់កាប់ដីធ្លីតាមទំនៀមទម្លាប់ធានានូវសន្តិសុខយូរអង្វែងសម្រាប់ជនជាតិសាម័រគ្រប់រូប"។[356] យន្តការគណនេយ្យភាពរបស់ ADB បានផ្តល់អនុសាសន៍ និងពិនិត្យតាមដានវឌ្ឍនភាពនៃដំណើរការពិគ្រោះយោបល់ ដើម្បីធានាឱ្យមានការចូលរួមពីសហគមន៍កាន់តែទូលំទូលាយនៅក្នុងដំណើរការជួល អាស្រ័យលើគោលនយោបាយ និងកំណែទម្រង់ច្បាប់ ដើម្បីធានាចំពោះសិទ្ធិដីធ្លីរបស់ម្ចាស់ដីធ្លីតាមទំនៀមទម្លាប់ និងស្វែងយល់អំពីបញ្ហា ហានិភ័យ កត្តាអំណោយផល និងឧបសគ្គ ដែលពាក់ព័ន្ធ។[357] ករណីការជួលរបស់សាម័រ គឺស្រដៀងនឹងគម្រោងមីក្រូ

---

[351] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជនជាតិដើមភាគតិច កំណត់សម្គាល់ខាងលើលេខ ៣៤៧ នៅកថាខណ្ឌ ១៨.

[352] *សូមមើល* ការដាក់ជូនរបស់ CIPA UPR ស្តីពី IPs កំណត់សម្គាល់ខាងលើ លេខ ៣៤៤ នៅកថាខណ្ឌ ៤.

[353] ក្រុមការងារអន្តរជាតិសម្រាប់កិច្ចការជនជាតិដើមភាគតិច (IWGIA) និង AIPP ការដាក់ជូនរួមគ្នា ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិអំពីស្ថានភាពសិទ្ធិមនុស្សរបស់ជនជាតិដើមភាគតិចនៅកម្ពុជា ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២០, https://www.iwgia.org/en/global-governance-cat/៣៨៤៨-hrc៤៥-cambodia.html.

[354] *Id.*

[355] [ត្រូវបានលុបចោល]

[356] ពាក្យបណ្តឹងពាក់ព័ន្ធនឹងហិរញ្ញប្បទានឥតសំណងលេខ ០៣៩២ (SAM) ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ នៅកថាខណ្ឌ ១ ៦ ៩ ១០ ១១ ១៣ ២០ *មាននៅ* https://www.accountabilityconsole.com/complaints/promoting-economic-use-of-customary-land-and-grant-no-0392-sam-samoa-agribusiness-support-project/.

[357] ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ហិរញ្ញប្បទានឥតសំណង លេខ ០៣៩២ (៤៦៤៣៦-00២)-SAM et al., ការត្រួតពិនិត្យសេចក្តីសង្ខេបឡើងវិញ និងរបាយការណ៍វាយតម្លៃរបស់អ្នកសម្របសម្រួលគម្រោងពិសេស ខែមីនា ឆ្នាំ២០១៥ នៅកថាខណ្ឌ ៧–៨ ១២ ១៤–១៥ *មាននៅ* https://www.accountabilityconsole.com/complaints/promoting-economic-use-of-customary-land-and-grant-no-0392-sam-samoa-agribusiness-

ហិរញ្ញវត្ថុរបស់ IFC នៅក្នុងពាក្យបណ្តឹងនេះ នៅខណៈពេលដែលវាមានបំណងធ្វើឱ្យប្រសើរឡើងនូវឱកាសសេដ្ឋកិច្ចសម្រាប់ជនជាតិដើមភាគតិចដែលងាយរងគ្រោះដោយការបញ្ចាំកម្មសិទ្ធិ ឬផលប្រយោជន៍នៅក្នុងការជួលដីធ្លីនោះ ការផ្តល់ហិរញ្ញប្បទានដល់ផលប្រយោជន៍ដីធ្លី មានហានិភ័យក្នុងការកែប្រែទំនាក់ទំនងតាមបែបប្រពៃណីជាមួយដីធ្លី និងប្រព័ន្ធកាន់កាប់ដីសហគមន៍ ដែលគាំទ្រសហគមន៍ជនជាតិដើមភាគតិច។ ដើមបណ្តឹងនៅទីនេះមានហានិភ័យខ្លាំងជាងករណីជួលរបស់ ADB សាម័រ ពីព្រោះ នៅទីបំផុត ពួកគេអាចបាត់បង់សិទ្ធិទាំងអស់លើដីជនជាតិដើមភាគតិចរបស់ពួកគេ។ **[ត្រូវបានលុបចោល]** ដូច្នេះ សហគមន៍បាត់បង់សិទ្ធិចូលប្រើប្រាស់ដីទាំងនោះ ដែលទាក់ទងនឹងការបាត់បង់អត្តសញ្ញាណ វប្បធម៌ និងជីវភាពរស់នៅដែលពឹងផ្អែកលើធនធានធម្មជាតិរបស់ពួកគេ ព្រមទាំងការកើនឡើងនៃហានិភ័យនៃភាពក្រីក្រកាន់តែខ្លាំង។

167. គម្រោងមីក្រូហិរញ្ញវត្ថុដែលកំពុងមាននៅក្នុងសហគមន៍ជនជាតិដើមភាគតិច [ត្រូវបានលុបចោល] ប៉ះពាល់បន្ថែមទៀតដល់ដីទំនៀមទម្លាប់ និងធនធានធម្មជាតិ ដូច្នេះហើយគួរតែទាមទារឲ្យមានការយល់ព្រមដោយសេរី ជាមុន និងមានព័ត៌មានគ្រប់ជ្រុងជ្រោយពីអ្នកខ្ចី។[358] សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច គឺជាលិខិតូបករណ៍អន្តរជាតិមួយ ដែលណែនាំគោលនយោបាយរបស់ IFC ស្តីពីជនជាតិដើមភាគតិច និងអាណត្តិ ដែលជនជាតិដើមភាគតិចមិនត្រូវបានបង្ខំឲ្យរើចេញពីដីធ្លី ឬទឹកដីរបស់ពួកគេ និងពុំមានការផ្លាស់ទីលំនៅណាមួយអាចប្រព្រឹត្តទៅបានដោយពុំមានការយល់ព្រមដោយសេរី ជាមុន និងមានព័ត៌មានគ្រប់គ្រាន់នោះទេ។[359] ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងករណីជាច្រើន មន្ត្រីឥណទានមិនធុញទ្រាន់នឹងពន្យល់អំពីកិច្ចសន្យា ឬលក្ខខណ្ឌដល់អ្នកខ្ចីដែលមិនចេះអក្សរនោះទេ ហើយក្រោយមកពឹងផ្អែកលើការមិនអើពើ និងកង្វះខាតការយល់ព្រមដោយមានព័ត៌មានគ្រប់គ្រាន់ ធ្វើការបំភ័ន្តអំពីនីតិវិធីតុលាការ និងដាក់សម្ពាធលើអ្នកខ្ចីឱ្យលក់ជាលក្ខណៈឯកជនដោយបង្ខំ។ **[ត្រូវបានលុបចោល]**

168. IFC ប្រើនិយមន័យទូលំទូលាយនៃដីធ្លីជនជាតិដើមភាគតិច ដូច្នេះហើយលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធកម្ម ទី៧ គួរតែអនុវត្តចំពោះដីធ្លីទាំងអស់ដែលជនជាតិដើមភាគតិចកាន់កាប់ និងប្រើប្រាស់តាមប្រពៃណី និងដែលអាចត្រូវបានប្រើប្រាស់សម្រាប់បញ្ចាំ ឬលក់ នៅក្នុងការលក់ដោយបង្ខំ ដើម្បីសងកម្ចីដោយមិនគិតថា ដីធ្លីទាំងនោះគឺជាផ្នែកមួយនៃបណ្ណកម្មសិទ្ធិរួម។[360]

169. [ត្រូវបានលុបចោល][361]

---

support-project/. *សូមមើល* ADB សេចក្តីសង្ខេបរបស់ប្រធានគណៈកម្មាធិការត្រួតពិនិត្យភាពអនុលោមរបស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍របស់ក្រុមការងារត្រួតពិនិត្យភាពអនុលោមស្តីពីភាពសមស្របនៃសំណើត្រួតពិនិត្យភាពអនុលោម សម្រាប់ TA ៤៧១២ ៧៣៨៧ និង ៨៤៨១ ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០១៦ នៅកថាខណ្ឌ ៣–៤ (ដែលថែងថា មានកង្វះខាតកិច្ចព្រមព្រៀង ថាតើនឹងធ្វើការត្រួតពិនិត្យភាពអនុលោមយ៉ាងពេញលេញដែរឬទេ ដូច្នេះការត្រួតពិនិត្យភាពអនុលោមនឹងមិនដំណើរការនោះទេ លើកលែងតែរដ្ឋាភិបាលសាម័រខកខានមិនបានលុបបំបាត់ហានិភ័យនៃការខូចខាតសំខាន់ៗចំពោះដើមបណ្តឹង តាមរយៈការកែប្រែច្បាប់ ដែលត្រូវបានស្នើឡើង)។

[358] *សូមមើល* PS7 កំណត់សម្គាល់ខាងលើ លេខ ៣៤១ នៅកថាខណ្ឌ ១០–១៤.

[359] សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច មាត្រា ១០.

[360] *សូមមើល* IFC កំណត់សម្គាល់ការណែនាំអំពីស្តង់ដារសមិទ្ធកម្ម ទី៧៖ ជនជាតិដើមភាគតិច (២០១២) នៅកថាខណ្ឌ ៧.

[361] *សូមមើល ឧ.* អនុសញ្ញា ILO លេខ ១៦៩ ស្តីពីជនជាតិដើមភាគតិច និងកុលសម្ព័ន្ធនៅបុព្វកថា មាត្រា ៥ (១៩៨៩).

170. ភាពភ័យខ្លាច និងការមិនអើពើ ពីដំណើរការតុលាការផ្លូវការចំពោះកំហុសឆ្គងនៃកម្ចី – បណ្ដាញសមស្របតាមផ្លូវច្បាប់ សម្រាប់កំហុសឆ្គងលើកិច្ចព្រមព្រៀងកម្ចី និងការដាក់វត្ថុបញ្ចាំណាមួយ – ដែលត្រូវបានមើលឃើញនៅក្នុងករណីរបស់ដើមបណ្ដឹង [ត្រូវបានលុបចោល] អាចព្យាករណ៍ជាមុនបាន ប៉ុន្តែត្រូវបានប្រើប្រាស់ដោយប្រយោលដោយមន្ត្រីប្រមូលប្រាក់ដោយបំពាន។ IFC បានបញ្ជាក់យ៉ាងច្បាស់ទាក់ទងនឹងការអនុវត្តស្តង់ដារសមិទ្ធកម្ម ទី៧ ថា "ក្នុងករណីជាច្រើន ស្ថានភាពសេដ្ឋកិច្ច សង្គម និងផ្លូវច្បាប់របស់ [ជនជាតិដើមភាគតិច] ដាក់កម្រិតលើសមត្ថភាពរបស់ពួកគេក្នុងការការពារសិទ្ធិ និងផលប្រយោជន៍ដីធ្លី និងធនធានធម្មជាតិ និងវប្បធម៌របស់ពួកគេ និងអាចរឹតត្បិតសមត្ថភាពរបស់ពួកគេក្នុងការចូលរួម និងទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍន៍"។[362] អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិជនជាតិដើមភាគតិចក៏បានទទួលស្គាល់ "ចន្លោះប្រហោងនៃការអនុវត្ត" ដែលរារាំងជនជាតិដើមភាគតិចពីការប្រឈមនឹងការបំពានលើសិទ្ធិរបស់ពួកគេ៖ "សូម្បីតែនៅក្នុងយុត្តាធិការដែលមានក្របខណ្ឌច្បាប់កម្រិតខ្ពស់ក៏ដោយ ការរើសអើងដែលមានរចនាសម្ព័ន្ធចាក់ឫសយ៉ាងជ្រៅ និងផលប្រយោជន៍ដែលជាប់ពាក់ព័ន្ធ អាចធ្វើឲ្យការការពារផ្លូវច្បាប់ដែលផ្ដល់ដល់ជនជាតិដើមភាគតិចគ្មានប្រសិទ្ធភាព"។[363] យុទ្ធសាស្ត្របង្កប់របស់អ្នកផ្ដល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC ក្នុងការប្រើប្រាស់គុណវិបត្តិជាប្រព័ន្ធទាំងនេះ តាមរយៈការបំភ័ន្ត និងការដាក់សម្ពាធលើការលក់ដីធ្លី គឺផ្ទុយពីចេតនារបស់ស្តង់ដារសមិទ្ធកម្ម ទី៧ និងការហាមឃាត់នៅក្នុងបញ្ជីផាត់ចេញ និងបន្ថែមការប្រឆាំងនឹងបទដ្ឋានអន្តរជាតិដែលកំពុងលេចចេញ ស្តីពីការការពារជនជាតិដើមភាគតិច។[364]

171. ការអនុវត្តនៃការតម្រូវឲ្យដាក់ដីធ្លីជនជាតិដើមភាគតិចជាវត្ថុបញ្ចាំ ដែលកាត់ចេញពីសហគមន៍ប្រពៃណីម្តងមួយករណីៗ ប៉ុន្តែវាក៏ជំរុញឱ្យមានការបែងចែកកាន់តែធំ ដែលគំរាមកំហែងដល់វប្បធម៌របស់ពួកគេផងដែរ។ ជនជាតិដើមភាគតិចមួយចំនួនត្រូវបានលើកទឹកចិត្តឱ្យចាកចេញពីប័ណ្ណកម្មសិទ្ធិសហគមន៍របស់ពួកគេ និងស្វែងរកប័ណ្ណកម្មសិទ្ធិដីផ្ទាល់ខ្លួន ដើម្បីធានាកម្ចី។[365] ដូច្នេះ ការកើនឡើងនៃហិរញ្ញប្បទានដីធ្លីបានបំផ្លាញបណ្ដាញកាន់កាប់ដីសហគមន៍ជាប្រវត្តិសាស្ត្រ ដែលបានគាំទ្រប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចអស់រយៈពេលជាច្រើនឆ្នាំ និងបង្ហាញអំពីការគំរាមកំហែងដល់ការរស់រានមានជីវិតរបស់ពួកគេ។[366] នៅពេលអនាគតដ៏ខ្លីខាងមុខ និន្នាការនេះក៏ប្រឆាំងនឹងការការពារ និងសន្តិសុខ ដែលត្រូវបានទទួលស្គាល់ ដែលបណ្ណកម្មសិទ្ធិសមូហភាពត្រូវបានសន្មតថាធានាដល់សហគមន៍ជនជាតិដើមភាគតិច ដែលធ្វើឱ្យកាន់តែងាយស្រួលសម្រាប់បុគ្គលក្នុងការបាត់បង់ដីជនជាតិដើមភាគតិចទៅឱ្យអ្នកផ្ដល់សេវាមីក្រូហិរញ្ញវត្ថុដ៏ឃោឃៅ ដែលជាអតិថិជនរបស់ IFC។

---

[362] *សូមមើល* PS7 កំណត់សម្គាល់ខាងលើ លេខ ៣៤១ នៅកថាខណ្ឌនៃសេចក្តីផ្តើមទី១.

[363] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជនជាតិដើមភាគតិច កំណត់សម្គាល់ខាងលើលេខ ៣៤៧ នៅកថាខណ្ឌ ២១.

[364] *សូមមើល ឧ.* អនុសញ្ញា ILO លេខ ១៦៩ ស្តីពីជនជាតិដើមភាគតិច និងកុលសម្ព័ន្ធនៅបុព្វកថា មាត្រា ៣ (២) ("ពុំមានទម្រង់នៃការបង្ខំ ឬការបង្ខិតបង្ខំណាមួយ នឹងត្រូវប្រើដោយរំលោភបំពានលើសិទ្ធិមនុស្ស និងសេរីភាពកម្រិតមូលដ្ឋានរបស់ប្រជាជនដែលពាក់ព័ន្ធនោះទេ").

[365] Jack Brook និង Borin Sopheavuthtey "ជនជាតិដើមភាគតិចកម្ពុជា ជ្រើសរើសរវាងឥណទាន និងដីសហគមន៍" Southeast Asia Globe ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ https://southeastasiaglobe.com/cambodians-credit-communal-land-titles/.

[366] *Cf. សូមមើល* អនុសញ្ញា ILO លេខ ១៦៩ ស្តីពីជនជាតិដើមភាគតិច និងកុលសម្ព័ន្ធនៅបុព្វកថា (១៩៨៩) ("ដោយកត់សម្គាល់ថានៅក្នុងផ្នែកជាច្រើននៃពិភពលោក ប្រជាជនទាំងនេះមិនអាចទទួលបានសិទ្ធិមនុស្សកម្រិតមូលដ្ឋានរបស់ពួកគេ នៅក្នុងកម្រិតដូចគ្នានឹងប្រជាជនដទៃទៀតនៃរដ្ឋដែលពួកគេរស់នៅនោះទេ និងថាច្បាប់ គុណតម្លៃ ទំនៀមទម្លាប់ និងទស្សនៈរបស់ពួកគេ ជាញាប់ញាប់ ត្រូវបានបំផ្លាញចោល")។

172. កំណើនហានិភ័យដែលមានស្រាប់នៅក្នុងដីធ្លីរបស់ជនជាតិដើមភាគតិច [ត្រូវបានលុបចោល] គាំទ្រថា ការអនុវត្តតាមលំនាំដើមនៃការតម្រូវឲ្យមានដីធ្លីរបស់ជនជាតិដើមភាគតិចជាវត្ថុបញ្ចាំ គឺជាសកម្មភាពដែលមានហានិភ័យខ្ពស់។ ពុំមានភស្តុតាងណាមួយដែលថា អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC បានវាយតម្លៃគម្រោងយ៉ាងត្រឹមត្រូវ ថាមានហានិភ័យខ្ពស់ និងបានអនុវត្តស្តង់ដារសមិទ្ធកម្ម ដើម្បីជៀសវាង ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ឬថា IFC បានពិចារណាយ៉ាងត្រឹមត្រូវអំពីហានិភ័យទាំងនេះ និងផ្តល់ទម្ងន់យ៉ាងសមស្របដល់ហានិភ័យទាំងនោះ ក្នុងអំឡុងពេលត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នមុនពេលអនុវត្តគម្រោង និងអំឡុងពេលត្រួតពិនិត្យណាមួយ នៅក្នុងវដ្តគម្រោងទាំងមូលនោះទេ។ លើសពីនេះទៀត វិសាលភាពនៃសកម្មភាព ដែលអនុវត្តដោយអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC បង្កផលប៉ះពាល់យ៉ាងច្បាស់ តាមវិធីជាច្រើន លើដីដែលត្រូវបានកាន់កាប់ដោយជនជាតិដើមភាគតិច ដោយគ្មានការយល់ព្រមពីពួកគេនោះទេ ដូច្នេះវាស្មើនឹងការរំលោភបំពានជាច្រើនលើបញ្ជីផាត់ចេញ និងស្តង់ដារសមិទ្ធកម្ម ទី៧ របស់ IFC។

V. <u>**ការបំពានលើច្បាប់កម្ពុជា ដែលពាក់ព័ន្ធ**</u>

173. [ត្រូវបានលុបចោល][367]

### A. ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជា

174. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាធានាថា ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិកាន់កាប់ដីធ្លីជាលក្ខណៈបុគ្គល ឬជាសមូហភាព ហើយកម្មសិទ្ធិនោះត្រូវបានការពារដោយច្បាប់។[368] មាត្រា ៣២ នៃរដ្ឋធម្មនុញ្ញធានាបន្ថែមទៀតថា ពលរដ្ឋគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាពផ្ទាល់ខ្លួន និងមានសន្តិសុខ។[369] ពលរដ្ឋខ្មែរគ្រប់រូបត្រូវមានសមភាពនៅចំពោះមុខច្បាប់ និងទទួលបានសិទ្ធិដូចគ្នា ដោយមិនគិតអំពីឋានៈសង្គម ទ្រព្យសម្បត្តិ ឬឋានៈផ្សេងទៀតនោះទេ។[370]

175. រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាចែងថា សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិត្រូវបានទទួលស្គាល់ និងគោរពជាផ្នែកមួយនៃច្បាប់កម្ពុជា។[371] ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាបានអះអាងជាថ្មីអំពីការអនុវត្តច្បាប់អន្តរជាតិនៅក្នុងប្រទេស នៅក្នុងសេចក្តីសម្រេចឆ្នាំ២០០៧ ដែលបានកំណត់ "ច្បាប់" ដើម្បីរួមបញ្ចូល "ច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់រួចរាល់ហើយ ដោយព្រះរាជាណាចក្រកម្ពុជា"។[372] ដូច្នេះ ប្រទេសកម្ពុជាមានកាតព្វកិច្ចគោរពគោលការណ៍នៃច្បាប់សិទ្ធិមនុស្សនៅក្នុងក្របខណ្ឌច្បាប់ក្នុងស្រុករបស់ខ្លួន។

176. ច្បាប់ភូមិបាល ឆ្នាំ២០០១ បានបង្កើតប្រព័ន្ធចុះបញ្ជីដីធ្លីសម្រាប់ការចេញបណ្ណកម្មសិទ្ធិដីធ្លី។ បណ្ណកម្ម

---

[367] [ត្រូវបានលុបចោល]

[368] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤៤ (១៩៩៣) (ការបកប្រែភាសាអង់គ្លេសមិនផ្លូវការមាននៅលើវែបសាយត៍របស់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញកម្ពុជា នៅ https://www.ccc.gov.kh/detail_info_en.php?_txtID=៧៩១).

[369] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣២

[370] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១

[371] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១

[372] សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ CC.D ករណីលេខ ១៣១/០០៣/២០០៧ ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧) *មាននៅ* https://www.ccc.gov.kh/detail_info_en.php?_txtID=៤៥៣.

សិទ្ធិដីធ្លី ភាគច្រើន នៅក្នុងទម្រង់ជា "ប្លង់រឹង" ឬ "ប្លង់ទន់"។ ប្លង់រឹង គឺជាវិញ្ញាបនបត្របញ្ជាក់កម្មសិទ្ធិ ដែលផ្តល់ដោយការិយាល័យរៀបចំដែនដី និងនគរូបនីយកម្ម និងត្រូវបានចាត់ទុកថាជាភស្តុតាងដ៏រឹងមាំបំផុតនៃកម្មសិទ្ធភាព។[373] ប្លង់ទន់ក៏ត្រូវបានទទួលស្គាល់ថាជាការអះអាងអំពីកម្មសិទ្ធិដីធ្លីដែរ និងត្រូវបានផ្តល់ដោយសាលាសង្កាត់/ឃុំ ឬសាលាខណ្ឌ និងមិនត្រូវបានចុះបញ្ជីនៅថ្នាក់ជាតិទេ។[374] ប្លង់ទន់ គឺជាទម្រង់ទូទៅបំផុតនៃកម្មសិទ្ធិដីធ្លី។ អ្នកខ្ចីនៅក្នុងមីក្រូហិរញ្ញវត្ថុកម្ពុជាភាគច្រើនមានប្លង់ទន់។

177. ធនាគារជាតិនៃកម្ពុជា (NBC) ចូលរួមក្នុងការកំណត់ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិគ្រប់គ្រង MFIs នៅកម្ពុជា ហើយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) ដែលជាអង្គការមិនមែនរដ្ឋាភិបាល និងសមាគម MFIs ដែលបានប្តេជ្ញាចិត្តចំពោះ "វិបុលភាព" នៃវិស័យនេះ មានតួនាទីប្រឹក្សាយោបល់ទូទៅ។[375] ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឆ្នាំ១៩៩៩ របស់កម្ពុជា ផ្តល់សិទ្ធិអំណាចដល់ NBC ក្នុងការ "ផ្តល់អាជ្ញាប័ណ្ណ និងត្រួតពិនិត្យ" គ្រឹះស្ថានហិរញ្ញវត្ថុឯកទេស។[376] ប្រកាសបន្តបន្ទាប់ទៀត នៅក្នុងឆ្នាំ ២០០០ និង ២០០៧ បានណែនាំអំពីលក្ខខណ្ឌតម្រូវក្នុងការផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs) និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDIs)[377] ដែលបានកំណត់និយមន័យនៅក្នុងឯកសារយោងនៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ថាជាការផ្តល់សេវាឥណទាន និងការសន្សំប្រាក់។[378] ពុំមាននិយមន័យជាក់លាក់អំពី "មីក្រូហិរញ្ញវត្ថុ" នៅក្នុងច្បាប់កម្ពុជានោះទេ។[379]

178. ក្រមរដ្ឋប្បវេណីកម្ពុជា តម្រូវឱ្យកិច្ចសន្យាស្ថិតក្នុងសណ្តាប់ធ្នាប់សាធារណៈ និងអនុវត្តតាម "ទំនៀមទម្លាប់ល្អ" មានន័យថា ពួកគេត្រូវតែគោរពច្បាប់ជាលាយលក្ខណ៍អក្សរ និងច្បាប់ទំនៀមទម្លាប់។[380] កិច្ចសន្យាមួយ ដូចជា កិច្ចសន្យាកម្ចី ត្រូវបានបង្កើតឡើងនៅពេលដែលភាគីម្ខាងផ្តល់សំណើ និងភាគីម្ខាងទៀតទទួលយកសំណើនោះ។[381] សេចក្តីប្រកាសរបស់ភាគីនីមួយៗអំពីចេតនាចុះកិច្ចសន្យា (ផ្តល់ ឬ

---

373 អង្គការលីកាដូ ការខូចខាតវត្ថុបញ្ចាំ កំណត់សម្គាល់ខាងលើលេខ ១៤១ នៅ ៦.

374 *Id.*

375 ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ មាត្រា ៦ (១៩៩៩) (ការបកប្រែភាសាអង់គ្លេសមិនផ្លូវការ) *មាននៅ* https://www.nbc.org.kh/download_files/legislation/laws_eng/86004-Law-on-Banking-and-Financial-Institutions-1999.pdf. ចូរមើល ERNST & YOUNG, NPM, កិច្ចការពារអតិថិជននៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ៖ ស្ថានភាពច្បាប់ និងបទប្បញ្ញត្តិនាពេលបច្ចុប្បន្ន នៅ ១៤ (២០១៤) IFC ការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅប្រទេសកម្ពុជា កំណត់សម្គាល់ខាងលើ ១៣០ នៅ ២១.

376 ច្បាប់ស្តីពីស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ មាត្រា ៦. អគ្គនាយកដ្ឋានពន្ធដារនៃប្រទេសកម្ពុជា ក៏មានតួនាទីត្រួតពិនិត្យតិចតួចចំពោះបញ្ហាដែលទាក់ទងនឹងពន្ធដារ។

377 គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ យ៉ាងតិចបីឆ្នាំ ទទួលបានការអនុញ្ញាតឲ្យប្រមូលប្រាក់សន្សំ និងប្រាក់បញ្ញើមានកាលកំណត់ជាបន្តបន្ទាប់ ដែលពុំមានការធានាពីអង្គភាពរដ្ឋាភិបាលនោះទេ។ ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ មាត្រា ២-៣ លេខ ធ៧-០៧-១៦៣ (ឆ្នាំ២០០៧) (ការបកប្រែមិនផ្លូវការជាភាសាអង់គ្លេស) *មាននៅ* https://www.nbc.org.kh/download_files/legislation/prakas_eng/2378B7-07-163.pdf.

378 ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លេខ ធ-៧-០០-០៦ (ឆ្នាំ២០០០) (បានធ្វើវិសោធនកម្មនៅឆ្នាំ២០០២ ២០០៦ ២០០៧) (ការបកប្រែមិនផ្លូវការជាភាសាអង់គ្លេស) *មាននៅ* https://www.nbc.org.kh/download_files/legislation/prakas_eng/7175B7-00-06.pdf and (amendment) https://www.nbc.org.kh/download_files/legislation/prakas_eng/322B7-06-209.pdf; ច្បាប់ស្តីពីស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ មាត្រា ២. *សូមមើល* ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ មាត្រា ២–៣.

379 MICROFINANCE CENTRE, GOOD RETURN, និងអ្នកដទៃទៀត ការសិក្សាអំពីការជំពាក់បំណុលច្រើនពេកនៅកម្ពុជា II៖ របាយការណ៍ចុងក្រោយ នៅ ២៨ និង ក.២១ (ខែតុលា ឆ្នាំ២០១៧).

380 ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៥៤ ៣៥៧ (២០០៧).

381 ក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជា មាត្រា ៣៣៦(១).

ទទួលយកសំណើ) ត្រូវតែគ្មានវិការៈ ដូចជា កំហុសឆ្គង ការក្លែងបន្លំ ឬការបំភ័ន្ត។[382] លើសពីនេះទៀត កិច្ចសន្យាចេញឥណទាន ត្រូវតែរួមបញ្ចូលព័ត៌មានអំពីផលិតផល និងសេវាកម្ម រួមទាំងនីតិវិធីដំណើរការ ខចែង និងលក្ខខណ្ឌនានា អត្រាការប្រាក់ និងរាល់ថ្លៃបន្ទុកដែលអាចអនុវត្តបានទាំងអស់។[383] ប្រសិន បើកិច្ចសន្យាផ្ទាល់ មានវិការៈ និងមិនអនុលោមតាមច្បាប់ ឧទាហរណ៍ កិច្ចសន្យាកម្ចីមិនបានរួមបញ្ចូលអត្រាការប្រាក់ទេនោះ វាត្រូវបានចាត់ទុកជាមោឃៈ ដោយមិនគិតអំពីចេតនារបស់គូភាគី ដែលនៅពីក្រោយការផ្ដល់ និងការទទួលយកសំណើនោះទេ។[384]

179. ប្រតិបត្តិការមីក្រូហិរញ្ញវត្ថុភាគច្រើន មានកិច្ចសន្យាស្តង់ដារមុនពេលបោះពុម្ព ដែលអ្នកខ្ចីចុះហត្ថលេខា ឬជាទូទៅ ផ្តិតស្នាមមេដៃរបស់ពួកគេនៅលើឯកសារ។[385] បន្ទាប់មក កិច្ចសន្យានឹងត្រូវអនុម័តដោយអាជ្ញាធរមូលដ្ឋាន ដូចជា មេឃុំ ជាដើម។[386] វាគឺជាការអនុវត្តទូទៅសម្រាប់អ្នកផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ក្នុងការទាមទារផលប្រយោជន៍លើដីធ្លី ដើម្បីធានាចំពោះប្រតិបត្តិការ។[387]

180. ច្បាប់ភូមិបាលចែងថា ដីធ្លីអាចត្រូវបានប្រើប្រាស់ជាវត្ថុបញ្ចាំសម្រាប់កម្ចី។[388] ដីធ្លីអាចត្រូវបានដាក់ជាវត្ថុធានាដោយម្ចាស់កម្មសិទ្ធិ ដើម្បីធានាបំណុលនៅក្នុងកិច្ចសន្យា ដែលជាការបញ្ចាំ *កិច្ចសន្យាដាក់បញ្ចាំ* ឬ *កិច្ចសន្យាធានា*។[389] *កិច្ចសន្យាដាក់បញ្ចាំ* គឺជាកិច្ចសន្យាមួយប្រភេទ ដែលអ្នកជំពាក់បំណុលផ្តល់អចលនទ្រព្យ ដីធ្លី ជូនម្ចាស់បំណុលជាការធានាចំពោះការសងបំណុល ហើយម្ចាស់បំណុលអាចលក់ទ្រព្យសម្បត្តិនោះដើម្បីបង្វិលប្រាក់សងបំណុល ឬរក្សាទុកទ្រព្យសម្បត្តិនោះបាន ប្រសិនបើត្រូវបានអនុញ្ញាតនៅក្នុងកិច្ចសន្យាច្បាប់ដើម។[390] ការលក់ទ្រព្យសម្បត្តិត្រូវតែដំណើរការដោយសេចក្តីសម្រេចរបស់តុលាការ។[391] *កិច្ចសន្យាធានា* គឺជាកិច្ចសន្យាមួយប្រភេទ ដែលកូនបំណុលផ្តល់បណ្ណកម្មសិទ្ធទ្រព្យសម្បត្តិជូនម្ចាស់បំណុល។[392] ក្នុងករណីអ្នកខ្ចីមានកំហុស ម្ចាស់បំណុលអាចស្នើសុំឲ្យតុលាការរឹបអូសទ្រព្យសម្បត្តិនោះបាន។[393] នៅក្រោម*កិច្ចសន្យាដាក់បញ្ចាំ* ឬកិច្ចសន្យាធានា ម្ចាស់បំណុលមិនអាចក្លាយជាម្ចាស់កម្មសិទ្ធិលើទ្រព្យសម្បត្តិនោះបានទេ។[394]

181. នៅឆ្នាំ២០១៧ [ត្រូវបានលុបចោល] រដ្ឋាភិបាលបានកំណត់អត្រាការប្រាក់ត្រឹម ១៨ ភាគរយ សម្រាប់

---

[382] ក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជា មាត្រា ៣៤៥.

[383] ប្រកាសស្តីពីតម្លាភាពក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ មាត្រា ៣ លេខ ធ៧-០១១-២៤៣ (ឆ្នាំ២០១១) (ការបកប្រែមិនផ្លូវការជាភាសាអង់គ្លេស) *មាននៅ* https://www.nbc.org.kh/download_files/legislation/prakas_eng/៦៦៨៣B៧-០១១-២៤៣.pdf.

[384] ក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជា មាត្រា ៣៥៤(១)(ក).

[385] អង្គការលីកាដូ ការខូចខាតវត្ថុបញ្ចាំ កំណត់សម្គាល់ខាងលើ លេខ ១៤១ នៅ ១៣.

[386] *Id.*

[387] *Id.*

[388] ច្បាប់ភូមិបាល មាត្រា ១៩៧, ២០៦, ២១១, ២១៩, ២២១, នស/រកម/០៨០១/១៤ (២០០១).

[389] ច្បាប់ភូមិបាល មាត្រា ១៩៧.

[390] ច្បាប់ភូមិបាល មាត្រា ២០៦.

[391] ច្បាប់ភូមិបាល មាត្រា ២១១; ក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជា មាត្រា ៤១៧, ៤៣៦.

[392] ច្បាប់ភូមិបាល មាត្រា ២១៩, ២២១.

[393] ច្បាប់ភូមិបាល មាត្រា ២២១.

[394] ច្បាប់ភូមិបាល មាត្រា ២១០, ២២១

កម្ចីពីធនាគារ MFIs MFDIs និងប្រតិបត្តិករឥណទានជនបទ ដែលក្រោមការគ្រប់គ្រងរបស់ NBC។[395] នៅឆ្នាំ២០១៩ អត្រាការប្រាក់ជាមធ្យមលើកម្ចីជារូបិយប័ណ្ណក្នុងស្រុក (រៀល) គឺ ១៧,៩ ភាគរយ។[396] លើសពីនេះទៀត MFIs គិតអត្រាការប្រាក់អ្នកខ្ចីលើសកម្រិត ១៨ ភាគរយ ដោយគិតកម្រៃជាមុន នៅពេលបញ្ចេញប្រាក់កម្ចី ហើយកាត់បន្ថយចំនួនប្រាក់កម្ចីសរុប ដែលចេញជូនអតិថិជនប្រកបដោយប្រសិទ្ធភាព ទោះបីជាអត្រាការប្រាក់នៅតែត្រូវបានគណនាដោយផ្អែកលើចំនួនទឹកប្រាក់ពេញលេញក៏ដោយ ថ្លៃសេវាជាមុន។[397] IFC បានប្រមើលមើល និងបានជូនដំណឹងអំពីបាតុភូតនេះនៅក្នុងរបាយការណ៍ស្តីពីកិច្ចការពារអ្នកប្រើប្រាស់នៅកម្ពុជា ឆ្នាំ២០១៥ របស់ខ្លួន។[398]

182. នៅឆ្នាំ២០១៧ រដ្ឋាភិបាលក៏បានចេញសេចក្តីសម្រេចអន្តរក្រសួងសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមអំណាចរបស់ NBC រួមទាំង MFIs ផងដែរ ដើម្បីបង្កើតក្របខណ្ឌគ្រប់គ្រងពាក្យបណ្តឹងរបស់អ្នកប្រើប្រាស់ និងគោលនយោបាយពាក់ព័ន្ធ។ បទបញ្ញានេះបានកំណត់ពេលវេលាសម្រាប់ការទទួល និងដោះស្រាយបណ្តឹង ព្រមទាំងលក្ខខណ្ឌក្នុងការរាយការណ៍ទៅកាន់ NBC ផងដែរ។[399]

183. CMA បានចេញគោលការណ៍ណែនាំស្តីពីការផ្តល់កម្ចីនៅឆ្នាំ២០១៧ សម្រាប់ MFIs រួមទាំងការដាក់កម្រិតលើចំនួនកម្ចី MFI សកម្មសម្រាប់អ្នកខ្ចី។[400] CMA ក៏បានផ្សព្វផ្សាយអំពីកម្មវិធីផ្តល់លិខិតបញ្ជាក់សម្រាប់យុទ្ធនាការវ្លាតវែសម្រាប់ការគ្រប់គ្រងខ្លួនឯង ដោយ MFIs។[401] ទោះបីជាយ៉ាងណាក៏ដោយ គោលការណ៍ណែនាំដែលចេញដោយ CMA មានបញ្ហា ដែលពួកគេគ្រប់គ្រងខ្លួនឯង និងខ្វះខាតការត្រួតពិនិត្យ ឬការពង្រឹងការអនុវត្ត។[402] IFC ដោយផ្ទាល់ បានទទួលស្គាល់ថា "កូដ [ស្ម័គ្រចិត្ត] [ដោយសមាគមឧស្សាហកម្ម MFI] មាននិន្នាការខ្សោយចំពោះកម្រិតលម្អិត ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ការរាយការណ៍ជាសាធារណៈ និងការពង្រឹងការអនុវត្ត"។[403] CMA មិនបានអនុវត្ត ឬពុំមានអំណាចត្រួតពិនិត្យជាផ្លូវការទេ និងត្រូវបានគេចាត់ថ្នាក់ថា តំណាងឱ្យ "ផលប្រយោជន៍របស់អ្នក

---

[395] ប្រកាសស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទាន មាត្រា ១–៥ លេខ ធ៧.០១៧.១០៩.ប្រក. (ឆ្នាំ២០១៧) (ការបកប្រែមិនផ្លូវការជាភាសាអង់គ្លេស) *មាននៅ* https://www.nbc.org.kh/download_files/legislation/prakas_eng/Prakas-on-Interest-Rate-Cap-Eng.pdf.

[396] ធនាគារជាតិកម្ពុជា របាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ នៅទំព័រ ៧ (ឆ្នាំ២០១៩).

[397] អង្គការលីកាដូ ការខូចខាតវត្ថុបញ្ចាំ កំណត់សម្គាល់ខាងលើ លេខ ១៤១ នៅ ១៤; កំណត់សម្គាល់អំពីគោលនយោបាយកម្ពុជារបស់ WB កំណត់សម្គាល់ខាងលើ លេខ ១៤៨ នៅ ១៥–១៦ ប្រអប់ ២ នៅ ១៧.

[398] *សូមមើល* IFC ការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា កំណត់សម្គាល់ខាងលើ លេខ ១៣០ នៅ ៣១ ("ក៏មានកង្វល់ផងដែរថា អ្នកផ្តល់កម្ចីអាចផ្សព្វផ្សាយអំពីអត្រាកម្ចីទាប... ប៉ុន្តែអ្នកផ្តល់កម្ចីអនុវត្តថ្លៃសេវាបន្ទាប់បន្សំ និងថ្លៃសេវាដែលមិនបានផ្សព្វផ្សាយ ឬសោហ៊ុយដែលមិនអាចជៀសផុតដទៃទៀត ដែលអាចធ្វើឲ្យកម្ចីសរុបមានតម្លៃថ្លៃជាងអ្វីដែលបានផ្សព្វផ្សាយ")។

[399] ប្រកាសស្តីពីដំណោះស្រាយពាក្យបណ្តឹងរបស់អ្នកប្រើប្រាស់ លេខ ធ៧-០១៧-២៩ (២០១៧) (ការបកប្រែមិនផ្លូវការជាភាសាអង់គ្លេស) *មាននៅ* https://www.nbc.org.kh/download_files/legislation/prakas_eng/Prakas_on_Resolution_of_Consumer_Complaints_ENG.pdf.

[400] សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា អនុស្សរណៈស្តីពីការយោគយល់គ្នាលើគោលការណ៍ណែនាំអំពីការផ្តល់កម្ចីបណ្តោះអាសន្ន (MOU ព្រះសីហនុ) ថ្ងៃ *ធនាគារពិភពលោក៖ ស៊ើបអង្កេតកម្ចីខ្នាតមីក្រូនៅកម្ពុជា ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ https://www.hrw.org/news/*2020/12/14/*world-bank-investigate-cambodias-micro-loans#.*

[401] David Hutt "តើយើងអាចទុកចិត្តសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាបានដែរឬទេ?" The Diplomat ថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១, https://thediplomat.com/2021/01/can-we-trust-the-cambodia-microfinance-association/.

[402] *សូមមើល Id.*

[403] IFC ការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា កំណត់សម្គាល់ខាងលើ លេខ ១៣០ នៅ ៨.

ផ្តល់កម្ចី មិនមែនអ្នកខ្ចីនោះទេ”។[404] លើសពីនេះទៀត ការដាក់កម្រិតលើចំនួនកម្ចីសកម្ម ជាក់ស្តែងបានបង្កើនបំណុល ពីព្រោះ ដោយសារតិត្ថិភាពនៃទីផ្សាខ្ពស់ អ្នកផ្តល់កម្ចី MFI ស្នើផ្តល់កម្ចីទៅកាន់អតិថិជនកាន់តែច្រើន ក្នុងគោលបំណង "សង" កម្ចីដែលមានស្រាប់ ដូច្នេះហើយ ធ្វើឲ្យពួកគេអាចចេញកម្ចីថ្មីនៅក្នុងចំនួនកំណត់នៃគោលការណ៍ណែនាំបាន។[405]

184. [ត្រូវបានលុបចោល][406]

## B. កង្វះខាតកិច្ចការពារអ្នកប្រើប្រាស់

185. ប្រទេសកម្ពុជាមានកំណត់ត្រាអាក្រក់បំផុតមួយ ស្តីពីការត្រួតពិនិត្យរបស់រដ្ឋាភិបាលលើវិស័យមីក្រូហិរញ្ញវត្ថុ។[407] ច្បាប់ស្តីពី MFIs និង MFDIs ស្ទើរតែគ្មានបញ្ញត្តិស្តីពីកិច្ចការពារអ្នកប្រើប្រាស់នោះទេ។[408] ក្នុងចំណោម ៥៥ ប្រទេស ដែលត្រូវបានវាយតម្លៃដោយ អង្គភាពស៊ើបការណ៍សេដ្ឋកិច្ចវិទូ (The Economist Intelligence Unit) នៅឆ្នាំ២០១៩ លើរបាយការណ៍មីក្រូទស្សន៍សកល (Global Microscope) របស់ពួកគេ ប្រទេសកម្ពុជាស្ថិតក្នុងចំណាត់ថ្នាក់ ១០ ប្រទេសខាងក្រោមបំផុត ដោយមានពិន្ទុត្រឹមតែ ៣៧ លើ ១០០ សម្រាប់គោលនយោបាយរដ្ឋាភិបាលនៃប្រជាជនកម្ពុជាសម្រាប់គោលនយោបាយ និងបទប្បញ្ញត្តិរបស់រដ្ឋាភិបាលក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។[409]

186. IFC បានរាយការណ៍អំពីកង្វះខាតកិច្ចការពារអ្នកប្រើប្រាស់នៅឆ្នាំ២០១៥។[410] ធនាគារពិភពលោកស្រដៀងគ្នានេះដែរ បានអំពាវនាវឱ្យមានការកែលម្អកិច្ចការពារអ្នកប្រើប្រាស់ ដើម្បីការពារអ្នកខ្ចីពីការផ្តល់កម្ចីដ៏ឃោឃៅនៅក្នុងកំណត់សម្គាល់គោលនយោបាយ ឆ្នាំ២០១៩ របស់ខ្លួន ស្តីពីមីក្រូហិរញ្ញវត្ថុ និងសុខុមាលភាពគ្រួសារ។[411]

---

[404] Hutt កំណត់សម្គាល់ខាងលើលេខ ៤០១.

[405] MIMOSA ឆ្នាំ២០១៦ សារាចរពិសេស កំណត់សម្គាល់ខាងលើ លេខ ១៣១.

[406] [ត្រូវបានលុបចោល]

[407] *Cf.* IFC ការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា កំណត់សម្គាល់ខាងលើ លេខ ១៣០ នៅ ៨ ("NBC គួរតែត្រួតពិនិត្យឡើងវិញលើភាពគ្រប់គ្រាន់នៃអភិបាលកិច្ច [អ្នកផ្តល់សេវាហិរញ្ញវត្ថុ រួមទាំង MFI ផងដែរ] ពាក់ព័ន្ធនឹងការពិនិត្យតាមដានគុណភាពនៃអនុលោមភាពផ្ទៃក្នុងរបស់គណៈគ្រប់គ្រង ពាក់ព័ន្ធនឹងភាពអនុលោមតាមច្បាប់ ក្រមសីលធម៌ គោលនយោបាយសាជីវកម្ម និងការអនុវត្តផ្នែកប្រតិបត្តិការ ដែលត្រូវបានរៀបចំឡើងដើម្បីការពារអ្នកប្រើប្រាស់").

[408] *ជាទូទៅ សូមមើល* ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ.

[409] The Economist, Global Microscope ឆ្នាំ២០១៩៖ បរិយាកាសអំណោយផលសម្រាប់បរិយាប័ន្នហិរញ្ញវត្ថុ និងការពង្រីកសេវាហិរញ្ញវត្ថុឌីជីថល នៅ ៨ (២០១៩).

[410] ផ្នែក III ខាងលើ.

[411] កំណត់សម្គាល់អំពីគោលនយោបាយកម្ពុជា របស់ WB ឆ្នាំ២០១៩ កំណត់សម្គាល់ខាងលើ លេខ ១៤៨ នៅ ២២–២៣.

187. [ត្រូវបានលុបចោល][412][413][414][415][416][417]

## C. [ត្រូវបានលុបចោល]

188. គ្រោងការណ៍ដ៏ទូលំទូលាយនៃការផ្តល់កម្ចីដ៏ឃោឃៅបានរីកចម្រើនដោយពុំមានការរឹតបន្តឹង និងការត្រួតពិនិត្យការវិនិយោគឲ្យបានគ្រប់គ្រាន់។ ការរួមបញ្ចូលគ្នានៃកត្តានានា រួមទាំងការទូទាត់ប្រាក់លើកទឹកចិត្តដោយធ្វេសប្រហែលដល់មន្ត្រីកម្ចី និងតិត្ថិភាពទីផ្សារខ្ពស់ និងការជ្រៀតចូល បានបន្តហានិភ័យរបស់អ្នកប្រើប្រាស់យ៉ាងពិតប្រាកដ ដែល IFC បានសង្កេតឃើញនៅក្នុងឆ្នាំ២០១៥ ដែលអ្នកផ្តល់កម្ចីគ្មានសីលធម៌បង្ខំអ្នកខ្ចី នៅដំណាក់កាលដំបូងនៃការមិនបង់ប្រាក់ ឲ្យលក់ដីធ្លីរបស់ពួកគេដោយគ្មានដំណោះស្រាយតាមនីតិវិធីច្បាប់ជាផ្លូវការ។

189. [ត្រូវបានលុបចោល][418]

190. MFIs ពុំមានកង្វះខាតឧបករណ៍នៅក្នុងការចាត់ចែងរបស់ពួកគេ ដើម្បីបង្ខំអ្នកខ្ចីឱ្យលក់ដីធ្លីជាលក្ខណៈឯកជននោះទេ។ MFIs ជាញឹកញាប់ តម្រូវឱ្យអ្នកខ្ចីដាក់បណ្ណកម្មសិទ្ធិដីធ្លីជាច្រើន លើសពីតម្លៃកម្ចី ដើម្បីធានាថា អ្នកខ្ចីមិនអាចប្រើប្រាស់បណ្ណកម្មសិទ្ធិដីធ្លីដទៃទៀតដើម្បីធានាកម្ចីពី MFIs ដទៃទៀតបានទេ។[419] នាយកប្រតិបត្តិ MFI បានបន្ថែមថា អាជ្ញាធរមូលដ្ឋានមានភាពស្មុគស្មាញក្នុងការដាក់សម្ពាធបន្ថែម និងជះឥទ្ធិពលលើម្ចាស់ដី ដែលស្ទាក់ស្ទើរ ឲ្យលក់ដីជាលក្ខណៈឯកជន។ ការពិតដែលថា MFI អាចកាន់កាប់បណ្ណកម្មសិទ្ធិបាន បង្កើតសម្ពាធបន្ថែមលើអ្នកខ្ចី ដែលមិនយល់អំពីដំណើរការតាមផ្លូវច្បាប់ ក្នុងករណីមានកំហុសឆ្គង ដោយភ័យខ្លាចថា MFI អាចលក់ទ្រព្យសម្បត្តិរបស់ពួកគេបាន ប្រសិនបើពួកគេយឺតយ៉ាវក្នុងការសងប្រាក់មួយថ្ងៃ ដោយភ័យខ្លាចន្ត្រីឥណទានដែលគ្មានសីលធម៌ទាញប្រយោជន៍ពីពួកគេ។[420] អ្នកខ្ចីដែលយឺតយ៉ាវក្នុងការសងវិញ តែងតែភ័យខ្លាចថា ប្រសិនបើពួកគេមិនលក់ដីធ្លីដោយខ្លួនឯងទេនោះ MFI នឹងលក់វាក្នុងតម្លៃទាបជាងទីផ្សារ ដើម្បីទទួលបានតម្លៃកម្ចីមកវិញ ដែលជាញឹកញាប់ ទាបជាងតម្លៃដីជាក់ស្តែងឆ្ងាយណាស់។[421] ការមិនអើពើរបស់អ្នកខ្ចីចំពោះដំណើរការតាមផ្លូវច្បាប់ និងសិទ្ធិរបស់ពួកគេ ក្រោមកិច្ចព្រមព្រៀងកម្ចី ធ្វើឱ្យ MFIs បង្ហាញអំពីផលវិបាកបន្ថែមទៀតនៃការសងប្រាក់យឺតយ៉ាវ និងគំរាមកំហែងអាជ្ញាធរមូលដ្ឋាន។ មន្ត្រីប្រតិបត្តិ MFI ចំនួនពីររូប ដែលបាននិយាយជាមួយអង្គការលីកាដូ អំពីលក្ខខណ្ឌនៃអនាមិកភាពក្នុងឆ្នាំ២០១៩ បានបញ្ជាក់ថា អាជ្ញាធរមូលដ្ឋាន ជាញឹកញាប់ មានភាពស្មុគស្មាញក្នុងការដាក់សម្ពាធបន្ថែមលើម្ចាស់ដីធ្លី

---

[412] [ត្រូវបានលុបចោល]

[413] [ត្រូវបានលុបចោល]

[414] [ត្រូវបានលុបចោល]

[415] [ត្រូវបានលុបចោល]

[416] [ត្រូវបានលុបចោល]

[417] [ត្រូវបានលុបចោល]

[418] អង្គការលីកាដូ ការខូចខាតវត្ថុបញ្ចាំង កំណត់សម្គាល់ខាងលើ លេខ ១៤១ នៅ ២ ៦–៧.

[419] *Id.* នៅ ៦ (ដកស្រង់ពី MICROFINANCE CENTRE, GOOD RETURN, និងអ្នកដទៃទៀត ការសិក្សាអំពីការជំពាក់បំណុលច្រើនពេកនៅកម្ពុជា II៖ របាយការណ៍ចុងក្រោយ (ខែតុលា ២០១៧))

[420] *Id.* នៅ ៧.

[421] *Id.*

ឲ្យធ្វើការលក់ដីធ្លីជាលក្ខណៈឯកជន។[422] ចំណុចនេះត្រូវបានបញ្ជាក់ថាជាការអនុវត្តទូទៅ នៅក្នុងការស្រាវជ្រាវទាំងមូល ដែលធ្វើឡើងដោយអង្គការលីកាដូ EC និង CSOs ដទៃទៀតនៅក្នុងប្រទេសកម្ពុជា។

191. IFC បានដឹងពីគ្រោងការណ៍ផ្តល់កម្ចីដ៏ឃោឃៅ និងហានិភ័យក្នុងការអនុវត្តការប្រមូលប្រាក់ដោយបំពាន នៅពេលដែល IFC ត្រួតពិនិត្យគំរូនៃកិច្ចសន្យាកម្ចី ដែលជាផ្នែកមួយនៃការពិនិត្យឡើងវិញរបស់ខ្លួននៅឆ្នាំ២០១៥ និងព័ត៌មានលម្អិតជាច្រើន ទាក់ទងនឹងខចែង ដែលគាំទ្រដល់ការផ្តល់កម្ចីដ៏ឃោឃៅ និងការបង្ខំឲ្យលក់ដីធ្លី។ ជាពិសេស IFC បានដាស់តឿនថា ភាសានៃកិច្ចសន្យាហាក់បីដូចជាបានអនុញ្ញាតឱ្យអ្នកផ្តល់កម្ចី "យកប្រាតិភោគ/វត្ថុបញ្ចាំ ទោះបីជាការទូទាត់ប្រាក់យឺតតែមួយថ្ងៃក៏ដោយ" និងថាពុំមានលក្ខខណ្ឌតម្រូវឲ្យអ្នកផ្តល់កម្ចី "ជូនដំណឹងដល់អតិថិជនជាមុន មុនពេលយកប្រាតិភោគ/វត្ថុបញ្ចាំ" នោះទេ។[423] IFC បានកត់សម្គាល់បន្ថែមទៀតថា ភាសានៃកិច្ចសន្យា "មិនបានបញ្ជាក់ថា ប្រសិនបើការលក់ប្រាតិភោគ/វត្ថុបញ្ចាំ បានលើសពីតម្លៃនៃកម្ចី អតិរេកនោះនឹងត្រូវប្រគល់ជូនអ្នកខ្ចីវិញនោះទេ ហើយប្រសិនបើត្រូវប្រគល់ជូនវិញ តើនៅពេលណា។ វាមិនបានបញ្ជាក់ថា ប្រសិនបើតម្លៃលក់តិចជាងតម្លៃកម្ចី អ្នកខ្ចីនៅតែត្រូវទទួលខុសត្រូវ"។[424] នៅខណៈពេលដែលអ្នកខ្ចីជាច្រើននាក់មិនអាចអានកិច្ចសន្យារបស់ពួកគេ ឬមិនយល់អំពីលក្ខខណ្ឌនោះ ភាសានេះកំពុងបង្ហាញអំពីសម្ពាធរបស់មន្ត្រីឥណទានដែលដាក់លើអ្នកខ្ចី ដើម្បីបង្ខំពួកគេឱ្យប្រញាប់លក់វាជាលក្ខណៈឯកជន។ **[ត្រូវបានលុបចោល]**

192. **[ត្រូវបានលុបចោល]**។ មាត្រា ៣៦៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា ចាត់ទុកថាជាបទល្មើសចំពោះ "ការជំរិតទារប្រាក់" ជាទង្វើនៃការទទួលបានហត្ថលេខា ឬស្នាមមេដៃ ការប្តេជ្ញាចិត្ត ឬការបោះបង់ចោល ឬការប្រគល់ទ្រព្យសកម្មណាមួយ នៅក្នុងចំណោមអ្វីផ្សេងទៀត ដោយហិង្សា ការគំរាមប្រព្រឹត្តអំពើហិង្សា ឬការបង្ខិតបង្ខំ។[425] ការបង្ខិតបង្ខំមិនត្រូវបានកំណត់និយមន័យដាច់ដោយឡែក នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជានោះទេ ប៉ុន្តែត្រូវបានរួមបញ្ចូលនៅក្នុងការហាមឃាត់ជាច្រើនផ្សេងទៀត នៅក្នុងបរិបទស្រដៀងគ្នា រួមជាមួយអំពើហិង្សា និងការគំរាមកំហែងប្រព្រឹត្តិអំពើហិង្សាផងដែរ។[426] ការបង្ខិតបង្ខំត្រូវបានកំណត់និយមន័យស្រដៀងគ្នា តាមរយៈការយោងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិថា "ដែលបណ្តាលមកពីភាពភ័យខ្លាចអំពើហិង្សា ការបង្ខិតបង្ខំ ការឃុំខ្លួន ការគៀបសង្កត់ផ្លូវចិត្ត ឬការបំពានដោយអំណាច"។[427] ដូច្នេះ ការបង្ខិតបង្ខំ គឺជាការបង្ខិតបង្ខំដោយខុសច្បាប់ ដោយប្រើមធ្យោបាយផ្សេងៗ ដើម្បីបង្ខំឱ្យទទួលបានលទ្ធផលដែលចង់បានពីភាគីផ្សេង។ ដូច្នេះ ការបង្ខិតបង្ខំ គឺជាការដាក់សម្ពាធដោយមិនស្របច្បាប់ ដោយតុណ្ហិភាព ដោយប្រើមធ្យោបាយផ្សេងៗ ដើម្បីបង្ខំឱ្យទទួលបានលទ្ធផល

---

[422] *Id.* នៅ ២, ៧.

[423] IFCការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា កំណត់សម្គាល់ខាងលើ លេខ ១៣០ នៅ ៣៤.

[424] *Id.*

[425] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៦៣ (២០០៩).

[426] *សូមមើល* ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ២៣៩ ២៨៨ ២៩៩.

[427] *សូមមើល ឧ.* តុលាការព្រហ្មទណ្ឌអន្តរជាតិ ធាតុនៃឧក្រិដ្ឋកម្ម មាត្រា ៦(ង) កថាខណ្ឌ១ និង ក.៥ មាត្រា ៧(១)(យ) កថាខណ្ឌ១ និង ក.១២ មាត្រា ៧(១)(ច)-១ កថាខណ្ឌ ២ (ឆ្នាំ២០១១).

ដែលចង់បានពីភាគីម្ខាងទៀត។[428] [ត្រូវបានលុបចោល]

193. [ត្រូវបានលុបចោល][429]

194. [ត្រូវបានលុបចោល][430] [431] [432] [433]

## ឃ. ការរំលោភបំពានលើសិទ្ធិរបស់ជនជាតិដើមភាគតិច

195. មាត្រា ២៣ និង ២៥ នៃច្បាប់ភូមិបាលកម្ពុជា ឆ្នាំ២០០១ ធានាសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការគ្រប់គ្រងសហគមន៍ និងអចលនវត្ថុរបស់ពួកគេ រួមទាំងដីធ្លីនៅកន្លែងដែលពួកគេបានបង្កើតលំនៅដ្ឋានស្របតាមទំនៀមទម្លាប់ប្រពៃណី។[434] ជនដែលមិនមែនជាសមាជិកសហគមន៍ត្រូវបានហាមឃាត់មិនឲ្យទទួលបានសិទ្ធិលើអចលនទ្រព្យរបស់ជនជាតិដើមភាគតិចនោះទេ។[435] ភាពជាប់ពាក់ព័ន្ធក្នុងការការពារទាំងនេះ គឺជាសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការផ្តល់ ឬកាត់ទុកការយល់ព្រមរបស់ពួកគេដោយសេរីចំពោះការប្រើប្រាស់ដីធ្លីរបស់ពួកគេ។[436] ការអនុវត្តការផ្តល់ប្រាក់កម្ចីយ៉ាងគឃ្លើនរបស់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុ IFC រួមមានការទាមទារសិទ្ធិលើដីរបស់ជនជាតិដើមភាគតិចជាវត្ថុបញ្ចាំ និងការបង្ខំឱ្យលក់ដីនោះ ដោយមិនគិតពីថាតើការលក់ទាំងនោះទៅឱ្យអ្នកខ្ចីនៅក្រៅសហគមន៍ជនជាតិដើមភាគតិចនោះទេ។ ការអនុវត្តការផ្តល់ប្រាក់កម្ចីយ៉ាងគឃ្លើនរបស់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC រួមមាន ការទាមទារសិទ្ធិលើដីធ្លីរបស់ជនជាតិដើមភាគតិច ដែលជាវត្ថុបញ្ចាំ និងការបង្ខំឱ្យលក់ដីធ្លីនោះ ដោយមិនគិតពីថាតើការលក់ទាំងនោះទៅឱ្យអ្នកខ្ចីនៅក្រៅសហគមន៍ជនជាតិដើមភាគតិចនោះទេ។ [ត្រូវបានលុបចោល] ដូច្នេះ រចនាបថនៃសកម្មភាពអាជីវកម្មរបស់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ IFC រំលោភបំពានលើសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការគ្រប់គ្រងសហគមន៍ និងអចលនទ្រព្យរបស់ពួកគេ និងផ្តាច់ទំនាក់ទំនងផ្នែកវប្បធម៌ពីដីដែលបានលក់នោះជារៀងរហូត។

196. [ត្រូវបានលុបចោល]

## ង. ការអនុវត្តនៃការផ្តល់កម្ចីដោយបោកបញ្ឆោត និង [ត្រូវបានលុបចោល]

[428] *សូមមើល id.*

[429] [ត្រូវបានលុបចោល]

[430] [ត្រូវបានលុបចោល]

[431] [ត្រូវបានលុបចោល]

[432] [ត្រូវបានលុបចោល]

[433] [ត្រូវបានលុបចោល]

[434] ច្បាប់ភូមិបាល មាត្រា ២៣ ២៥.

[435] ច្បាប់ភូមិបាល មាត្រា ២៨.

[436] *សូមមើល* បណ្តឹងពាក់ព័ន្ធនឹងការវិនិយោគរបស់ IFC នៅក្នុងធនាគារពាណិជ្ជរួមទុន Tien Phong Commercial Joint Stock Bank (TPBank) និង ធនាគារពាណិជ្ជរួមទុន Vietnam Prosperity Joint Stock Commercial Bank (VPBank), ១២ មីនា ២០១៩ កថាខណ្ឌ ៣៦។

197. [ត្រូវបានលុបចោល][437] [438]

198. [ត្រូវបានលុបចោល]

## VI. <u>លទ្ធផលដែលដើមបណ្តឹងបានស្នើសុំ</u>

199. [ត្រូវបានលុបចោល]

200. [ត្រូវបានលុបចោល]

201. [ត្រូវបានលុបចោល]

[437] [ត្រូវបានលុបចោល]

[438] [ត្រូវបានលុបចោល]

ឧបសម្ព័ន្ធទី ៥៖ ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC

# សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ

## ការឆ្លើយតបរបស់គណៈគ្រប់គ្រង
## ចំពោះពាក្យបណ្ដឹងដែលបានដាក់ជូនទៅការិយាល័យ ស៊ីអេអូ
## ពាក់ព័ន្ធនឹង

អតិថិជន IFC ចំនួនបី៖

អេស៊ីលីដា (គម្រោងលេខ ៤២៤៨០ លេខ ៤៤៨៨២)

អម្រឹត (គម្រោងលេខ ៣៤៧៤៨ លេខ ៤៤២៣១)

ធនាគារហត្ថា (គម្រោងលេខ ៤៤៧៤២ លេខ ៤៥៥៣៥)

និង

អនុគម្រោងចំនួនបួន ពាក់ព័ន្ធនឹង

ធនាគារអេស៊ីលីដា ធនាគារហត្ថា អម្រឹត ប្រាសាក់ ស្ថាបនា និង អិលអូអិលស៊ី

(គម្រោងលេខ ២៧៨២៧ ៣១៤៦៧ ២១៨៥៦ ៣៨៦០៩)

ប្រទេសកម្ពុជា

ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២

# តារាងមាតិកា

អក្សរកាត់ ..... 3
សេចក្តីសង្ខេប ..... 4
I. សេចក្តីផ្តើម ..... 9
II. សាវតារបស់គម្រោង ..... 10
A. អេស៊ីលីដា ..... 11
B. HTB ..... 13
C. អម្រឹត ..... 14
D. ប្រាសាក់ អិលអូអិលស៊ី និង ធនាគារ ស្ថាបនា ..... 15
III. ពាក្យបណ្តឹងទៅស៊ីអេអូ ..... 16
IV. ការឆ្លើយតបរបស់គណៈគ្រប់គ្រង ..... 18

# អក្សរកាត់

| | |
|---|---|
| ABC | សមាគមធនាគារកម្ពុជា |
| អេស៊ីលីដា | ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| Advans | Advans SA SICAR |
| អម្រឹត | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត |
| ស៊ីអេអរ | ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ |
| CMA | សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា |
| CPF | ក្របខណ្ឌភាពជាដៃគូប្រចាំប្រទេស |
| CSO | អង្គការសង្គមស៊ីវិល |
| E&S | បរិស្ថាន និងសង្គម |
| EC | អង្គការសមធម៌កម្ពុជា |
| FCP | កិច្ចការពារអតិថិជនហិរញ្ញវត្ថុ |
| FI | គ្រឹះស្ថានហិរញ្ញវត្ថុ |
| FY | ឆ្នាំហិរញ្ញវត្ថុ |
| HKL | ហត្ថាកសិករ លីមីតធីត |
| HTB | ធនាគារ ហត្ថា |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| លីកាដូ | អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស |
| អិលអូអិលស៊ី | អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី |
| MEF | ឥណទានពង្រឹងមីក្រូហិរញ្ញវត្ថុ S.A., SICAV-SIF |
| MFI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| MIFA | មូលនិធិគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុលអាស៊ី |
| MSMEs | សហគ្រាសធុនមីក្រូ តូច និងមធ្យម |
| NBC | ធនាគារជាតិកម្ពុជា |
| NFIS | យុទ្ធសាស្ត្រជាតិស្តីពីបរិយាប័ន្នហិរញ្ញវត្ថុ |
| North Haven | ក្រុមហ៊ុន North Haven Thai Private Equity L.P. |
| ប្រាសាក់ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក |
| ស្ថាបនា | ធនាគារ ស្ថាបនា ភីអិលស៊ី |
| SMEs | សហគ្រាសធុនតូច និងមធ្យម |
| US$ | ដុល្លារអាមេរិក |
| WBG | ក្រុមធនាគារពិភពលោក |
| WMSMEs | សហគ្រាសធុនមីក្រូ តូច និងមធ្យម ដែលគ្រប់គ្រងដោយស្ត្រី |
| WSMEs | សហគ្រាសធុនតូច និងមធ្យម ដែលគ្រប់គ្រងដោយស្ត្រី |

# សេចក្តីសង្ខេប

i. ការឆ្លើយតបរបស់គណៈគ្រប់គ្រងនេះទាក់ទងនឹងពាក្យបណ្តឹងដែលការិយាល័យភាពអនុលោម ទីប្រឹក្សាដោះស្រាយវិវាទ (ស៊ីអេអូ) បានទទួល កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ ទាក់ទងនឹងគម្រោងសកម្មចំនួនដប់ និងគម្រោងបិទចំនួនបី និងអនុគម្រោង ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ (FIs) ចំនួនប្រាំមួយនៅប្រទេសកម្ពុជា (ពាក្យបណ្តឹង)។ ពាក្យបណ្តឹងនេះទាក់ទងនឹងអតិថិជន IFC ចំនួនបីគឺ ធនាគារ អេស៊ីលីដា ភីអិលស៊ី (អេស៊ីលីដា) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត (អម្រឹត) និងធនាគារ ហត្ថា (HTB) និងអតិថិជនរងចំនួនបីគឺ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី (អិលអូអិលស៊ី) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក (ប្រាសាក់) និងធនាគារស្ថាបនាភីអិលស៊ី (ស្ថាបនា) តាមរយៈការវិនិយោគដោយមូលនិធិចំនួនបី រួមមាន ឥណទានពង្រឹងមីក្រូហិរញ្ញវត្ថុ S.A., SICAV-SIF (MEF), មូលនិធិគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុលអាស៊ី SA, SICAV-SIF (MIFA) និងក្រុមហ៊ុន North Haven Thai Private Equity L.P. (North Haven) និងក្រុមហ៊ុនហូងឌីង Advans SA SICAR (Advans) ដែល IFC មានការវិនិយោគផ្ទាល់។

ii. ពាក្យបណ្តឹងនេះត្រូវបានដាក់ដោយអង្គការសង្គមស៊ីវិល (CSOs) ក្នុងស្រុកចំនួនពីរគឺ អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) និងអង្គការសមធម៌កម្ពុជា (EC) តាងនាមឲ្យអ្នកខ្ចីប្រាក់មួយក្រុមដែលរងផលប៉ះពាល់ (ដើមបណ្តឹង)។ ពាក្យបណ្តឹងនេះបានលើកឡើងអំពីកង្វល់ពាក់ព័ន្ធនឹងការអនុវត្តក្នុងការផ្តល់កម្ចី និងការប្រមូលប្រាក់របស់គ្រឹះស្ថានហិរញ្ញវត្ថុចំនួនប្រាំមួយនៅប្រទេសកម្ពុជា។ ដើមបណ្តឹងបានចោទប្រកាន់ថា ពួកគេមិនត្រូវបានផ្តល់ជូននូវព័ត៌មានគ្រប់គ្រាន់ ជាភាសាដែលពួកគេអាចយល់បានដើម្បីយល់យ៉ាងច្បាស់អំពីលក្ខខណ្ឌនៃកម្ចីដែលពួកគេបានព្រមព្រៀងនោះទេ។ ពាក្យបណ្តឹងនេះបានចោទប្រកាន់អំពីផលប៉ះពាល់អវិជ្ជមានផ្នែកសង្គមនៃសកម្មភាពប្រមូលបំណុលរបស់ FIs ទាំងនេះ រួមមានការបាត់បង់ដីធ្លី ការបាត់បង់មុខរបរចិញ្ចឹមជីវិត អសន្តិសុខស្បៀង ការគំរាមកំហែងដល់សុខភាព និងពលកម្មកុមារ ព្រមទាំងផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិចផងដែរ។ ពាក្យបណ្តឹងនេះក៏លើកឡើងអំពីកង្វល់ទាក់ទងនឹងការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នផ្នែកបរិស្ថាន និងសង្គម (E&S) របស់ IFC ការចាត់ថ្នាក់គម្រោង និងការគ្រប់គ្រងគម្រោង និងអនុលោមភាពរបស់អតិថិជន IFC ចំពោះលក្ខខណ្ឌតម្រូវ E&S របស់ខ្លួនផងដែរ។ ដើមបណ្តឹងបានស្នើសុំឱ្យ CAO រក្សាការសម្ងាត់នៃអត្តសញ្ញាណរបស់ពួកគេ ដោយភ័យខ្លាចការសងសឹក។

iii. CAO បានយល់ឃើញថា បណ្តឹងមានលក្ខខណ្ឌសមស្របដើម្បីធ្វើការវាយតម្លៃ នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ បន្ទាប់ពីបានកំណត់ថា បណ្តឹងនោះបំពេញតាមលក្ខណៈវិនិច្ឆ័យសមស្របរបស់ខ្លួន។ IFC យកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងនេះ។ ទាក់ទងនឹងការសងសឹក សេចក្តីថ្លែងការណ៍អំពីគោលជំហររបស់ IFC ចំពោះការសងសឹកទៅនឹងសង្គមស៊ីវិល និងភាគីពាក់ព័ន្ធរបស់គម្រោង (ខែតុលា ឆ្នាំ២០១៨)[1] បញ្ជាក់យ៉ាងច្បាស់ថា IFC មិនអត់ឱនចំពោះសកម្មភាពណាមួយរបស់អតិថិជន IFC ដែលមានអត្ថន័យស្មើនឹងការសងសឹក – រួមទាំងការគំរាមកំហែង ការបំភិតបំភ័យ ការ

[1] https://www.ifc.org/wps/wcm/connect/ade6a8c3-12a7-43c7-b34e-f73e5ad6a5c8/EN_IFC_Reprisals_Statement_201810.pdf?MOD=AJPERES&CVID=ocZ1hXY

បៀតបៀន ឬអំពើហិង្សាផងដែរ – ប្រឆាំងនឹងអ្នកដែលបានបញ្ចេញមតិទាក់ទងនឹងសកម្មភាពរបស់ IFC ឬអតិថិជនរបស់ខ្លួននោះទេ។

iv. FIs ទាំងប្រាំមួយ ដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង ត្រូវបានចាត់ទុកថា មានសារសំខាន់ជាប្រព័ន្ធសម្រាប់វិស័យហិរញ្ញវត្ថុកម្ពុជា។ គម្រោង និងអនុគម្រោងមានភាពស្របគ្នាយ៉ាងពេញលេញទៅនឹងក្របខណ្ឌភាពជាដៃគូប្រចាំប្រទេសរបស់ក្រុមធនាគារពិភពលោក (WBG) ឯកសារស្តីពីអភិក្រមឆ្លើយតបនឹងវិបត្តិកូវីដ-១៩ របស់ WBG និងអាទិភាពជាយុទ្ធសាស្ត្ររបស់ IFC សម្រាប់ប្រទេសកម្ពុជា។ ក្នុងចំណោមគម្រោងសកម្មទាំង ១០ គម្រោងចំនួន ២ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាដើមទុនលំដាប់ទី ២ និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រមូលដ្ឋានមូលធននិយតកម្ម និងភាពធន់របស់ FIs ផ្សេងៗគ្នាក្នុងអំឡុងពេលមានជំងឺរាតត្បាតសកល កូវីដ។ មីក្រូហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រទេសកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ គាំទ្រដល់ជីវភាពរស់នៅ និងបង្កើតការងារ ជាពិសេសនៅពេលដែលសេដ្ឋកិច្ចងើបចេញពីភាពតានតឹងនៃជំងឺកូវីដ-១៩។

v. IFC បានបន្តធ្វើការពង្រឹងការអនុវត្តផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវនៅក្នុងប្រទេសកម្ពុជា ទាំងនៅកម្រិតស្ថាប័ន និងវិស័យ។ ការងារនេះលើសពីលក្ខខណ្ឌតម្រូវនៃក្របខណ្ឌនិរន្តរភាពរបស់ IFC។ នៅកម្រិតស្ថាប័ន IFC ធ្វើការយ៉ាងសម្រិតសម្រាំងជាមួយ FIs ដែលមានការអនុវត្តផ្តល់កម្ចីប្រកបដោយទំនួលខុសត្រូវ វាយតម្លៃការអនុវត្តក្នុងការធានា និងការប្រមូលប្រាក់របស់ FIs ក្នុងអំឡុងពេលដំណើរការការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន និងពិនិត្យតាមដានការវិវត្តនៃការអនុវត្តទាំងនេះតាមរយៈការត្រួតពិនិត្យផលប័ត្រ។ IFC បានរួមបញ្ចូលកិច្ចព្រមព្រៀងដោយមានការបញ្ជាក់ ដែលតម្រូវឱ្យមានភាពអនុលោមតាមកិច្ចការពារអតិថិជន និងគោលការណ៍ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ (សូមមើលគំរូនៅក្នុងឧបសម្ព័ន្ធទី ៣) ដែលគ្របដណ្តប់លើការជៀសវាងពីការជំពាក់បំណុលច្រើនពេក ការកំណត់តម្លៃប្រកបដោយតម្លាភាព ការអនុវត្តនៃការប្រមូលប្រាក់យ៉ាងសមស្រប អាកប្បកិរិយារបស់បុគ្គលិកប្រកបដោយសីលធម៌ យន្តការដោះស្រាយបណ្តឹងសារទុក្ខ និង/ឬការការពារឯកជនភាពនៃទិន្នន័យនៅក្នុងកិច្ចព្រមព្រៀងកម្ចីរបស់អតិថិជន និងមូលនិធិដែលពាក់ព័ន្ធនឹងពាក្យបណ្តឹង។[2] លើសពីនេះទៀត IFC បានផ្តល់សេវាទីប្រឹក្សាដល់ FIs រួមទាំងការជួយផ្លាស់ប្តូរពីអង្គការមិនមែនរដ្ឋាភិបាលទៅជាស្ថាប័នមីក្រូហិរញ្ញវត្ថុពាណិជ្ជកម្ម (MFIs) និងធនាគារពាណិជ្ជ កែលម្អអភិបាលកិច្ចសាជីវកម្ម និងសមត្ថភាពគ្រប់គ្រងហានិភ័យ និងលើកកម្ពស់ស្តង់ដារនៃការអនុវត្តផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់ពួកគេផងដែរ។ IFC ក៏កំពុងអនុវត្តគំនិតផ្តួចផ្តើមមួយ ចាប់តាំងពីខែមេសា ឆ្នាំ២០២១ (RF កម្ពុជា លេខ ៦០៦១១៩)[3] ដើម្បីវាយតម្លៃការអនុវត្តផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់អតិថិជន IFC និង

[2] អតិថិជន IFC ទាំងបី ដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង រួមមាន អេស៊ីលីដា អម្រឹត និង HTB។ IFC ពុំមានកិច្ចព្រមព្រៀងជាមួយអតិថិជនរងដោយផ្ទាល់នោះទេ។ IFC បានរួមបញ្ចូលកិច្ចព្រមព្រៀងមានការបញ្ជាក់ស្តីពីកិច្ចការពារអតិថិជន និងគោលការណ៍ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវនៅក្នុងប្រាក់កម្ចីដោយផ្ទាល់របស់ខ្លួន ទៅកាន់ ប្រាសាក់ នៅក្នុងឆ្នាំ២០១៥ និងឆ្នាំ២០១៦ (គម្រោងលេខ ៣៦២៨០ និង ៣៨២៣៥) អេស៊ីលីដា (គម្រោងលេខ ៣៨៣៨៦) HTB (គម្រោងលេខ ៤៨៧៤២ និង ៤៥៥៣៥) អម្រឹត (គម្រោងលេខ ៣៧៥០៥ និង ៤៤២៣១) ព្រមទាំងនៅក្នុងការវិនិយោគមូលធនរបស់ខ្លួននៅក្នុង MEF (គម្រោងលេខ ២៧៨២៧) និង MIFA (គម្រោងលេខ ៣១៤៦៧)។

[3] IFC បាន និងកំពុងធ្វើការលើគំនិតផ្តួចផ្តើមផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវនៅក្នុងប្រទេសកម្ពុជា (កម្ពុជា RF លេខ ៦០៦១១៩) ចាប់តាំងពីខែមេសា ឆ្នាំ២០២១ ដែលវាយតម្លៃលើការអនុវត្តផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់អតិថិជន FI របស់ខ្លួន ជួយដល់អតិថិជនរបស់ខ្លួនក្នុង

ជួយពួកគេក្នុងការធ្វើឱ្យមានភាពប្រសើរឡើងទៅតាមពេលវេលាផងដែរ។

vi. នៅកម្រិតវិស័យ IFC បានធ្វើការជាមួយ NBC ចាប់តាំងពីឆ្នាំ២០០៦ ដើម្បីបង្កើតការិយាល័យឥណទានកម្ពុជា (CBC) ដែលជាការិយាល័យឥណទានដំបូងគេប្រចាំប្រទេស និងជាប្រភពនៃតម្លាភាព និងព័ត៌មានសម្រាប់ការរាយការណ៍អំពីឥណទាន ព្រមទាំងជាឧបករណ៍កាត់បន្ថយហានិភ័យនៃការជំពាក់បំណុលច្រើនពេករបស់អ្នកខ្ចី។ IFC បានសហការជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) CBC និងយុទ្ធនាការ SMART[4] ដើម្បីផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីការផ្តល់កម្ចី – ជាគំនិតផ្តួចផ្តើម ដែលត្រូវបានបង្កើតឡើងដើម្បីកាត់បន្ថយហានិភ័យនៃកំណើនទីផ្សារឥណទាន និងបានអនុវត្តគម្រោងអសាធនភាព និងគម្រោងដោះស្រាយបំណុលសម្រាប់ចរន្តខាងលើ ដែលគ្របដណ្តប់លើការគ្រប់គ្រងកម្ចី និងការដោះស្រាយបំណុលមិនដំណើរការ ដើម្បីពង្រឹងការអនុវត្តក្នុងការប្រមូលបំណុលប្រកបដោយយុត្តិធម៌ និងតម្លាភាព។ IFC ជឿជាក់ថា ការបន្តចូលរួមក្នុងវិស័យហិរញ្ញវត្ថុកម្ពុជាមានសារសំខាន់ទាំងនៅកម្រិតស្ថាប័ន និងកម្រិតវិស័យ ដើម្បីជះឥទ្ធិពលបន្ថែមទៀតដល់ការអនុវត្តផ្នែកហិរញ្ញវត្ថុប្រកប ដោយទំនួលខុសត្រូវ និងកិច្ចការពារអ្នកប្រើប្រាស់។

vii. គណៈគ្រប់គ្រង IFC គោរពដំណើរការរបស់ស៊ីអេអូ ក្នុងការវាយតម្លៃពាក្យបណ្តឹង ដែលពាក់ព័ន្ធនឹងការវិនិយោគរបស់ IFC នៅក្នុងអតិថិជន និងអតិថិជនរងរបស់ IFC ទាំងប្រាំមួយ។ ការខូចខាតដែលត្រូវបានចោទប្រកាន់ នៅខណៈពេលដែលមានភាពធ្ងន់ធ្ងរ វាមិនមែនជាលទ្ធផលនៃបដិលោមភាពតាមគោលនយោបាយ E&S របស់ IFC នោះទេ ប៉ុន្តែវាទាក់ទងនឹងការអនុវត្តក្នុងការផ្តល់កម្ចី និងការប្រមូលប្រាក់ដោយអតិថិជនរបស់ IFC ដែល IFC ដោះស្រាយតាមរយៈក្របខណ្ឌហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់ខ្លួន ដូចបានរៀបរាប់នៅក្នុងចំណុច v និង vi ខាងលើ។ អាស្រ័យហេតុនេះ គណៈគ្រប់គ្រង IFC យល់ឃើញថា ពុំមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់សម្រាប់ការស៊ើបអង្កេតអំពីភាពអនុលោមឡើយ។

viii. ក្របខណ្ឌនិរន្តរភាពរបស់ IFC អនុវត្តចំពោះហានិភ័យ E&S និងផលប៉ះពាល់ជាសក្តានុពលនៃ*សកម្មភាពអាជីវកម្ម* ដែលបានទទួលការគាំទ្រ ទៅលើ*សហគមន៍ជុំវិញ និងពលករ*។ អតិថិជន ឬអ្នកប្រើប្រាស់ផលិតផលរបស់អតិថិជន មិនត្រូវបានលើកឡើង នៅក្នុងគោលនយោបាយនិរន្តរភាព ឬស្តង់ដារអនុវត្តថាជាភាគីពាក់ព័ន្ធមួយប្រភេទ ដែលវិធានការកាត់បន្ថយហានិភ័យរបស់ E&S គួរតែអនុវត្តចំពោះពួកគេនោះទេ។[5] ក្នុងករណីអន្តរការីហិរញ្ញវត្ថុ សកម្មភាពអាជីវកម្ម ដែល IFC គាំទ្រ និងវាយតម្លៃហានិភ័យ

---

ការធ្វើឱ្យមានភាពប្រសើរឡើងតាមពេលវេលា និងអនុញ្ញាតឱ្យអតិថិជន FI របស់ IFC បន្តផ្តល់ដំណោះស្រាយហិរញ្ញប្បទានប្រកបដោយនិរន្តរភាពដល់អតិថិជនរបស់ពួកគេ។

[4] ស្ថាប័នកំណត់ស្តង់ដារសកលសម្រាប់ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងកិច្ចការពារអតិថិជន ដែលបានផ្តល់លិខិតបញ្ជាក់ដល់ស្ថាប័ននានាសម្រាប់ការប្រកាន់ខ្ជាប់នូវក្រមប្រតិបត្តិនៃហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។ យុទ្ធនាការ SMART ត្រូវបានបញ្ឈប់នៅឆ្នាំ២០២០ ហើយគណៈគ្រប់គ្រងស្តង់ដារហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងកិច្ចការពារអតិថិជន ត្រូវបានផ្ទេរទៅកាន់ក្រុមការងារសង្គមកិច្ច (SPTF) និង CERISE។ នៅខែកញ្ញា ឆ្នាំ២០២១ SPTF និង CERISE បានចាប់ផ្តើមដំណើរការគន្លងការពារអតិថិជន ដែលជាគំនិតផ្តួចផ្តើមថ្មីមួយដើម្បីគាំទ្រដល់ការអនុវត្តកិច្ចការពារអតិថិជន។

[5] គោលនយោបាយនិរន្តរភាពឆ្នាំ២០១២ (កថាខណ្ឌទី ៣ ជើងទំព័រទី ២) សំដៅដល់ហេតុប៉ះពាល់បរិស្ថាន និងសង្គម ថាជាការផ្លាស់ប្តូរណាមួយ ជាសក្តានុពល ឬយ៉ាងជាក់ស្តែងចំពោះ (i) បរិស្ថានរូបវន្ត ធម្មជាតិ ឬវប្បធម៌ និង (ii) ផលប៉ះពាល់លើ "សហគមន៍ជុំវិញ និងកម្មករ" ដែលបណ្តាលមកពីសកម្មភាពអាជីវកម្ម ដែលនឹងទទួលការគាំទ្រ។ "សហគមន៍ជុំវិញ និងកម្មករ" គឺជាភាគីពាក់ព័ន្ធ ដែលត្រូវបានយកមកពិចារណា នៅពេលវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមជាសក្តានុពល។ ស្តង់ដារការអនុវត្តទី១ ក៏បញ្ជាក់អំពី "ភាគីពាក់ព័ន្ធដទៃទៀត" (លើសពីសហគមន៍ជុំវិញ និងកម្មករ)

E&S គឺជាការប្រើប្រាស់ប្រាក់កម្ចីដោយអ្នកខ្ចីបន្ត។ ក្របខណ្ឌនិរន្តរភាពរបស់ IFC មិនផ្ដោតលើហានិភ័យ និងផលប៉ះពាល់លើអ្នកខ្ចីបន្តនីមួយៗនោះទេ។

ix. ផ្ទុយទៅវិញ IFC ត្រួតពិនិត្យឡើងវិញលើប្រភេទបញ្ហាកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុទាំងនេះ តាមរយៈកញ្ចប់នៃហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងជាផ្នែកមួយនៃដំណើរការត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុយ៉ាងប្រុងប្រយ័ត្នដ៏ទូលំទូលាយរបស់ខ្លួន។ ទន្ទឹមនឹងការអនុវត្តលក្ខខណ្ឌតម្រូវនៃក្របខណ្ឌនិរន្តរភាពរបស់ខ្លួននោះ IFC ប្ដេជ្ញាចិត្តធ្វើការត្រួតពិនិត្យឡើងវិញ និងដោះស្រាយបញ្ហា ដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្ដឹង ដែលពាក់ព័ន្ធនឹងការអនុវត្តផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ (FCP) ប្រកបដោយទំនួលខុសត្រូវ រួមជាមួយភាគីពាក់ព័ន្ធដទៃទៀត ដែលមានភាពសកម្មនៅក្នុងប្រទេសកម្ពុជា ដូចជា ធនាគារពិភពលោក NBC, CMA សមាគមធនាគារកម្ពុជា (ABC) និងស្ថាប័នហិរញ្ញវត្ថុអភិវឌ្ឍន៍ពហុភាគីដទៃទៀត។ IFC នឹងអនុវត្តសកម្មភាពដូចខាងក្រោម នៅកម្រិតគម្រោង វិស័យ និងនិយ័តកម្ម៖

*ភាពមិនប្រក្រតីតាមគម្រោងជាក់លាក់ ដែលត្រូវបានចោទប្រកាន់នៅក្នុងពាក្យបណ្ដឹង៖*

- វាយតម្លៃថាតើមានភាពមិនប្រក្រតីណាមួយ ទាក់ទងនឹងគោលការណ៍ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ នៅក្នុងប្រាក់កម្ចី ដែលផ្ដល់ជូនដើមបណ្ដឹង បានកើតឡើងដែរឬទេ (ក្នុងលក្ខខណ្ឌដែលព័ត៌មានអំពីដើមបណ្ដឹងម្នាក់ៗ ត្រូវបានចែករំលែកជាមួយ IFC) និងរួមគ្នាជាមួយអតិថិជន FI កំណត់ការកែលម្អណាមួយ ដែលចាំបាច់ដើម្បីជៀសវាងភាពមិនប្រក្រតីទាំងនោះនាពេលអនាគត។
- ក្នុងករណីដែល IFC បញ្ជាក់ថា ភាពមិនប្រក្រតីទាក់ទងនឹងគោលការណ៍ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវបានកើតឡើងនោះ ធ្វើការជាមួយអតិថិជនរបស់ខ្លួន ដើម្បីដោះស្រាយភាពមិនប្រក្រតីទាំងនោះនៅកម្រិតអ្នកខ្ចីម្នាក់ៗ ទៅតាមភាពសមស្រប។

*ហានិភ័យនៃការសងសឹក*

- បន្តចូលរួមជាមួយ និងបណ្ដុះបណ្ដាលអតិថិជន និងអតិថិជនរងរបស់ IFC អំពីការទប់ស្កាត់ ការគ្រប់គ្រង និងការដោះស្រាយហានិភ័យនៃការសងសឹក។ IFC នឹងបង្កើតការបណ្ដុះបណ្ដាលលើប្រធានបទនេះដល់អម្រឹត HTB និងប្រាសាក់ ក្នុងខែវិច្ឆិកា ឆ្នាំ២០២២ ដើម្បីបង្កើនសមត្ថភាពរបស់ពួកគេក្នុងការដោះស្រាយការសងសឹក។ លើសពីនេះទៀត IFC មានគម្រោងផ្ដល់ការបណ្ដុះបណ្ដាល និងការណែនាំស្រដៀងគ្នាដល់អតិថិជន និងអតិថិជនរង ដែលពាក់ព័ន្ធនឹងពាក្យបណ្ដឹងនេះ ក៏ដូចជាពង្រីកវគ្គបណ្ដុះបណ្ដាលទាំងនេះទៅកាន់ផ្នែកដទៃទៀតនៃឧស្សាហកម្មដោយចាប់ដៃគូជាមួយ NBC និង CMA។ ដោយគាំទ្រចំពោះសំណើសុំរក្សាការសម្ងាត់របស់ដើមបណ្ដឹង IFC នឹងស្វាគមន៍រាល់ការចូលរួមជាមួយដើមបណ្ដឹង និងតំណាងរបស់ពួកគេនៅក្នុងសកម្មភាពដែលបានពណ៌នា ដើម្បីផ្ដល់ព័ត៌មាន និងពង្រឹងការអនុវត្តផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។

---

ថាជាអាជ្ញាធរជាតិ និងអាជ្ញាធរមូលដ្ឋាន គម្រោងជិតខាង និង/ឬអង្គការមិនមែនរដ្ឋាភិបាល (កថាខណ្ឌទី១ ជើងទំព័រទី១)។

*អភិក្រមរបស់ IFC ចំពោះហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ៖*

- បើកការពិគ្រោះយោបល់ជាសាធារណៈអំពីអភិក្រមរបស់ IFC ចំពោះហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគោលការណ៍កិច្ចការពារអតិថិជន និងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ រួមទាំងលក្ខខណ្ឌជាក់លាក់សម្រាប់ការបញ្ចេញព័ត៌មានទាក់ទងនឹងកម្ចីដែលពាក់ព័ន្ធ ទៅកាន់អ្នកខ្ចីផងដែរ។ ការពិគ្រោះយោបល់នឹងបើកសម្រាប់រយៈពេល ៤៥ ថ្ងៃ ក្នុងអំឡុងពេលដែលភាគីពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា រួមទាំងដើមបណ្ដឹង ហើយពួកគេអាចផ្ដល់មតិយោបល់របស់ពួកគេបាន
- ធ្វើវិសោធនកម្មអភិក្រមហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវក្នុងរយៈពេលប្រាំមួយខែ ចាប់ពីពេលបញ្ចប់ការពិគ្រោះយោបល់ ដោយឆ្លុះបញ្ចាំងអំពីរបកគំហើញនៃការពិគ្រោះយោបល់
- បោះពុម្ពផ្សាយអភិក្រមឆ្លើយតបនឹងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងប្រើកំណែ ដែលបានកែសម្រួលរួច ជាលក្ខខណ្ឌស្ដង់ដារនៃហិរញ្ញប្បទានសម្រាប់ការផ្ដល់កម្ចីមីក្រូហិរញ្ញវត្ថុទាំងអស់នៅក្នុងប្រទេសកម្ពុជា។

*បទប្បញ្ញត្តិស្ដីពីកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ (FCP) នៅកម្ពុជា៖*

- ចូលរួមជាមួយរដ្ឋាភិបាលកម្ពុជាក្នុងការរៀបចំបទប្បញ្ញត្តិ FCP ដើម្បីដោះស្រាយចំណុចខ្វះខាតដែលមានស្រាប់នៅកម្រិតវិស័យ។ នេះអាចរួមបញ្ចូលដោះស្រាយការអនុវត្តច្បាប់នានា ដូចបានពណ៌នានៅក្នុង NFIS កម្ពុជា ផងដែរ។

## I. សេចក្តីផ្តើម

1. នៅខែកុម្ភៈ ឆ្នាំ២០២២ ពាក្យបណ្តឹងមួយ (ពាក្យបណ្តឹង) បានដាក់ជូនមកការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ស៊ីអេអូ) ពាក់ព័ន្ធនឹងគម្រោង និងអនុគម្រោងរបស់ IFC ជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី (អេស៊ីលីដា) ធនាគារហត្ថា (HTB) និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត (អម្រឹត) និង អនុគម្រោងរបស់ IFC ជាមួយ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី (អិលអូអិលស៊ី) គ្រឹះស្ថានមីក្រូហិរញ្ញ វត្ថុប្រាសាក់ ម.ក (ប្រាសាក់) និង ធនាគារ ស្ថាបនា ភីអិលស៊ី (ស្ថាបនា) (ជារួម មានស្ថាប័នហិរញ្ញវត្ថុ ឬ FIs ចំនួនប្រាំមួយ) នៅប្រទេសកម្ពុជា។ គម្រោង IFC បានទទួលហិរញ្ញប្បទានដោយផ្ទាល់ពី IFC ហើយអនុគម្រោង IFC បានទទួលហិរញ្ញប្បទានពីឥណទានពង្រឹងមីក្រូហិរញ្ញវត្ថុ S.A., SICAV-SIF (MEF), មូលនិធិគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុលអាស៊ី SA, SICAV-SIF (MIFA), ក្រុមហ៊ុន Advans SA SICAR (Advans) និង ក្រុមហ៊ុន North Haven Thai Private Equity L.P. (North Haven)។

2. ពាក្យបណ្តឹងនេះទាក់ទងនឹងគម្រោង IFC ដែលមានភាពសកម្ម និងបានបិទរួចហើយ រួមមានដូចខាងក្រោម (ជារួម ហៅថាគម្រោង)៖ គម្រោងអេស៊ីលីដា លេខ ៤២៤៨០ និង ៤៤៨៨២, គម្រោង HTB លេខ ៤៤២១១ ៤៤៧៤២ និង ៤៥៥៣៥, គម្រោងអម្រឹតលេខ ៣៤៧៤៨ ៤១២៩៤ និង ៤៤២៣១, មូលធន MEF (លេខ ២៧៨២៧), មូលធន MIFA (លេខ ៣១៤៦៧), មូលធន Advans SA (លេខ ២១៨៥៦) និង មូលធន North Haven (លេខ ៣៨៦០៩) គ្រប់គម្រោងទាំងអស់មានភាពសកម្ម និងកម្ចីជាន់ខ្ពស់ HTB (គម្រោងលេខ ៣២៦៤២) ត្រូវបានបិទរួចរាល់ហើយ។

3. ពាក្យបណ្តឹងនេះត្រូវបានដាក់ដោយអង្គការសង្គមស៊ីវិល (CSOs) ក្នុងស្រុក ចំនួនពីរគឺ អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) និងអង្គការសមធម៌កម្ពុជា (EC) តាងនាមឲ្យអ្នកខ្ចីប្រាក់មួយក្រុម ដែលស្នាក់នៅក្នុងប្រទេសកម្ពុជា (ដើមបណ្តឹង)។ IFC ពុំមានព័ត៌មានអំពីចំនួនសរុបនៃដើមបណ្តឹង ឬ ព័ត៌មានលម្អិតអំពីចំនួនដើមបណ្តឹងក្នុងមួយគម្រោង ឬអនុគម្រោងនោះទេ។ ដើមបណ្តឹងបានធ្វើការចោទប្រកាន់ជាច្រើន ដែលនឹងបង្ហាញកាន់តែលម្អិតថែមទៀតនៅក្នុងផ្នែក III ខាងក្រោម។ ដើមបណ្តឹងបានស្នើសុំឱ្យ ស៊ីអេអូ រក្សាការសម្ងាត់នៃអត្តសញ្ញាណរបស់ពួកគេ ដោយភ័យខ្លាចការសងសឹក។

4. នៅខែមេសា ឆ្នាំ២០២២ ស៊ីអេអូ បានរកឃើញថា ពាក្យបណ្តឹងមានលក្ខខណ្ឌសមស្រប និងបានចាប់ផ្តើមការវាយតម្លៃ។ នៅខែសីហា ឆ្នាំ២០២២ ស៊ីអេអូបានពន្យារពេលធ្វើការវាយតម្លៃក្នុងរយៈពេល ៣០ ថ្ងៃអាជីវកម្មបន្ថែមទៀត ស្របតាមគោលនយោបាយរបស់ស៊ីអេអូ ដោយភាគីមួយចំនួននៃពាក្យបណ្តឹង បានបង្ហាញចំណាប់អារម្មណ៍ចំពោះដំណើរការដោះស្រាយវិវាទក្រោមការសម្របសម្រួលរបស់ស៊ីអេអូ។ នៅខែកញ្ញា ឆ្នាំ២០២២ គេបានកំណត់ថា ដំណើរការបែបនេះមិនអាចកើតឡើងបានទេ ដោយសារកង្វះការព្រមព្រៀងពីគ្រប់ភាគីទាំងអស់ និងថា ពាក្យបណ្តឹងនឹងបន្តទៅការវាយតម្លៃអំពីភាពអនុលោម ដើម្បីកំណត់ថាតើ ពាក្យបណ្តឹងនេះស័ក្តិសមនឹងទទួលបានការស៊ើបអង្កេតអំពីភាពអនុលោមដែរឬទេ ឬថាតើករណីនេះនឹងត្រូវបិទ។

5. IFC យកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការចោទប្រកាន់នៅក្នុងពាក្យបណ្តឹង និងមានកង្វល់ជាពិសេស អំពីការភ័យខ្លាចការសងសឹក ដែលបង្ហាញដោយដើមបណ្តឹង។ សេចក្តីថ្លែងការណ៍អំពីគោលជំហររបស់ IFC

ស្តីពីការសងសឹកចំពោះសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនឹងគម្រោង បានបញ្ជាក់យ៉ាងច្បាស់ថា IFC មិនអត់ឱនចំពោះសកម្មភាពណាមួយរបស់អតិថិជន IFC ដែលមានអត្ថន័យស្មើនឹងការសងសឹក – រួមទាំងការគំរាមកំហែង ការបំភិតបំភ័យ ការបៀតបៀន ឬអំពើហិង្សា – ប្រឆាំងនឹងអ្នកបញ្ចេញមតិអំពីសកម្មភាពរបស់ IFC ឬអតិថិជនរបស់ខ្លួនឡើយ។ បន្ទាប់ពីបានដឹងអំពីភាពភ័យខ្លាចការសងសឹករបស់ដើមបណ្តឹង IFC បានចាត់វិធានការភ្លាមៗ។ IFC បានចូលរួមដោយផ្ទាល់ជាមួយអតិថិជន FI របស់ខ្លួន ដែលជាកម្មវត្ថុនៃពាក្យបណ្តឹង ដើម្បីពង្រឹងគោលជំហររបស់ IFC ទាក់ទងនឹងការសងសឹក។ IFC បានជូនដំណឹងដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរទៅកាន់អតិថិជនទាំងនេះថា IFC មិនអត់ឱនចំពោះសកម្មភាពណាមួយរបស់អតិថិជន IFC ដែលមានអត្ថន័យស្មើនឹងការសងសឹកនោះទេ និងបានបង្កើត និងចែករំលែកការណែនាំជាក់លាក់អំពីរបៀបគ្រប់គ្រងហានិភ័យនៃការសងសឹក ក្នុងនាមជា FI ផងដែរ។ លើសពីនេះទៀត IFC បានបង្កើត និងបន្តផ្តល់ការបណ្តុះបណ្តាលដល់អតិថិជន FI ទាក់ទងនឹងការគ្រប់គ្រងហានិភ័យនៃការសងសឹក ការទប់ស្កាត់ការសងសឹកដោយបុគ្គលិករបស់ពួកគេ និងការដោះស្រាយកង្វល់នៃការសងសឹក។ នៅខែវិច្ឆិកា ឆ្នាំ២០២២ IFC បានផ្តល់ការបណ្តុះបណ្តាលដល់អម្រឹត HTB និងប្រាសាក់ អំពីប្រធានបទនេះ និងកំពុងសម្របសម្រួលផ្តល់ការបណ្តុះបណ្តាលស្រដៀងគ្នានេះដល់អង្គភាពដទៃទៀត ដែលពាក់ព័ន្ធនឹងពាក្យបណ្តឹងនេះ នៅមុនដំណាច់ឆ្នាំ។[6] IFC បានគាំទ្រ និងសហការយ៉ាងពេញលេញជាមួយស៊ីអេអូ នៅក្នុងការវាយតម្លៃពាក្យបណ្តឹង រួមទាំងការសម្របសម្រួលការប្រាស្រ័យទាក់ទងរវាង FIs និង ស៊ីអេអូ ផងដែរ។

6. គណៈគ្រប់គ្រងបានត្រួតពិនិត្យឡើងវិញលើរបាយការណ៍វាយតម្លៃរបស់ស៊ីអេអូ និងបានរៀបចំការឆ្លើយតបរបស់ខ្លួន។ ផ្នែកបន្ទាប់ផ្តល់សេចក្តីពណ៌នាអំពីសាវតារបស់គម្រោង និងពាក្យបណ្តឹង និងបង្ហាញការឆ្លើយតបរបស់គណៈគ្រប់គ្រង។

## II. សាវតារបស់គម្រោង

7. មីក្រូហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រទេសកម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្រ ការគាំទ្រដល់ជីវភាពរស់នៅ និងការបង្កើតការងារ ជាពិសេសនៅពេលដែលសេដ្ឋកិច្ចងើបចេញពីភាពតានតឹងនៃជំងឺកូវីដ-១៩។ FIs ទាំងប្រាំមួយ ដែលបានលើកឡើង នៅក្នុងពាក្យបណ្តឹង ត្រូវបានចាត់ទុករួមគ្នាថា មានសារសំខាន់ជាប្រព័ន្ធចំពោះវិស័យហិរញ្ញវត្ថុកម្ពុជា។ គម្រោង និងអនុគម្រោងនានា មានភាពស្របគ្នាទាំងស្រុងទៅនឹងក្របខណ្ឌភាពជាដៃគូប្រចាំប្រទេស (CPF) របស់ក្រុមធនាគារពិភពលោក (WBG) ឯកសារស្តីពីអភិក្រមឆ្លើយតបនឹងវិបត្តិជំងឺកូវីដ-១៩ របស់ WBG ព្រមទាំងអាទិភាពជាយុទ្ធសាស្ត្ររបស់ IFC សម្រាប់ប្រទេសកម្ពុជាផងដែរ។

8. ចំពោះគម្រោងរបស់ IFC ដែលគាំទ្រអាជីវកម្មមីក្រូហិរញ្ញវត្ថុរបស់ FIs ហានិភ័យ E&S និងផលប៉ះពាល់ជាសក្តានុពល ដែលកើតចេញពី *ការប្រើប្រាស់ប្រាក់ចំណូល*របស់បុគ្គល ឬសហគ្រាសធុនមីក្រូ តាមធម្មតា

[6] IFC បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងហានិភ័យនៃការសងសឹកជាមួយអម្រឹត នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២, ជាមួយ HTB នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ និងជាមួយប្រាសាក់ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២។

មានតិចតួចណាស់។ ទំហំប្រាក់កម្ចី តាមធម្មតា មិនលើសពី ១០.០០០ ដុល្លារអាមេរិកនោះទេ ហើយប្រាក់ចំណូលត្រូវបានប្រើប្រាស់សម្រាប់តម្រូវការរបស់បុគ្គល ឬដំណើរការអាជីវកម្មកម្រិតមីក្រូ ដូចជាកសិកម្ម ឬហាងលក់សម្ភារប្រើប្រាស់ ជាដើម។ ការផ្តល់ប្រាក់កម្ចីបែបនេះ តាមធម្មតា ត្រូវបានចាត់ទុកថាមានហានិភ័យទាប យោងតាមទស្សនៈ E&S និងត្រូវបានចាត់ថ្នាក់ជា FI-៣ (ប្រភេទហានិភ័យ E&S ទាបបំផុតសម្រាប់គម្រោង FI)។ ស្របតាមកថាខណ្ឌទី ៣៥ នៃគោលនយោបាយនិរន្តរភាព អតិថិជន FI-៣ ត្រូវបានតម្រូវឱ្យអនុវត្តនីតិវិធីត្រួតពិនិត្យ E&S ដ៏សាមញ្ញមួយ។ ការត្រួតពិនិត្យបែបនេះត្រូវបានចាត់ទុកថា នឹងបង្កើតប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) ដែលស្របតាមកម្រិតអប្បបរមានៃហានិភ័យ E&S នៅក្នុងប្រតិបត្តិការទាំងនេះ។ ប្រសិនបើអាចមានការផ្តល់ប្រាក់កម្ចីដល់សហគ្រាសធុនតូច និងមធ្យម (SMEs) ផងដែរនោះ ហានិភ័យ E&S អាចខ្ពស់ជាងនេះ ហើយប្រតិបត្តិការបែបនេះ តាមធម្មតា ត្រូវបានចាត់ថ្នាក់ថាជា FI-២។ អតិថិជននៃប្រតិបត្តិការ FI-២ ត្រូវបានតម្រូវឱ្យប្រើប្រាស់ ESMS ដែលមានភាពទំនើបជាងនេះ។

## A. អេស៊ីលីដា

9. ***ការវិនិយោគរបស់ IFC នៅក្នុងអេស៊ីលីដា៖*** អេស៊ីលីដា គឺជាដៃគូយូរអង្វែងរបស់ IFC នៅកម្ពុជា ចាប់តាំងពីការចូលរួមលើកដំបូងរបស់ IFC ក្នុងឆ្នាំ១៩៩៨៖ មូលនិធិអភិវឌ្ឍន៍វិស័យឯកជនមេគង្គ ដែលគ្រប់គ្រងដោយ IFC និងបានទទួលមូលនិធិពីម្ចាស់ជំនួយ។ ជាច្រើនឆ្នាំកន្លងមកនេះ IFC បានគាំទ្រដល់ការផ្លាស់ប្តូររបស់ខ្លួន ពីអង្គការមិនមែនរដ្ឋាភិបាលទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពាណិជ្ជកម្ម (MFI) និងបន្ទាប់មក ទៅជាធនាគារពាណិជ្ជ ហើយបានផ្តល់ជូនអេស៊ីលីដា និងក្រុមហ៊ុនសាខា នូវដើមទុន មូលនិធិ និងសេវាទីប្រឹក្សា ដើម្បីជួយពង្រឹងសមត្ថភាពរបស់ស្ថាប័ន ពង្រឹងភាពធន់ បង្កើតផលិតផលប្រកបដោយនវានុវត្តន៍ និងពង្រឹងការអនុវត្តផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងការគ្រប់គ្រងហានិភ័យប្រកបដោយសមាហរណកម្ម។ ដោយមានការលើកទឹកចិត្តពី IFC អេស៊ីលីដា បានស្នើសុំលិខិតបញ្ជាក់ពីយុទ្ធនាការ SMART និងបានក្លាយជាធនាគារពាណិជ្ជទីមួយនៅក្នុងប្រទេស ដែលបានទទួលលិខិតបញ្ជាក់នៅឆ្នាំ២០១៧។ បច្ចុប្បន្ន IFC មានការវិនិយោគសកម្មចំនួនពីរ (គម្រោងលេខ ៤២៤៨០ និង ៤៤៨៨២) ជាមួយអេស៊ីលីដា ដោយមានការបង្ហាញគណនីផ្ទាល់ខ្លួនសរុបចំនួន ១៦០ លានដុល្លារអាមេរិក (សូមមើលឧបសម្ព័ន្ធទី១ សម្រាប់ព័ត៌មានលម្អិត)។ IFC ក៏បានវិនិយោគទុនចំនួន ១៥ លានដុល្លារអាមេរិកនៅក្នុងក្រុមហ៊ុន North Haven Thai (គម្រោងលេខ ៣៨៦០៩) ដែលជាមូលនិធិមូលធនឯកជន ដែលបានទិញភាគហ៊ុន ៣,៥ ភាគរយនៅក្នុងអេស៊ីលីដា កាលពីខែមេសា ឆ្នាំ២០២២។

10. ***បរិបទរបស់គម្រោង៖*** គម្រោងកម្ចីថ្នាក់ក្រោម និងជាន់ខ្ពស់ (គម្រោងលេខ ៤២៤៨០ និង ៤៤៨៨២) ស្របតាម CPF របស់ WBG សម្រាប់ប្រទេសកម្ពុជា (ឆ្នាំសារពើពន្ធ ២០១៩-២០២៣) និងជាពិសេសដោយមានចំណុចផ្តោតជាដំបូងលើការលើកកម្ពស់ប្រសិទ្ធភាពរដ្ឋ និងជំរុញភាពរីកចម្រើននៃវិស័យឯកជនតាមរយៈការបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូច និងមធ្យម និងការលើកកម្ពស់ សហគ្រិនភាព និងបរិយាប័ន្នហិរញ្ញវត្ថុតាមរយៈគោលដៅជាក់លាក់សម្រាប់សហគ្រាសធុនតូច និងមធ្យម និងសហគ្រាសធុនតូច និងមធ្យមដែលគ្រប់គ្រងដោយស្ត្រី (WSMEs)។ គម្រោងលេខ ៤៤៨៨២ មានភាពស្របគ្នាយ៉ាងពេញលេញទៅនឹងសសរស្តម្ភនៃដំណាក់កាលងើបឡើងវិញនៃ "ការ

កសាងឡើងវិញឱ្យកាន់តែល្អប្រសើរ" ដែលត្រូវបានគូសបញ្ជាក់នៅក្នុង "ការសង្គ្រោះជីវិត ការបង្កើនផលជះ និងការត្រលប់ទៅរកផ្លូវត្រូវវិញ៖ ឯកសារអភិក្រមឆ្លើយតបនឹងវិបត្តិជំងឺកូវីដ-១៩ របស់ WBG" (ខែមិថុនា ឆ្នាំ២០២០) ដែលផ្តោតលើឱកាសថ្មីៗក្នុងការកសាងអនាគតដែលកាន់តែមាននិរន្តរភាព មានបរិយាប័ន្ន និងមានភាពធន់។ ការវិនិយោគទាំងនេះក៏សមស្របនឹងអាទិភាពជាយុទ្ធសាស្រ្តរបស់ IFC ក្នុងការពង្រឹងភាពប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច និងបរិយាប័ន្នហិរញ្ញវត្ថុនៅក្នុងប្រទេសផងដែរ (FY ២០២០-២០២៤)។

11. ***គោលបំណងរបស់គម្រោង៖*** កម្ចីថ្នាក់ក្រោម (គម្រោងលេខ ៤២៤៨០) ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាដើមទុនលំដាប់ទី២ ស្របតាមបទប្បញ្ញត្តិក្នុងស្រុក គឺជាការប៉ុនប៉ងលើកដំបូងរបស់ IFC ក្នុងការប្រមូលដើមធនលំដាប់ទី២ នៅកម្ពុជា ពីអ្នកផ្តល់កម្ចីអន្តរជាតិ ដែលមានចំណង់តិចតួចបំផុតសម្រាប់ដើមទុនលំដាប់ទី២ ដោយសារមានរយៈពេលវែង និងទម្រង់ផលិតផលមានហានិភ័យខ្ពស់ជាង។ គម្រោងនេះបានជួយដល់អេស៊ីលីដា ក្នុងការធ្វើពិពិធកម្មរចនាសម្ព័ន្ធដើមទុនរបស់ខ្លួន ពង្រឹងភាពគ្រប់គ្រាន់នៃដើមទុន និងគាំទ្រយុទ្ធសាស្រ្តឌីជីថលនីយកម្មរបស់ខ្លួន។ កម្ចីជាន់ខ្ពស់ (គម្រោងលេខ ៤៤៨៨២) បានអនុញ្ញាតឱ្យមានការបង្កើនសេវាហិរញ្ញវត្ថុសម្រាប់ SMEs រួមទាំង WSMEs និង SMEs នៅក្នុងវិស័យកសិកម្មផងដែរ ដោយសារសហគ្រាសទាំងនេះធ្វើការដើម្បីទ្រទ្រង់អាជីវកម្មរបស់ពួកគេ និងងើបឡើងវិញពីផលប៉ះពាល់នៃជំងឺរាតត្បាតសកល កូវីដ-១៩។ ប្រាក់ចំណូលពីការវិនិយោគរបស់ IFC ផ្តោតទាំងស្រុងលើគោលបំណងទាំងនេះ។ ស្របតាមឯកសារច្បាប់ ពុំមានប្រាក់ចំណូលណាមួយពីប្រាក់កម្ចីទាំងនេះ អាចត្រូវបានប្រើប្រាស់ដើម្បីផ្តល់កម្ចីឡើងវិញ ឬកំណត់ឡើងវិញនូវកាលវិភាគនៃបំណុលដែលមានស្រាប់របស់អ្នកខ្ចីបន្ត ដែលមានលក្ខខណ្ឌសមស្រប របស់អេស៊ីលីដានោះទេ (រួមទាំងការបំប្លែងពីបំណុលទៅជាមូលធនផងដែរ) លើកលែងតែការផ្តល់ហិរញ្ញប្បទានឡើងវិញ ឬការកំណត់កាលវិភាគឡើងវិញគឺជាផ្នែកមួយនៃការរៀបចំឥណទានឡើងវិញ ដោយមានបំណងទិញទ្រព្យសកម្មជាដើមទុនថ្មីៗដោយអ្នកខ្ចីបន្ត ដែលមានលក្ខខណ្ឌសមស្របនោះ។ ការចូលរួមរបស់ IFC ជាមួយអេស៊ីលីដា មានឥទ្ធិពលផ្នែកអាកប្បកិរិយាយ៉ាងខ្លាំង និងបានលើកទឹកចិត្តអេស៊ីលីដាឱ្យពង្រឹងការវាយតម្លៃឥណទានដែលផ្អែកលើលំហូរសាច់ប្រាក់របស់ខ្លួន និងការប្តេជ្ញាចិត្តចំពោះហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងនិរន្តរភាព។

12. ***សេវាទីប្រឹក្សា៖*** ចាប់តាំងពីការចូលរួមលើកដំបូងជាមួយអេស៊ីលីដា ក្នុងឆ្នាំ១៩៩៨ IFC បានផ្តល់ជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីជួយអេស៊ីលីដារៀបចំខ្លួនសម្រាប់ការផ្លាស់ប្តូរពី MFI ទៅជាធនាគារពាណិជ្ជ និងបានចែករំលែកជំនាញក្នុងការអភិវឌ្ឍន៍ផលិតផលហិរញ្ញវត្ថុពាណិជ្ជកម្ម ហិរញ្ញវត្ថុ SME និងហិរញ្ញវត្ថុផ្នែកកសិកម្ម ជាដើម។ នៅខែមិថុនា ឆ្នាំ២០២២ IFC បានបញ្ចប់គម្រោងប្រឹក្សាលើការគ្រប់គ្រងហានិភ័យ ដែលបានជួយដល់អេស៊ីលីដាក្នុងការពង្រឹងសមត្ថភាពគ្រប់គ្រងហានិភ័យ ដោយផ្តោតលើអភិបាលកិច្ចហានិភ័យ ការគ្រប់គ្រងដើមទុន (ដំណើរការវាយតម្លៃភាពគ្រប់គ្រាន់នៃដើមទុនផ្ទៃក្នុង) និងការធ្វើតេស្តភាពតានតឹង ដើម្បីធានាបាននូវភាពរឹងមាំរបស់ស្ថាប័ន ស្របតាមស្ថានភាពទីផ្សារ និងព្រឹត្តិការណ៍ដ៏តានតឹងផ្សេងៗ ដូចជា វិបត្តិជំងឺកូវីដ-១៩ ក៏ដូចជាផលធៀបភាពភាពគ្រប់គ្រាន់នៃដើមទុនកាន់តែខ្ពស់ ដែលត្រូវបានទាមទារដោយ NBC។

B. HTB

13. ***ការវិនិយោគរបស់ IFC នៅក្នុង HTB៖*** HTB ជាធនាគារពាណិជ្ជ ដែលបានទទួលអាជ្ញាបណ្ណពី NBC ក្នុងខែសីហា ឆ្នាំ២០២០ គឺជាដៃគូរបស់ IFC នៅប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ២០១៥ នៅពេលដែលវាគឺជាគ្រឹះស្ថានទទួលប្រាក់បញ្ញើ មីក្រូហិរញ្ញវត្ថុឈានមុខគេមួយ ហៅថា ហត្ថាកសិករ លីមីតធីត (HKL)។ ច្រើនឆ្នាំកន្លងមកនេះ IFC បានផ្តល់មូលនិធិ និងដើមទុនលំដាប់ទី២ ដល់ HTB បានគាំទ្រការផ្លាស់ប្តូរ HTB ពី MFI ទៅជាធនាគារពាណិជ្ជ និងបានផ្តល់សេវាទីប្រឹក្សា និងការចែករំលែកចំណេះដឹង ដើម្បីជួយកែលម្អភាពធន់ អភិវឌ្ឍហិរញ្ញវត្ថុយេនឌ័រ និងការផ្តល់ប្រាក់កម្ចីដល់ SME និងពង្រឹងការអនុវត្តផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។ គិតត្រឹមថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ IFC បានធ្វើការវិនិយោគសកម្មចំនួន ៤ នៅក្នុង HTB ជាមួយនឹងការបង្ហាញគណនីផ្ទាល់ខ្លួនចំនួន ៤៥,៧ លានដុល្លារអាមេរិក (សូមមើលឧបសម្ព័ន្ធទី១) ក្នុងចំណោមគម្រោងទាំងនេះ គម្រោងចំនួនពីរ (លេខ ៣៩១៦៧ និង ៤៤២១១) ត្រូវបានទូទាត់សងទាំងស្រុងនៅខែមិថុនា ឆ្នាំ២០២២ ហើយគម្រោងពីរទៀត (លេខ ៤៤៧៤២ និង ៤៥៥៣៥) នៅតែមានភាពសកម្ម គិតត្រឹមកាលបរិច្ឆេទនៃការឆ្លើយតបរបស់គណៈគ្រប់គ្រងនេះ។ IFC ផ្តល់កម្ចីដោយប្រយោលដល់ HTB បន្ថែមទៀត តាមរយៈការវិនិយោគនៅក្នុង MEF (គម្រោងលេខ ២៧៨២៧) ដែលបានផ្តល់កម្ចីមិនទាន់សង ចំនួន ៣,៥ លានដុល្លារអាមេរិកដល់ HTB។

14. ***បរិបទគម្រោង៖*** គម្រោងវិនិយោគជាមួយ HTB មានភាពស្របគ្នានឹង CPF របស់ WBG សម្រាប់ប្រទេសកម្ពុជា (FY ២០១៩-២០២៣) និងអាទិភាពជាយុទ្ធសាស្ត្ររបស់ IFC ប្រចាំប្រទេស ដោយរួមចំណែកដល់ការពង្រឹងភាពប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច និងបរិយាប័ន្នហិរញ្ញវត្ថុ។ លើសពីនេះទៀត គម្រោងលេខ ៤៤២១១, ៤៤៧៤២ និង ៤៥៥៣៥ មានភាពស្របគ្នាយ៉ាងពេញលេញទៅនឹងសសរស្តម្ភនៃដំណាក់កាលងើបឡើងវិញនៃ "ការកសាងឡើងវិញឱ្យកាន់តែល្អប្រសើរ" ដែលត្រូវបានគូសបញ្ជាក់នៅក្នុង "ការសង្គ្រោះជីវិត ការបង្កើនផលជះ និងការត្រលប់ទៅរកផ្លូវត្រូវវិញ៖ ឯកសារអភិក្រមឆ្លើយតបនឹងវិបត្តិជំងឺកូវីដ-១៩ របស់ WBG" (ខែមិថុនា ឆ្នាំ២០២០) ដែលផ្តោតលើឱកាសថ្មីៗក្នុងការកសាងអនាគតដែលកាន់តែមាននិរន្តរភាព មានបរិយាប័ន្ន និងមានភាពធន់។

15. ***គោលបំណងរបស់គម្រោង៖*** រាល់គម្រោងរបស់ HTB ទាំងអស់ ដែលបានលើកឡើងខាងលើ មានបំណងលើកកម្ពស់សហគ្រិនភាព និងបរិយាប័ន្នហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) នៅក្នុងប្រទេសកម្ពុជា។ គម្រោងលេខ ៤៤២១១ ៤៤៧៤២ និង ៤៥៥៣៥ មានគោលបំណងជាពិសេសក្នុងការគាំទ្រ HTB និងអតិថិជន MSME (រួមទាំង WMSMEs ផងដែរ) ក្នុងអំឡុងពេល និងក្រោយពេលមានជំងឺរាតត្បាតសកល កូវីដ-១៩ ដែលតាមរយៈការគាំទ្រនេះ អនុញ្ញាតឲ្យមានការបន្តអាជីវកម្ម និងភាពរីកចម្រើនប្រកបដោយនិរន្តរភាពរបស់ MSMEs ដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យសេដ្ឋកិច្ច។ លើសពីនេះទៀត គម្រោងលេខ ៤៤៧៤២ ដែលជាការរួមបញ្ចូលប្រាក់កម្ចីថ្នាក់ក្រោម ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ដើមទុនលំដាប់ទី២ ស្របតាមបទប្បញ្ញត្តិក្នុងស្រុក មានបំណងធ្វើពិពិធកម្មរចនាសម្ព័ន្ធដើមទុនរបស់ HTB ពង្រឹងភាពគ្រប់គ្រាន់នៃដើមទុន និងរួមចំណែកដល់ស្ថេរភាពហិរញ្ញវត្ថុ នៅពេលមានផលប៉ះពាល់ដ៏យូរអង្វែងនៃជំងឺរាតត្បាតសកល។

16. ***សេវាទីប្រឹក្សា និងការចូលរួមនៅចន្លោះខាងលើ៖*** IFC បានផ្តល់ការគាំទ្រផ្នែកទីប្រឹក្សាសម្រាប់ការផ្លាស់ប្តូររបស់ HKL ទៅជាធនាគារពាណិជ្ជ នៅចន្លោះឆ្នាំ២០១៧ និង ២០១៨។ លើសពីនេះទៀត IFC បានធ្វើការវាយតម្លៃផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវលើ HTB នៅចន្លោះឆ្នាំ២០២១ និង ២០២២ ដែលបានរួមបញ្ចូលការត្រួតពិនិត្យតាមបែបប្រៀបធៀបលើការអនុវត្តការផ្តល់កម្ចីរបស់ HTB ធៀបនឹងស្តង់ដារដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិផងដែរ ដោយមានបំណងលើកកម្ពស់ការប្រើប្រាស់ស្តង់ដារហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវខ្ពស់បំផុត និងអនុញ្ញាតឱ្យ HTB បន្តផ្តល់ដំណោះស្រាយហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពដល់អតិថិជនរបស់ខ្លួន។

C. **អម្រឹត**

17. ***ការវិនិយោគរបស់ IFC នៅក្នុងអម្រឹត៖*** អម្រឹត គឺជាដៃគូដ៏យូរអង្វែងរបស់ IFC នៅប្រទេសកម្ពុជា ចាប់តាំងពីខែកញ្ញា ឆ្នាំ២០១៤ នៅពេលដែល IFC បានធ្វើការវិនិយោគមូលធនចំនួន ១៧,៥ លានដុល្លារអាមេរិក ក្នុងតម្លៃសមមូលជាប្រាក់រៀលកម្ពុជា សម្រាប់ភាគហ៊ុន ១៩,៩៩ ភាគរយនៃភាគហ៊ុនមូលធនរួមនៅក្នុងអម្រឹត (គម្រោងមូលធនអម្រឹត លេខ ៣៤៧៤៨)។ ចាប់តាំងពីពេលនោះមក IFC បាន និងកំពុងផ្តល់មូលនិធិដើម្បីគាំទ្រដល់ការផ្តល់ប្រាក់កម្ចីរបស់អម្រឹត AMRET ដល់ MSME រួមទាំង WMSMEs ផងដែរ នៅប្រទេសកម្ពុជា។ នៅខែមិថុនា ឆ្នាំ២០២០ និងខែមិថុនា ឆ្នាំ២០២១ IFC បានផ្តល់ជូនអម្រឹត នូវប្រាក់កម្ចីបង្ខិលជាន់ខ្ពស់រយៈពេលមួយឆ្នាំ ជាទឹកប្រាក់សរុបចំនួន ៣៧,៥ លានដុល្លារអាមេរិក តាមរយៈចំណែកហ៊ុនចំនួនពីរ ស្របតាមមូលនិធិឆ្លើយតបនឹងវិបត្តិនៃដំណោះស្រាយទុនបង្វិលសម្រាប់ជំងឺកូវីដ-១៩ របស់ IFC ដើម្បីគាំទ្រដល់អតិថិជន MSME (រួមទាំង WMSME) របស់អម្រឹតដែលរងផលប៉ះពាល់ដោយសារជំងឺរាតត្បាតសកល កូវីដ-១៩ (គម្រោងលេខ ៤៤២៣១)។ គិតត្រឹមថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ IFC មានគម្រោងវិនិយោគសកម្មចំនួនបី ជាមួយអម្រឹត ដោយមានការបង្ហាញគណនីផ្ទាល់ខ្លួនចំនួន ៤៥ លានដុល្លារអាមេរិក (សូមមើលឧបសម្ព័ន្ធទី១) ហើយគិតត្រឹមកាលបរិច្ឆេទនៃការឆ្លើយតបរបស់គណៈគ្រប់គ្រងនេះ គម្រោងចំនួនពីរគឺ គម្រោងលេខ ៣៤៧៤៨ និង ៤៤២៣១ នៅតែមានភាពសកម្ម ដោយមានការបង្ហាញគណនីផ្ទាល់ខ្លួនដែលមិនទាន់ទូទាត់សង សរុបចំនួន ៣០ លានដុល្លារអាមេរិក។ ព័ត៌មានលម្អិតអំពីទំនាក់ទំនងការវិនិយោគដោយផ្ទាល់របស់ IFC ត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធទី១។ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ IFC បានផ្តល់កម្ចីដោយប្រយោលដល់អម្រឹត តាមរយៈការវិនិយោគនៅក្នុង MEF (គម្រោងលេខ ២៧៨២៧) និងមូលនិធិ MIFA (គម្រោងលេខ ៣១៤៦៧) ដែលបានផ្តល់ប្រាក់កម្ចីមិនទាន់សង ដល់អម្រឹត ចំនួន ១៣,៨ លានដុល្លារអាមេរិក និង ៥,៥ លានដុល្លារអាមេរិកផ្សេងៗគ្នា។ លើសពីនេះទៀត IFC កាន់កាប់ភាគហ៊ុន ១៦ ភាគរយនៅក្នុងក្រុមហ៊ុនមេរបស់អម្រឹត គឺ Advans (គម្រោងលេខ ២១៨៥៦)។ ផ្ទុយមកវិញ Advans កាន់កាប់ភាគហ៊ុន ៥២,៧៨ ភាគរយនៅក្នុងអម្រឹត។

18. ***បរិបទគម្រោង៖*** គម្រោងមូលធនអម្រឹត លេខ ៣៤៧៤៨ គឺស្របតាម CPF របស់ WBG និងយុទ្ធសាស្ត្ររបស់ IFC នៅកម្ពុជា ដែលផ្តោតលើការលើកកម្ពស់ភាពរីកចម្រើនប្រកបដោយបរិយាប័ន្ន និងការពង្រឹងភាពប្រកួតប្រជែងផ្នែកសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាតាមរយៈការពង្រីកទីផ្សារហិរញ្ញវត្ថុ។ គម្រោងនេះមានបំណងចូលរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា តាមរយៈការគាំទ្រអម្រឹត ក្នុង

ការកែលម្អ និងពង្រីកសេវាកម្មហិរញ្ញវត្ថុដល់អតិថិជន MSME របស់ខ្លួន នៅតាមតំបន់ជនបទ និងចូលរួមនៅក្នុងសកម្មភាពនានា ដែលទាក់ទងនឹងកសិកម្ម។ គម្រោង លេខ ៤១២៩៤ មានភាពស្របតាមយុទ្ធសាស្ត្រ WBG នៅកម្ពុជា ក្នុង FY ២០១៦-២០១៧ ដែលផ្តោតលើការគាំទ្រសេដ្ឋកិច្ចដែលជំរុញដោយការនាំចេញរបស់ប្រទេសកម្ពុជា ដើម្បីពង្រឹងបរិយាកាសធុរកិច្ចរបស់ប្រទេស និងដោះស្រាយឧបសគ្គនៃភាពប្រកួតប្រជែង កែលម្អការផ្តល់សេវាដើម្បីកាត់បន្ថយភាពងាយរងគ្រោះ និងលើកកម្ពស់ឱកាសស្វែងរកប្រាក់ចំណូលសម្រាប់ប្រជាជនក្រីក្របំផុត។ គម្រោង លេខ ៤៤២៣១ គឺជាផ្នែកមួយនៃមូលនិធិឆ្លើយតបនឹងវិបត្តិដំណោះស្រាយទុនបង្វិលនៃជំងឺកូវីដ-១៩ របស់ IFC និងមានភាពស្របគ្នាយ៉ាងពេញលេញទៅនឹងសសរស្តម្ភនៃដំណាក់កាលងើបឡើងវិញ "ការកសាងឡើងវិញឱ្យកាន់តែល្អប្រសើរ" ដែលត្រូវបានគូសបញ្ជាក់នៅក្នុង "ការសង្គ្រោះជីវិត ការបង្កើនផលជះ និងការត្រលប់ទៅរកផ្លូវត្រូវវិញ៖ ឯកសារអភិក្រមឆ្លើយតបនឹងវិបត្តិជំងឺកូវីដ-១៩ របស់ WBG" (ខែមិថុនា ឆ្នាំ២០២០) ដែលផ្តោតលើឱកាសថ្មីៗក្នុងការកសាងអនាគតដែលកាន់តែមាននិរន្តរភាព មានបរិយាប័ន្ន និងមានភាពធន់។

19. ***គោលបំណងរបស់គម្រោង៖*** គម្រោងមូលធនអម្រឹត លេខ ៣៩៧៤៨ មានបំណងកែលម្អរចនាសម្ព័ន្ធការកាន់កាប់ភាគហ៊ុន អភិបាលកិច្ចសាជីវកម្ម និងសមត្ថភាពរបស់ស្ថាប័ន។ ក្នុងនាមជាម្ចាស់ភាគហ៊ុន IFC អាចផ្តល់ការគាំទ្រកាន់តែខ្លាំងក្លាបន្ថែមទៀត ទាក់ទងនឹងយុទ្ធសាស្ត្រជួយពង្រឹងបេសកកម្មរបស់ក្រុមហ៊ុន ដោយកំណត់គោលដៅផ្នែបាតនៃពីរ៉ាមីត និង MSMEs ស្របពេលជាមួយគ្នានោះ ស្វែងរកផ្លូវសម្រាប់ការផ្លាស់ប្តូរអម្រឹតទៅជាធនាគារពាណិជ្ជ ដើម្បីធ្វើឱ្យប្រតិបត្តិការរបស់អម្រឹតកាន់តែមាននិរន្តរភាពបន្ថែមទៀត។ គម្រោងលេខ ៤២២៩៤ មានបំណងផ្តល់មូលនិធិរយៈពេលមធ្យម ដើម្បីគាំទ្រសកម្មភាពផ្តល់ប្រាក់កម្ចីរបស់អម្រឹត ទៅកាន់ MSMEs និង WMSMEs។ គម្រោងលេខ ៤៤២៣១ បានផ្តល់ជំនួយហិរញ្ញវត្ថុរយៈពេលខ្លីដល់ MSMEs និង WMSMEs នៅកម្ពុជា ដែលរងផលប៉ះពាល់ដោយជំងឺរាតត្បាតសកល កូវីដ-១៩។

## D. ប្រាសាក់ អិលអូអិលស៊ី និង ធនាគារ ស្ថាបនា

20. បច្ចុប្បន្ន IFC ពុំមានការវិនិយោគសកម្មនៅក្នុងប្រាសាក់ អិលអូអិលស៊ី ឬធនាគារ ស្ថាបនា នោះទេ ប៉ុន្តែបានផ្តល់កម្ចីដោយប្រយោលដល់គ្រឹះស្ថានហិរញ្ញវត្ថុទាំងនេះ តាមរយៈការវិនិយោគដូចខាងក្រោម៖

- MEF (គម្រោងលេខ ២៧៨២៧) ជាមធ្យោបាយនៃការវិនិយោគលើមីក្រូហិរញ្ញវត្ថុ ដែល IFC មានភាគហ៊ុនចំនួន ២០ ភាគរយ។ MEF មានកម្ចីជាន់ខ្ពស់ដែលមិនទាន់សង ចំនួន ៧,៨ លានដុល្លារអាមេរិក នៅប្រាសាក់ និង ១៤.២ លានដុល្លាអាមេរិកនៅអិលអូអិលស៊ី គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២។
- MIFA (គម្រោងលេខ ៣១៤៦៧) ជាមធ្យោបាយនៃការវិនិយោគលើមីក្រូហិរញ្ញវត្ថុ ដែល IFC មានភាគហ៊ុនចំនួន ១០ ភាគរយ។ MIFA មានកម្ចីថ្នាក់ទាបដែលមិនទាន់សង ចំនួន ៣.២ លានដុល្លារអាមេរិក នៅស្ថាបនា និងកម្ចីជាន់ខ្ពស់ចំនួនពីរ ដែលមានទឹកប្រាក់សរុបចំនួន ៥.៥ លានដុល្លាអាមេរិកនៅអម្រឹត និងកម្ចីថ្នាក់ទាបចំនួនពីរ ដែលមានទឹកប្រាក់សរុបចំនួន ៩លានដុល្លាអាមេរិកនៅអិលអូអិលស៊ី។

21. ***ការវិនិយោគរបស់ IFC នៅក្នុង MEF និង MIFA៖*** ចាប់តាំងពីមានការត្រួតត្រាយផ្លូវនៃវិស័យមីក្រូហិរញ្ញវត្ថុពាណិជ្ជកម្មនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ យុទ្ធសាស្ត្ររបស់ IFC សម្រាប់បរិយាប័ន្នហិរញ្ញវត្ថុ រួមមានការវិនិយោគលើវិស័យមីក្រូហិរញ្ញវត្ថុ តាមរយៈមធ្យោបាយវិនិយោគដែលមានរចនាសម្ព័ន្ធ និងទម្រង់ហិរញ្ញប្បទានខ្នាតធំដទៃទៀត ដែលបង្ហាញអំពីករណីអាជីវកម្មសម្រាប់មីក្រូហិរញ្ញវត្ថុពាណិជ្ជកម្ម និងផ្សព្វផ្សាយវាជាប្រភេទទ្រព្យសកម្មដែលអាចសម្រេចបាន ទៅកាន់វិនិយោគិននៅតាមស្ថាប័នផ្សេងៗ។ ទាំង MEF និង MIFA គឺជាគំនិតផ្តួចផ្តើមរួមគ្នារបស់ IFC និង KfW (ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់)។ អ្នកគ្រប់គ្រងមូលនិធិធ្វើការសម្រេចចិត្តលើការវិនិយោគរបស់ពួកគេដោយឯករាជ្យ ដោយអនុវត្តតាមសំណុំលក្ខណវិនិច្ឆ័យអំពីលក្ខខណ្ឌសមស្រប និងគោលការណ៍ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងត្រូវបានតម្រូវដោយ IFC ឲ្យអនុវត្តលក្ខខណ្ឌតម្រូវ E&S ដែលពាក់ព័ន្ធនឹងការវិនិយោគរបស់ពួកគេនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុផងដែរ។

- MEF ត្រូវបានបង្កើតឡើងជាការឆ្លើយតបនឹងវិបត្តិហិរញ្ញវត្ថុសកលលោក ឆ្នាំ២០០៨/២០០៩ ដើម្បីថែរក្សាទំនុកចិត្តនៅក្នុងឧស្សាហកម្មមីក្រូហិរញ្ញវត្ថុ។ IFC បានវិនិយោគទុនចំនួន ១៥០ លានដុល្លារអាមេរិកនៅក្នុងភាគហ៊ុនបន្ថែម (mezzanine shares) នៃមូលនិធិ ដែលតំណាងឱ្យ ២,២ ភាគរយ។ គិតត្រឹមខែធ្នូ ឆ្នាំ២០២១ MEF មានទ្រព្យសកម្មសរុបជាង ៧១៥ លានដុល្លារអាមេរិក និងវិនិយោគិនរបស់ខ្លួន រួមមាន ធនាគារ និងទីភ្នាក់ងារអភិវឌ្ឍន៍អឺរ៉ុបជាច្រើន និងអ្នកវិនិយោគឯកជន។ ចាប់តាំងពីពេលចាប់ផ្តើម MEF បានផ្តល់ការគាំទ្រដល់អ្នកខ្ចីប្រាក់ដែលមានចំណូលទាប ដោយផ្តល់ប្រាក់ជាង ២,៦ ពាន់លានដុល្លារអាមេរិក តាមរយៈកម្ចីចំនួន ៨០០ ដល់គ្រឹះស្ថានហិរញ្ញវត្ថុជាង ២៩១ គ្រឹះស្ថាន ដែលមានភាពសកម្មនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ នៅ ៥៩ ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងចំណោមគ្រឹះស្ថានទាំងនោះ រួមមាន អម្រឹត HTB អិលអូអិលស៊ី ប្រាសាក់ និង ស្ថាបនា។
- MIFA បានចាប់ផ្តើមដំណើរការនៅឆ្នាំ២០១២ ក្នុងនាមជាមូលនិធិមីក្រូហិរញ្ញវត្ថុដំបូងគេ ដែលផ្តោតទាំងស្រុងលើតំបន់អាស៊ី ក្នុងគោលបំណងពង្រីក និងពង្រឹងការផ្តល់សេវាមីក្រូហិរញ្ញវត្ថុនៅទីនោះ នៅកន្លែងដែលតម្រូវការ និងសក្តានុពលក្នុងការចូលទៅជិតប្រជាជនមួយចំនួនធំគឺមានសារសំខាន់។ IFC បានវិនិយោគទុន ១៦,៧៥ លានដុល្លារអាមេរិកនៅក្នុងភាគហ៊ុនបន្ថែម។ គិតត្រឹមខែមិថុនា ឆ្នាំ២០២២ MIFA បានកាន់កាប់ទ្រព្យសកម្មសរុបចំនួន ១៦៦ លានដុល្លារអាមេរិក ហើយវិនិយោគិនរបស់ខ្លួនរួមមាន មូលនិធិសោធននិវត្តន៍ និងមូលនិធិឯកជននានា។ ចាប់តាំងពីពេលចាប់ផ្តើម MIFA បានផ្តល់ទឹកប្រាក់ជាង ៥៤០ លានដុល្លារអាមេរិក នៅក្នុងកម្ចីចំនួន ១០០ ដល់ MFIs ជាង ៤០ នៅ ១៤ ប្រទេសក្នុងតំបន់អាស៊ី ក្នុងចំណោមគ្រឹះស្ថានទាំងនោះ រួមមាន អិលអូអិលស៊ី ស្ថាបនា និងអម្រឹត។

## III. ពាក្យបណ្តឹងទៅ ស៊ីអេអូ

22. នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ ពាក្យបណ្តឹងបានដាក់ទៅ ស៊ីអេអូ ដោយអង្គការសង្គមស៊ីវិលក្នុងស្រុកចំនួនពីរ គឺអង្គការលីកាដូ និង EC ជំនួសឱ្យដើមបណ្តឹង។ ពួកគេបានចោទប្រកាន់ថា ពួកគេមិនត្រូវបាន

ផ្តល់ជូននូវព័ត៌មានគ្រប់គ្រាន់ ជាភាសាដែលពួកគេអាចយល់បាន ដើម្បីស្វែងយល់ឱ្យបានពេញលេញនូវលក្ខខណ្ឌនៃកិច្ចព្រមព្រៀងប្រាក់កម្ចី ដែលពួកគេបានចុះ។ ពួកគេបានចោទប្រកាន់អំពី ផលប៉ះពាល់អវិជ្ជមានលើសង្គម ដោយសារសកម្មភាពប្រមូលបំណុលរបស់អ្នកផ្តល់កម្ចី រួមមាន ការបាត់បង់ដីធ្លី ការបាត់បង់មុខរបរចិញ្ចឹមជីវិត អសន្តិសុខស្បៀង ការគំរាមកំហែងដល់សុខភាព និងពលកម្មកុមារ ព្រមទាំងផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិចផងដែរ។ ពាក្យបណ្តឹងនេះក៏លើកឡើងអំពីកង្វល់ទាក់ទងនឹងការត្រួតពិនិត្យផ្នែក E&S យ៉ាងប្រុងប្រយ័ត្ន របស់ IFC ការចាត់ថ្នាក់គម្រោង និងការត្រួតពិនិត្យគម្រោង និងភាពអនុលោមរបស់អតិថិជន IFC ចំពោះលក្ខខណ្ឌតម្រូវផ្នែក E&S របស់ IFC ផងដែរ។

23. នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ ស៊ីអេអូ បានជូនដំណឹងដល់ IFC ថាពាក្យបណ្តឹងមានលក្ខខណ្ឌសមស្របសម្រាប់ការវាយតម្លៃ ទាក់ទងនឹងការវិនិយោគរបស់ IFC នៅក្នុងគម្រោងនានា បន្ទាប់ពីបានពិចារណាលើលក្ខណវិនិច្ឆ័យចំនួនបីសម្រាប់លក្ខខណ្ឌសមស្រប៖ (i) ពាក្យបណ្តឹងទាក់ទងនឹងគម្រោងដែល IFC កំពុងចូលរួម (ii) បញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង ទាក់ទងនឹងអាណត្តិរបស់ស៊ីអេអូ ក្នុងការដោះស្រាយផលប៉ះពាល់ E&S នៃគម្រោង IFC និង (iii) ដើមបណ្តឹងបានរង ឬអាចរងផលប៉ះពាល់ពីផលប៉ះពាល់ផ្នែកបរិស្ថាន និង/ឬសង្គម ដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង។

24. នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២ អង្គការលីកាដូ និង EC បានចេញសេចក្តីថ្លែងការណ៍រួមមួយ ដែលបានបោះពុម្ពផ្សាយនៅលើវែបសាយត៍របស់ពួកគេផ្សេងៗគ្នា ដែលមានសេចក្តីសង្ខេបអំពីពាក្យបណ្តឹង និងឈ្មោះរបស់អតិថិជន និងអតិថិជនរងរបស់ IFC ទាំងប្រាំមួយ។ សេចក្តីថ្លែងការណ៍នោះមិនបានបង្ហាញអត្តសញ្ញាណរបស់ដើមបណ្តឹងនោះទេ។

25. នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ស៊ីអេអូ បានចែករំលែកពាក្យបណ្តឹងដែលត្រូវបានកែសម្រួលឡើងវិញជាមួយ IFC ដើម្បីផ្តល់ព័ត៌មានបន្ថែមដល់អតិថិជន និងអតិថិជនរង ដែលពាក់ព័ន្ធ។ ស៊ីអេអូ ក៏បានចែករំលែកកំណែដែលបានកែសម្រួលឡើងវិញ សម្រាប់ការប្រើប្រាស់ផ្ទៃក្នុងរបស់ IFC ផងដែរ។ ដោយដើមបណ្តឹងមានបំណងបន្តរក្សាភាពអនាមិកនោះ ស៊ីអេអូ មិនបានចែករំលែកអត្ថបទពេញលេញនៃពាក្យបណ្តឹងនោះជាមួយ IFC នោះទេ។ តាមរយៈពាក្យបណ្តឹងដែលត្រូវបានកែសម្រួលឡើងវិញ គេមិនច្បាស់ថាតើ FIs ត្រូវបានចោទប្រកាន់ចំពោះការអនុវត្តណាមួយ និងមិនច្បាស់អំពីទំហំនៃការប្រព្រឹត្តមិនត្រឹមត្រូវ ដែលត្រូវបានចោទប្រកាន់នោះទេ ដោយសារចំនួនដើមបណ្តឹង ដែលរងផលប៉ះពាល់ មិនទាន់បានលាតត្រដាងទៅកាន់ IFC នៅឡើយទេ។

26. ដូចបានកត់សម្គាល់ខាងលើ ដើមបណ្តឹងបានស្នើសុំឲ្យស៊ីអេអូ រក្សាអត្តសញ្ញាណរបស់ពួកគេជាការសម្ងាត់ ដោយភ័យខ្លាចការសងសឹក។ នៅខណៈពេលដែលគណៈគ្រប់គ្រងយល់ច្បាស់អំពីបំណងរបស់ដើមបណ្តឹងក្នុងការរក្សាអនាមិកភាពនោះ គេបានរកឃើញការពន្យល់របស់ស៊ីអេអូ ដែលភ្ជាប់ទំនាក់ទំនងរវាងការបង្ហាញទិន្នន័យស្ថិតិអំពីចំនួនដើមបណ្តឹង និងហានិភ័យនៃការសងសឹក ដែលពិបាកយល់។ ក្នុងអំឡុងពេលនៃដំណើរការវាយតម្លៃរបស់ស៊ីអេអូ IFC បានជួយសម្របសម្រួល និងលើកទឹកចិត្តដល់ការចូលរួមរបស់អតិថិជនរបស់ខ្លួននៅក្នុងដំណើរការនេះ បានបង្កើនការយល់ដឹងអំពីកង្វល់នៃការសងសឹក និងបានផ្តល់ការកសាងសមត្ថភាពដល់អតិថិជនរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហាទាំងនោះ។ នៅថ្ងៃទី

១០ ខែតុលា ឆ្នាំ២០២២ IFC ក៏បានស្នើសុំតាមរយៈស៊ីអេអូ ឱ្យរៀបចំកិច្ចប្រជុំជាមួយអង្គការលីកាដូ និង EC ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីការចោទប្រកាន់ដទៃទៀតដែលបានបង្ហាញនៅក្នុងពាក្យបណ្តឹង ប៉ុន្តែនៅពេលចេញផ្សាយរបាយការណ៍នេះ ឆន្ទៈរបស់អង្គការលីកាដូ និង EC ក្នុងការជួបតំណាង IFC មិនត្រូវបានបញ្ជាក់នោះទេ។

27. នៅខែសីហា ឆ្នាំ២០២២ ស៊ីអេអូ បានពន្យារពេលវាយតម្លៃ ចំនួន ៣០ថ្ងៃ នៃថ្ងៃធ្វើការ ស្របតាមគោលនយោបាយស៊ីអេអូ ដោយហេតុថាដើមបណ្តឹងចំនួនប្រាំបួននាក់មានបំណងចូលរួមក្នុងការដោះស្រាយវិវាទជាមួយ FIs ដើម្បីស្វែងរកដំណោះស្រាយ ដែលអាចទទួលយកបានទៅវិញទៅមកចំពោះកង្វល់របស់ពួកគេ។ អតិថិជនរបស់ IFC អម្រឹត និងអតិថិជនរងចំនួនពីរ គឺ ប្រាសាក់ និង អិលអូអិលស៊ី ដំបូងឡើយ បានបង្ហាញអំពីឆន្ទៈចូលរួមក្នុងការដោះស្រាយវិវាទ ប៉ុន្តែក្រោយមកមិនបានបញ្ជាក់អំពីចេតនានេះទេ។

28. ស៊ីអេអូ បានចេញផ្សាយសេចក្តីព្រាងរបាយការណ៍វាយតម្លៃរបស់ខ្លួន នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២។ ដោយមិនអាចសម្រេចបាននូវការព្រមព្រៀងជាឯកច្ឆន្ទ លើការចូលរួមក្នុងដំណើរការដោះស្រាយវិវាទដោយស្ម័គ្រចិត្ត ដើម្បីដោះស្រាយពាក្យបណ្តឹងទេនោះ ពាក្យបណ្តឹងត្រូវបានប្តូរទៅដំណាក់កាលត្រួតពិនិត្យភាពអនុលោមរបស់ស៊ីអេអូ ដើម្បីធ្វើការវាយតម្លៃ ស្របតាមគោលនយោបាយរបស់ស៊ីអេអូ។

## IV. ការឆ្លើយតបរបស់គណៈគ្រប់គ្រង

29. គណៈគ្រប់គ្រងរបស់ IFC គោរពដំណើរការរបស់ស៊ីអេអូក្នុងការវាយតម្លៃអំពីពាក្យបណ្តឹង ទាក់ទងនឹងការវិនិយោគរបស់ IFC លើអតិថិជន និងអតិថិជនរងទាំងប្រាំមួយ របស់ IFC។ IFC ទទួលស្គាល់ថាបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង មានភាពធ្ងន់ធ្ងរ និងចាំបាច់ត្រូវមានការវិភាគ និងតាមដានបន្ថែមទៀតដោយ IFC និងភាគីពាក់ព័ន្ធដទៃទៀត។

30. *កិច្ចប្រឹងប្រែងរបស់ IFC ចំពោះហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវនៅកម្រិតស្ថាប័ន*

- IFC ខិតខំធ្វើការតែជាមួយក្រុម FIs ដែលត្រូវបានជ្រើសរើសប៉ុណ្ណោះ ដែលមានការប្តេជ្ញាចិត្តចំពោះការអនុវត្តល្អក្នុងកិច្ចការពារអតិថិជន និងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។
- ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវគឺជាទិដ្ឋភាពដ៏សំខាន់មួយ សម្រាប់រាល់ការវិនិយោគរបស់ IFC លើអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុ រួមទាំងគម្រោង និងអនុគម្រោងនានា ដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង។ ការវាយតម្លៃលើការវិនិយោគរបស់ IFC លើអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុ រួមបញ្ចូលការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នដ៏លម្អិត ដែលគ្របដណ្តប់លើ៖ (i) ការត្រួតពិនិត្យឡើងវិញយ៉ាងទូលំទូលាយលើអភិបាលកិច្ចសាជីវកម្ម (ii) ការសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធផ្ទៃក្នុង និងខាងក្រៅ (iii) ការត្រួតពិនិត្យឡើងវិញលើគោលនយោបាយរបស់អ្នកទទួលការវិនិយោគ ពាក់ព័ន្ធនឹងផលិតផលរបស់ពួកគេ ការអនុវត្តក្នុងការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់ គោលនយោបាយកិច្ចការពារអ្នកប្រើប្រាស់ គោលនយោបាយវត្ថុបញ្ចាំ ការគ្រប់គ្រងធនធានមនុស្ស និងគ្រឿងលើកទឹកចិត្តចំពោះការអនុវត្ត និងគោលនយោបាយ និងក្របខណ្ឌ ដែលទាក់ទងនឹង E&S (iv) ការត្រួតពិនិត្យឡើងវិញលើឯកសារកម្ចី ដើម្បីពិនិត្យមើលសង្គតិភាពរវាងគោលនយោបាយដែលត្រូវបាន

ដាក់ចេញ និងការអនុវត្ត និង (v) ការចុះទៅកាន់សាខាដែលត្រូវបានជ្រើសរើសដោយផ្ទាល់ រួមជាមួយបទសម្ភាសន៍រវាងអ្នកគ្រប់គ្រងសាខា និងអ្នកខ្ចី (ការចុះទៅកាន់ទីតាំងបែបនេះមិនអាចធ្វើឡើងបានក្នុងអំឡុងពេលមានជំងឺរាតត្បាត ប៉ុន្តែត្រូវបានជំនួសដោយកិច្ចប្រជុំតាមអនឡាញជាមួយអ្នកគ្រប់គ្រងជាន់ខ្ពស់ និងអ្នកគ្រប់គ្រងសាខា ក្នុងអំឡុងពេលដំណើរការការវាយតម្លៃនីមួយៗ)។ រាល់គម្រោងជាន់គ្នា ត្រូវបានតម្រូវឲ្យមានការត្រួតពិនិត្យឡើងវិញទាំងស្រុងលើអាជីវកម្មរបស់អតិថិជន។ នីតិវិធីត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នទាំងនេះ អនុញ្ញាតឲ្យ IFC យល់ច្បាស់អំពីការអនុវត្តផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់អតិថិជនបច្ចុប្បន្ន និងអតិថិជន FI នាពេលអនាគត។

- IFC កំពុងចូលរួមជាមួយអតិថិជនរបស់ខ្លួន ដើម្បីធ្វើការលើគំនិតផ្តួចផ្តើមផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ដើម្បីលើកកម្ពស់គោលការណ៍ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ដែល IFC មានបំណងធ្វើការជាមួយអតិថិជន FI ដែលមានស្រាប់ និងអតិថិជននាពេលអនាគត ដើម្បីត្រួតពិនិត្យឡើងវិញ វាយតម្លៃ និងផ្តល់អនុសាសន៍ ដើម្បីអភិវឌ្ឍគោលនយោបាយ និងការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់ FIs បន្ថែមទៀតនូវ ព្រមទាំងព្រមព្រៀងរួមគ្នាលើផែនការសកម្មភាព ដើម្បីអនុវត្តអនុសាសន៍ដែលបានកំណត់។ IFC បានរួមបញ្ចូលកិច្ចព្រមព្រៀងមានការបញ្ជាក់ ដែលតម្រូវឱ្យមានភាពអនុលោមតាមគោលការណ៍ការពារអតិថិជន និងគោលការណ៍ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ (សូមមើលគំរូនៅក្នុងឧបសម្ព័ន្ធទី ៣) ដែលគ្របដណ្តប់លើការជៀសវាងពីការជំពាក់បំណុលច្រើនពេក ការកំណត់តម្លៃប្រកបដោយតម្លាភាព ការអនុវត្តការប្រមូលប្រាក់យ៉ាងសមស្រប អាកប្បកិរិយារបស់បុគ្គលិកប្រកបដោយសីលធម៌ យន្តការដោះស្រាយបណ្តឹងសារទុក្ខ និង/ឬការការពារឯកជនភាពរបស់ទិន្នន័យ នៅក្នុងកិច្ចព្រមព្រៀងប្រាក់កម្ចីរបស់អតិថិជន និងមូលនិធិ ដែលពាក់ព័ន្ធនឹងពាក្យបណ្តឹង។[7] IFC ធ្វើការវាយតម្លៃភាពអនុលោមរបស់អតិថិជនចំពោះគោលការណ៍ទាំងនេះ និងតម្រូវឲ្យមានចំណាត់ការដោះស្រាយគម្លាតនៃការបំពេញតាមណាមួយ ដែលត្រូវបានសម្គាល់ឃើញ ក្នុងរយៈពេលដែលបានព្រមព្រៀងគ្នាជាមុន។ ឧទាហរណ៍៖ ប្រសិនបើចាំបាច់ IFC កំណត់ការព្រមព្រៀងផ្នែកហិរញ្ញវត្ថុនៅក្នុងកិច្ចព្រមព្រៀងកម្ចីជាមួយអតិថិជន FI ដើម្បីតម្រូវឱ្យកម្ចីដែលមានហានិភ័យខ្ពស់[8] មានការថយចុះទៅតាមពេលវេលា ស្របតាមសមាមាត្រនៃការបញ្ចេញប្រាក់ប្រចាំខែ ពីព្រោះវារារាំង FIs មិនឱ្យផ្តល់កម្ចីកាន់តែធំទៅឱ្យអ្នកខ្ចីក្នុងរយៈពេលខ្លីពេក បន្ទាប់ពីទទួលបានកម្ចីលើកមុន ពីព្រោះការអនុវត្តនៃការផ្តល់កម្ចីបែបនេះអាចធ្វើឱ្យអ្នកខ្ចីមានបំណុលច្រើនពេក។ ពិសេសជាងនេះទៀត IFC បានវាយតម្លៃលើការអនុវត្តផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់អតិថិជននីមួយៗដែលជាប់

[7] IFC បានរួមបញ្ចូលកិច្ចព្រមព្រៀងមានការបញ្ជាក់ស្តីពីគោលការណ៍ការពារអតិថិជន និងគោលការណ៍ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវនៅក្នុងប្រាក់កម្ចីរបស់ខ្លួន ដែលផ្តល់ជូនប្រាសាក់ ដោយផ្ទាល់ នៅឆ្នាំ២០១៥ និងឆ្នាំ២០១៦ (គម្រោងលេខ ៣៦២៨០ និង ៣៨២៣៥) អេស៊ីលីដា (គម្រោងលេខ ៣៨៣៨៦) HTB (គម្រោងលេខ ៤៤៧៤២ និង ៤៥៥៣៥) អម្រឹត (គម្រោងលេខ ៣៧៥០៥ និង ៤៤២៣១) ព្រមទាំងនៅក្នុងការវិនិយោគមូលធនរបស់ខ្លួននៅក្នុង MEF (គម្រោងលេខ ២៧៨២៧) និង MIFA (គម្រោងលេខ ៣១៤៦៧)។

[8] កម្ចីនៃការផ្តល់ហិរញ្ញប្បទានឡើងវិញ ដែលមានហានិភ័យខ្ពស់ នៅក្នុងរបាយការណ៍ស្តីពីគោលការណ៍ណែនាំអំពីការផ្តល់កម្ចីរបស់ CMA ត្រូវបានកំណត់ថាជា៖ (i) កម្ចីដែលបានផ្តល់ហិរញ្ញប្បទានឡើងវិញក្នុងអំឡុងត្រីមាសទី១ ដែលមានចំនួនទឹកប្រាក់កម្ចីថ្មីខ្ពស់ជាង ១៤០ ភាគរយនៃកម្ចីចាស់ ឬ (ii) កម្ចីដែលបានផ្តល់ហិរញ្ញប្បទានឡើងវិញក្នុងអំឡុងត្រីមាសទីពីរ ដែលមានចំនួនទឹកប្រាក់កម្ចីថ្មីខ្ពស់ជាង ១៨០ ភាគរយនៃកម្ចីចាស់។

ពាក់ព័ន្ធនឹងពាក្យបណ្តឹង ក្នុងអំឡុងពេលវាយតម្លៃ ដែលបានធ្វើឡើងតាមបរិបទនៃគម្រោងដែលបានលើកឡើង និងបានដោះស្រាយចំណុចដែលត្រូវបានសម្គាល់ឃើញ ដើម្បីធ្វើការកែលម្អតាមរយៈការចាប់ផ្តើមប្រើប្រាស់កិច្ចព្រមព្រៀងជាវិជ្ជមាន ដូចមានបញ្ជាក់ខាងលើ នៅក្នុងផ្នែកនេះ។

31. ***កិច្ចប្រឹងប្រែងរបស់ IFC នៅក្នុងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវនៅកម្រិតវិស័យ៖*** IFC បានលើកកម្ពស់យ៉ាងសកម្មនូវការអនុវត្តផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងកិច្ចការពារអតិថិជននៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដោយសហការជាមួយភាគីពាក់ព័ន្ធផ្សេងៗ។ ចាប់តាំងពីឆ្នាំ២០០៦ មក IFC បានធ្វើការជាមួយ WBG និង NBC ដើម្បីបង្កើតការិយាល័យឥណទានកម្ពុជា (CBC) ដំបូងគេបង្អស់នៅក្នុងប្រទេស ដែលជាប្រភពនៃតម្លាភាព និងព័ត៌មានសម្រាប់ការរាយការណ៍អំពីឥណទាន និងការធានា ព្រមទាំងជាឧបករណ៍សម្រាប់ FIs ក្នុងការកាត់បន្ថយហានិភ័យនៃការជំពាក់បំណុលច្រើនពេករបស់អ្នកខ្ចី។ បច្ចុប្បន្ន CBC មានសមាជិក FIs ចំនួន ១៧៦ ដែលរួមបញ្ចូលទាំង FIs ទាំងប្រាំមួយ ដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹងផងដែរ ហើយមកទល់បច្ចុប្បន្ន មូលដ្ឋានទិន្នន័យរបស់វាគ្របដណ្តប់លើប្រជាជនពេញវ័យប្រហែល ៦០ ភាគរយនៅក្នុងប្រទេស។ CBC បានរួមចំណែកក្នុងការត្រួតពិនិត្យហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ តាមរយៈការចេញរបាយការណ៍ជូនសមាជិកគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ និងផ្តល់របាយការណ៍ទូទាំងវិស័យដល់ CMA និងសមាគមធនាគារកម្ពុជា (ABC)។ IFC បានសហការជាមួយ CMA CBC និង យុទ្ធនាការ SMART ដើម្បីលើកកម្ពស់គោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចី ពោលគឺ វាជាគំនិតផ្តួចផ្តើម ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១៦ ដើម្បីកាត់បន្ថយហានិភ័យនៃកំណើនទីផ្សារឥណទាន និងការជំពាក់បំណុលច្រើនពេករបស់អ្នកខ្ចី។ នៅឆ្នាំ២០២០ IFC បានចាប់ផ្តើមអនុវត្តគម្រោងអសាធនភាព និងការដោះស្រាយបំណុលនៅចរន្តខាងលើនៅកម្ពុជា ដែលគ្របដណ្តប់លើការគ្រប់គ្រងកម្ចីមិនដំណើរការ និងការដោះស្រាយបំណុល ដើម្បីពង្រឹងការអនុវត្តនៃការប្រមូលបំណុលប្រកបដោយយុត្តិធម៌ និងតម្លាភាព។ ក្រោមគំនិតផ្តួចផ្តើមនេះ IFC បច្ចុប្បន្ន កំពុងធ្វើការលើសមាសធាតុចំនួនពីរ៖ (i) បង្កើតយន្តការសម្រាប់ដំណោះស្រាយក្រៅតុលាការ ដែលអាចបត់បែនបាន និង (ii) បង្កើត និងអនុវត្តបទប្បញ្ញត្តិជាក់លាក់ ដែលត្រូវបានតម្រូវស្របតាមច្បាប់អសាធនភាព ជាពិសេសវិធានគ្រប់គ្រងរដ្ឋបាលអសាធនភាព។ នៅក្រោមសមាសធាតុផ្សំទីមួយ IFC កំពុងផ្តល់ការគាំទ្រដល់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មកម្ពុជា ដើម្បីបង្កើតវិធានសន្ទានកម្មផ្នែកពាណិជ្ជកម្ម ដើម្បីជួយសម្រួលដល់វិធីជំនួសក្នុងការដោះស្រាយវិវាទ។ គម្រោងនេះបានផ្តល់ការបណ្តុះបណ្តាលអំពីសន្ទានកម្មផ្នែកពាណិជ្ជកម្មដល់សន្ទានករផ្នែកពាណិជ្ជកម្មក្នុងស្រុកចំនួន ១៦ រូប ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។ សមាសធាតុទាំងពីរនេះត្រូវបានគេរំពឹងថានឹងទទួលបានការអនុម័តសំខាន់ៗពីអាជ្ញាធររដ្ឋាភិបាលដែលពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា នៅពាក់កណ្តាលឆ្នាំ២០២៣ បន្ទាប់មក IFC នឹងចាប់ផ្តើមធ្វើការពង្រឹងសមត្ថភាពរបស់ភាគីពាក់ព័ន្ធក្នុងការដោះស្រាយបំណុល ដូចជា ធនាគារកណ្តាល អ្នកផ្តល់កម្ចី មេធាវី ចៅក្រមផ្នែកអសាធនភាព និងរដ្ឋបាល។

32. គោលនយោបាយស៊ីអេអូ ផ្តល់ជូននូវលក្ខណវិនិច្ឆ័យនៃការវាយតម្លៃជាក់លាក់សម្រាប់កំណត់ថាតើការស៊ើបអង្កេតភាពអនុលោម មានភាពចាំបាច់ដែរឬទេ ក្នុងនោះរួមមាន៖ (ក) ថាតើមានការចង្អុលបង្ហាញបឋមអំពីគ្រោះថ្នាក់ ឬគ្រោះថ្នាក់ដែលអាចកើតឡើងដែរឬទេ (ខ) ថាតើមានការចង្អុលបង្ហាញជាបឋម

ដែល IFC ប្រហែលជាមិនបានអនុលោមតាមគោលនយោបាយ E&S របស់ខ្លួនដែរឬទេ និង (គ) ថាតើគ្រោះថ្នាក់ ដែលត្រូវបានចោទប្រកាន់ មានទំនាក់ទំនងយ៉ាងសមហេតុផល ទៅនឹងភាពបដិលោម ដែលអាចកើតឡើងដែរឬទេ។[9] ពាក់ព័ន្ធនឹង IFC គោលនយោបាយស៊ីអេអូ កំណត់និយមន័យ "គោលនយោបាយ E&S" ថា រួមបញ្ចូល៖ (i) គោលនយោបាយរបស់ IFC ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម (គោលនយោបាយនិរន្តរភាព) (ii) បទប្បញ្ញត្តិតាមគម្រោងជាក់លាក់នៃគោលនយោបាយសិទ្ធិទទួលបានព័ត៌មានរបស់ IFC និង (iii) ការប្តេជ្ញាចិត្តផ្នែកបរិស្ថាន និងសង្គមណាមួយផ្សេងទៀត ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលសម្រាប់គម្រោងនានា។[10] នៅខណៈពេលដែលមានការគោរពឯករាជ្យភាពរបស់ស៊ីអេអូ ក្នុងការសម្រេចចិត្តលើលក្ខខណ្ឌសមស្រប និងរបកគំហើញនៃរបាយការណ៍វាយតម្លៃរបស់ស៊ីអេអូនោះ ថ្នាក់គ្រប់គ្រងបានត្រួតពិនិត្យឡើងវិញលើការចោទប្រកាន់ ដែលមានចែងនៅក្នុងពាក្យបណ្តឹង និងយល់ឃើញថា ពុំមានលក្ខណវិនិច្ឆ័យ "ខ" ទាក់ទងនឹង "ការចង្អុលបង្ហាញជាបឋមដែល IFC ទំនងជាមិនអនុលោមតាមគោលនយោបាយ E&S របស់ខ្លួន" នោះឡើយ។

33. IFC ចាត់ទុកថា ការអនុវត្តផ្តល់កម្ចី និងកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ (FCP) និងហានិភ័យ ដែលកើតឡើងចំពោះអ្នកខ្ចីបន្ត ក្នុងបរិបទនេះ មិនស្ថិតនៅក្នុងវិសាលភាព ឬលក្ខខណ្ឌតម្រូវជាក់លាក់នៃក្របខណ្ឌនិរន្តរភាព ឆ្នាំ២០១២ របស់ IFC ទេ។ គោលនយោបាយនិរន្តរភាពផ្តោតលើការគ្រប់គ្រងផលប៉ះពាល់ E&S ដែលអាចកើតឡើងចំពោះ*សហគមន៍ជុំវិញ និងពលករ* បណ្តាលមកពី *សកម្មភាពអាជីវកម្ម* ដែលនឹងទទួលបានការគាំទ្រ។[11]

34. ស្របតាមគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម សំដៅលើការប្រែប្រួលណាមួយចំពោះបរិស្ថានរូបវន្ត ធម្មជាតិ ឬវប្បធម៌ និងផលប៉ះពាល់លើ*សហគមន៍ជុំវិញ និងពលករ*។[12] ស្តង់ដារសមិទ្ធកម្មទី១ ក៏បានកំណត់និយមន័យ ភាគីពាក់ព័ន្ធដទៃទៀត ថាជាអ្នកដែលមិនរងផលប៉ះពាល់ដោយផ្ទាល់ពីគម្រោង ប៉ុន្តែមានប្រយោជន៍ពីគម្រោង រួមមាន អាជ្ញាធរជាតិ និងអាជ្ញាធរមូលដ្ឋាន គម្រោងជិតខាង និង/ឬអង្គការមិនមែនរដ្ឋាភិបាល។[13] ភ្ញៀវ ឬអ្នកប្រើប្រាស់ផលិតផលរបស់អតិថិជនមិនត្រូវបានលើកឡើង នៅក្នុងគោលនយោបាយនិរន្តរភាព ឬស្តង់ដារសមិទ្ធកម្ម ថាជាភាគីពាក់ព័ន្ធមួយប្រភេទ ដែលវិធានការកាត់បន្ថយហានិភ័យ E&S គួរតែអនុវត្តចំពោះពួកគេនោះទេ។

35. យោងតាមស្តង់ដារសមិទ្ធកម្មទី១ ពាក្យ "គម្រោង" សំដៅលើ បណ្តុំសកម្មភាពអាជីវកម្ម ដែលត្រូវបានកំណត់ រួមទាំងសកម្មភាព ដែលទិដ្ឋភាពនៃធាតុរូបវន្តជាក់លាក់ និងឥណទាន ទំនងជាបង្កើតហានិភ័យ និងផលប៉ះពាល់ ដែលមិនទាន់បានកំណត់និយមន័យនៅឡើយ។ ចំពោះអន្តរការីផ្នែកហិរញ្ញវត្ថុ *សកម្មភាពអាជីវកម្ម* ដែល IFC ផ្តល់ការគាំទ្រតាមរយៈអតិថិជន FI និងអតិថិជនរងរបស់ខ្លួន គឺជាសកម្មភាពអាជីវកម្មដែលកើតចេញពីការប្រើប្រាស់ប្រាក់ចំណូលនៃកម្ចីរបស់អ្នកខ្ចីបន្ត (ឧទាហរណ៍៖ កម្ចីសម្រាប់ប្រើប្រាស់

---

[9] គោលនយោបាយស៊ីអេអូ កថាខណ្ឌ ៩១(ខ).

[10] គោលនយោបាយស៊ីអេអូ សទ្ទានុក្រម.

[11] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី៣ ជើងទំព័រទី២.

[12] គោលនយោបាយនិរន្តរភាព កថាខណ្ឌទី៣ ជើងទំព័រទី២.

[13] ស្តង់ដារសមិទ្ធកម្មទី១ កថាខណ្ឌទី១ ជើងទំព័រទី១.

ផ្ទាល់ខ្លួន ឬកម្ចីទិញធាតុចូលសម្រាប់កសិកម្មខ្នាតតូច ឬដើម្បីផ្តល់ហិរញ្ញប្បទានដល់សកម្មភាពពាណិជ្ជកម្មខ្នាតតូច)។ គោលនយោបាយនិរន្តរភាពមិនអនុវត្តចំពោះផលប៉ះពាល់ E&S លើអ្នកខ្ចីបន្តដោយផ្ទាល់នោះទេ។

36. ផ្ទុយមកវិញ IFC ដោះស្រាយបញ្ហា និងហានិភ័យផ្នែកកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុទាំងនេះ ជាផ្នែកមួយនៃដំណើរការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នលើផ្នែកហិរញ្ញវត្ថុដ៏ទូលំទូលាយរបស់ខ្លួន និងតាមរយៈកញ្ចប់នៃហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។ ក្នុងបរិបទនេះ IFC ទទួលស្គាល់យ៉ាងពេញលេញនូវសារសំខាន់នៃការអនុវត្តក្នុងការផ្តល់កម្ចី និងកិច្ចការពារអ្នកប្រើប្រាស់ដ៏រឹងមាំ នៅក្នុងឧស្សាហកម្មមីក្រូហិរញ្ញវត្ថុ ហើយបានចាត់វិធានការមួយចំនួននៅកម្រិតស្ថាប័ន វិស័យ និងថ្នាក់ជាតិ ដើម្បីពង្រឹងកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា ដែលត្រូវបានពណ៌នាយ៉ាងលម្អិតនៅក្នុងកថាខណ្ឌទី៣០ និង ៣១។

37. ដើមបណ្តឹងបានចោទប្រកាន់ថា ការត្រួតពិនិត្យរបស់ IFC មុនពេលអនុវត្តគម្រោង បណ្តាលឲ្យមានការចាត់ថ្នាក់ហានិភ័យនៃការវិនិយោគរបស់ខ្លួនមិនបានត្រឹមត្រូវ។ ស្របតាមលក្ខខណ្ឌតម្រូវនៃគោលនយោបាយនិរន្តរភាព ការត្រួតពិនិត្យទៅលើ E&S របស់ IFC ផ្តោតលើការវាយតម្លៃហានិភ័យ E&S និងផលប៉ះពាល់ដែលអាចកើតឡើង ទាក់ទងនឹង*ការប្រើប្រាស់ប្រាក់ចំណូល* របស់អ្នកខ្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែល IFC ផ្តល់ជូនតាមរយៈអតិថិជន FI របស់ខ្លួន និងមិនមែនជាផលប៉ះពាល់ E&S ដែលអាចកើតឡើងលើអ្នកខ្ចីបន្តដោយផ្ទាល់នោះទេ។ នៅពេលដែលផលប័ត្រដែលមានស្រាប់ ឬដែលបានស្នើឡើងរបស់ FI រួមបញ្ចូលទំនាក់ទំនងផ្នែកហិរញ្ញវត្ថុចំពោះសកម្មភាពអាជីវកម្ម ដែលភាគច្រើន មានផលប៉ះពាល់តិចតួច ឬគ្មានផលប៉ះពាល់ផ្នែកបរិស្ថាន ឬសង្គមនោះ IFC ចាត់ថ្នាក់ការវិនិយោគទាំងនេះជា FI-៣។ ហានិភ័យ E&S និងផលប៉ះពាល់ដែលអាចកើតឡើង ទាក់ទងនឹងការប្រើប្រាស់ប្រាក់ចំណូលរបស់បុគ្គល ឬសហគ្រាសធុនមីក្រូ ពីឥណទាន ដែល IFC ផ្តល់ជូនតាមរយៈកម្មវិធីមីក្រូហិរញ្ញវត្ថុរបស់អតិថិជន FI របស់ខ្លួន ត្រូវបានវាយតម្លៃ ហើយតាមធម្មតា ត្រូវបានគេរកឃើញថាមានចំនួនតិចតួចបំផុត។ ដូច្នេះ ការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុប្រភេទនេះ តាមធម្មតា ត្រូវបានចាត់ទុកថាមានហានិភ័យទាប និងត្រូវបានចាត់ថ្នាក់ជា FI-៣។ ក្រៅពីការផ្តល់កម្ចីខ្នាតមីក្រូដល់បុគ្គល ឬសហគ្រាសធុនមីក្រូ គម្រោងសកម្មមួយចំនួនក៏បានរួមបញ្ចូលសមាសធាតុក្នុងការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យមផងដែរ ដែលក្នុងករណីនេះ និងដើម្បីឆ្លុះបញ្ចាំងអំពីហានិភ័យ E&S ជារួម នៃការវិនិយោគនោះ ប្រតិបត្តិការទាំងនេះត្រូវបានចាត់ថ្នាក់ជា FI-២។

38. ស្របតាមកថាខណ្ឌទី ៣៥ នៃគោលនយោបាយនិរន្តរភាព អតិថិជន FI ត្រូវបានតម្រូវឱ្យបង្កើត និងដំណើរការ ESMS ដែលសមស្របនឹងកម្រិតហានិភ័យផ្នែកបរិស្ថាន និងសង្គម នៅក្នុងផលប័ត្ររបស់ខ្លួន និងសកម្មភាពអាជីវកម្មនាពេលអនាគត។ ចំពោះការវិនិយោគ FI-៣ វាពាក់ព័ន្ធនឹងការពិនិត្យមើលសកម្មភាពអាជីវកម្ម ដែលពួកគេផ្តល់ការគាំទ្រ ធៀបនឹងបញ្ជីផាត់ចេញរបស់ IFC និងច្បាប់ជាតិ។ នីតិវិធីត្រួតពិនិត្យ E&S បែបនេះ ត្រូវបានចាត់ទុកថាជាការបង្កើត ESMS ដែលសមស្របនឹងកម្រិតអប្បបរមានៃហានិភ័យ E&S នៅក្នុងប្រតិបត្តិការទាំងនេះ។[14] អតិថិជន FI-២ ត្រូវបានតម្រូវឲ្យដំណើរការ ESMS

[14] គោលនយោបាយនិរន្តរភាព ជើងទំព័រទី៧។

ដែលទំនើបជាងនេះ ដែលលក្ខខណ្ឌតម្រូវដែលពាក់ព័ន្ធនៃស្តង់ដារសមិទ្ធកម្ម អាចត្រូវបានអនុវត្តចំពោះសកម្មភាពអាជីវកម្មដែលមានហានិភ័យខ្ពស់ ពោលគឺគម្រោង ឬការផ្តល់កម្ចីសាជីវកម្មរយៈពេលវែង។[15] ដូចបានកត់សម្គាល់ ការផ្តល់កម្ចីខ្នាតមីក្រូដល់បុគ្គល ឬសហគ្រាសធុនមីក្រូ ត្រូវបានចាត់ទុកថាជាសកម្មភាពដែលមានហានិភ័យទាប ស្របតាមគោលនយោបាយផ្តោតលើផលប៉ះពាល់ E&S ដែលកើតចេញពីការប្រើប្រាស់ប្រាក់ចំណូល។ ចំណាត់ថ្នាក់ហានិភ័យ E&S នៃគម្រោងសកម្មទាំងអស់ ក៏ដូចជា ESMS របស់អតិថិជនផងដែរ មានភាពស្របតាមលក្ខខណ្ឌតម្រូវនៃគោលការណ៍និរន្តរភាព។ អាស្រ័យហេតុនេះ គណៈគ្រប់គ្រងមានការយល់ឃើញថា ពុំមានការចង្អុលបង្ហាញជាបឋម ដែលថា IFC ប្រហែលជាមិនបានអនុលោមតាមគោលនយោបាយ E&S របស់ខ្លួន ពាក់ព័ន្ធនឹងទិដ្ឋភាពនេះនោះទេ។

39. ការត្រួតពិនិត្យការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ គឺអាស្រ័យលើការត្រួតពិនិត្យផលប័ត្រវិនិយោគរបស់ IFC ជាជាងការពិនិត្យតាមដានដោយអ្នកឯកទេស E&S។ ក្នុងដំណាក់កាលត្រួតពិនិត្យគម្រោង ក្រុមការងារត្រួតពិនិត្យផលប័ត្រវិនិយោគរបស់ IFC (i) ត្រួតពិនិត្យឡើងវិញលើរបាយការណ៍ និងកិច្ចព្រមព្រៀង ដែលត្រូវបានតម្រូវជាទៀងទាត់ រួមទាំងរបាយការណ៍ និងកិច្ចព្រមព្រៀង ដែលទាក់ទងនឹងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវផងដែរ (ii) រក្សាទំនាក់ទំនងជាប្រចាំជាមួយគណៈគ្រប់គ្រងរបស់អតិថិជន FI ម្ចាស់ភាគហ៊ុនសំខាន់ៗ និងភាគីពាក់ព័ន្ធសំខាន់ៗផ្សេងទៀត ដើម្បីបន្តទទួលបានព័ត៌មានអំពីការអភិវឌ្ឍន៍យុទ្ធសាស្ត្រចុងក្រោយបង្អស់របស់អតិថិជន រួមទាំងយុទ្ធសាស្ត្រ ដែលទាក់ទងនឹងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវផងដែរ និង (iii) ធ្វើបច្ចុប្បន្នភាពតាមកាលកំណត់ចំពោះការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន ប្រកបដោយសុចរិតភាព ក្នុងអំឡុងពេលត្រួតពិនិត្យផលប័ត្រ ដែលព្យាយាមចាប់យកហានិភ័យផ្នែកកេរ្តិ៍ឈ្មោះរបស់នាយក គណៈគ្រប់គ្រង និងអ្នកឧបត្ថម្ភរបស់អ្នកទទួលការវិនិយោគ។

40. ដើមបណ្តឹងបានចោទប្រកាន់ថា មានចន្លោះប្រហោងនៅក្នុងក្របខណ្ឌ E&S របស់ IFC ដែលវាយតម្លៃនិងគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់ E&S ទាក់ទងនឹងសកម្មភាពមីក្រូហិរញ្ញវត្ថុ។ ទោះបីជាយ៉ាងណាក៏ដោយ លក្ខណវិនិច្ឆ័យនៃការវាយតម្លៃរបស់ស៊ីអេអូ វាយតម្លៃថាតើមានការចង្អុលបង្ហាញជាបឋមដែលថា IFC ប្រហែលជាមិនបានអនុលោមតាមគោលនយោបាយ E&S របស់ខ្លួនដែរឬទេ ថាតើគោលនយោបាយ E&S ទាំងនោះមានភាពគ្រប់គ្រាន់នៅក្នុងទម្រង់បច្ចុប្បន្នរបស់ពួកគេដែរឬទេ ឬថាតើ IFC គួរតែកែសម្រួលគោលនយោបាយ E&S របស់ខ្លួនដែរឬទេ។ IFC ប្តេជ្ញាចិត្តដោះស្រាយផលប៉ះពាល់សង្គមដូចជា អ្វីដែលបានបញ្ជាក់នៅក្នុងពាក្យបណ្តឹង តាមរយៈការអនុវត្តកិច្ចការពារអតិថិជន និងហិរញ្ញវត្ថុប្រកបដោយទំនួលទំនួលខុសត្រូវ ដែលត្រូវបានពណ៌នានៅខាងក្រោម។ គណៈគ្រប់គ្រងទទួលស្គាល់ថាបញ្ហាដែលទាក់ទងនឹងការផ្តល់ហិរញ្ញប្បទានប្រកបដោយទំនួលខុសត្រូវនៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានបង្ហាញនៅក្នុងពាក្យបណ្តឹង គឺជាបញ្ហាធ្ងន់ធ្ងរ ដែលទាមទារឱ្យមានការវិភាគ និងតាមដានបន្ថែមដោយ IFC និងភាគីពាក់ព័ន្ធដទៃទៀត ដូចជា NBC CMA និង ABC។ IFC ប្តេជ្ញាចិត្តដោះស្រាយបញ្ហាទាំងនេះ និងពង្រឹងការអនុវត្តកិច្ចការពារអតិថិជន និងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់ខ្លួន នៅខាងក្រៅដំណើរការស៊ើបអង្កេតអំពីភាពអនុលោមរបស់ស៊ីអេអូ ដែលផ្តោតយ៉ាងខ្លាំងលើភាពអនុលោម

[15] គោលនយោបាយនិរន្តរភាពរបស់ IFC កថាខណ្ឌទី៣៥។

តាមគោលនយោបាយនិរន្តរភាព។

41. IFC បានអនុម័តអភិក្រមកម្មវិធីមួយចំពោះហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវនៅក្នុងប្រទេសកម្ពុជា ដើម្បីបណ្តុះ និងពង្រឹងការអនុវត្តនៃកិច្ចការពារអតិថិជន និងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់អតិថិជន IFC។ ដូចបានពណ៌នាខាងលើ (កថាខណ្ឌទី ៣០ ដល់ ៣១) គឺជាសកម្មភាព ដែល IFC បានអនុវត្តនៅកម្រិតស្ថាប័ន វិស័យ និងថ្នាក់ជាតិ ដើម្បីពង្រឹងកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា។

42. គណៈគ្រប់គ្រងទទួលស្គាល់ថា កិច្ចការពារអ្នកប្រើប្រាស់អាចត្រូវបានពង្រឹងបន្ថែមតាមរយៈការអនុវត្តយុទ្ធសាស្ត្រ ដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីបរិយាប័ន្នហិរញ្ញវត្ថុ (NFIS) របស់ប្រទេសកម្ពុជា។[16] ទាំងនេះរួមបញ្ចូលជំហាននានា ដូចជា៖ (i) ការចេញបទប្បញ្ញត្តិស្តីពីកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ (FCP) តាមរយៈនិយតករ NBC (ii) កិច្ចប្រឹងប្រែងពង្រឹងការអប់រំដល់អ្នកប្រើប្រាស់ហិរញ្ញវត្ថុ (iii) ការណែនាំអ្នកដោះស្រាយវិវាទឯករាជ្យ និង (iv) ការសម្រួលយន្តការដោះស្រាយវិវាទ និងពង្រឹងអភិបាលកិច្ចដោយខ្លួនឯង តាមរយៈសមាគមឧស្សាហកម្ម។ IFC រួមជាមួយស្ថាប័នហិរញ្ញវត្ថុអភិវឌ្ឍន៍ពហុភាគីដទៃទៀត នឹងសម្របសម្រួលជាមួយ NBC CMA ABC និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីគាំទ្រដល់ការធ្វើឲ្យប្រសើរឡើងទាំងនេះ។

43. IFC ប្តេជ្ញាចិត្តយ៉ាងខ្លាំងក្លាក្នុងការត្រួតពិនិត្យឡើងវិញ និងដោះស្រាយបញ្ហា ដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង ទាក់ទងនឹងការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ រួមជាមួយភាគីពាក់ព័ន្ធដទៃទៀត ដែលមានភាពសកម្ម នៅក្នុងប្រទេសកម្ពុជា ដូចជាធនាគារពិភពលោក NBC CMA ABC និងស្ថាប័នហិរញ្ញវត្ថុនៃការអភិវឌ្ឍន៍ពហុភាគីដទៃទៀត។ ជាចុងក្រោយ និងដោយមានឯករាជ្យភាពពីដំណើរការស៊ើបអង្កេតភាពអនុលោមរបស់ស៊ីអេអូ ទាក់ទងនឹងពាក្យបណ្តឹងនោះ IFC ប្តេជ្ញាចិត្តបន្តអនុវត្តអភិក្រម និងសកម្មភាពនានា ដូចខាងក្រោម៖

***ភាពមិនប្រក្រតីតាមគម្រោងជាក់លាក់ ដែលត្រូវបានចោទប្រកាន់នៅក្នុងពាក្យបណ្តឹង៖***

- វាយតម្លៃថាតើមានភាពមិនប្រក្រតីណាមួយ ដែលទាក់ទងនឹងគោលការណ៍ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវនៅក្នុងកម្ចីដែលផ្តល់ជូនដើមបណ្តឹង បានកើតឡើងដែរឬទេ (ក្នុងលក្ខខណ្ឌដែលព័ត៌មានអំពីដើមបណ្តឹងម្នាក់ៗត្រូវបានចែករំលែកជាមួយ IFC) និងរួមគ្នាជាមួយអតិថិជន FI កំណត់ការកែលម្អណាមួយដែលចាំបាច់ ដើម្បីជៀសវាងភាពមិនប្រក្រតីទាំងនោះនាពេលអនាគត។
- ក្នុងករណីដែល IFC បញ្ជាក់ថា ភាពមិនប្រក្រតីទាក់ទងនឹងគោលការណ៍ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវបានកើតឡើងនោះ ធ្វើការជាមួយអតិថិជនរបស់ខ្លួន ដើម្បីដោះស្រាយភាពមិនប្រក្រតីទាំងនោះនៅកម្រិតអ្នកខ្ចីនីមួយៗ តាមភាពសមស្រប។

***ហានិភ័យនៃការសងសឹក***

- បន្តចូលរួមជាមួយ និងបណ្តុះបណ្តាលអតិថិជន និងអតិថិជនរងរបស់ IFC អំពីការទប់ស្កាត់ ការគ្រប់គ្រង និងការដោះស្រាយហានិភ័យនៃការសងសឹក។ IFC នឹងបង្កើតការបណ្តុះបណ្តាលលើ

[16] យុទ្ធសាស្ត្រជាតិស្តីពីបរិយាប័ន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ ដែលបានបោះពុម្ពផ្សាយនៅលើវេបសាយត៍របស់ NBC៖ https://www.nbc.org.kh/download_files/publication/blueprints_eng/Final_NFIS_in_English.pdf

ប្រធានបទនេះដល់អម្រឹត HTB និងប្រាសាក់ ក្នុងខែវិច្ឆិកា ឆ្នាំ២០២២ ដើម្បីបង្កើនសមត្ថភាពរបស់ពួកគេក្នុងការដោះស្រាយការសងសឹក។ លើសពីនេះទៀត IFC មានគម្រោងផ្តល់ការបណ្តុះបណ្តាល និងការណែនាំស្រដៀងគ្នាដល់អតិថិជន និងអតិថិជនរង ដែលពាក់ព័ន្ធនឹងពាក្យបណ្តឹងនេះ ក៏ដូចជាពង្រីកវគ្គបណ្តុះបណ្តាលទាំងនេះទៅកាន់ផ្នែកដទៃទៀតនៃឧស្សាហកម្ម ដោយចាប់ដៃគូជាមួយ NBC និង CMA។ ដោយគាំទ្រចំពោះសំណើសុំរក្សាការសម្ងាត់របស់ដើមបណ្តឹង IFC នឹងស្វាគមន៍រាល់ការចូលរួមជាមួយដើមបណ្តឹង និងតំណាងរបស់ពួកគេនៅក្នុងសកម្មភាពដែលបានពណ៌នា ដើម្បីផ្តល់ព័ត៌មាន និងពង្រឹងការអនុវត្តផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។

***អភិក្រមរបស់ IFC ចំពោះហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ៖***

- បើកការពិគ្រោះយោបល់ជាសាធារណៈអំពីអភិក្រមរបស់ IFC ចំពោះហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគោលការណ៍កិច្ចការពារអតិថិជន និងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ រួមទាំងលក្ខខណ្ឌជាក់លាក់សម្រាប់ការបញ្ចេញព័ត៌មានដែលទាក់ទងនឹងកម្ចី ដែលពាក់ព័ន្ធ ទៅកាន់អ្នកខ្ចីផងដែរ។ ការពិគ្រោះយោបល់នឹងបើកសម្រាប់រយៈពេល ៤៥ ថ្ងៃ ក្នុងអំឡុងពេលដែលភាគីពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា រួមទាំងដើមបណ្តឹង នឹងអាចផ្តល់មតិយោបល់របស់ពួកគេបាន
- ធ្វើវិសោធនកម្មអភិក្រមហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវក្នុងរយៈពេលប្រាំមួយខែ ចាប់ពីពេលបញ្ចប់ការពិគ្រោះយោបល់ ដោយឆ្លុះបញ្ចាំងអំពីរបកគំហើញនៃការពិគ្រោះយោបល់
- បោះពុម្ពផ្សាយអភិក្រមឆ្លើយតបនឹងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងប្រើកំណែ ដែលបានកែសម្រួលរួច ជាលក្ខខណ្ឌស្តង់ដារនៃហិរញ្ញប្បទានសម្រាប់ការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុទាំងអស់នៅក្នុងប្រទេសកម្ពុជា។

***បទប្បញ្ញត្តិស្តីពីកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ (FCP) នៅកម្ពុជា៖***

- ចូលរួមជាមួយរដ្ឋាភិបាលកម្ពុជាក្នុងការរៀបចំបទប្បញ្ញត្តិ FCP ដើម្បីដោះស្រាយចំណុចខ្វះខាតដែលមានស្រាប់ នៅកម្រិតវិស័យ។ នេះអាចរួមបញ្ចូលការដោះស្រាយការអនុវត្តច្បាប់នានា ដូចបានពណ៌នានៅក្នុង NFIS កម្ពុជា ផងដែរ។

44. IFC ស្វាគមន៍រាល់ការចូលរួមជាមួយ និងការចូលរួមរបស់ដើមបណ្តឹង និងតំណាងរបស់ពួកគេនៅក្នុងសកម្មភាពខាងលើ ដើម្បីផ្តល់ព័ត៌មាន និងពង្រឹងការអនុវត្តនៃការផ្តល់កម្ចីប្រកបដោយទំនួលខុសត្រូវស្របពេលជាមួយគ្នា បន្តគាំទ្រដល់សំណើសុំរក្សាការសម្ងាត់របស់ពួកគេ។

45. គណៈគ្រប់គ្រងប្តេជ្ញាចិត្តផ្តល់ជូនក្រុមប្រឹក្សាភិបាល តាមការស្នើសុំ នូវបច្ចុប្បន្នភាពអំពីស្ថានភាពនៃការអនុវត្តសកម្មភាពដែលបានលើកឡើងខាងលើ។

## ឧបសម្ព័ន្ធទី១៖ ទំនាក់ទំនងនៃការវិនិយោគរបស់ IFC ជាមួយអតិថិជន FI ដោយផ្ទាល់ អេស៊ីលីដា HTB និង អម្រឹត

### តារាងទី១៖ គម្រោងរបស់ IFC ជាមួយអេស៊ីលីដា ដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្ដឹងដើម

| លេខគម្រោង | ឈ្មោះគម្រោង | ឆ្នាំអនុវត្ត | ចំនួនដែលត្រូវបានអនុវត្តជាលើកដំបូង | | | ស្ថានភាព គិតត្រឹមថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០២២ | ស្ថានភាព គិតត្រឹមរបាយការណ៍របស់គណៈគ្រប់គ្រងនេះ | ការចាត់ថ្នាក់ E&S |
|---|---|---|---|---|---|---|---|---|
| | | | ការវិនិយោគលើគណនីផ្ទាល់ខ្លួនរបស់ IFC | ការប្រមូលផ្ដុំរបស់ IFC | សរុប | | | |
| ៣០៦០៧ | បំណុលបន្ទាប់បន្សំរបស់អេស៊ីលីដា | ២០១១ | ៦ | - | ៦ | ត្រូវបានបិទ | ត្រូវបានបិទ | FI |
| ៣២៦៤២ | CF បំណុលបន្ទាប់បន្សំរបស់អេស៊ីលីដា ២ | ២០១២ | ៤០ | - | ៤០ | ត្រូវបានបិទ | ត្រូវបានបិទ | FI-២ |
| ៣៤៣៨៦ | កម្ចីរបស់អេស៊ីលីដា ឆ្នាំ២០១៣ | ២០១៣ | ៥០ | - | ៥០ | ត្រូវបានបិទ | ត្រូវបានបិទ | FI-២ |
| ៣៥៩៦៣ | កម្ចីជាក្រុមរបស់អេស៊ីលីដា | ២០១៥ | ៤០ | ៧០ | ១១០ | ត្រូវបានបិទ | ត្រូវបានបិទ | FI-២ |
| ៣៧៥៩៤ | កម្ចីយេនជ៉ររបស់អេស៊ីលីដា | ២០១៦ | ១០០ | ១៣០ | ២៣០ | ត្រូវបានបិទ | ត្រូវបានបិទ | FI-២ |
| ៤២៤៨០ | បំណុលបន្ទាប់បន្សំរបស់អេស៊ីលីដា | ២០១៩ | ៦០ | ៥០ | ១១០ | សកម្ម | សកម្ម | FI-២ |
| ៤៤៨៨២ | កម្ចីជាន់ខ្ពស់របស់អេស៊ីលីដា ឆ្នាំ២០២០ | ២០២១ | ១០០ | ៦៩ | ១៦៩ | សកម្ម | សកម្ម | FI-២ |

### តារាងទី២៖ គម្រោងរបស់ IFC ជាមួយ HTB ដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្ដឹងលើកដំបូង

| លេខគម្រោង | ឈ្មោះគម្រោង | ឆ្នាំអនុវត្ត | ចំនួនដែលត្រូវបានអនុវត្តជាលើកដំបូង | | | ស្ថានភាព គិតត្រឹមថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០២២ | ស្ថានភាព គិតត្រឹមរបាយការណ៍របស់គណៈគ្រប់គ្រងនេះ | ការចាត់ថ្នាក់ E&S |
|---|---|---|---|---|---|---|---|---|
| | | | ការវិនិយោគលើគណនីផ្ទាល់ខ្លួនរបស់ IFC | ការប្រមូលផ្ដុំរបស់ IFC | សរុប | | | |
| ៣៦២៤២ | កម្ចីជាន់ខ្ពស់របស់ HKL | ២០១៥ | ១០ | - | ១០ | ត្រូវបានបិទ | ត្រូវបានបិទ | FI-៣ |
| ៣៨២៣៩ | កម្ចី AB របស់ HKL | ២០១៦ | ២០ | ៣០ | ៥០ | ត្រូវបានបិទ | ត្រូវបានបិទ | FI-៣ |
| ៣៩១៦៧ | កម្ចីជាន់ខ្ពស់របស់ HKL ឆ្នាំ២០១៧ | ២០១៧ | ៥ | - | ៥ | សកម្ម | ត្រូវបានបិទ | FI-៣ |
| ៤១២២៣ | សញ្ញាបណ្ណ DCM HKL LCY | ២០១៨ | ២០ | - | ២០ | ត្រូវបានបិទ | ត្រូវបានបិទ | FI-៣ |
| ៤៤២១១ | WCS Covid HKL | ២០២០ | ២៥ | - | ២៥ | សកម្ម | ត្រូវបានបិទ | FI-៣ |
| ៤៤៧៤២ | បំណុលបន្ទាប់បន្សំរបស់ HTB | ២០២១ | ១០ | ៣០ | ៤០ | សកម្ម | សកម្ម | FI-២ |
| ៤៥៥៣៥ | កម្ចីជាន់ខ្ពស់របស់ HTB នៅផ្ទៃបាតនៃពីរ៉ាមីត (BOP) | ២០២១ | ១<br>០ | ៦០ | ៧០ | សកម្ម | សកម្ម | FI-២ |

AB – កម្ចី A និង កម្ចី B របស់ IFC; BOP – ផ្ទៃបាតនៃពីរ៉ាមីត; DCM – ទីផ្សារមូលធនបំណុល; WCS - ដំណោះស្រាយទុនបង្វិល

## តារាងទី ៣៖ គម្រោងរបស់ IFC ជាមួយ អម្រឹត ដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្តឹងដើម

| លេខគម្រោង | ឈ្មោះគម្រោង | ឆ្នាំអនុវត្ត | ចំនួនដែលត្រូវបានអនុវត្តជាលើកដំបូង | | | ស្ថានភាព គិតត្រឹមថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០២២ | ស្ថានភាព គិតត្រឹមរបាយការណ៍របស់គណៈគ្រប់គ្រងនេះ | ការចាត់ថ្នាក់ E&S |
|---|---|---|---|---|---|---|---|---|
| | | | ការវិនិយោគលើគណនីផ្ទាល់ខ្លួនរបស់ IFC | ការប្រមូលផ្តុំរបស់ IFC | សរុប | | | |
| ៣៤៧៤៨ | គម្រោងមូលធនអម្រឹត | ២០១៤ | ១៧.៥ | - | ១៧.៥ | សកម្ម | សកម្ម | FI-២ |
| ៣៧៥០៥ | កម្ចី AB អម្រឹត | ២០១៦ | ៧ | ៥៣ | ៦០ | ត្រូវបានបិទ | ត្រូវបានបិទ | FI-២ |
| ៦០១៦០២ | ការផ្លាស់ប្តូរអម្រឹត | ២០១៦-២០១៧ | គម្រោងទីប្រឹក្សា | | | ត្រូវបានបិទ | ត្រូវបានបិទ | |
| ៤១២៩៤ | កម្ចីជាន់ខ្ពស់របស់អម្រឹត ១៨ | ២០១៨ | ២.៥ | ១៥ | ១៧.៥ | សកម្ម | ត្រូវបានបិទ | FI-២ |
| ៤៤២៣១ | WCS ចំណែកទឹកប្រាក់សម្រាប់កូវីដ ១ | ២០២០ | ១២.៥ | ១២.៥ | ២៥ | សកម្ម | ត្រូវបានបិទ | FI-៣ |
| ៤៤២៣១ | WCS ចំណែកទឹកប្រាក់សម្រាប់កូវីដ ២ | ២០២១ | ១២.៥ | - | ១២.៥ | សកម្ម | សកម្ម | FI-៣ |

AB – កម្ចី A និង កម្ចី B របស់ IFC; WCS - ដំណោះស្រាយទុនបង្វិល

## តារាងទី ៤៖ គម្រោងរបស់ IFC ជាមួយ ប្រាសាក់ ដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្តឹងដើម

| លេខគម្រោង | ឈ្មោះគម្រោង | ឆ្នាំអនុវត្ត | ចំនួនដែលត្រូវបានអនុវត្តជាលើកដំបូង | | | ស្ថានភាព គិតត្រឹមថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០២២ | ស្ថានភាព គិតត្រឹមរបាយការណ៍របស់គណៈគ្រប់គ្រងនេះ | ការចាត់ថ្នាក់ E&S |
|---|---|---|---|---|---|---|---|---|
| | | | ការវិនិយោគលើគណនីផ្ទាល់ខ្លួនរបស់ IFC | ការប្រមូលផ្តុំរបស់ IFC | សរុប | | | |
| ៣៦២៨០ | កម្ចី Sr ប្រាសាក់ ៣ | ២០១៥ | ១០ | - | ១០ | ត្រូវបានបិទ | ត្រូវបានបិទ | FI-២ |
| ៣៨២៣៥ | កម្ចី AB ប្រាសាក់ | ២០១៦ | ២០ | ៧០ | ៩០ | ត្រូវបានបិទ | ត្រូវបានបិទ | FI-២ |

AB – កម្ចី A និង កម្ចី B របស់ IFC

# ឧបសម្ព័ន្ធទី២៖ ទំនាក់ទំនងនៃការវិនិយោគរបស់ IFC ជាមួយ មូលនិធិទាំងពី – MEF MIFA និង North Haven

## តារាងទី១៖ គម្រោងរបស់ IFC ជាមួយ MEF MIFA និង North Haven ដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្តឹងដើម

| លេខគម្រោង | ឈ្មោះគម្រោង | ឈ្មោះមូលនិធិ | ឆ្នាំអនុវត្ត | ចំនួនទឹកប្រាក់ដែលបានអនុវត្តដំបូង | ស្ថានភាពគិតត្រឹមថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០២២ | ស្ថានភាពគិតត្រឹមរបាយការណ៍របស់គណៈគ្រប់គ្រងនេះ |
|---|---|---|---|---|---|---|
| ២៧៨២៧ | IFC – MLF | MEF | ២០០៩ | ១៥០ | សកម្ម | សកម្ម |
| ៣១៤៦៧ | មូលនិធិបំណុល MIFA | មូលនិធិបំណុល MIFA | ២០១២ | ១៦.៧៥ | សកម្ម | សកម្ម |
| ៣៨៦០៩ | North Haven Fund | North Haven Thai Private Equity Fund L.P. | ២០១៨ | ១៥ | សកម្ម | សកម្ម |

## តារាងទី២៖ ការផ្តល់កម្ចីរបស់ MEF ដល់ FIs កម្ពុជា

| MEF (គម្រោងលេខ ២៧៨២៧) | ប្រភេទផលិតផល | ចំនួនទឹកប្រាក់ដែលបានអនុវត្ត លានដុល្លារអាមេរិក | ការផ្តល់កម្ចីដែលមិនទាន់សង លានដុល្លារអាមេរិក |
|---|---|---|---|
| អិលអូអិលស៊ី ខេមបូឌា | កម្ចីជាន់ខ្ពស់ | ១៤,២ | ១៤,២ |
| អម្រឹត | កម្ចីជាន់ខ្ពស់ | ១៣,៨ | ១៣,៨ |
| ប្រាសាក់ | កម្ចីជាន់ខ្ពស់ | ៧,៨ | ៧,៨ |
| HTB | កម្ចីជាន់ខ្ពស់ | ៥,៥ | ៣,៥ |
| **ការផ្តល់កម្ចីសរុបរបស់ MEF ដល់ FIs កម្ពុជា** | | ៤១,៣ | ៣៩,៣ |

## តារាងទី៣៖ ការផ្តល់កម្ចីរបស់ MIFA ដល់ FIs កម្ពុជា

| MIFA (គម្រោងលេខ ៣១៤៦៧) | ប្រភេទផលិតផល | ចំនួនទឹកប្រាក់ដែលបានអនុវត្ត លានដុល្លារអាមេរិក | ការផ្តល់កម្ចីដែលមិនទាន់សង លានដុល្លារអាមេរិក |
|---|---|---|---|
| ធនាគារ ស្ថាបនា ភីអិលស៊ី | កម្ចីបន្ទាប់បន្សំ | ៤,០ | ៣,២ |
| អម្រឹត | កម្ចីជាន់ខ្ពស់ | ២,៥ | ២,៥ |
| អម្រឹត | កម្ចីជាន់ខ្ពស់ | ៣,០ | ៣,០ |
| អិលអូអិលស៊ី ខេមបូឌា | កម្ចីបន្ទាប់បន្សំ | ៥,០ | ៥,០ |
| អិលអូអិលស៊ី ខេមបូឌា | កម្ចីបន្ទាប់បន្សំ | ៥,០ | ៤,០ |
| **ការផ្តល់កម្ចីសរុបរបស់ MIFA ដល់ FIs កម្ពុជា** | | ១៩,៥ | ១៧,៧ |

## តារាងទី៤៖ ការផ្តល់កម្ចីរបស់ North Haven ដល់ FIs កម្ពុជា

| North Haven (គម្រោងលេខ ៣៨៦០៩) | ប្រភេទផលិតផល | ចំនួនទឹកប្រាក់ដែលបានអនុវត្ត លានដុល្លារអាមេរិក | ការផ្តល់កម្ចីដែលមិនទាន់សង លានដុល្លារអាមេរិក |
|---|---|---|---|
| ធនាគារអេស៊ីលីដា | មូលធន ៣,៥% ត្រូវបានអនុវត្តនៅខែមេសា ឆ្នាំ ២០២២ | ៤៤,៨ | ៤៤,៨ |

## ឧបសម្ព័ន្ធទី៣៖ គោលការណ៍កិច្ចការពារអតិថិជន និងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ

(ឧទាហរណ៍អំពីគោលការណ៍ដែលត្រូវបានរួមបញ្ចូលនៅក្នុងកិច្ចព្រមព្រៀងកម្ចីរបស់ IFC ជាមួយអតិថិជន FI សម្រាប់កម្ចី IFC ដើម្បីគាំទ្រដល់អាជីវកម្មមីក្រូហិរញ្ញវត្ថុរបស់ FIs)

ក្រៅពីភាពអនុលោមតាមការអនុវត្តកិច្ចការពារអ្នកប្រើប្រាស់ ដែលត្រូវបានកំណត់ដោយធនាគារកណ្តាល ឬ អង្គភាពនិយ័តកម្ម ឬត្រួតពិនិត្យ និងស្ថាប័នច្បាប់ផ្សេងទៀតនោះ អ្នកខ្ចីក៏ត្រូវធានាថា ខ្លួនមានតម្លាភាពពេញលេញក្នុងការកំណត់តម្លៃ ខ និងលក្ខខណ្ឌនៃផលិតផលហិរញ្ញវត្ថុទាំងអស់។ អ្នកខ្ចីត្រូវប្រើការអនុវត្តការប្រមូលប្រាក់ប្រកបដោយការគោរព និងប្រកាន់ខ្ជាប់នូវស្តង់ដារសីលធម៌ខ្ពស់ក្នុងការអនុវត្តចំពោះអតិថិជន។ គោលការណ៍កិច្ចការពារអតិថិជនខាងក្រោម គឺជាស្តង់ដារអប្បបរមា ដែលអ្នកខ្ចីត្រូវប្រកាន់ខ្ជាប់នៅពេលផ្តល់សេវាកម្មហិរញ្ញវត្ថុដល់អតិថិជនរបស់ខ្លួន៖

- ជៀសវាងការជំពាក់បំណុលច្រើនពេក៖ អ្នកខ្ចីនឹងចាត់វិធានការសមស្របដើម្បីធានាថា ឥណទាននឹងត្រូវបានពង្រីកលុះត្រាតែអ្នកខ្ចីបានបង្ហាញអំពីសមត្ថភាពគ្រប់គ្រាន់ក្នុងការទូទាត់សង ហើយកម្ចីនឹងមិនធ្វើឱ្យអតិថិជនមានហានិភ័យខ្ពស់នៃការជំពាក់បំណុលច្រើនពេក។ ស្រដៀងនេះដែរ អ្នកខ្ចីនឹងយកចិត្តទុកដាក់គ្រប់គ្រាន់ថា មានតែផលិតផលហិរញ្ញវត្ថុមិនមែនជាឥណទានសមរម្យ (ដូចជា ការធានារ៉ាប់រង) ប៉ុណ្ណោះ ដែលត្រូវបានពង្រីកជូនអតិថិជន។
- ការកំណត់តម្លៃប្រកបដោយតម្លាភាព និងទំនួលខុសត្រូវ៖ តម្លៃ ខ និងលក្ខខណ្ឌនៃផលិតផលហិរញ្ញវត្ថុ (រួមទាំងបន្ទុកការប្រាក់ ថ្លៃធានារ៉ាប់រង ថ្លៃសេវាទាំងអស់។ល។) នឹងមានតម្លាភាព ហើយនឹងត្រូវបានបង្ហាញយ៉ាងគ្រប់គ្រាន់ នៅក្នុងទម្រង់ដែលអតិថិជនអាចយល់បាន។ ការកំណត់តម្លៃប្រកបដោយទំនួលខុសត្រូវមានន័យថា ការកំណត់តម្លៃ ខ និងលក្ខខណ្ឌត្រូវបានកំណត់តាមវិធី ដែលមានភាពសមរម្យសម្រាប់អតិថិជន និងមាននិរន្តរភាពសម្រាប់ស្ថាប័នហិរញ្ញវត្ថុ។
- ការអនុវត្តការប្រមូលប្រាក់យ៉ាងសមស្រប៖ ការអនុវត្តនៃការប្រមូលបំណុលរបស់អ្នកខ្ចីនឹងមិនមានការបំពាន ឬបង្ខិតបង្ខំឡើយ។
- អាកប្បកិរិយារបស់បុគ្គលិកប្រកបដោយសីលធម៌៖ បុគ្គលិករបស់អ្នកខ្ចីនឹងអនុលោមតាមស្តង់ដារសីលធម៌ខ្ពស់នៅក្នុងអន្តរកម្មរបស់ពួកគេជាមួយអតិថិជន ហើយអ្នកផ្តល់សេវាទាំងនេះនឹងធានាថា មានការការពារសុវត្ថិភាពយ៉ាងគ្រប់គ្រាន់ ដើម្បីស្វែងរក និងកែតម្រូវអំពើពុករលួយ ឬការប្រព្រឹត្តិមិនសមរម្យចំពោះអតិថិជន។
- យន្តការដោះស្រាយបណ្តឹងសារទុក្ខ៖ អ្នកខ្ចីនឹងមានយន្តការឆ្លើយតបយ៉ាងទាន់ពេលវេលាចំពោះពាក្យបណ្តឹង និងការដោះស្រាយបញ្ហាជូនអតិថិជនរបស់ពួកគេ។
- ឯកជនភាពនៃទិន្នន័យអតិថិជន៖ ឯកជនភាពនៃទិន្នន័យរបស់អតិថិជនម្នាក់ៗនឹងត្រូវបានគោរព ស្របតាមច្បាប់ និងបទប្បញ្ញត្តិនៃយុត្តាធិការនីមួយៗ ហើយទិន្នន័យបែបនេះមិនត្រូវបានប្រើសម្រាប់គោលបំណងផ្សេងទៀត ដោយពុំមានការអនុញ្ញាតពីអតិថិជននោះទេ (នៅខណៈពេលដែលទទួលស្គាល់ថា អ្នកខ្ចីអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយអតិថិជនឲ្យសម្រេចបាននូវអត្ថប្រយោជន៍នៃការបង្កើតប្រវត្តិឥណទាន)។

## ការបដិសេធទំនួលខុសត្រូវ

ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC នេះត្រូវបានផ្ដល់ជូន ជាការឆ្លើយតបនឹងរបាយការណ៍វាយតម្លៃរបស់ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ស៊ីអេអូ) អំពីរបកគំហើញនៃពាក្យបណ្ដឹងចំពោះគម្រោងដែលគាំទ្រដោយហិរញ្ញវត្ថុ ឬការវិនិយោគរបស់ IFC ដែលមានលក្ខខណ្ឌសមស្របសម្រាប់ការវាយតម្លៃភាពអនុលោម។

ពុំមានចំណុចណាមួយនៅក្នុងការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC នេះ ឬនៅក្នុងដំណើរការ ដែលត្រូវបានផ្ដល់ជូននៅក្នុងគោលនយោបាយស៊ីអេអូ ("ដំណើរការស៊ីអេអូ") (១) បង្កើតកាតព្វកិច្ចតាមផ្លូវច្បាប់ (២) អះអាង ឬលះបង់សិទ្ធិចំពោះមុខតំណែងតាមផ្លូវច្បាប់ (៣) កំណត់ទំនួលខុសត្រូវតាមផ្លូវច្បាប់ ការទទួលខុសត្រូវ ឬការប្រព្រឹត្តិខុសឆ្គង (៤) បង្កើតបានជាការទទួលស្គាល់ ឬការទទួលយកកាលៈទេសៈ ឬភស្តុតាងជាក់ស្ដែងណាមួយនៃកំហុស ឬការប្រព្រឹត្តិខុសឆ្គង ឬ (៥) បង្កើតបានជាការលះបង់សិទ្ធិ បុព្វសិទ្ធិ ឬអភ័យ-ឯកសិទ្ធិណាមួយរបស់ IFC ស្របតាមមាត្រានៃកិច្ចព្រមព្រៀង អនុសញ្ញាអន្តរជាតិ ឬច្បាប់ដែលអាចអនុវត្តបានផ្សេងទៀតនោះទេ។ IFC រក្សាសិទ្ធិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងអស់។ IFC មិនបង្កើត ទទួលយក ឬបន្តកាតព្វកិច្ច ឬភារកិច្ចតាមផ្លូវច្បាប់ ឬកំណត់ ឬទទួលយកការចោទប្រកាន់ណាមួយអំពីការរំលោភលើកាតព្វកិច្ច ឬភារកិច្ចផ្លូវច្បាប់ ជាលទ្ធផលនៃការឆ្លើយតបរបស់គណៈគ្រប់គ្រងរបស់ IFC នោះទេ។

បើទោះបីជាមានកិច្ចប្រឹងប្រែងសមស្រប ដើម្បីកំណត់ថាព័ត៌មានដែលមាននៅក្នុងការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC នេះ មានភាពត្រឹមត្រូវក៏ដោយ ប៉ុន្តែពុំមានការបញ្ជាក់អះអាង ឬការធានាណាមួយត្រូវបានផ្ដល់ជូនចំពោះភាពត្រឹមត្រូវ ឬភាពពេញលេញនៃព័ត៌មានទាំងនោះទេ។ ស៊ីអេអូមិនមែនជាយន្តការតុលាការ ឬយន្តការអនុវត្តច្បាប់នោះទេ។ ការវិភាគ ការសន្និដ្ឋាន និងរបាយការណ៍របស់ស៊ីអេអូ ពុំមានបំណងយកទៅប្រើប្រាស់នៅក្នុងនីតិវិធីតុលាការ ឬនិយ័តកម្ម ឬដើម្បីបញ្ជាក់អំពីកំហុស ឬទំនួលខុសត្រូវតាមផ្លូវច្បាប់នោះទេ ហើយស៊ីអេអូ ក៏មិនចូលរួមក្នុងការស្វែងរកអង្គហេតុ ឬកំណត់ទម្ងន់ ដែលគួរតែមាន ចំពោះភស្តុតាង ឬព័ត៌មានណាមួយនោះដែរ។ គ្មានផ្នែកណាមួយនៃការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC នេះ ឬដំណើរការស៊ីអេអូ អាចត្រូវបានប្រើប្រាស់ ឬបញ្ជូនទៅកាន់ដំណើរការតុលាការ អាជ្ញាកណ្ដាល និយ័តកម្ម ឬដំណើរការផ្សេងទៀតដោយពុំមានការយល់ព្រមជាលាយលក្ខណ៍អក្សរច្បាស់លាស់ពី IFC ឡើយ។

## ឧបសម្ព័ន្ធទី ៦៖ ការពិចារណាអំពីគោលនយោបាយស៊ីអេអូចំពោះការវាយតម្លៃភាពអនុលោម

គោលនយោបាយស៊ីអេអូ[127] ចែងអំពីការវាយតម្លៃភាពអនុលោមដោយរួមបញ្ចូលការពិចារណាបន្ថែមទៀត ដូចបានគូសបញ្ជាក់នៅក្នុងតារាងខាងក្រោម។

| បញ្ញត្តិនៃគោលនយោបាយស៊ីអេអូ | ការវិភាគចំពោះសំណុំរឿងនេះ |
| --- | --- |
| ចំពោះគម្រោង ឬអនុគម្រោងណាមួយ ដែលការចាកចេញរបស់ IFC/MIGA បានកើតឡើងនៅពេលដែលស៊ីអេអូបានបញ្ចប់ការវាយតម្លៃអំពីភាពអនុលោមរបស់ខ្លួន ថាតើការស៊ើបអង្កេតនឹងផ្តល់គុណតម្លៃជាក់លាក់ទាក់ទងនឹងគណនេយ្យភាព ការរៀនសូត្រ និងវិធានការដោះស្រាយដែរឬទេ ទោះបីជាមានការចាកចេញរបស់ IFC/MIGA ក៏ដោយ (កថាខណ្ឌទី ៩២ក) | ស៊ីអេអូបានសន្និដ្ឋានថា ការស៊ើបអង្កេតភាពអនុលោមដែលរួមបញ្ចូលការវិនិយោគដែលបានចាកចេញទាំងបីនៅក្នុងសំណុំរឿងនេះ បន្ថែមពីលើគម្រោងដែលមានភាពសកម្មនឹងផ្តល់គុណតម្លៃជាក់លាក់ ទាក់ទងនឹងគណនេយ្យភាព ការរៀនសូត្រ និងវិធានការដោះស្រាយ។ ស្រដៀងគ្នានេះដែរ ស្របតាមគោលបំណងរបស់ពួកគេ និងការប្រើប្រាស់ប្រាក់ចំណូលសម្រាប់ការវិនិយោគសកម្មនៅអម្រឹត និងធនាគារ ហត្ថា ការវិនិយោគដែលបានចាកចេញទាំងបីនេះគ្របដណ្តប់លើរយៈពេលខុសៗគ្នា ច្រើនជាងការវិនិយោគដែលមានភាពសកម្មនាពេលបច្ចុប្បន្ន។ ការរួមបញ្ចូលគម្រោងដែលបានចាកចេញទាំងបីនេះនឹងធ្វើឱ្យមានការយល់ដឹងអំពីការអនុវត្តរបស់ IFC ដែលកំពុងតែមានការវិវត្ត នៅក្នុងវិស័យនេះ ធៀបនឹង GIIP ក្នុងរយៈពេលវែង ដែលអាចផ្តល់គណនេយ្យភាពកាន់តែល្អប្រសើរ និងលទ្ធភាពនៃការរៀនសូត្រសម្រាប់ IFC។ លើសពីនេះទៀត ការរួមបញ្ចូលការវិនិយោគដែលបានចាកចេញ នៅក្នុងការស៊ើបអង្កេតនេះអាចពង្រីកឱកាស ក្នុងការទទួលបានវិធានការដោះស្រាយសម្រាប់អតិថិជនបន្ត ដែលអាចបានរងគ្រោះថ្នាក់ ក្នុងអំឡុងពេលដែលគម្រោងដែលបានចាកចេញនោះ មានភាពសកម្ម។ |
| ភាពពាក់ព័ន្ធនៃនីតិវិធីតុលាការ ឬក្រៅតុលាការ ដែលបានធ្វើសេចក្តីសន្និដ្ឋាន រង់ចាំសេចក្តីសម្រេច ឬកំពុងដំណើរការទាក់ទងនឹងប្រធានបទនៃពាក្យបណ្តឹង (កថាខណ្ឌ ៩២ខ) | មានពាក់ព័ន្ធ |
| ថាតើគណៈគ្រប់គ្រងបានបង្ហាញយ៉ាងច្បាស់ថា ខ្លួនបានដោះស្រាយបញ្ហា ដែលបានលើកឡើងដោយដើមបណ្តឹង ឬនៅក្នុងសំណើផ្ទៃក្នុងបានយ៉ាងសមស្របដែរឬទេ និងបានអនុវត្តតាមគោលនយោបាយ E&S ដែរឬទេ ឬថាតើ | ដូចបានគូសបញ្ជាក់នៅក្នុងតួសេចក្តីនៃរបាយការណ៍នេះ ស៊ីអេអូរកឃើញការចង្អុលបង្ហាញជាបឋមអំពីបដិលោមភាព។ ស៊ីអេអូសន្និដ្ឋានថា IFC មិនបានបង្ហាញយ៉ាងច្បាស់ថា ខ្លួនបានដោះស្រាយបញ្ហាដែលបានលើកឡើងដោយដើមបណ្តឹង |

[127] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ៩២.

| | |
|---|---|
| គណៈគ្រប់គ្រងបានទទួលស្គាល់ថា ខ្លួនមិនបានអនុលោមតាមគោលនយោបាយ E&S ដែលពាក់ព័ន្ធ (កថាខណ្ឌ ៩២គ) ដែរឬទេ។ | នៅកម្រិតគម្រោងនីមួយៗបានយ៉ាងសមស្របនោះទេ ហើយ IFC ក៏មិនទទួលស្គាល់អំពីភាពបដិលោមតាមគោលនយោបាយ E&S ដែលពាក់ព័ន្ធដែរ។ |
| ថាតើគណៈគ្រប់គ្រងបានផ្តល់សេចក្តីថ្លែងការណ៍អំពីវិធានការដោះស្រាយជាក់លាក់មួយដែរឬទេ និងថាតើនៅក្នុងការវិនិច្ឆ័យរបស់ស៊ីអេអូ បន្ទាប់ពីបានពិចារណាលើទស្សនៈរបស់ដើមបណ្តឹង វិធានការដោះស្រាយដែលបានស្នើឡើងទាំងនេះ ដោះស្រាយបញ្ហាដែលបានលើកឡើងដោយដើមបណ្តឹងបានយ៉ាងល្អដែរឬទេ (កថាខណ្ឌទី ៩២ឃ)។ | គណៈគ្រប់គ្រង បានស្នើបណ្តុំអភិក្រម និងសកម្មភាព ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងនេះនៅកម្រិតគម្រោង វិស័យ និងនិយ័តកម្ម (សូមមើលឧបសម្ព័ន្ធទី៥)។ ទោះបីជាយ៉ាងណាក៏ដោយ ស៊ីអេអូសន្និដ្ឋានថា សកម្មភាពដែលបានស្នើឡើងទាំងនេះមិនបង្កើតបានជាសេចក្តីថ្លែងការណ៍អំពីវិធានការដោះស្រាយនោះទេ ហើយក៏មិនដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងបានយ៉ាងល្អដែរ ពីព្រោះគណៈគ្រប់គ្រង IFC មិនបានចាត់ទុកថាបញ្ហាទាំងនេះស្ថិតនៅក្នុងវិសាលភាពនៃគោលនយោបាយ E&S របស់ខ្លួននោះទេ។ នៅក្នុងដំណើរការភាពអនុលោមរបស់ស៊ីអេអូ ការដោះស្រាយឆ្លើយតបនឹងគ្រោះថ្នាក់ដែលបានបង្កើតឡើង ឬរួមចំណែកដោយភាពបដិលោមតាមគោលនយោបាយ E&S។ IFC បង្ហាញសកម្មភាពដែលខ្លួនបានស្នើឡើងថា មានឯករាជ្យភាពពីដំណើរការភាពអនុលោមរបស់ស៊ីអេអូ និងកាតព្វកិច្ចរបស់ IFC ក្រោមក្របខណ្ឌនិរន្តរភាព។ លើសពីនេះទៀត ពុំមានសកម្មភាពណាមួយក្នុងចំណោមសកម្មភាពទាំងនេះ ដោះស្រាយបញ្ហាសំខាន់ ដែលបានលើកឡើងដោយដើមបណ្តឹង អំពីកង្វះខាតការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន និងការត្រួតពិនិត្យ E&S ឲ្យបានត្រឹមត្រូវដោយ IFC លើការវិនិយោគមីក្រូហិរញ្ញវត្ថុរបស់ខ្លួន ទាក់ទងនឹងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងគោលការណ៍ការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនោះទេ។ |
| ទាក់ទងនឹងគម្រោង ឬអនុគម្រោង ដែលជាកម្មវត្ថុនៃការស៊ើបអង្កេតភាពអនុលោម ស៊ីអេអូអាច (ក) បិទពាក្យបណ្តឹង (ខ) រួមបញ្ចូលពាក្យបណ្តឹងជាមួយដំណើរការភាពអនុលោមកាលពីមុន ប្រសិនបើនៅតែបើកចំហ ហើយពាក្យបណ្តឹងគឺពាក់ព័ន្ធយ៉ាងខ្លាំងនឹងបញ្ហាតែមួយនឹងដំណើរការភាពអនុលោមកាលពីមុននោះ ឬ (គ) ចាប់ផ្តើមការស៊ើបអង្កេតភាពអនុលោមថ្មីមួយ តែនៅពេលដែលពាក្យបណ្តឹងលើកឡើងអំពីបញ្ហាថ្មីៗ ឬមានភស្តុតាងថ្មីៗតែប៉ុណ្ណោះ (កថាខណ្ឌទី ៩៣)។ | មិនពាក់ព័ន្ធ |

## ឧបសម្ព័ន្ធទី៧៖ លក្ខខណ្ឌយោងនៃការស៊ើបអង្កេត

---

**លក្ខខណ្ឌយោងនៃការស៊ើបអង្កេតភាពអនុលោមតាមសមិទ្ធកម្មបរិស្ថាន និងសង្គមរបស់ IFC ពាក់ព័ន្ធនឹងការផ្តល់កម្ចីដល់គ្រឹះស្ថានហិរញ្ញវត្ថុចំនួនប្រាំមួយនៅកម្ពុជា (អេស៊ីលីដា អម្រឹត ធនាគារ ហត្ថាប្រាសាក់ អិលអូអិលស៊ី និងស្ថាបនា)**

*គម្រោង IFC លេខ ២១៨៥៦ ២៧៨២៧ ៣១៤៦៧ ៣៤៧៤៨ ៣៨៦០៩ ៣៩១៦៧ ៤១២៩៤ ៤២៤៨០ ៤៤២១១ ៤៤២៣១ ៤៤៧៤២ ៤៤៨៨២ ៤៥៥៣៥*

---

### អំពីស៊ីអេអូ

ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ស៊ីអេអូ) គឺជាយន្តការគណនេយ្យភាពឯករាជ្យរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និង ទីភ្នាក់ងារធានាការវិនិយោគពហុភាគី (MIGA) ដែលជាសមាជិកក្រុមធនាគារពិភពលោក។ យើងធ្វើការសម្របសម្រួលដោះស្រាយបណ្តឹងពីប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ពីគម្រោងរបស់ IFC និង MIGA ដោយយុត្តិធម៌ ឥតលម្អៀង និងប្រកបដោយភាពស្ថាបនា លើកកម្ពស់លទ្ធផលផ្នែកបរិស្ថាន និងសង្គមនៃគម្រោងទាំងនោះ និងបង្កើនគណនេយ្យភាពសាធារណៈ និង ការរៀនសូត្រនៅ IFC និង MIGA។

ស៊ីអេអូ គឺជាការិយាល័យឯករាជ្យ ដែលរាយការណ៍ទៅកាន់ក្រុមប្រឹក្សានាយកប្រតិបត្តិការរបស់ IFC និង MIGA ដោយផ្ទាល់។ សម្រាប់ព័ត៌មានបន្ថែម សូមមើល៖ www.cao-ombudsman.org។

### អំពីមុខងារភាពអនុលោម

មុខងារភាពអនុលោមរបស់ស៊ីអេអូ ត្រួតពិនិត្យឡើងវិញលើភាពអនុលោមរបស់ IFC និង MIGA ចំពោះគោលនយោបាយបរិស្ថាន និងសង្គម វាយតម្លៃលើគ្រោះថ្នាក់ដែលពាក់ព័ន្ធ និងផ្តល់អនុសាសន៍អំពីវិធានការដោះស្រាយដែលសមស្រប។

មុខងារអនុលោមភាពរបស់ស៊ីអេអូអនុវត្តតាមអភិក្រមបីជំហាន៖

| ការវាយតម្លៃ | ការស៊ើបអង្កេត | ការពិនិត្យតាមដាន |
|---|---|---|
| ត្រួតពិនិត្យជាបឋម ដើម្បីកំណត់ថា តើពាក្យបណ្ដឹង ឬសំណើផ្ទៃក្នុង ចាំបាច់ត្រូវធ្វើការស៊ើបអង្កេតភាពអនុលោមដែរឬទេ។ | ការកំណត់ជាប្រព័ន្ធ និងប្រកបដោយភាពអព្យាក្រឹត្យ ថាតើ IFC/MIGA បានអនុលោមតាមគោលនយោបាយបរិស្ថាន និងសង្គមរបស់ខ្លួនដែរឬទេ និងថាតើមានគ្រោះថ្នាក់ ពាក់ព័ន្ធនឹងបដិលោមភាពណាមួយដែរឬទេ។ | ការផ្ទៀងផ្ទាត់អំពីការអនុវត្តវិធានការគ្រប់គ្រង ដែលត្រូវបានបង្កើតឡើង ឆ្លើយតបនឹងរបកគំហើញ និងអនុសាសន៍ពីការស៊ើបអង្កេតអំពីភាពអនុលោម ប្រកបដោយប្រសិទ្ធភាព។ |

## បរិបទ និងការវិនិយោគ

ការជំពាក់បំណុលច្រើនពេក នៅក្នុងចំណោមប្រជាជនក្រីក្រ និងងាយរងគ្រោះនៅកម្ពុជា គឺជាកង្វល់អន្តរជាតិដែលកំពុងកើនឡើង ដែលលើកឡើងដោយធនាគារពិភពលោក IFC និងទីភ្នាក់ងារអង្គការសហប្រជាជាតិជាច្រើនទៀត [128] រួមជាមួយក្របខណ្ឌការពារអ្នកប្រើប្រាស់ដែលមានភាពទន់ខ្សោយ ស្ថានភាពនេះមានផលអវិជ្ជមានដល់សង្គម ដែលប៉ះពាល់ដល់កម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាជាច្រើននាក់។[129]

ក្រុមធនាគារពិភពលោកបានផ្ដល់ការគាំទ្រយ៉ាងទូលំទូលាយដល់វិស័យហិរញ្ញវត្ថុកម្ពុជា តាមរយៈជំនួយបច្ចេកទេស និងការវិនិយោគផ្ទាល់ ជាពិសេសចំពោះការផ្ដល់មីក្រូហិរញ្ញវត្ថុ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ។ IFC បានធ្វើការវិនិយោគជាច្រើននៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើន។ ពាក់ព័ន្ធសំណុំរឿងនេះ IFC មានការវិនិយោគផ្ទាល់នៅអេស៊ីលីដា, អម្រឹត និង ធនាគារ ហត្ថា ព្រមទាំងការផ្ដល់កម្ចីហិរញ្ញវត្ថុដោយប្រយោលដល់ប្រាសាក់, អិលអូលអិលស៊ី និងស្ថាបនា តាមរយៈការវិនិយោគនៅក្នុងឥណទានពង្រឹងមីក្រូហិរញ្ញវត្ថុ (MEF), មូលនិធិគំនិតផ្ដួចផ្ដើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុលអាស៊ី (MIFA), ក្រុមហ៊ុន North Haven Thai (ក្រុមហ៊ុនមូលធនឯកជន) និង Advans S.A. (ក្រុមហ៊ុនមេរបស់អម្រឹត)។ ជារួម សំណុំរឿងនេះជាប់ពាក់ព័ន្ធនឹងគម្រោងរបស់ IFC ចំនួន ១៣ គម្រោង ដែលគាំទ្រកម្មវិធីផ្ដល់ដល់សហគ្រាសធុនមីក្រូ ធុនតូច និងមធ្យម (MSME) ដែល

[128] ប្រភពនានានៅក្នុងតួសេចក្ដីនៃរបាយការណ៍។ សូមមើលជើងទំព័រទី ២៧ ដល់ ៣៤។

[129] របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស របាយការណ៍ប្រចាំឆ្នាំរបស់ OHCHR តួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សក្នុងការជួយរដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០២២, A/HRC/51/63, កថាខណ្ឌ ៤២។ របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស តួនាទី និងសមិទ្ធិផលរបស់ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយរដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១, A /HRC/48/49 កថាខណ្ឌ ៤០។ របាយការណ៍អ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិស្ដីពីបំណុលឯកជន និងសិទ្ធិមនុស្ស របាយការណ៍របស់អ្នកជំនាញឯករាជ្យស្ដីពីផលប៉ះពាល់នៃបំណុលបរទេស និងកាតព្វកិច្ចហិរញ្ញវត្ថុអន្តរជាតិពាក់ព័ន្ធផ្សេងទៀតរបស់រដ្ឋស្ដីពីការទទួលបានសិទ្ធិពេញលេញនៃសិទ្ធិមនុស្ស ជាពិសេសសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ឆ្នាំ ២០២០)។ A/HRC/43/45 នៅ ទំព័រ ១ និងកថាខណ្ឌ ៣២–៣៤។ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សេចក្ដីសន្និដ្ឋានបញ្ចប់លើរបាយការណ៍ខួបលើកទីពីររបស់កម្ពុជា ថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០២៣ E/C.12/KHM/CO/2 កថាខណ្ឌ ៣៨ និង ៣៩(ខ)។

មានភាពសកម្ម នៅពេលដែលពាក្យបណ្តឹងនេះត្រូវបានដាក់ជូនស៊ីអេអូ និងដែលភ្ជាប់ទំនាក់ទំនង IFC និងគ្រឹះស្ថានហិរញ្ញវត្ថុទាំងប្រាំមួយនេះ នៅក្នុងប្រទេសកម្ពុជា។

**ពាក្យបណ្តឹង**

នៅខែកុម្ភៈ ឆ្នាំ២០២២ ស៊ីអេអូបានទទួលពាក្យបណ្តឹង ទាក់ទងនឹងការអនុវត្តក្នុងការផ្តល់កម្ចី និងការប្រមូលប្រាក់របស់អេស៊ីលីដា អម្រឹត ធនាគារ ហត្ថា អិលអូអិលស៊ី ប្រាសាក់ និង ធនាគារ ស្ថាបនា នៅក្នុងប្រទេសកម្ពុជា។ ដើមបណ្តឹងចោទប្រកាន់ថា IFC បានបរាជ័យម្តងហើយម្តងទៀតក្នុងការអនុវត្តការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នផ្នែកបរិស្ថាន និងសង្គម (E&S) និងការត្រួតពិនិត្យអតិថិជនរបស់ខ្លួន ដែលជាអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុ ឱ្យបានគ្រប់គ្រាន់។ ពួកគេចោទប្រកាន់ថា ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) របស់អតិថិជន "មានភាពមិនគ្រប់គ្រាន់យ៉ាងច្បាស់ ក្នុងការដោះស្រាយការអនុវត្តកម្ចីដ៏ឃោឃៅ និងមានការបោកប្រាស់ ការផ្តល់កម្ចីដោយគ្មានទំនួលខុសត្រូវ [...] និងការបង្ខិតបង្ខំ និងការគំរាមកំហែងពីមន្ត្រីឥណទាន" ដែលជាការអនុវត្តទូទៅនៅប្រទេសកម្ពុជា។

ជាពិសេស ដើមបណ្តឹងចោទប្រកាន់ថា ពួកគេបានបាត់បង់ដីធ្លី និងមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ ដោយសារអ្នកផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុតែងតែស្នើសុំឱ្យពួកគេដាក់ដីធ្លីរបស់ពួកគេជាវត្ថុបញ្ចាំ ដើម្បីទទួលបានការអនុម័តលើកម្ចី រួមទាំងដីសហគមន៍ជនជាតិដើមភាគតិចផងដែរ បន្ទាប់មក បង្ខំឲ្យពួកគេលក់ដីធ្លីមុនពេលកំណត់ ដើម្បីប្រមូលប្រាក់។ លើសពីនេះទៀត ដើម្បីសងបំណុលដែលកើនឡើង ពួកគេក៏បានលក់ប្រភពចំណូលដទៃទៀត ដូចជាឧបករណ៍នានា កាត់បន្ថយការទទួលទានអាហារ បញ្ឈប់កូនពីសាលារៀន និងត្រូវបានបង្ខំឱ្យធ្វើចំណាកស្រុកដើម្បីទៅធ្វើការ។ ដើមបណ្តឹងបញ្ជាក់ថា IFC បានដឹងអំពីព័ត៌មានដែលមានជាសាធារណៈ ទាក់ទងនឹងគ្រោះថ្នាក់ដល់សង្គមយ៉ាងទូលំទូលាយ និងការការពារអ្នកប្រើប្រាស់មិនបានគ្រប់គ្រាន់ នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុរបស់កម្ពុជា ប៉ុន្តែបានបន្តអនុម័តការផ្តល់ហិរញ្ញប្បទានបន្ថែមទៀតនៅក្នុងវិស័យនេះ ដោយពុំមានលក្ខខណ្ឌតម្រូវបន្ថែមនោះទេ។ ពួកគេផ្តល់ទឡ្ហីករណ៍ថា IFC មិនបានត្រួតពិនិត្យឱ្យបានត្រឹមត្រូវលើសកម្មភាពអាជីវកម្មរបស់អតិថិជនមីក្រូហិរញ្ញវត្ថុរបស់ខ្លួននោះទេ ដោយផ្អែកលើហេតុផលថា អ្នកផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុមិនត្រូវបានតម្រូវឱ្យត្រួតពិនិត្យសកម្មភាពផ្តល់កម្ចីរបស់ពួកគេ សម្រាប់ហានិភ័យ E&S នោះទេ និងបណ្តាលឱ្យមានគ្រោះថ្នាក់ដល់អ្នកខ្ចី។ ពួកគេចាត់ទុកថា ចំណុចនេះមានសារសំខាន់ជាពិសេស ដោយសារអ្នកខ្ចីមីក្រូហិរញ្ញវត្ថុទំនងជាផ្នែកមួយនៃប្រជាជនដែលងាយរងគ្រោះ ដូច្នេះហើយ ទាមទារឲ្យមានការការពារ និងការត្រួតពិនិត្យបន្ថែមទៀតដើម្បីធានាថាគម្រោង IFC ពុំមានផលប៉ះពាល់ដែលបង្កគ្រោះថ្នាក់ដល់សង្គម។

ដើមបណ្តឹងក៏បានបង្ហាញអំពីភាពភ័យខ្លាចការសងសឹង ចំពោះការនិយាយប្រឆាំងនឹងឧស្សាហកម្មមីក្រូហិរញ្ញវត្ថុផងដែរ និងបានស្នើសុំឲ្យស៊ីអេអូរក្សាអត្តសញ្ញាណរបស់ពួកគេជាការសម្ងាត់។

## លក្ខខណ្ឌយោងនៃការស៊ើបអង្កេត[130]

នៅក្នុងសំណុំរឿងបច្ចុប្បន្ន ប្រសិនបើដំណើរការវាយតម្លៃរបស់ស៊ីអេអូ នាំឱ្យមានការសម្រេចចិត្តធ្វើការស៊ើបអង្កេតនោះ របាយការណ៍វាយតម្លៃរបស់ស៊ីអេអូ រួមបញ្ចូលលក្ខខណ្ឌយោងសម្រាប់ការស៊ើបអង្កេតភាពអនុលោម ដូចបានគូសបញ្ជាក់នៅខាងក្រោម៖

*ក. វត្ថុបំណង និងវិសាលភាពនៃការស៊ើបអង្កេត*

*ខ. ដែនកំណត់ណាមួយលើវិសាលភាពនៃការស៊ើបអង្កេត ដែលអាចមានភាពសមស្រប ដោយពិចារណាលើបញ្ហាផ្សេងទៀត ដែលបានបិទនៅដំណាក់កាលវាយតម្លៃ វត្តមាននៃនីតិវិធីតុលាការក្នុងពេលតែមួយឬការចាកចេញរបស់ IFC/MIGA*

*គ. អភិក្រម និងវិធីសាស្ត្រនៃការស៊ើបអង្កេត និងលក្ខណៈសម្បត្តិទីប្រឹក្សាជាក់លាក់ និង*

*ឃ. កាលវិភាគសម្រាប់កិច្ចការស៊ើបអង្កេត ពេលវេលា និងលក្ខខណ្ឌតម្រូវក្នុងការរាយការណ៍។ កាលវិភាគនេះនឹងរួមបញ្ចូលកាលកំណត់សម្រាប់ការផ្តល់ព័ត៌មានដោយ IFC/MIGA ដើម្បីជូនដំណឹងអំពីដំណើរការស៊ើបអង្កេតភាពអនុលោម។[131]*

## វត្ថុបំណង និងវិសាលភាពនៃការស៊ើបអង្កេត

ដូចមានចែងនៅក្នុងរបាយការណ៍វាយតម្លៃភាពអនុលោម ដែលពាក់ព័ន្ធនឹងពាក្យបណ្តឹង ស៊ីអេអូនឹងធ្វើការស៊ើបអង្កេតភាពអនុលោមនៃការវិនិយោគរបស់ IFC នៅអេស៊ីលីដា, អម្រឹត, ធនាគារ ហត្ថា, Advans, North Haven Thai, MEF និង MIFA និងការវិនិយោគដោយប្រយោលនៅប្រាសាក់ អិលអូអិលស៊ី និងស្ថាបនា តាមរយៈ MEF និង MIFA។ ការស៊ើបអង្កេតនឹងកំណត់ថាតើ IFC បានអនុលោមតាមគោលនយោបាយ E&S របស់ខ្លួន ដែលពាក់ព័ន្ធនឹងការវិនិយោគដែរឬទេ និងថាតើមានគ្រោះថ្នាក់ ដែលទាក់ទងនឹងភាពបដិលោមរបស់ IFC ដែរឬទេ។ នៅក្នុងការកំណត់ថាតើ IFC បានអនុលោមតាមគោលនយោបាយ E&S របស់ខ្លួនដែរឬទេនោះ ស៊ីអេអូនឹងរួមបញ្ចូល ប្រសិនបើសមស្រប ការវាយតម្លៃថាតើ IFC បានបង្វែរទិសដៅយ៉ាងសំខាន់ ពីការណែនាំ និងនីតិវិធីដែលពាក់ព័ន្ធដែរឬទេ។

ពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង វត្ថុបំណងនៃការស៊ើបអង្កេតនឹងកំណត់៖

១ ថាតើ IFC បានអនុលោមតាមគោលនយោបាយ E&S របស់ខ្លួនដែរឬទេ ដែលរួមមាន៖

ក. ថាតើ IFC បានធ្វើការត្រួតពិនិត្យ E&S មុនពេលវិនិយោគ លើការវិនិយោគរបស់ខ្លួននៅអេស៊ីលីដា, អម្រឹត, ធនាគារ ហត្ថា, Advans, North Haven Thai, MEF និង MIFA ដូចបានតម្រូវដោយគោលនយោបាយនិរន្តរភាព ដែលសមស្របនឹងហានិភ័យ និងផលប៉ះពាល់នៃការវិនិយោគទាំងនេះលើអ្នកខ្ចី MSME ដែរឬទេ (អតិថិជនបន្តនៅក្នុងការវិនិយោគទាំងនេះ) និង

---

[130] អនុវត្តតាមកថាខណ្ឌទី ១១៩ នៃគោលនយោបាយស៊ីអេអូ ស៊ីអេអូបានប្រឹក្សាយោបល់ជាមួយ IFC ក្នុងការរៀបចំ TOR ទាំងនេះ.

[131] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី១១៨.

ខ. ថាតើ IFC បានដាក់ចេញនូវបញ្ញត្តិនៃកិច្ចសន្យា ដែលតម្រូវឱ្យអតិថិជនរបស់ខ្លួន ដែលមានឈ្មោះខាងលើ បំពេញតាមច្បាប់ជាតិកម្ពុជា បញ្ជីផាត់ចេញរបស់ IFC និងស្តង់ដារសមិទ្ធកម្មរបស់ IFC ដែលពាក់ព័ន្ធនឹងការវិនិយោគនីមួយៗ ទាក់ទងនឹងហានិភ័យ និងផលប៉ះពាល់លើអ្នកខ្ចី MSME ដែរឬទេ និង

គ. ថាតើ IFC បានត្រួតពិនិត្យការវិនិយោគរបស់ខ្លួននៅអេស៊ីលីដា, អម្រឹត, ធនាគារ ហត្ថា, Advans, North Haven Thai, MEF និង MIFA ដើម្បីធានាថា ពួកគេអនុលោមតាមលក្ខខណ្ឌតម្រូវនៃគោលនយោបាយនិរន្តរភាព ស្តង់ដារសមិទ្ធកម្ម បញ្ជីផាត់ចេញរបស់ IFC និងច្បាប់ជាតិដែលពាក់ព័ន្ធចំពោះការវិនិយោគនីមួយៗ ទាក់ទងនឹងហានិភ័យ និងផលប៉ះពាល់លើអ្នកខ្ចី MSME ដែរឬទេ។

២ ថាតើគ្រោះថ្នាក់ និងគ្រោះថ្នាក់ដែលអាចកើតឡើង ដែលបានលើកឡើងដោយដើមបណ្តឹង មានទំនាក់ទំនងនឹងភាពបដិលោមរបស់ IFC ដែរឬទេ។[132]

ដោយពិចារណាលើរបកគំហើញ ទាក់ទងនឹងគ្រោះថ្នាក់ និងថាតើមានគ្រោះថ្នាក់ណាមួយ ទាក់ទងនឹងភាពបដិលោមរបស់ IFC ដែរឬទេនោះ ស៊ីអេអូនឹងវាយតម្លៃលើការត្រួតពិនិត្យឡើងវិញ និងការត្រួតពិនិត្យរបស់ IFC លើលក្ខខណ្ឌតម្រូវ E&S របស់ខ្លួន ស្របតាមគោលនយោបាយនិរន្តរភាព និងគោលនយោបាយសិទ្ធិទទួលបានព័ត៌មាន។ ស៊ីអេអូនឹងពិចារណាលើសមិទ្ធកម្ម E&S របស់គម្រោង រួមទាំងទំនាក់ទំនងនឹងការអនុវត្តស្តង់ដារសមិទ្ធកម្មទី១ (ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម) ស្តង់ដារសមិទ្ធកម្មទី៧ (ជនជាតិដើមភាគតិច) និងបញ្ជីផាត់ចេញ ដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង។

## អភិក្រមនៃវិធីសាស្ត្រ

ស៊ីអេអូនឹងផ្អែកការស៊ើបអង្កេតភាពអនុលោមលើបទសម្ភាសន៍ សេចក្តីថ្លែងការណ៍ របាយការណ៍ ការឆ្លើយឆ្លង ការសង្កេតមើលសកម្មភាព និងលក្ខខណ្ឌរបស់ស៊ីអេអូ និងប្រភពដទៃទៀត ដែលស៊ីអេអូយល់ថាពាក់ព័ន្ធ។[133]

ដំណើរការស៊ើបអង្កេតភាពអនុលោម និងរបាយការណ៍ស៊ើបអង្កេតអំពីភាពអនុលោម នឹងរួមបញ្ចូលៈ

*ក. របកគំហើញនៃការស៊ើបអង្កេត ទាក់ទងនឹងភាពអនុលោម ភាពបដិលោម និងគ្រោះថ្នាក់ណាមួយដែលពាក់ព័ន្ធ*

*ខ. បរិបទ ភស្តុតាង និងការលើកហេតុផល ដើម្បីគាំទ្រដល់របកគំហើញ និងសេចក្តីសន្និដ្ឋានរបស់ស៊ីអេអូ ទាក់ទងនឹងមូលហេតុឫសគល់នៃភាពបដិលោម ដែលបានកំណត់។*

អនុសាសន៍សម្រាប់ IFC/MIGA ធ្វើការពិចារណា ក្នុងការបង្កើតផែនការសកម្មភាពគ្រប់គ្រង (MAP) ទាក់ទងនឹងការដោះស្រាយភាពបដិលោមនៅកម្រិតគម្រោង ឬអនុគម្រោង និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ និង/ឬជំហាន

[132] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ១១២-១១៤

[133] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ១១៥ និង ១១៧

ដែលចាំបាច់ ដើម្បីទប់ស្កាត់ភាពបដិលោមនាពេលអនាគត ដែលពាក់ព័ន្ធ នៅក្នុងកាលៈទេសៈនេះ។ ក្នុងករណីគម្រោង ដែលការចាកចេញរបស់ IFC/MIGA បានកើតឡើង អនុសាសន៍នឹងគិតគូរអំពីទំនាក់ទំនងនៃការចាកចេញរបស់ IFC/MIGA នោះ។[134]

ភស្តុតាងដែលពាក់ព័ន្ធគ្រប់គ្រាន់ ត្រូវបានតម្រូវដើម្បីផ្តល់មូលដ្ឋានសមហេតុផលសម្រាប់របកគំហើញ និងសេចក្តីសន្និដ្ឋានអំពីភាពអនុលោមរបស់ស៊ីអេអូ។ ស៊ីអេអូនឹងវាយតម្លៃថាតើមានភស្តុតាងដែល IFC បានអនុវត្តលក្ខខណ្ឌតម្រូវ E&S ដែលពាក់ព័ន្ធដែរឬទេ ដោយពិចារណាលើប្រភពព័ត៌មានដែលមាននៅពេលធ្វើការសម្រេចចិត្ត ហើយនឹងបង្កើតរបកគំហើញ និងការសន្និដ្ឋាន ដោយមានអត្ថប្រយោជន៍ដែលមិនអាចដឹងជាមុននោះទេ។[135]

## អ្នកជំនាញខាងក្រៅ

ដោយអនុវត្តតាមការអនុវត្តដែលបានចែង ស៊ីអេអូនឹងរួមបញ្ចូលអ្នកជំនាញខាងក្រៅម្នាក់ ឬច្រើននាក់ នៅក្នុងការស៊ើបអង្កេតនេះ និងពិចារណាលើលក្ខណៈសម្បត្តិដូចខាងក្រោម តាមភាពចាំបាច់៖

- ជំនាញ និងបទពិសោធន៍សំខាន់ៗក្នុងការវិនិយោគមីក្រូហិរញ្ញវត្ថុ ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងស្តង់ដារការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ
- ជំនាញសំខាន់លើសិទ្ធិដីធ្លី និងបញ្ហាដីធ្លីរបស់ជនជាតិដើមភាគតិចនៅកម្ពុជា
- ជំនាញសំខាន់ក្នុងការវាយតម្លៃសេដ្ឋកិច្ចសង្គម
- ចំណេះដឹងអំពីក្រុមជាតិពន្ធុ និងជនជាតិដើមភាគតិចនៅកម្ពុជា
- ចំណេះដឹងអំពីក្របខណ្ឌនិយ័តកម្ម ការអនុវត្ត និងនីតិវិធីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា
- ចំណេះដឹងអំពីគោលនយោបាយ E&S ស្តង់ដារ និងនីតិវិធីរបស់ IFC ជាពិសេសគោលនយោបាយនិរន្តរភាព ស្តង់ដារសមិទ្ធកម្មទី១ (ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម) ស្តង់ដារសមិទ្ធកម្មទី៧ (ជនជាតិដើមភាគតិច) បញ្ជីផាត់ចេញរបស់ IFC និងគោលនយោបាយសិទ្ធិទទួលបានព័ត៌មាន
- បទពិសោធន៍ និងចំណេះដឹង ពាក់ព័ន្ធនឹងការស៊ើបអង្កេតអំពីភាពអនុលោម
- មានបទពិសោធន៍ក្នុងការគ្រប់គ្រង ដោះស្រាយ និងពិចារណាអំពីហានិភ័យនៃការគំរាមកំហែង និងការសងសឹកចំពោះដើមបណ្តឹង
- បង្ហាញសមត្ថភាពក្នុងការវិភាគគោលនយោបាយ និងការអនុវត្ត និងបង្កើតសំណើសម្រាប់កំណែទម្រង់នៅក្នុងបរិបទស្ថាប័នស្មុគស្មាញ និង
- ចេះភាសាខ្មែរ និងអង់គ្លេសស្ទាត់ជំនាញ។

[134] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ១២០

[135] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ១១៦-១១៧

## ការចុះត្រួតពិនិត្យ

ការចុះត្រួតពិនិត្យសហគមន៍របស់ដើមបណ្តឹង ត្រូវបានរំពឹងទុកថានឹងធ្វើឡើងក្នុងអំឡុងពេលស៊ើបអង្កេតភាពអនុលោម ក៏ដូចជាទៅកាន់ការិយាល័យ និង/ឬសាខារបស់ធនាគារអេស៊ីលីដា អម្រឹត ធនាគារ ហត្ថា អិលអូអិលស៊ី ប្រាសាក់ និងធនាគារស្ថាបនា ផងដែរ។ សម្រាប់ការចុះត្រួតពិនិត្យបែបនេះ ក្រុមការងារផ្នែកសំណុំរឿងរបស់ស៊ីអេអូ អ្នកជំនាញខាងក្រៅ និងអ្នកបកប្រែ នឹងត្រូវបានរំពឹងថានឹងចូលរួម។ ការសម្ភាសន៍ជាមួយមន្ត្រីពាក់ព័ន្ធនៃ MEF, MIFA, North Haven Thai និង Advans ក៏ត្រូវបានរំពឹងទុកផងដែរ។

## កាលវិភាគស៊ើបអង្កេតអំពីភាពអនុលោម រយៈពេល និងលក្ខខណ្ឌតម្រូវក្នុងការរាយការណ៍

យោងតាមគោលនយោបាយស៊ីអេអូ[136] សេចក្តីព្រាងរបាយការណ៍ស៊ើបអង្កេតនឹងត្រូវបញ្ចប់ក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីមានការលាតត្រដាងរបាយការណ៍វាយតម្លៃ។[137] សេចក្តីព្រាងរបាយការណ៍ស៊ើបអង្កេតភាពអនុលោមសម្រាប់សំណុំរឿងនេះ នឹងត្រូវបញ្ជូនទៅកាន់គណៈគ្រប់គ្រង IFC ដើម្បីត្រួតពិនិត្យ និងផ្តល់យោបល់ជាក់ស្តែង។ គណៈគ្រប់គ្រងអាចចែករំលែកសេចក្តីព្រាងរបាយការណ៍នេះជាមួយអតិថិជន ដោយមានលក្ខខណ្ឌថា ត្រូវមានវិធានការសមស្រប ដើម្បីការពារភាពសម្ងាត់នៃសេចក្តីព្រាងរបាយការណ៍នេះ មុនពេលលាតត្រដាងជាសាធារណៈ។[138] IFC នឹងមានរយៈពេល ២០ ថ្ងៃធ្វើការ ដើម្បីផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ។

ទន្ទឹមនឹងនោះ សេចក្តីព្រាងរបាយការណ៍ស៊ើបអង្កេតនឹងត្រូវបញ្ជូនទៅកាន់ដើមបណ្តឹង ដើម្បីត្រួតពិនិត្យ និងផ្តល់យោបល់ជាក់ស្តែង ក្នុងលក្ខខណ្ឌដែលមានវិធានការសមស្របដើម្បីការពារការសម្ងាត់នៃសេចក្តីព្រាងរបាយការណ៍នេះ មុនពេលលាតត្រដាងជាសាធារណៈ។ ប្រសិនបើគ្មានវិធានការរក្សាការសម្ងាត់ទេនោះ ដើមបណ្តឹងយ៉ាងហោចណាស់ នឹងទទួលបានសេចក្តីព្រាងតារាងរបកគំហើញនៃការស៊ើបអង្កេត ដើម្បីត្រួតពិនិត្យ និងផ្តល់យោបល់ជាក់ស្តែង និងជាប្រភពព័ត៌មាន ដើម្បីជូនដំណឹងអំពីការពិគ្រោះយោបល់នាពេលអនាគតលើផែនការសកម្មភាពគ្រប់គ្រង (MAP) IFC ណាមួយ។[139]

បន្ទាប់ពីទទួលបានយោបល់លើសេចក្តីព្រាងការពិគ្រោះយោបល់ពី IFC និងដើមបណ្តឹងរួចរាល់ហើយ ស៊ីអេអូនឹងបញ្ចប់របាយការណ៍ស៊ើបអង្កេត។ របាយការណ៍ចុងក្រោយនឹងត្រូវដាក់ជូនគណៈគ្រប់គ្រងជាន់ខ្ពស់របស់ IFC និងបញ្ជូនទៅកាន់ក្រុមប្រឹក្សាភិបាល សម្រាប់ជាព័ត៌មាន។ ក្រុមប្រឹក្សាភិបាលពុំមានការបញ្ចូលវិចារណកថាលើខ្លឹមសារនៃរបាយការណ៍ស៊ើបអង្កេតភាពអនុលោមរបស់ស៊ីអេអូនោះទេ។ នៅពេលដែលរបាយការណ៍

---

[136] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ១២១

[137] ជាវិធានការបណ្តោះអាសន្នចំពោះការអនុវត្តខ្សែបន្ទាត់ពេលវេលានៃគោលនយោបាយស៊ីអេអូ នៅ FY២៤ ស៊ីអេអូនឹងបញ្ចប់សេចក្តីព្រាងការស៊ើបអង្កេតអំពីភាពអនុលោម ក្នុងរយៈពេល ១៨ខែ បន្ទាប់ពីបានលាតត្រដាងរបាយការណ៍វាយតម្លៃ។

[138] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ១២២

[139] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ១២៤-១២៥

ស៊ើបអង្កេតត្រូវបានដាក់ជូនគណៈគ្រប់គ្រង IFC ជាផ្លូវការ និងបានបញ្ជូនទៅកាន់ក្រុមប្រឹក្សាភិបាល ស៊ីអេអូនឹងជូនដំណឹងដល់សាធារណជន នៅលើវែបសាយត៍របស់ខ្លួន អំពីការបញ្ចប់ការស៊ើបអង្កេត។[140]

បន្ទាប់ពីមានការដាក់ជូនលើកចុងក្រោយរបស់ស៊ីអេអូ នូវរបាយការណ៍ស៊ើបអង្កេតអំពីភាពអនុលោម ទៅកាន់ IFC គណៈគ្រប់គ្រង IFC មានរយៈពេល ៥០ ថ្ងៃធ្វើការ ដើម្បីដាក់ជូនរបាយការណ៍គ្រប់គ្រងទៅកាន់ក្រុមប្រឹក្សាភិបាលដើម្បីពិចារណា។ របាយការណ៍គ្រប់គ្រង ត្រូវតែរួមបញ្ចូល MAP ដើម្បីទទួលបានការអនុម័តពីក្រុមប្រឹក្សាភិបាល។ MAP មានវិធានការដោះស្រាយ ដែលបានកំណត់ពេលវេលា ដែល IFC ស្នើឡើង ក្នុងគោលបំណងដោះស្រាយរបកគំហើញរបស់ស៊ីអេអូ អំពីភាពបដិលោម និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ។ IFC ត្រូវតែពិគ្រោះយោបល់ជាមួយដើមបណ្តឹង និងអតិថិជន ក្នុងអំឡុងពេលដំណើរការរៀបចំ MAP របស់ខ្លួន ហើយរបាយការណ៍គ្រប់គ្រងក៏ត្រូវតែរួមបញ្ចូលការឆ្លើយតបយ៉ាងសមហេតុផលចំពោះរបកគំហើញ ឬអនុសាសន៍របស់ស៊ីអេអូ ទាក់ទងនឹងភាពបដិលោម ឬគ្រោះថ្នាក់ដែលពាក់ព័ន្ធ ដែល IFC មិនអាចដោះស្រាយបាន នៅក្នុង MAP។[141]

ស៊ីអេអូនឹងផ្តល់យោបល់អំពី MAP ដែលត្រូវបានស្នើឡើង ទៅកាន់ក្រុមប្រឹក្សាភិបាល ហើយដើមបណ្តឹងអាចដាក់សេចក្តីថ្លែងការណ៍ទៅកាន់ស៊ីអេអូ នៅលើ MAP ដែលត្រូវបានស្នើឡើង និងភាពគ្រប់គ្រាន់នៃការពិគ្រោះយោបល់ ដើម្បីបញ្ជូនទៅកាន់ក្រុមប្រឹក្សាភិបាល។[142] នៅពេលមានការអនុម័តពីក្រុមប្រឹក្សាភិបាលនៅលើ MAP របាយការណ៍ស៊ើបអង្កេតភាពអនុលោម របាយការណ៍គ្រប់គ្រង និង MAP នឹងត្រូវបានបោះពុម្ពផ្សាយនៅលើវែបសាយត៍របស់ស៊ីអេអូ។[143]

[140] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ១២៣ ១២៧-១២៩

[141] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ១៣០-១៣២ ១៣៤

[142] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ១៣៥

[143] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ១៣៨។